CEN
CAMBODIA EXPRESS NEWS

រឿង

# មាលាដួងចិត្ត

នូ ហាច

វប្បធម៌ អក្សរសាស្ត្រ

ព.ស ២៥១៦ គ.ស ១៩៧២

# កថាមុខ

ប្រលោមលោកថ្មីដែលខ្ញុំសូមយកមកស្នើ ជាគ្រឿងកំសាន្ត សម្រាប់មិត្ត អ្នកអានក្នុងពេលនេះ ជារឿងគំរប់ទី ៤ របស់ខ្ញុំ ។ ដូចមុនៗដែរ សៀវភៅនេះ បានតែងចប់ក្នុងពេលឧត្តមគតិទាន់ត្រូវទម្លុះទម្លាយ ជាណាស់ណាពេកទេដោយ បញ្ហាជីវិត ពោលគឺ រវាង២០ ឆ្នាំមកហើយ ។ ក្រដាសសំណៅដើមប្រែសម្បុរ ឡើងលឿងពណ៌ស្ករត្នោត ហើយផុយរបេះដុំៗ ព្រោះជរាភាព ។

ហេតុធំដែលនាំអោយខ្ញុំស្ទាក់ស្ទើរ យឺតយ៉ាវក្រផ្សាយដល់ម្ល៉េះមកពី មានបារម្ភ ក្រែងអ្នកផងលើកតួបុគ្គលខ្លះក្នុងរឿងទៅប្រដូច ឬចោទថាជាផ្នែក ជីវភាពរបស់ស្ត្រីណាមួយ ឬយល់ថា ជាការរិះគន់ចំពោះអ្នកមុខ អ្នកការណាមួយទៅវិញ ។ ក្នុងចំណុចនេះពិសោធន៍នៃរឿង **"ផ្កាស្រពោន"** បានផ្តល់ឧទាហរណ៍ស្រាប់មកហើយ ព្រោះមានអ្នកអានច្រើននាក់បានយល់ច្រឡំហើយ លើកប្រដូចតួបុគ្គលនានាក្នុងរឿងនោះទៅលើជនដែលមានជីវិតរស់នៅមែនទែន ។ ដើម្បីជៀសវាងមន្ទិលសង្ស័យយ៉ាងនេះទៀត ខ្ញុំបានយល់ថា គប្បីទុកពេលវេលាកន្លងហួសទៅ ហើយឱ្យបានវែងឆ្ងាយបន្តិចសិនក្នុងបំណងសន្សាប ការប្រដូច ឬ អត្ថាធិប្បាយផ្សេងៗ ដែលអាចកើតមានឡើង ។

ដូច្នេះខ្ញុំសូមបញ្ជាក់ជូនជាថ្មីថា សៀវភៅនេះពុំមែនជាប្រវត្តិរបស់ជន រូបណាមួយឡើយ ទោះមានឋានៈក្នុងសង្គមខ្ពស់ឬទាបយ៉ាងណាក៏ដោយ ថ្វីបើ នៅភាគខាងចុងមាន ព្រឹត្តិការណ៍ប្រវត្តិសាស្រ្តចូលមកជាផ្ទាំងតម្បាញនៃរឿង លើក ។ អាស្រ័យហេតុនេះប្រសិនបើអ្នកអានសង្កេតឃើញ ឬយល់ថា មាន កន្លែងណាមកដូចការពិតខ្លះ សូមសន្និដ្ឋានចាត់ជាដំណើរចៃដន្យទៅវិញផងចុះ ។

ប្រលោមលោក **"មាលាដួងចិត្ត"** នេះនិទានបានផ្តើមក្នុងឆ្នាំ១៩៣៩ គឺនៅពេលសង្គ្រាមលោកលើកទីពីរចាប់ឆ្លលឆេះឡើង ហើយមកចប់នៅចុងឆ្នាំ ១៩៤៦ គឺនៅពេលខេត្តបាត់ដំបង និងដែនដីយើងទាំងប៉ុន្មានដែលបាត់បង់ទៅ នោះបានវិលត្រឡប់មកចូលរួមក្នុងសហគមន៍ជាតិវិញ ។

អ្នកនិពន្ធមានបំណងអោយសៀវភៅនេះមានគុណភាពជាកញ្ចក់ ឬជាផ្ទាំងគំនូររូបភាពសំរាប់គំនិត និងឧត្តមគតិរបស់យុវជនខ្មែរក្នុងសម័យនោះ ។

មានហេតុមួយទៀតដែលនាំឱ្យខ្ញុំប្រតិស្ឋរឿង **"មាលាដួងចិត្ត"** នេះ ។ អ្នកអាន យ៉ាងក្រាស់ក្រែលមាននារីជាភាគច្រើនបានបន្ទោសខ្ញុំថា ចិត្តអាក្រក់ណាស់ដោយបណ្តោយអោយ នាង **ទិធាវី** ក្នុងរឿង" **ផ្កាស្រពោន**" ស្លាប់បាត់បង់ជីវិត ទាំងក្មេងខ្ចី ហើយស្លូតត្រង់ផង ។ ខ្ញុំសរសេររឿងថ្មីនេះក្នុង បំណងចង់លុបលាងនូវការរិះគន់បែបនេះទៀត តើសម្រេចដូចប្រាថ្នាមែនឬ យ៉ាងណាសូមមិត្តទាំងឡាយមេត្តាវិនិច្ឆ័យផងចុះ ។

សរុបសេចក្តីទៅសៀវភៅរឿងនេះដែលបរិបូណ៌ដោយយុវភាព ហើយដែលពិពណ៌នាអំពីគំនិត និងឧត្តមគតិនៃយុវជនក្នុងអំឡុងឆ្នាំ ១៩៣៩-១៩៤៦ សូមយុវជន យើងជំនាន់ក្រោយទុកជាសក្ខីភាពមួយនាកាលសម័យនោះ ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះចំពោះវិញ្ញាណក្ខន្ធ លោក **ឃួន នៅ** ជា បិតា និងលោក **ខិវ ស៊ិន** ជាសថឪពុកធំដែលលោកបានណែនាំខ្ញុំឱ្យស្រលាញ់ អក្សរសាស្រ្តតាំងពីកុមារភាព ហើយចំពោះយុវជនយើង វីរបុរសយើង ដែលបានបូជាជីវិតដើម្បីមាតុភូមិ ។

ភ្នំពេញ មេសា ១៩៧២

**ន. ហ**

## វិទ្យាល័យ គ.ស ១៩៣៩

ដូចជាពិបាកគិតដែរ ! ...មិនដឹងជាត្រូវចាប់និយាយពីត្រឹមណារឿងនេះ ព្រោះមានរាង និង ភាពដូចពពកមានពណ៌ចម្រុះដូចឥន្ទធនូ ហើយមានមាឌ នឹង កំពស់កំពរប៉ុនយក្សា ។

ក្នុងដួងចិត្តយុវជនអាយុម្ភៃឆ្នាំអារម្មណ៍ដ៏អស្ចារ្យនេះ ជួនណាបោកបក់ ជាព្យុះ ជួនណាផាយផាត់ជាខ្យល់ជំនោរ ។ ទុក្ខនិងសេចក្តីសង្ឃឹមតែងផ្លាស់វេន គ្នាក្នុងសតិមួយ ដែលមានគំនិតវែងឆ្ងាយ តែស្រួយដូចពពុះសាប៊ូដែលអណ្តែត មួយសន្ទុះ លំអដោយឆព្វណ្ណរង្សីចាំងឆ្លុះទៅលើ ។

ឱ ! ឆ្នេរសមុទ្រដែលបរិបូណ៌ដោយក្លិនក្រអូបឈ្ងួល ដែលវិចិត្រដោយកូនខ្ចម ជ្រកក្រោមដើមដូងល្វន់ល្វៃ មានកម្រងវល្លិផ្កាវុំស្រោបដូចហត្ថានាង នាដកា ។ វាយោហើរពីផ្ទៃសាគរមកយោលដួងធម្មជាតិ អោយមានចលនាទន់ភ្លន់ រួចហើយក៏តាំងដឹកនាំទៅឆ្ងាយនូវពិដោរឈ្ងុយឈ្ងប់ ។

ទេសភាពត្រកាលនេះ មាននាទីជាអង្រឹងសម្រាប់យោលរំសាយទុក្ខនៃ យុវជន ដែលស្រវឹងដោយឃ្លោង ដោយកាព្យថ្លាដូចចរណៃ ហើយស្អាតដូចពន្លឺ ព្រះចន្ទពេញបូណ៌មី ។ កវិនិពន្ធដ៏មានពាក្យពិរោះ ហាក់ដូចជាកើតពី ទេព្យកោសល្យ ដែលត្រាំទៅក្នុងទុក្ខព្រួយ ហើយរមែង ក្តោបស្រោបនូវ វិការដ្ឋាននៃជីវិត បរិបូណ៌ទៅដោយការប្រយុទ្ធ ការដណ្តើមស៊ើរស៊ីសាច់គ្នា ។

អាត្មនជរា ព្រលឹងរេចរិលអាចរត់ចូលជ្រកបានក្នុងសាសនា ប៉ុន្តែអាត្មន ក្មេង យុវចិន្តានឹងរកកំពង់ផែចូលសម្រាកបានតែក្នុងកាមារម្មណ៍ ។

គិតសព្វៗទៅ សេចក្តីស្នេហាជាសាសនាមួយបែបដែរសម្រាប់យុវជន ព្រោះរមែងមានសទ្ធា មានជំនឿ មានសេចក្តីទៅវិញទៅមក ។ តែសាសនានេះ ចាស់ៗបែរជា មិនយល់ដោយភ្លេចសូន្យឈឹង ថាកាលពីដើមមកខ្លួនធ្លាប់ក្មេង ដូចគ្នាដែរទេតើ ! ហេតុដូច្នេះហើយបានជាចាស់ៗទាំងនោះតែងកាន់គំនិតរឹង ត្អឹង កាន់លទ្ធិសម្បូរជ្វាសិទ្ធិចំពោះ លំពង់ត្រួយខ្ចីនៃមនុស្សជាតិ ។

គួរយើងគិតថា ផ្កាក្រូចពោធិ៍សាត់មានក្លិនក្រអូបជាងផ្លែវាដែលទុំ លឿងផូរ ។ យ៉ាងនេះហើយបានជាយុវជនអាចក្រេបឱជារសជីវភាពបានជា ជាងមនុស្សរសៀល ដែលជាហេតុនាំឱ្យ **មាណព** និង **មាណវី** មានទីតាំង ជិតជាងក្នុងគោលបំណង ព្រះកាមថេប ។

គំនិតពិពណ៌នាខាងលើនេះ ជាយោបល់របស់ក្មេងដែលរៀននៅវិទ្យា ល័យស៊ីសុវត្ថិ ក្នុងសម័យមុនកើតសង្គ្រាមលោកលើកទីពីរ ។ យុវជនទាំងនោះយល់ខុស ហើយដោយអយុត្តិធម៌ខ្លះផង ក៏ពុំដឹងថាចាស់ៗសង្កត់សង្កិនព្រលឹងនិងចន្ទារបស់ខ្លួន ហើយថែមទាំងបំពុលសេចក្តីត្រេកត្រអាលទៀតផង ។

គិតខុសក៏ដោយ ត្រូវក៏ដោយ ក្មេងៗ បើយល់យ៉ាងណាហើយ តែងជួញ ចិត្តធ្វើឱ្យគំនិតនោះបានសម្រេច បានពិតប្រាកដដោយសកម្មក្រៃលែង ។ ដើម្បីងាយយល់នូវមនោសញ្ចេតនាផ្សេងៗ ដែលរមែងកញ្ជ្រោកបោកបោះអា ត្មនយុវជននោះ ទើបសូមនាំរឿងនេះមកនិទានជូនដូចតទៅ :

ថ្ងៃអាទិត្យ ! អរុណចាប់លាបពណ៌ក្រហមទុំទៅលើជើងមេឃខាងកើត ។ ក្នុង សយនដ្ឋានមួយនៃវិទ្យាល័យស៊ីសុវត្ថិ ដែលសេចក្តីស្ងប់ស្ងាត់គ្រប់ដណ្តប់ នៅឡើយ ព្រោះមិនទាន់ដល់ម៉ោង សម្លេងខ្សិបខ្សាវចាប់ឮខ្សៀវៗ ពីត្រង់នេះ បន្តិច ត្រង់នោះបន្តិច ។ មាត់មាន់រងាវបង្អួសបែបបទវែងអន្លាយក្នុងពន្លឺស្រាង ៗនៃព្រហាម ។ សេះសំគមដែលទាញរទេះដឹកបន្លែមួយអន្លើ និងស្បែកជើង ឈើចិនកន្តាំងបាននាំគ្នាវាយផ្ទៃថ្នល់ចាក់ជ័រឮសូរភ្លិប ផ្លាប់ៗ ឮក្រោកក្រាក ។ កងទ័ពក្អែកចេញពីទ្រនំដើមអំពិល ខ្វកកេកាកៗលាន់រំពងហើយហើរឆ្ពោះទៅ ទិសខាងលិចដែលមានពំនូកពពកធំៗ ដេកទ្រមក់ត្រាំក្នុងកម្រិលច្រអូសនៅ ឡើយ ។

មួយសន្ទុះក្រោយមក ស្គរអ្នកយាមទ្វាររោទិ៍កំរើករំជួយអាកាស ពណ៌ ខៀវនៃព្រឹកព្រហាម ហើយសូរសព្ទហ៊ោកញ្ច្រៀវក៏ផ្ទុះឡើងដូចចិនអុជផាវ សែនអ្នកតា ។ អ្នកខ្លះចាប់ប្រយុទ្ធ នឹងសង្កើចដោយយកស្បែកជើងឈើវាយបំពៀចបច្ចាមិត្រ ដែលបានស្រូបយកឈាមពីយប់ទៅលើក្តារគ្រែឮផូងផាង។ ក្នុងសម័យនោះមិនទាន់ស្គាល់ច្បាស់នៅឡើយទេ នូវការប្រើម្សៅដេដេតេ សម្រាប់សម្លាប់សត្វល្អិត ។ អ្នកខ្លះទៀតប្រជុំគ្នាសប់បាល់ឡុង ឮភិតៗ ហើយមួយពួកផ្សេងដទៃ ក្រមាមួយវណ្ណនៅចង្កេះនាំគ្នាប្រមូលខោអាវយកទៅបោកនៅក្បាលម៉ាស៊ីនទឹកក្រោយ " ដំរត្នារ " ។

សូរទ្រហឹងអឺងអាប់បានដាស់ **ធីយារទុធ** ភ្ញាក់ពីដំណេកក្រោកឡើង ប្រមូលក្រសោបជើងមុងពាក់ទៅលើដំបូល រួចហើយក៏តាំងអង្គុយសញ្ជប់សញ្ជឹងនៅលើគ្រែ ដោយមានមុខស្ងួតស្ងប់ ក្មេងកំលោះនេះនឹកគួចដល់នារីដែល កាលពីល្ងាចម៉ិញវិទ្យុបាន នាំមកនូវសំឡេងថ្លាដូចកែវទិព្វ ។ នៅជិតសយនដ្ឋាន គឺនៅម្ខាងវិថីប្រ៊្វង់ស្វាហ្សុងតែន អ្នកម្ចាស់ផ្ទះមួយបានបើកវិទ្យុស្តាប់ចំរៀង សិល្បការិនីសៀម ពិរោះទន់ល្ហើយ ។ គឺសំឡេងនេះហើយ ដែលមកប្រលោមបំពេរអាត្មន **ធីយារទុធ** ដែលស្រេកឃ្លាននូវកាមារម្មណ៍ ។ ចៅមាណពស្តាប់ពុំបានច្បាស់នូវទំនុកច្រៀងទេ តែសាច់ពិរោះ ដែលមានផ្ចត់ទូលាយល្វឹងល្វើយ បានគួចព្រលឹងឱ្យអណ្តែតអណ្តូង ក្នុងរមណីដ្ឋានមួយនាទីមានសួគ៌ាល័យ ។

សៀវភៅដាក់លើដើមទ្រូង ទៀនលើក្បាលដំណេកឆេះចោលទទេ អ្នកកំលោះតាំងបង្ហើរគំនិតទៅទីឆ្ងាយមនោរម្យ ។ បិតក្នុងសភាពយ៉ាងនេះ ចិន្តាតាំងនឹកគួចពីចម្ងាយនូវសោភណភាពនៃសិល្បការិនី ។ ម្ល៉េះសមនាងមាន មុខមូលពេញ មានភ្នែកខ្មៅថ្លាយង់ ដែលមានរោមត្របកវែងទន្ទាំចាំការពារ មានសក់ខ្មៅរលើបទម្លាក់រលកអង្កាញ់មកលើស្មា ពណិសណ្តែកបាយ ហើយជារនាំងសម្រាប់កញ្ចឹងកដែលកំរើកចុះឡើងដោយសមសួន ធ្វើឱ្យក្បាលរេរាគួរ អោយគយគន់ បីដូចដើមស្មៅយោលផ្កាលឿងឆ្អិនក្នុងក្រសែខ្យល់ជំនោរ ។ ម្ល៉េះសមនាងមានបបូរមាត់ពណ៌ផ្កាឈូកដែលបិទហើយបើក ដើម្បីបង្ហាញឱ្យឃើញធ្មេញសថ្លាដូចផ្កាម្លិះលា ។ ម្ល៉េះសមនៅលើទ្រូងអាវប្រែសាច់ម៉ង្គខៃ កាត់ ដេរយ៉ាងប្រណីតទុកឱ្យស្មារនូវរាងប៉ោងក្បំលើឱរា នាងពាក់បន្តោងពេជ្រដែល ដេញរស្មីភ្លើងភ្លឺពព្រាយ ។

**ធីយារទុធ** ស្តាប់សំឡេងច្រៀងក្នុងរាត្រី ហើយស្រមៃឃើញជាក់ ច្បាស់ដូចទល់មុខគ្នានូវរូបឆោមនារីដែលមានសំដីពិរោះក្រអៅ ។ សិស្សលីសេ មិនដែលគិតដល់ម្តងណាសោះថា រមណីវត្ថុនេះអាចចេញបានពីរូបរាងមួយ ដែលធម្មជាតិពុំមានសម្បុរសធមិតុបតែងយ៉ាងនេះទេ ។ បើអ្នកណាចង់ភ្ញាល់ក៏ **ធីយារទុធ** ហ៊ានភ្នាល់ដែរ សំឡេងបរិសុទ្ធឥតមន្ទិលឥតស្រាំ ឥតឆារយ៉ាង នេះប្រាកដជាពុំមែនចេញពីអង្គខ្លួនក្រងិងក្រងង់បានឡើយ ! កំពុងតែយល់សប្តិទាំងភ្នែកបើកយ៉ាងនេះស្រាប់តែវិទ្យុឈប់ស្ងាត់ឈឹង ។ អន្ទះអន្ទែងក្រហាយក្រហល់ក្រៃលែង **ធីយារទុធ** បិទសៀវភៅគណិតសាស្ត្រដែលខ្លួនមាន បំណងបញ្ចប់មេរៀនមួយ ហើយចាប់កម្រងកវីនិពន្ធមកអានវិញ ។ នាយ កំលោះបើកក្រេបជញ្ជក់ម្តងទៀតនូវសាច់កាព្យ " ឡឺសូល" របស់អ័លហ្វ្រិដដឺ មុស្សេត៍ ។ មួយសន្ទុះក្រោយមកលុះបានផ្លុំពន្លត់ទៀនស្រេចហើយ សេចក្តី លង់លក់ក៏ស្រូបគំនិតចិន្តាចៅមាណព ទៅក្នុងសាកលសុបិនយល់សប្តិ ។

ប៉ុន្តែនៅព្រឹកថ្ងៃអាទិត្យ កម្លាំងដែលភ្ជាប់អង្គុយ **ទីយ៉ារុធ** យ៉ាងយូរ ទៅលើគ្រែ គឺវិការដ្ឋានដែលវិញ្ញាណប្រតិស្ឋឡើងក្នុងពេលដែលដេកលក់ ។ ថ្វីបើដឹងថាជាការភូតកុហក ថ្វីបើជាសេចក្តីសង្ឃឹមក្លែងក្លាយដែលភ្លឺព្រោងព្រាយ តែមួយភ្លែតដូច ផ្លេកបន្ទោរ តែកម្លោះយើងនៅតែសញ្ជឹងគិតទៅរកដោយសប្បាយផងឈឺអួលផ្សារផង ។ ជាប្រក្រតី សុបិន្តនិមិត្តជាតំណនៃប្រាកដនិយម ។

យល់សប្តិនោះបានបន្លប់ **ទីយ៉ារុធ** ថាមានរថយន្តដំបូលផ្លឹតដែល មាននារីទីត្រួយចិត្តជាអ្នកបើកបរ ឯខ្លួនអ្នកកំលោះឯងអង្គុយនៃបនិត្យក្រេប ឱជារសសុភមង្គលល្អ រកនិយាយពុំបាន ។ រថយន្តបង្អិលខ្លួនធូរខ្សៀកលើថ្នល់ ចាក់ជ័រដែលមានគគីរ ខ្ពស់ត្រៃឈៃដុះអមហែសងខាង ។ លុះដល់ទីថ្នល់ខ្វែងប្រទាក់គ្នា ឡានបត់តម្រង់ទៅរកភ្នំដែលព្រះអាទិត្យពេលល្ងាចកំពុងយកមាស ស្រោបលើកំពូល ។ ខ្យល់ក្រអូបដោយក្លិនរុក្ខជាតិបានស្ទុះមកប្រឡែងលេងជា មួយសក់នារី ។ លលកមួយគូផ្អើលនឹងឡាន ស្ទុះហើរយ៉ាងលឿនដោយទទះស្លាបញាប់ខ្ញាញ់ ។ **ទីយ៉ារុធ** ក៏យកដៃទៅបបោសអង្អែលស្មានៃឆោមស្និទ្ធ ។

រថយន្តឈប់គៀកនឹងជើងភ្នំដ៏មានថ្មធំៗ ដែលភ្លៀងនិងធាតុអាកាស បានឆ្លាក់ជារូបសត្វនៅក្នុងសម័យបុព្វប្រវត្តិសាស្ត្រ ។ គូសង្សារទំនើបអង្គុយលើ ថ្មមួយផ្ទាំងនៅចំពីមុខបឹងទឹកថ្លា ដែលក្នុងទីនោះព្រះសុរិយាកំពុងទាញពន្លត់នូវ កាំរស្មីរបស់ខ្លួនម្តងមួយៗ ។ ប្របកផ្កាព្រលឹតដែលរីករហង់ក៏ញាប់ញ័រព្រឹព្រួច ព្រោះសុភីវាតបក់មកថ្នាក់ថ្នម ។ កូនត្រីរស់ល្អិតៗ ពណ៌ក្រហមរងាលនៅហែបហែលចន្លោះដើមស្មៅ ដែលកំពុងយោលបង្គួតគ្នា នូវចង្កោមផ្កាពណ៌លឿងឆ្អៅ និង ត្រកួនផ្កាពណ៌ស្វាយដែលកំពុងបោះដៃរកគ្នារវាម ។ រនាលស្លាបពណ៌ជម្ពូ ខំរំពៃរកឆ្មក់មច្ឆាជាតិនៅជុំវិញមាត់បឹង ដើម្បីជាអាហារបង្អើយមុនពេលវិលរកទ្រនំ ។ មួយសន្ទុះក្រោយមកបក្សីជើងវែងស្ទុះហើរទាំងគូៗឆ្ពោះទៅទិសខាង
លិច ឯអាកាសក៏ធ្លាក់ត្រជាក់ស្រឹត ។

"ទិនករល្អថ្លារលាយសូន្យ សល់តែម្លប់ក្រអូបឈ្ងួល"[១] ទីយ៉ារុធ ឪរិប កាព្យនេះរបស់កវីបារាំងម្នាក់ ដែលខ្លួនពេញចិត្តហើយ ស្ញើចក្រៃលែង ។ ហ្វូង ជ្រឹងចេញពីគុហាភ្នំយកស្លាបល្អិតជ្រាយវាយអាកាសប្រផេះនៃរាត្រីកាល ។ ដោយមានសត្វនេះមួយហើរ ឆាបមកជិតនាងពេក នាងយុវតីតក់ស្លុត គេចរកជម្រកពួនភ័យនារដើមទ្រូងនៃនាយកម្លោះ ។

មកដល់ត្រឹមនេះ សុបិនក៏អន្តរធានបាត់ទុកអោយ **ទីយ៉ារុធ** អល់ឯក ព្រោះសុភមង្គលស្រពិចស្រពិលនេះ នាំអោយរសាប់រសល់ខ្វល់ចិន្តាពន់ ប្រមាណ ។

**ទីយ៉ារុធ** ជាសិស្សឧស្សាហ៍ មានប្រាជ្ញាឈ្លាសវៃនៅថ្នាក់ទីពីរនៃ មធ្យមសិក្សា ។ អ្នកកម្លោះចូលចិត្តរៀនជីវភាសាណាស់ ហើយតែងបានលេខ បានទីល្អៗក្នុងវិជ្ជាភាសាអង់គ្លេស បារាំង និង ខ្មែរ ។ មួយទៀត ដោយបានជាវ វចនានុក្រមបារាំង-សៀមមួយក្បាលមកទុកមាណពក៏ខំសិក្សាភាសាជិតខាង នោះទៀតក្នុងឱកាសទំនេរ ។ ហេតុនេះហើយ បានខំព្យាយាមទាល់តែអាន សៀវភៅថៃបានខ្លះ ថ្វីបើនៅរឹងមាត់និយាយពុំសូវច្បាស់ ព្រោះដាក់ខ្យល់ខ្ពស់ ទាបមិនត្រូវ ។

ប៉ុន្តែសិស្សនេះមិនសូវចូលចិត្តវិទ្យាសាស្ត្រទេ ។ ក្នុងពេលរៀនរូប សាស្ត្រ ឬគនិតសាស្ត្រព្រលឹងតែងអណ្តែតអណ្តូងទៅឆ្ងាយ ។ មួយទៀតពាក្យពេចន៍ដែល **ទីយ៉ារុធ** និយាយច្រើនដូចក្នុងសៀវភៅពេក បានជាសាស្ត្រាចារ្យខាងវិទ្យាសាស្ត្រ តែងស្តីបន្ទោសជាញឹកញាប់ថា ខ្វះសេចក្តីជាក់លាក់ ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកកម្លោះខំព្យាយាមណាស់ ហើយចាត់របៀបប្រើ ពេលយ៉ាងទៀងទាត់ ។ ថ្វីបើទើបតែចាប់រៀនអង់គ្លេស តែអាចនិយាយភាសា នេះបានខ្លះ ហើយអានទស្សនាវដ្តីអាមេរិចកាំង ឬប្រលោមលោកអង់គ្លេស ក្នុងកាប៉ូលីស ឬ ផ្សងព្រេងបានធូរបង្គួរ ។ ជាធម្មតាក្មេងនេះអានទាំងអស់មិនថាអ្វី

---

[១] " Le beau jour n'est rien que son ombre odorante " H. de Regnier

ជាអ្វីទេ ចេះតែចង់ដឹង ចង់យល់ជានិច្ច ។ បើគេនិយាយអំពីនយោបាយក្តី រឿង កុនក្តី អក្សរសាស្ត្រក្តី **ឌីយ៉ាឌុឌ** ចេះជូនយោបល់ ចេះអធិប្បាយដោយពិរោះ ហើយអ្នកផងចូលចិត្តស្តាប់ណាស់ ដោយឃើញថាជាក្មេងមានគំនិតជ្រៅ មានចិត្តទន់ ពួកម៉ាកទាំងឡាយតែងស្មោះស្ម័គ្ររាប់រកដោយសមានចិត្ត ប្រសិនបើ ទៅពើបលើមជ្ឈដ្ឋានមួយថ្មី **ឌីយ៉ាឌុឌ** សំឡឹងហើយស្តាប់មួយសន្ទុះក៏ថ្លឹងឈ្វេងយល់ភ្លាមថា ពពួកជននោះមានប្រាជ្ញាត្រឹមនេះជំរៅត្រឹមនោះ ។ តមកក៏តាំងលៃសំដីប្រមាណពាក្យឱ្យបានសមល្មម តែអ្នកទាំងនោះរីករាយចង់ស្តាប់ ។ ទោះនៅចំពោះមុខមនុស្សមានកិរិយាយ៉ាងណាក៏ដោយ អ្នកម្លោះចេះរកពាក្យមកថ្លែងកំសាន្តលេងបានពុំខានឡើយ ។ ទាំងនេះ ត្បិតមានបំណងតែមួយ គឺមិនចង់ឱ្យអ្នកផងឈឺចាប់ ឬ ថ្នាក់ថ្នល់ក្នុងចិត្តដោយសារខ្លួន ព្រោះខ្លួន សោះឡើយ ។

**ឌីយ៉ាឌុឌ** ជាអ្នករហ័សខឹងបន្តិច ប៉ុន្តែចេះទប់មាត់ទប់កបាន មិនឱ្យក្លាយទៅជាច្រឡោតដល់ទៅស្រែកឡូឡានោះទេ ។ បើឃើញមិត្តណាចេះ ស្រាកស្រួលនឹងខ្លួន ចៅមាណពយើងមានចិត្តរីករាយនឹកគុណគេពុំភ្លេចទេ តែ បើគេធ្វើព្រងើយកន្តើយ ឬរំលោភត្រង់ណា ចិត្តអ្នកកម្លោះក៏ថ្នាក់ថ្នល់គ្នាប់ គ្នាញ់មិនងាយនឹងរសាយបានឡើយ ។ ក្នុងពេលរៀបចំមុខកិច្ចការសិក្សា **ឌីយ៉ាឌុឌ** ខំផ្ចិតផ្ចង់មិនឱ្យពួកម៉ាកកើតរំខានដល់ខ្លួនសោះ ចំណែកខ្លួនវិញក៏ មិនអត់ឱនដល់អ្នកណាដែលធ្វើអោយមានអំពល់បានឡើយ ។

**ឌីយ៉ាឌុឌ** ចូលចិត្តកវីនិពន្ធបារាំងណាស់ តែមិនស្រឡាញ់ពួកបុរាណ លើសពួកទំនើបទេ ឱ្យតែជារបស់ទន់ត្រជាក់បរិបូណ៌ដោយមនោសញ្ចេតនាចុះ មុខជារាប់អានពុំខានឡើយ ។ សិស្សនេះតែងសេចក្តីបានយ៉ាងធូរ បើកាលណាត្រូវនិយាយពីដួងចិត្តពីមនោសញ្ចេតនា ។ ប៉ុន្តែសាច់និពន្ធប្រែជារដិបរដុបទៅវិញ ក្នុងពេលដែលនិយាយអំពីកាណ៍អ្វី ដែលមានគ្រោតគ្រើត ។ ក្នុងវិស្សមកាល អ្នកកម្លោះតែងសរសេរសំបុត្រជាច្រើនច្បាប់មានសេចក្តីទន់ភ្លន់ទៅរកមិត្តសំឡាញ់ ។ ប្រសិនបើអ្នកនោះឯងថ្លោះធ្លោយពុំបានតបវិញទេមុខតែ **ឌីយ៉ាឌុឌ** រងសេចក្តីឈឺចាប់ក្រៃលែង

មួយទៀត ចៅមាណពចេះលើកកំណាព្យស្រងេះស្រងោចបរិបូណ៌ ដោយសេចក្តីស្នេហា។ ចំពោះគុណជាតិនេះ អ្នកកម្លោះបានក្រេបសោភណភាព តែដោយសៀវភៅដោយ ប្រលោមលោក និងដោយភាពយន្តប៉ុណ្ណោះ ។ **ឌីយ៉ាឌុឌ** តែងអានដោយចាប់ចិត្តនូវរឿងនានាដូចជា "ទ្វារចង្អៀត" របស់ អង់ដ្រេហ្សីដ និង "ប្រិយនារី " របស់វ៉ូដ្វាយែរ[១] ជាដើម ។ មិនថាទេ បើអ្នក និពន្ធមិនសូវប្រសប់តែងពាក្យ គ្រាន់តែចេះធ្វើអោយទាក់ចិត្តចុះ មុខជារាប់អានពុំខានឡើយ ។ ក្មេងកំលោះនេះអានញាប់ណាស់រហ័សណាស់ជួនកាលជក់រឿងពេកក៏បញ្ចប់សៀវភៅក្រាស់បង្គួរតែក្នុងមួយយប់ ។

រាល់រសៀលថ្ងៃអាទិត្យ **ឌីយ៉ាឌុឌ** តែងចេញពីសាលាដើម្បីទៅរក មើលកុន ។ ក្នុងពេលនោះអ្នកកំលោះតែងផ្ទៀងឃ្លាំឆាកណាដែលប្រកប ដោយសេចក្តីស្នេហាយ៉ាងត្រកាល ដូចជាគូសង្សារទាំងពីរជិះទូកលេងក្នុងបឹង ឬលំហែដោយរថយន្តដែលបរកាត់ទេសភាពយ៉ាងចាប់ចិត្ត ។ ញញឹមដែលរីក ពព្រាយលើបបូរមាត់ស្រស់មួយ តែងធ្វើឱ្យចៅមាណពសប្បាយចិត្តជាងវិការ ដ្ឋានអ្វីឯទៀតទាំងអស់ ។ លុះវិលមកដំណេកវិញ រូបសិល្បនារីទាំងឡាយដែល ខ្លួនបានឃើញស្រមោលពីថ្ងៃ ក៏ផុសអណ្តែតឡើងជាថ្មីក្នុងសេចក្តីស្រមៃមួយ ដែលមានវង់រស្មីស្រោបព័ទ្ធពន្លឺភ្លឺចិញ្ចាច ។ ឱ ! កញ្ញាមានឆោមលោមពណ៌ដូច ទេពអប្សរ ដែលបានបញ្ចេញកាយវិការល្វះល្វន់ ក្នុងទេសភាពល្អឆើតឆាយដូច គាល័យ អនុស្សាវរីយ៍ស្នេហ៍ទាំងនេះ តែងមកស្ថិតនៅពាសពេញក្នុងសេចក្តីនឹក រលឹករបស់យុវបុរស ហើយធ្វើឱ្យដួងចិត្តគេលិចលង់ទៅក្នុងពិដោរកាមារម្មណ៍ ដែលរសាត់មកពីទីឆ្ងាយ ។

---

(១) " La prote et Roite D'andre Fide et La Bien Aimee De Vandoyer "

ជួនកាល ពេលដើរលំហែបាននាំនាយកម្លោះឱ្យប្រទះឃើញមួយភ្លែតនូវ រាងក្បៀវក្លំនៃនារីមួយនាក់ ។ រូបស្រពិចស្រពិលនេះបានបណ្តាលឱ្យមាណព យើងភ័ន្តភាំងស្មារតី ជំហានបោះដើរទៅមុខដោយស្វ័យប្រវត្តិ ។ ថ្ងៃមួយកំពុង ដើរតាមវិថីផ្សារស្រាប់តែមានអារម្មណ៍ថា មានក្រសែភ្នែកសំឡឹងខ្លួន ។ **ឌីយាវុធ** ងើយមើលឡើងលើឃើញនារីចិនម្នាក់សក់សីងម៉ឹង សាច់ដៃទ្រលុក ច្រត់លើមាត់បង្អួច ហើយបង្ហើរញញឹមទៅទិសមួយដែលទីយាវុធស្មានថា ទ្រង់មករកខ្លួន ។ គ្រាន់តែប៉ុណ្ណោះក៏ព្រលឹងអណ្តែតអណ្តូង ស្វែងទៅរកការយល់ សប្តិ ជើងលែងជាប់ដីទៅហើយ ។

មួយទៀត **ឌីយាវុធ** មិនចូលចិត្តឮសំដីបន្ថោកបន្ទាប ឬបង្អាប់អំពី ស្ត្រីភេទទេ តែងកាន់ជើងឥត្ថីភាពជានិច្ច ទោះបីខុសក៏ដោយ ត្រូវក៏ដោយ ។ កម្លោះមានយោបល់ថា គួរតែផ្តាច់នារីខ្មែរឱ្យផុតស្រលះពីប្រពៃណី ។ ប្រសិន បើឃើញស្ត្រីណាមួយប្រព្រឹត្តឆ្គង និង កន្លងចរិយាបថ **ឌីយាវុធ** តែងថ្នាក់ ថ្នល់ក្នុងចិត្តដែរ ប៉ុន្តែមួយសន្ទុះក្រោយមកក៏រកលេសបានមកលើកទោសអោយ ជានិច្ច ។

នៅព្រឹកថ្ងៃអាទិត្យនេះ លុះបានត្រាត្រែងសញ្ចប់សញ្ជឹងក្នុងគំនិតឥត ប្រាកដនិយមយ៉ាងនេះអស់ពេលយ៉ាងវែងមក **ឌីយាវុធ** ក៏ចូលទៅលុបមុខ សិតសក់រៀបចំខ្លួនយ៉ាងស្រស់បស់ ។ ចេញផុតពីភាពរាយមាយកាលណា អ្នកកំលោះក៏ក្លាយជាអ្នកសើចលេងក្អាកក្អាយក្នុងចំណោមពួកម៉ាកជាច្រើននាក់ ។ លុះឃើញចៅមាណពនិយាយឆ្កាដៃឆ្កាជើងដូចគ្រាតឡូវនេះ អ្នកផងដែលពុំ ដែលស្គាល់ពីមុនមកមុខតែមិនអាចស្មានបានទេថា កាលពីកន្លះម៉ោងមុនគេជា មនុស្សរវើរវាយ ។

ក្នុងឱកាសរៀបចំមុខរៀន **ឌីយាវុធ** ខំផ្ចិតផ្ចង់មិនឱ្យល្បៀងទេ។ នៅពេលលើកមែកថ្លុវជិតបន្ទប់រៀន គ្រលឹងគ្រលោងស្រើងដោយពន្លឺថ្ងៃ និងសន្តិភាពរបស់ធម្មជាតិច្រៀងតន្ត្រាពុំដាច់មាត់ ដែលជាហេតុនាំឱ្យចៅមាណពគគួច នឹកព្រួចទៅភូមិកំនើតដែលជាភូមិតូចមួយតាំងនៅកណ្តាលវាលស្រែចំងាយជាង ១០ គ.ម ពីក្រុងបាត់ដំបងតាមថ្នល់ទៅមង្គលបុរី ។ មួយសន្ទុះ **ឌីយាវុធ** នឹកដល់រលកសន្ទូង និងពង្រោះដែលអង្កាញ់ប្រដេញគ្នាតាម ក្រោមរស្មីភ្លឺថ្លានៃ ព្រះសុរិយា ឬ ដល់ដងអូរក្បាលស្រែដែលខ្លួនធ្លាប់នាំគ្នីគ្នាទប់ទឹកបាចចាប់ត្រី ។ កម្លោះគិតឃើញដោយរីករាយថា នៅមិនប៉ុន្មានថ្ងៃទៀតទេនឹងដល់វិស្សមកាលឈប់ចូលឆ្នាំចិនហើយ ។ អែយ៉ា ! ខ្លួននឹងបាន ឱកាសទៅលេងភូមិកំនើតហើយ តើ ។

រសៀលថ្ងៃនោះ **ឌីយាវុធ** ស្លៀកពាក់ស្អាតបាតហើយចេញពីសាលា ដើរទៅជាមួយមិត្តភ័ក្តិតាមវិថីមហាធានី ។ បន្តិចក្រោយមកក៏នាំគ្នាចូលញ៉ាំទឹក ក្រូចនៅភោជនី ដ្ឋាន**"កុងសាន"** ទំរារោងកុន **"ដេអិន"** បើកទ្វារនឹងទិញ សំបុត្រចូលមើល ។ ពួកយុវជនប្តូរយោបល់គ្នាដោយធៀបផ្ទឹមការប៉ិនប្រសប់ អ្នកដើរតួកុន ស្រី-ប្រុស ហើយសើច ធូរស្រួលសប្បាយ **ឌីយាវុធ** ជូន ឧទាហរណ៍ដោយធ្វើត្រាប់អ្នកដើរតួរបារាំងម្នាក់យ៉ាងក្រមាច់ក្រមើម នាំឱ្យសំណើចផ្ទុះប្រាវទទួលឡើង ។

មិនប៉ុន្មាននាទីក្រោយមក កណ្តឹងអគ្គិសនីរោង **"ដេអិន"** រោទិ៍រន្ថាន់ ឯទ្វារដែក ខាងមុខក៏បើកញែកជាពីរផ្ទៃកក្កូញចូលគៀន ។

**ឌីយាវុធ** ក្រោកឈរឡើងស្មើនឹងគេដែរ ក៏ឧទាន :

នៅតែមួយអាទិត្យទៀតទេ យើងដល់ពេលឈប់ចូលឆ្នាំចិនហើយ.... មកដល់ត្រង់នេះអ្នកនិពន្ធសូមបើកវង់ក្រចកមួយ ដើម្បីសូមឱ្យអ្នកអានអភ័យទោស ដោយបានថ្លែងរៀបរាប់វែងបន្តិចអំពីបរិយាកាសនៅវិទ្យាល័យស៊ីសុ វត្តិក្នុងឆ្នាំគ.ស ១៩៣៩ ហើយអំពីកិរិយា

ទឹកចិត្តអ្នកកម្លោះ **ឆឹយាទុង**។ ប៉ុន្តែអ្នកនិពន្ធយល់ថា ជាការចាំបាច់ណាស់ ដើម្បីងាយយល់រឿង ដែលហួរល្អិត តាមនាទីនៃជីវិតដែលលើកមកពណ៌នាក្នុងគ្រានេះ ។

**២**

## យល់សប្តិគង់ក្លាយជាការពិតមួយដងមួយកាលដែរ

កាលពីយប់មានភ្លៀងមួយមេធំ ។ ភ្លៀងធ្លាក់ក្នុងរដូវនេះ ជាការចំលែកដែរមិនសូវមានទេ ។ ទឹកល្អក់ខ្វល់កាត់ក្នុងជង្ហុក និងក្រឡុកវិថីនៃក្រុងបាត់ដំបង ។ នៅពេលទៀបភ្លឺ **ឆឹយាទុង** ទុំបន្តើតលើរ៉ឺម៉កដែលដឹកវ៉ាលីសខ្លួន មួយផងបានសំដៅឆ្ពោះទៅស្ថានីយ៍រថភ្លើង ដើម្បីធ្វើដំណើរត្រឡប់ទៅភ្នំពេញវិញ ក្រោយដែលបានមកលំហែចិត្ត និងកំសាន្តជាមួយគ្រួសារនាភូមិអូរតាគីក្នុងអំឡុងពេលឈប់បុណ្យចូលឆ្នាំចិនរួច អ្នកកម្លោះក៏បានមកស្នាក់អាស្រ័យនៅ ផ្ទះបងប្អូនក្នុងក្រុងមួយយប់ ដើម្បីក្រោកមកជិះរថភ្លើងឱ្យបានទាន់ពេល ព្រោះ ត្រូវចេញដំណើរពីព្រះហាមស្រាងៗ ។

យានតូចបានបត់កាច់ចូលតាមថ្នល់ត្រង់ទៅស្ថានីយ៍ ។ ផ្លូវនោះមានទឹកដក់តាមក្រឡុកច្រើនអនេក ព្រោះខ្វះការជួសជុលជាយូរយារណាស់មកហើយ ។ ផ្ទៃថ្នល់ជាភក់ស្អិត ដូចបាយម៉ាន ។ ស្រាប់តែមានរថយន្តប៉ឺហ្សូ ៤០២ មួយ បរយ៉ាងលឿនជៀសហួសទៅដោយបាចទឹកកខ្វក់មកលើអ្នកដែលវារររតើមៗ ។ អ្នកឌឺរ៉ឺម៉កក៏តាំងជេរប្រទេច ។ ឯ **ឆឹយាទុង** បានសម្លឹងមើលលេខឡាន ហើយស្គាល់ជាក់ជារថយន្តអ្នក **សៅរ៉េប្ស**។

ស្ត្រីនេះជាប្រពន្ធមួយនាក់ ក្នុងចំណោមប្រពន្ធច្រើននាក់របស់ **ពញ្ញា គនាធរ** អតីត ទេសាភិបាលបាត់ដំបងក្នុងអាណាចក្រសៀម ។ ក្រោយមកក្នុងគ្រាផែនដី " ភ័ន្តប្រែ" បាត់ដំបងត្រូវបានរួបរួមក្នុងអាណាចក្រខ្មែរវិញ អ្នក **សៅរ៉េប្ស** ក៏រត់ភៀសខ្លួនជាមួយចង្កោមប្រពន្ធឯទៀតៗដើម្បីទៅតាមស៊ីបុណ្យ " លោកម្ចាស់ " ជាស្វាមីឯប្រទេសសៀមទៀត ។ ដោយបានរួមវាសនាចែកហ៊ុនគ្នាជាមួយស្ត្រីឯទៀតផង អ្នក**សៅរ៉េប្ស** ក៏ទទួលបានកូនស្រីមួយ កូនប្រុស មួយពី **ពញ្ញាគនាធរ** មួយអន្លើ និងទ្រព្យសម្បត្តិជាមរតកយ៉ាងក្រាស់ក្រែល ។ ឥឡូវនេះអ្នក **សៅរ៉េប្ស** រំលៀកខ្លួនត្រឡប់ចូលមកដែនកំណើតវិញ ហើយ សង់ផ្ទះថ្មមួយស្កឹមស្កៃកំណាចនៅភូមិល្វៀប ។

អ្នក **សៅរ៉េប្ស** ក្តី បុត្រាបុត្រីគាត់ក្តី ដែលអ្នកបាត់ដំបងហៅដោយ គោរពថា "**យុន**"ៗ នោះតែងបញ្ចេញបង្អួតឱ្យអ្នកផងកោតថាខ្លួនជាអ្នកមានទ្រព្យ ជាអ្នកអម្បូរខ្ពស់ ហើយជាអ្នកធ្លាប់នៅទីក្រុងធំៗ ។ នៅក្នុងផ្ទះគាត់ ដែលតុបតែងដោយវត្ថុជាច្រើនស្អេកស្កះឥតសមសួនសោះ គឺមានប្រើសុទ្ធតែរបស់ថ្លៃៗ ឱ្យគេស្ញប់ស្ញែងដូចជា ផ្តិលមាស ប្រអប់ស្លាមាស ជាដើម ។ ថ្វីបើ គាត់មានអាយុហាសិបប្លាយទៅហើយ គាត់នៅស្លៀកខៀវទពណ៌ស្រស់ៗមុខ ទទះម្សៅរទូសៗ ជើងគាត់ពាក់ស្បែកជើងថ្ពខ្មៅចុងស្រួចហើយងឡើងលើហើយគាត់ដើរកែក្រោយខ្នងបន្ទេរមកក្រោយបន្តិច ភ្នែកសម្លឹងទៅឆ្ងាយ មានឫកខ្ពស់ក្រអឺតបែបចង់សំដែងឱ្យឃើញថា ដីនេះ ទីនេះកាលពីដើមមិញជា របស់ប្តីអញ គឺនៅជារបស់ខ្លួនអញខ្លះដែរ ។

ចំណែកឯកូនប្រុសគាត់ ជើងខោព្រែកខ្មៅធំៗប៉ុនការុងអំបិល ហើយពាក់អាវព្រៃ អន្ទញ្ញតាប្លាកធំៗ ពណ៌ខៀវក្រហម ថ្ងៃៗឡើងគិតតែពីបើកឡាន ដើរជល់ត្រីក្រឹម ឬជល់មាន់ ហើយយប់ៗឡើងដើរចែចង់ស្រីជាមួយដៃគូត្បាញ អាយពីរបីនាក់ ។ រីឯ "**យុន**" ស្រីវិញអស្ចារ្យហើយ ដឹងតែប្រភឹបតែម្តង ជិះកង់ម៉ូតូតែងខ្លួនភោភាវរកគ្មានពីរទេក្នុងដែនបាត់ដំបង ! យុនឯលិច យុនឯកើតអ្នកជង

ស្ទឹងសង្កែភាំងស្មារតី ដោយមិនដែលឃើញសោះនូវសេចក្ដីហ៊ឺហាចម្លែកដល់ម្ល៉េះឡើយ ត្បិតសម័យនេះពុំដែល មានស្ត្រីមានពូជអម្បូរណា ហ៊ានជិះទោ ចក្រយានឡើយ ។

**នីយាវុធ** សម្លឹងមើលរថយន្តអ្នកមានថ្មីដែលបរផុតទៅ ហើយគយគន់ដោយគ្នាន់ក្នាញ់នូវអាវ "កុមប្លេ" របស់ខ្លួនដែលប្រឡាក់ទឹកភក់ស្របក់ ។

ស្ថានីយ៍ក្នុងពេលនោះ ពេញកកប៉ប្រីកដោយអ្នកដំណើរ និងអីវ៉ាន់ ។ មនុស្សទាំងនោះស្លៀកពាក់តាមតែបាន មិនសូវស្អាតពេក ទេនៅលាយឡំពាក់ ពព្វូនជាមួយត្រកត្រី ស្រស់ ជាលត្រីងៀត កញ្ចេត្រីឆ្អើរ បាច់បន្លែ និងពពួកជ្រូក ដែលគេចងជើងទាំងបួនគួបគ្នា ហើយជះក្លិនហាក់ដូចជាពុំសូវធុំស្រួលប៉ុន្មាន ឡើយ ។

ក្នុងចំណោមនិករ និងវត្ថុដែលកកកុញរកជ្រៀតជើងពុំចុះនេះ សំលៀក បំពាក់បែប អឺរ៉ុបបួនដប់មកលាយឡំផង បង្កើតនូវបរិយាកាសមួយប្លែកភ្នែក ហើយឥតប្រាកដនិយម ។ **នីយាវុធ** ក្រឡេកឃើញពួកម៉ាកក៏ញញឹមទៅរកមិត្តពីរបីនាក់ស្ទុះមកចាប់សួរសុខទុក្ខដោយរីករាយ ហើយនិយាយចំអកអំពីខោ អាវ **នីយាវុធ** ដែលប្រឡាក់ស្រមូញ ។

ក្នុងពេលដើរតម្រង់ទៅរកបញ្ជរលក់សំបុត្រ នាយកលោះក៏ប្រទាក់ផ្លូវ គ្នានឹងបុរសម្នាក់ពាក់ "កេពី" សឈានជើងចេញពីទីនោះមក ។ **នីយាវុធ** សង្កេតស្គាល់ភ្លាមថា ជាអ្នកបើកឡានរបស់អ្នក **សៅរីម្ស** ហើយក៏ចោលភ្នែក តាមទៅ ។ បុរសបួកក្រអឺត ដោយអាងចៅហ្វាយខ្លួនជាអ្នកមានពើងទ្រូង ហើយដើរឆ្ពោះទៅរកឡានដែលចត អែបចិញ្ចើមថ្នល់ខាងជើង ។ ដល់ហើយ ក៏ហុចសំបុត្រជិះរថភ្លើងទៅឱ្យស្ត្រីបីនាក់ដែលឃើញស្រមោលស្ទុងៗ អង្គុយក្នុងយាន ។ អ្នកបំរើនេះស្ទុះទៅបើកឃ្លុបឡានខាងក្រោយ បញ្ចេញវ៉ាលីសពីរធ្ងន់ៗ ដើរយួរនាំផ្លូវស្ត្រីទាំងបីនាក់ គឺយុវតីក្រមុំម្នាក់និងស្ត្រីកណ្ដាល មនុស្សពីរនាក់ ដែលយួរប្រអប់ស្បែកម្នាក់មួយ ។ **នីយាវុធ** ភ្ញាក់ខ្លួនព្រឺត : ខ្លួនស្មានថាអ្នក **សៅរីម្ស** នាំកូនចៅគាត់មកណាទៅណា ឥឡូវមិនមែនសោះ ។ តើជនមិន ស្គាល់ឈ្មោះ ទាំងនោះមកពីទីណាអ៊ែះបានជាជិះឡាននេះមកឡើងរថភ្លើង ?

សេចក្ដីចង់ដឹងយ៉ាងនេះ បាននាំឱ្យ**នីយាវុធ** ប្រញាប់ប្រញាល់ទៅទិញ សំបុត្រនឹងគេ ដោយភ្នែករំពៃ មើលម្ដងៗទៅលើស្ត្រីចម្លែកៗទាំងបីនាក់ តែកន្ទុយភ្នែកនាយកម្លោះសង្កត់ទៅលើ**មាណវី**ច្រើនជាង ។ យី! នារីនេះប្រកបដោយសោភណភាពឥតងាយរកមកផ្ទឹមបានទេ ហើយស្លៀកពាក់តែងខ្លួនក៏ រមិលមើលមិនទាស់ភ្នែកសោះ ! មើលចុះ អាយុមិនលើសពី ១៨ ឆ្នាំទេភក្ត្រផូរ សាច់ម៉ដ្ឋ រាងមូលទ្រវែងបន្តិចតែប្រកបដោយគំនូសយ៉ាងសុក្រិត សក់រលក អង្កាញ់ទូលាយ ហើយសិតរៀបយ៉ាងឆើត រង្វះមាត់តូចដែល មានបបូរណិទទឹម សែតបណ្ដែតញញឹមបង្ហាញនូវធ្មេញសល្អិតស្មើឥតខ្ចោះ អាវបើកពណ៌ផ្កាឈូក ដែលមានកញ្ចុំដូចចង្កោមផ្កាមកជួយរំលេចលំអ ហើយសាកឹតស៊ីនួនខ្ចី សំយុង ពាក់កណ្ដាលស្មង បង្ហាញនូវកំភួនវៀវស្រសូលដែលមានភាគចុងបញ្ចប់បង្កប់ ទៅក្នុងស្បែកជើងពណ៌ក្រមៅខាត់រលោងស្រឹល ។

ក្នុងសេចក្ដីយល់សប្តិក្នុងការវវើរវាយទាំងភ្នែកស្រស់របស់ខ្លួន **នីយាវុធ** តែងតែបែងចែកលំអនារីជាបីប្រភេទទីទៃពីគ្នា ។

ប្រភេទទីមួយ បានដល់ពពួកយុវតីដែលប្រកបដោយសោភណភាព ឃោរឃៅហៅ បបួលឱ្យស្ទុះទៅចាប់ក្រញី ឬលេបដូចចំណីព្រោះបរិបូណ៌ ដោយសម្ផស្ស ដែលដេញ ដែលទាញសំរើបយ៉ាងខ្លាំ ។ នារីប្រភេទនេះ តាមយោបល់ចៅមាណពយើង មិនសូវចេះតែងខ្លួនទេ ច្រើនស្លៀកពាក់ពណ៌ឆើតៗ លេចធ្លោ ពាក់មាសពេជ្រស្នេកស្កុះហើយមានកាយ វិការឆ្ងាយពីសេចក្ដីស្រគត់ ស្រគំទៀតផង ។

បើលំអឃោរឃៅជាបាតុកម្មខាងក្រៅ ឯលំអទីពីរតែងមានគុណភាព កប់ជ្រៅនៅខាងក្នុងវិញ គឺលំអដែលបញ្ចេញឱ្យឃើញឱ្យសរសើរ ឱ្យស្ងើចបន្តិច ម្ដងៗ នូវទឹកដមចិន្តាថ្លាហ្មត់ហ្មងទាន់ត្រជាក់ ។ សរុបសេចក្ដីទៅ ស្ត្រីដែលប្រ កបដោយសោភ័ណភាពបែបនេះ

ទំនៀមទម្លាប់យើងតែងតែហៅថាល្អគន់ តែ **នីយាទុធ** ដែលមានគំនិតចាក់ស្រេះបន្តិច តែងចាត់ថាជាលំអដែលទាញនូវ សមានចិត្ត និង សេចក្តីគោរពដូចមនោសញ្ចេតនាដែល អ្នកផងតែងមានចំពោះ បងស្រី ។

សោភ័ណភាពទីបីរបស់ **នីយាទុធ** តែងប្រគល់ដល់នារីមានកិរិយា ទន់ភ្លន់ មានគុណភាពស្រួយស្តើង នាំឱ្យចិត្តបុរសចង់ជួយ យកអាសា ឬស្ទុះ ចេញការពារតទល់នឹងសត្រូវ ទោះបីសត្រូវនោះមានរូប ឬឥតរូបក៏ដោយ ។ គឺលំអនេះហើយដែលតែងអង្រួនបេះដូង កវីបញ្ចេញជាពាក្យនៅគ្រប់ភាសា ។

**នីយាទុធ** ត្រិះរិះទទួលស្គាល់ថា សោភ័ណភាពទាំងបីប្រភេទនេះ ឥតមានព្រំដែន ឬជញ្ជាំងមកកាត់បែងចែកឱ្យច្បាស់លាស់ទេ ។ ដូចជាចិត្តអីចឹងដែរ មនោសញ្ចេតនាតែវិវត្តវិលពីទីមួយទៅទីមួយទៀត ។ ដូច្នោះស្ត្រីដែល ប្រកបដោយលំអដែលអារម្មណ៍ដំបូង ពន្យុះឱ្យញាក់ញីនោះអាចក្លាហានបានក្នុងកាលៈទេសៈថ្មីចំឡែកជាគុណភាពបណ្តាលឱ្យថ្នាក់ថ្នមទៅវិញ។ តែទោះជាយ៉ាងណាក៏ដោយ**នីយាទុធ** ចាត់នាងក្រមុំមិនទាន់ស្គាល់ឈ្មោះ ក្នុងប្រភេទ ទីបីស្រេចទៅហើយ ។

អ្នកដំណើរស្ត្រីទាំងបីរដើរតាមតៃកុងឡាន ចូលទៅក្នុងបន្ទប់ថ្នាក់លេខ ៣ ។ លុះបានរៀបដាក់វ៉ាលីសលើធ្នើរស្រួលបួលហើយ ជននោះក៏សំពះលាស្ត្រី ដោយ "**និយាយភាសាថៃ**" ពីរ-បីម៉ាត់ ។

នៅតែ១៥នាទីទៀតរថភ្លើងចេញហើយយ ។ តាមធម្មតាថ្នាក់លេខ ៣ ពុំសូវមានអ្នកជិះទេ តែថ្ងៃនេះពេញដោយសិស្សលីសេកក ស្រទាប់ ។ យុវជនយើងដែលគោរពច្បាប់ សុជីវធម៌ ហើយកាន់សេចក្តីគួរសមយ៉ាងប្រពៃ ស៊ូទ្រាំនៅប្រជ្រៀតគ្នាក្នុងសង្កាត់ឯទៀត ទាំងអស់ ហើយបើសេសសល់ខ្លះ ក៏សុខចិត្ត ឈរតាមរបៀងទុកឱ្យស្ត្រីបរទេសទាំងនោះអង្គុយសង្កាត់តែមួយដោយផាសុក ។ **នីយាទុធ** ដែលឡើងមកក្រោយគេរកកន្លែងឈរ ឬអង្គុយពុំបាន ក៏ដាច់ចិត្តចូលទៅរកជើងម៉ាក្នុងសង្កាត់ស្ត្រីទាំងនោះដែរ ។ អ្នកកំលោះចូលមក ដោយស្ទាក់ស្ទើរ ហើយអៀនខ្មាសក្រៃលែង ព្រោះខោអាវប្រឡាក់ភក់យ៉ាងនេះ ។ តើធ្វើម្តេច បើជៀសពុំរួចហើយ !

គង់មានអ្នកអានខ្លះឆ្ងល់ថា តើហេតុដូចម្តេច នារីដែលមានពាហណៈជា អ្នកសម្បូរ ដោយភោគទ្រព្យ មកទិញសំបុត្រថ្នាក់លេខ ៣ ម្តេចក៏ពុំជ្រើសយក ថ្នាក់លេខ ២ឬលេខ១ វិញ ដែលប្រកបដោយផាសុកភាពជាង ? ត្រង់នេះយើង គួរយល់ថាសព្វដងសព្វកាល បន្ទប់ លេខមួយនិងលេខពីរតែងមានអ្នករាជការ បារាំង ឬនាយទាហានបារាំងគេជិះទៅមកពុំលស់ថ្ងៃទេ ។ ធម្មតាជនជាតិអាស៊ី ក្នុងសម័យនោះ ពុំសូវចង់នៅលាយឡំនឹងពួកច្រមុះកោងប៉ុន្មានឡើយ ។ ឯអ្នកដំណើរមិនស្គាល់ឈ្មោះនោះ សុទ្ធតែស្រី១ទៀតផង តែងមានសេចក្តីធុញ ទ្រាន់ ចិត្តនៅជិតប្រុស១អឺរ៉ុបពេកទេ ។ មួយទៀតតាមចំណាំរៀងមក ថ្នាក់លេខ បី ដែលមានរថមួយ ដាច់ពិសេសតែឯងនោះ មិនសូវសំបូរអ្នកជិះប៉ុន្មានទេ ព្រោះគេច្រើនតែនាំគ្នាទៅកកកុញនៅយានថ្នាក់លេខបួនជាមួយនឹងជាលត្រី កញ្ជើ បន្លែត្បិតក្នុងសម័យនោះ ឋានៈជីវិតនៅទាបខ្សោយណាស់នៅឡើយ ។ ឥឡូវមកចំពប់លើថ្ងៃដែលថ្នាក់លេខបី ពេញណែនយ៉ាងនេះ ។

រថភ្លើងទាញកញ្ចែវែងហើយផ្អើកពីរ-បីឃឹក...ទើបលូនចេញដំណើរទៅមុខ ។ នាង កញ្ញាអើតតាមបង្អួចមើលទេសភាពវាលស្រែ ដែលដេកលក់ នៅឡើយ ដោយដណ្តប់ក្នុងភួយកប្បាសនៃអាកាសចុះអ័ព្ទ ។ ស្រមោលស្វរ១ នៅមុខខ្ទមស្រែ ខ្លះជាអ្នកបញ្ជាន់ដែល កំពុង បង្វិលត្របាញ់លើភ្នែនកណ្តប់នូវ គំនួចគោបួនប្រាំសត្វ ដែលមានមាត់ឃ្លុំនៅក្នុងកូនជាលភ្នែកក្រួច ដើម្បីកុំឱ្យអណ្តាតវារពីសកៀវចាប់ ស្រូវ ។ ស្រីកណ្តាលមនុស្សពីរនាក់ គិតតែប្តូរយោបល់ រប៉ាច់រប៉ោចមិនឈប់មាត់សោះ ។ ឯ **មាណវី** នៅស្ងប់ស្ងៀម ស្មារតីឡឺន ឡង់ ព្រោះប្លែកមជ្ឈដ្ឋាន ហើយប្លែកទម្លាប់ពេក ។

របៀបដូចជាមេដែកដែលមានឥទ្ធិពលទាញម្ជុលត្រីវិស័យ ឱ្យវិលទៅរកសោភ័ណភាព និងការតុបតែងឆើតស្រស់នៃនារីបរទេស ប្រទាញក្រសែភ្នែក **នីយាទុធ** ឱ្យគ្រលៀសចោលទៅចំជាញឹកញាប់យ៉ាងនោះដែរ ។ មួយសន្ទុះ នាយកម្លោះក៏នឹកឃើញដល់សំដី និយោជិកអយស្ម័យយានម្នាក់ ដែលបានប្រាប់ខ្លួនថា បើកាលណាមានអ្នកដំណើរច្រើនលើសលប់ក្នុងថ្នាក់ណាមួយ មេខ្សែរថភ្លើងអាច

អនុញ្ញាតជាអាទិភាពឱ្យអ្នកជិះស្រីៗទៅអង្គុយនៅថ្នាក់ខ្ពស់ណាដែល មានកន្លែងនៅទំនេរ ។ នឹកឃើញសំដីនេះហើយ អ្នកកំលោះក៏ក្រោកដើរចេញ ញែកហ្វូងពួកម៉ាកសួតាមរបៀង ហើយឆ្លងទៅមើលយានខាងក្រោយ ដែលចែកជាថ្នាក់លេខពីរនិងលេខមួយ ។ ក្នុងពេលនោះ បន្ទប់លេខពីរនៅសល់ទំនេរ ស្អាត ឯលេខមួយមានគ្រួសារបារាំងតាំងនៅជាអ្នកតំកើងឫទ្ធិ ។

**ធីយាទុធ** បាននាំដំណើរការណ៍នេះ មកស្នើជាមួយមេខ្សែរថភ្លើង ដែលកំពុងក្រេបកាហ្វេខ្មៅ ក្លែបចាខ្វៃនៅក្នុងរថលក់បាយ ។ ភ្នាក់ងារលុះបាន ស្រស់ស្រូបរួចហើយក៏នាំអ្នកកម្លោះមកជួបស្ត្រីបរទេស :

- អត់ទោសខ្ញុំចុះឃុន **ធីយាទុធ** និយាយជាភាសាសៀមទៅកាន់នារី បើខ្ញុំនិយាយពុំច្បាស់ ហើយពុំចំអក្សរ ។

កញ្ញានាងបែរភក្ត្រមករកដោយភ្នែកមូលក្រឡង់សំដែងការងឿងឆ្ងល់ ហើយតប ដោយសំដីទន់ផ្អែមល្ហែមត្រជាក់ទៅរកជាភាសាដដែលថា :

- ឃុនមានការអ្វីដែរ ?

ដៃចង្អុលទៅភ្នាក់ងាររថភ្លើង **ធីយាទុធ** តបថា :

-លោកនាយខ្សែរថភ្លើងនេះ បានអនុញ្ញាតនាងហើយ និងអ្នកស្រីទាំង ពីរអញ្ជើញត្រូវអង្គុយនៅថ្នាក់លេខពីរវិញ ព្រោះកន្លែងនោះស្ងាត់ស្រួលជាង ។ នៅទីនេះ មានអ្នកសិស្សសាលាច្រើនណាស់ ។

- អរគុណលោកពេក នាងតបដោយញញឹមបង្ហើបឱ្យឃើញធ្មេញតំរៀប ថ្លា ។ តែខ្ញុំនៅទីនេះស្រួលហើយតើ ។ មិត្តភក្តិឃុនអាចចូលមកអង្គុយក្នុង សង្កាត់នេះបានដែរ ។ បើប្រជ្រៀតគ្នាបន្តិចក៏មិនអីទេ ។

- កុំមានប្រសាសន៍យ៉ាងនេះ គ្នាមិនហ៊ានមកទេ ឯខ្លួនខ្ញុំសោតទាល់ ច្រកណាស់ហើយទើប.......

- ខ្ញុំមិនបានស្មានថា ខ្លួនខ្ញុំមានអំណាចអីដល់ម្លេះទេ នាងតបដោយ ញញឹមត្រវីក្បាល ដែលជាហេតុនាំឱ្យរយ៉ាបន្តោងនៅត្រចៀកចោលរស្មីព្រោង ព្រាយ នាងក្រោកឈរ ហើយបែរមុខទៅរកស្រីជូនដំណើរទាំងពីរនាក់ :

- មកបងទៅ ឃុននេះមកបណ្តេញយើងហើយ ។

ថាហើយ នាងសើចបន្តិចបង្ហាញឱ្យឃើញថា នាងនិយាយលេងផង ហើយអរគុណអ្នកកម្លោះដែលជួយយកអាសាផង ។

**ធីយាទុធ** ជួយយួរវ៉ាលីសអ្នកដំណើរបរទេស ហើយនាំផ្លូវទៅកាន់បន្ទប់លេខពីរ ដែលនៅទំនេរ ។ ភីលៀងទាំងពីរអង្គុយទន្ទឹមគ្នានៅលើជើងម៉ា ពាសពូកស្បែកម្ខាង ហើយតរុណីនាងអង្គុយត្រង់ជ្រុងម្ខាងក្បែរបង្អួច ។

លុះបានរៀបចំវ៉ាលីស នៅលើផ្ទាំងសំណាញ់សម្រាប់ដាក់អីវ៉ាន់រួចស្រេច បាច់ហើយ **ធីយាទុធ** ក៏និយាយលាដកខ្លួនបំណងវិលទៅកន្លែងដើមខ្លួនវិញ ។ ប៉ុន្តែកញ្ញាសៀម ឃាត់ដោយចិត្តស្មោះថា :

- សូមអគុណឃុនច្រើន ដែលជួយឈឺឆ្អាលយើងខ្ញុំនេះ ប៉ុន្តែឃុនពុំមាន ការអ្វីពិសេសទេ ឬពុំធុញទ្រាន់នឹងយើងខ្ញុំទេ ឃុននៅទីនេះហើយ ដ្បិតយើងខ្ញុំ ជាអ្នកដំណើរ ភាសាខ្មែរក៏ពុំចេះ សូមឃុនជួយណែនាំឱ្យស្គាល់ស្រុកទេសផង បាន ឬទេ ?

ធុញទ្រាន់នឹងនាង ? នាងមានប្រសាសន៍អ្វីយ៉ាងនុំះ ត្រូវតែខ្ញុំវិញទេ ដែលភ័យក្រែងនាងធុញទ្រាន់នឹងខ្ញុំ មើលចុះខ្ញុំនិយាយភាសាថៃរអាក់រអួល រកាក់រកុប ខុសខ្លះត្រូវខ្លះ ។ ឯសំលៀកបំពាក់ខ្ញុំសោត ក៏ពុំគប្បីផង .....

- មិនមែនដូច្នោះទេឃុន ដែលឃុនជួយយកអាសារនេះ ខ្ញុំនឹកគុណពុំ ភ្លេចឡើយ ។ យីចុះឃុនដួលឯណាក៏ប្រឡាក់ខោអាវថ្មីៗអស់យ៉ាងនេះ ?

**ធីយាទុធ** សញ្ជឹងមួយសន្ទុះ ទើបដាច់ស្រេចថា គួរតែនិយាយការពិត ប្រាប់នាង :

- មានរថយន្តមួយបរមកជះទឹកភក់លើខ្ញុំ ។ ក្នុងពេលនោះ ខ្ញុំនឹកក្តៅ ឈ្ងួលដែរ តែឥឡូវនេះបាត់ខឹងអស់ហើយ ។

- ឱប្រហែលជាឡានដែលខ្ញុំបានជិះមកឡើងរថភ្លើងហើយមើលទៅ ។ សូមអភ័យទោសផងចុះ ។ សុហ្វ័រនោះព្រហើនអស់យ៉ាងហើយ ចង់តែពីលឿនមិនសូវគិតនាយអាយសោះ ។ គិតទៅ ផ្ទះដែលខ្ញុំបានមកសំណាក់នោះកាន់ឫក ខ្ពស់ៗអស់យ៉ាងហើយនាយក៏ដូចបាវដែរ ។

- មិនអីទេនាង ប្រឡាក់ប៉ុណ្ណេះ ។

ថាហើយ **នីយាវុធ** គិតចេញទៅក្រៅ ។ នាងកញ្ញា យាត់ទៀត :

យីយុនអញ្ជើញទៅណា ? នុ៎ះហ៊្វូមិអីហ្នឹង ?

នាយកម្លោះចោលភ្នែកទៅក្រៅ ឃើញរស្មីព្រឿងៗ នៃព្រះសុរិយាជះ មកលើចំការចេក និងស្លានៃភូមិអូរស្រឡៅក៏ឆ្លើយប្រាប់នាងតាមពាក្យសួរ ។ ដោយនាងជជីកអង្វរពេក **នីយាវុធ** ក៏ព្រមឈរជិតបង្អួច ហើយនិយាយពន្យល់ ឬអធិប្បាយការផ្សេងៗតាមស្រុកទេស ដែលខ្សែរថភ្លើងកំពុងរត់ ។ ពិដោរមាត់ដែលសាយពីរូបកាយនាង ហើយសេចក្តីរាក់ទាក់និងស្មោះស្ម័គ្រដែល ចេញពីសំដីនាង បណ្តាលឱ្យមានការស្រើង ឱ្យមានការភ្លេចខ្មាសអៀន ព្រោះសំលៀកបំពាក់មិនគប្បីនោះមករុំស្រោបវិញ្ញាណចៅមាណព ហើយនាំឱ្យសេចក្តីស្គាល់ចិត្តគ្នាកាន់តែលូតលាស់ឡើង ។

នាងសួរឈ្មោះវាលស្រែ ឈ្មោះស្ថានីយ៍ ឈ្មោះភូមិ ឈ្មោះភ្នំ ហើយ **នីយាវុធ** ឆ្លើយប្រាប់តាមតែធ្លាប់ដឹងឮ ។ រថភ្លើងក៏លឿនទៅមុខ ពេលវេលាក៏លឿនទៅមុខ តែយុវជនទាំងពីរគ្មានចាប់អារម្មណ៍ចំពោះការត់ឆ្ងាយនៃព្រះកាលទេ ។

ម៉ោង ៩ ក្បួនរថភ្លើងចេញផុតពីស្ថានីយ៍ពោធិ៍សាត់ ហើយជ្រែកចូលក្នុងផែនព្រៃខ្លុង ដែលសន្ធឹងវែងស្រោងស្រាងរំលីកម្តងៗដល់ចំការកៅស៊ូ ។

ទេសភាពលែងមានអ្វីជាល្អគួរមិលមើលទៀតហើយ ចៅមាណពក៏ អញ្ជើញនាងទៅស្រស់ស្រូបឯបន្ទប់ភោជនីយដ្ឋាន ដោយភីល្បៀងជូនដំណើរទាំងពីរនាក់ មិនព្រមទៅជាមួយផង ព្រោះថាដើរក្នុងយានកំពុងបើកចេះតែវិលមុខ **តរុណី** និងនាយកំលោះក៏លីលាឆ្ពោះទៅតែពីរនាក់ ។ តុមួយនៅជិតជ្រុង ក្បែរបង្អួច ឃ្លាតពីអ្នកបរិភោគឯទៀតបន្តិចបានបបួលឱ្យយុវជនជ្រើសយក ដោយរួមមតិគ្នា ។

- នាងពិសាអ្វី ? **នីយាវុធ** សួរដោយសម្លឹងមើលបញ្ជីរាយឈ្មោះមុខម្ហូប ។

- យុនពិសារអី ខ្ញុំក៏យកនោះដែរ ។ ដោយសើចបន្តិចនាងបន្ថែម :

- ខ្ញុំមកស្រុកយុនស្រេចហើយ យុនដឹកនាំទាំងអស់ ។

សំដីនេះនាំឱ្យនាយកម្លោះខ្មែរ និងក្រមុំសៀមសើចប្រាវស្មើគ្នា ។

**នីយាវុធ** សង្កេតថា :

- គួរឱ្យអស្ចារ្យណាស់ យើងទាំងពីរនាក់មិនទាន់ស្គាល់នាមគ្នាផងក៏ទុក ចិត្តគ្នាដូចមិត្តភក្តិស្គាល់ចិត្តថ្លើមគ្នាយូរយារមកហើយ ខ្ញុំសូមអភ័យទោស ចំពោះការភ្លេចភ្លាំងដូច្នេះ។ ខ្ញុំឈ្មោះ **នីយាវុធ** រៀននៅថ្នាក់ទីមួយ ប៉ែក មធ្យម សិក្សានាវិទ្យាល័យ **ស៊ីសុវត្ថិ** ។

នាងបើកកាបូបយួររបស់នាង យកនាមប័ណ្ណមួយសន្លឹកឱ្យទៅគូសន្ទនា :

- ដូចយុនឃើញស្រាប់ ខ្ញុំឈ្មោះ **ចន្ទមណី** វិចិត្រករ ជាសិស្សនៅ សកលវិទ្យា ល័យ **"ជុឡាឡុងកន"** តែនៅថ្នាក់ទាបនៅឡើយទេ ។ ខ្ញុំធ្វើដំណើរទៅភ្នំពេញទៅលេងនឹងឪពុកខ្ញុំ ដែលមកសំណាក់អាស្រ័យនៅទីនោះ ។ យុនប្រហែលឮឈ្មោះ ឬ ស្គាល់ឪពុកខ្ញុំដែរមើលទៅ ។ គាត់ឈ្មោះ **ថេព ភូសុន** វិចិត្រករ (ទេព្យកោសល្ល វិចិត្រករ) ដែលកាលពីមុនជាសក្តិបីក្នុងកងទ័ពថៃ ហើយបានរត់ភៀសខ្លួនមកជ្រកនៅកម្ពុជា ក្រោយដែលមានរដ្ឋប្រហារ ក្នុងឆ្នាំ ១៩៣៧ នាក្រុង ថេបមហានគរ (បាងកក) ។

- អាចីហាំ ស៊ីអុយហាំ ? សម្ដីចិនធ្វើម្ហូបសួរយ៉ាងនេះនាំឱ្យ **ឌីយ៉ាវុឌ** ភ្ញាក់ខ្លួនព្រើត ។ ត្រូវដកខ្លួនពីការសញ្ជឹងសញ្ជប់នាយ កំលោះបែរជាញញឹម ទៅរក **មាណវី** ទើបបញ្ជាជាខ្មែរ :

- អើ យកបាយលីងសាច់ក្ដាម លាយសាច់មាន់ហើយដាក់ពងទាផង ពីរ ចានមក ....ទឹកក្រូចពោធិ៍សាត់ច្របាច់ ពីរកែវ... ....ប៉ុណ្ណឹងបានហើយ ។ បែរទៅ រកកញ្ញា **ឌីយ៉ាវុឌ** អធិប្បាយថា :

- ខ្ញុំបង្គាប់ឱ្យធ្វើម្ហូបឱ្យបានម៉ាធ្ងន់បន្តិច ព្រោះទំរាំដល់ភ្នំពេញថ្ងៃត្រង់ ឯណោះ បើពុំដូច្នោះទេ រទេះភ្លើងរលាក់ទម្រើកធ្វើឱ្យយើង ឃ្លានណាស់ ។

- ខ្ញុំពេញចិត្តណាស់ សូមអរគុណ ។

មិត្តថ្មោងថ្មីបរិភោគបណ្ដើរ និយាយសំណេះសំណាលបណ្ដើរ ។ ដល់មកស្ថានីយ៍ ទទឹងថ្ងៃក្បួនរថដែលមកពីបាត់ដំបងក៏ត្រូវឈប់ រងចាំខ្សែយានដែល ទៅភ្នំពេញដើម្បីជៀសគ្នា ។ ក្នុងពេលនោះ **ឌីយ៉ាវុឌ** បាននាំនាងសៀមចុះ ដើរឱ្យបាត់រោយដៃជើង ។

ភ្នែកនាងគយគន់ព្រៃព្រឹក្សា មាត់នាងនិយាយថា :

- តាំងពីធំដឹងក្ដីកាលមក ខ្ញុំតែងនឹកចង់ឃើញស្រុកខ្មែរពន់ពេក នឹក ស្រឡាញ់តែក្នុងចិត្ត ឥឡូវបានសម្រេចដូចប្រាថ្នាហើយ ។ ដោយសារយើងមានទំនៀមទម្លាប់ដូចគ្នា មានប្រពៃណីកាន់សាសនា ព្រមទាំងប្រកបដោយសម្បត្តិ វប្បធម៌ដូចគ្នាថែមទៀត ទើបឪពុក ខ្ញុំកាលបើគាត់រត់ចោលស្រុក គាត់មកសុំ
ស្នាក់អាស្រ័យនៅទីក្រុងភ្នំពេញ ។

- ខ្ញុំរីករាយណាស់ ដោយឮថានាងនឹងមកនៅក្រុងភ្នំពេញ ។

- ទីក្រុងនេះជនរួមជាតិខ្ញុំបានសរសើរថាស្អាតណាស់ ឪពុកខ្ញុំបានទិញ ផ្ទះមួយនៅខាងជើងវត្តភ្នំ ។

សំដីនារីខាងចុងក្រោយ បានធ្វើឱ្យចៅមាណពចាប់អារម្មណ៍មួយភ្លាម ។ យី ! គ្រួសារនាងនេះមានណាស់តើ គេមានប្រាក់ទិញ ភូមិគ្រឹះមួយក្នុងសង្កាត់ ដែលបរិបូណ៌ដោយគេហដ្ឋានល្អស្អាតស្អុកស្អម ។ រីឯគ្រួសារឯងនៅឯភូមិអូរតា គឺនៅចុងកាត់មាត់ញក ។ ឱ ! សេចក្ដីសង្ឃឹមដែលប៉ុចជាត្រួយក្នុងចិត្តមួយ សន្ទុះ .....ណ្ហើយកុំគិតវែងពេក វានាំតែឆ្កួត វិលខួរក្បាលទេ ។

លុះខ្សែភ្លើងបានជៀសគ្នារួចកាលណា **ឌីយ៉ាវុឌ** បាននាំនាងកញ្ញា មកអង្គុយនៅបន្ទប់ថ្នាក់លេខពីរដោយមុខស្ងួត ។ **មាលាដួងចិត្ត** ដែលខ្លួន តែងយល់សប្ដិរវើរវាយឃើញ ឥឡូវបានប្រាកដរូបមកនៅជិតបង្កើយ តែបែរជាឆ្ងាយទៅវិញ ព្រោះឈោង ដៃមិនងាយដល់ទេ ។ ចៅមាណពសញ្ជឹងសញ្ជាប់ ប្រាសចាកសេចក្ដីរីករាយអស់រលីង តែនៅខំប្រុងស្មារតីកុំឱ្យរាយមាយ ដើម្បីចាំឆ្លើយ នឹងសំណួរនាង ។ នារីដែលបានសង្កេតទឹកមុខស្រពោនរបស់មិត្តថ្មី ក៏នឹកក្រែងថាមានទុក្ខ ឬភារៈអ្វីដែលមិនគួរគប្បីនឹងសាកសួរឡើយ ។ ថ្វីបើមានពិ ភាល់ក្នុងចិត្ត នាងគោរពតុណ្ហីភាពដោយសម្លឹងទៅខាងក្រៅ ។

ឥឡូវរថភ្លើងបានកាត់ផុតព្រៃក្រាស់ហើយ **មាណវី** ក៏គយគន់ជួរដើមត្នោតដែលដុះផ្ដុំៗគ្នា ។ មិនយូរប៉ុន្មានយានក៏ចូលមកដល់ ស្ថានីយ៍ពោធិ៍ចិនតុង ។ ពេលដែលត្រូវឃ្លាតកាន់តែខិតជិតមកដល់ហើយ ។ តើនឹងជួបគ្នាទៀតឬទេ ? គំនិតនេះនាំមកនូវសេចក្ដីអួលផ្សា ដែលចោលម្លប់ទៅលើទឹកមុខ ។ អ្នកអាន ដែលបានស្គាល់នូវចិត្តគំនិតនាយកម្លោះស្រេចមកហើយ ប្រហែលជាមិនសូវ ងឿងឆ្ងល់ពេកទេ ចំពោះកិរិយាចំឡែកយ៉ាងនេះ ។

ដោយស្ងប់ស្ងួត **ឌីយ៉ាវុឌ** និយាយទៅកាន់គូសន្ទនា :

- យុននៅរវាងដប់គីឡូម៉ែតទៀតទេ យើងដល់ភ្នំពេញហើយ ។

ថាហើយ ក៏ឈោងយកវ៉ាលីសពីផ្ទាំងសំណាញ់ដាក់ចុះមកលើក្តារ ដើម្បី ឱ្យងាយលើកហុចទៅឱ្យអ្នកជញ្ជូន។ ឯភីលៀងចាប់ពីរនាក់ដែលពុំបាននិយាយ ស្តីអីមួយម៉ាត់ជាមួយ **ឌីឃាទុឆ** ក៏ក្រោកឈរវៀបរបដែរ ។ ចំណែកនារី នាងបើកកាបូបយួរយកកូនញូក់ឆ្នុះសម្រួលសក់ ផាត់ម្សៅបន្ថែលើភក្ត្រាហើយ យកបណ្តូលក្រហមមកជូតបន្ថែមលើបបូរមាត់ ។ កាយវិការដ៏សមសួននេះ **ឌីឃាទុឆ** គយគន់មិនដាក់ភ្នែកទេ ដើម្បីចារឹកទុកក្នុងហឫទ័យកុំឱ្យភ្លេចបាន ។

ក្បាលរថភ្លើងទាញកញ្ចៃវែងពីរ-បីដង ហើយក៏ចូលទៅឈប់អែបជរក ស៊ីម៉ង់តិ៍ ។ ក្នុងពពួកមនុស្សអ៊ូអរដែលមករកចាំអ្នកដំណើរ មានបុរសម្នាក់អា យុប្រហែលសែសិបប្លាយឆ្នាំ សំលៀកបំពាក់បែបអឺរ៉ុបហើយទឹកមុខរីកថ្លា សម ជាអ្នកមានចិត្តធមិ មានសេចក្តីប្រណី។ ភ្នែក គាត់រំពៃមើលពីទូររថភ្លើងមួយ ទៀត ។ នាង **ចន្ទមណី** អើតតាមបង្អួចឃើញក៏ស្រែកហៅភ្លាម :

- យុន ៨ (លោកឪពុក) ចាំះ !

ទឹកមុខគាត់ញញឹមព្រាយ ទទួលសេចក្តីគោរពពីបុត្រីដែលលើកដៃប្រណម្យយ៉ាងទន់ភ្លន់ ។ ក្នុងពេលជាមួយនេះ **ឌីឃាទុឆ** ក៏បានហៅអ្នកជញ្ជូន អីវ៉ាន់ម្នាក់មកទទួលយកវ៉ាលីសនាង រួចហើយក៏ទៅយកអីវ៉ាន់របស់ខ្លួនឯងចុះ ទៅដែរ ។ នាយកម្លោះរៀបនឹងចូលទៅលានាង ស្រាប់ **មាណវី** នាងហៅ ហើយប្រាប់ឪពុកថា :

- យុន ៨ នេះនាយ **ឌីឃាទុឆ** ដែលបានយកចិត្តទុកដាក់ខ្ញុំក្នុងដំណើរ នេះ កុំអីខ្ញុំប្រទះការលំបាកមិនតិចទេ ។

អតីតសក្តិបីសៀមញញឹម ហើយស្ទុះមកចាប់ដៃនាយកំលោះយ៉ាងរាក់ ទាក់អរគុណលោក កមួយ (ក្មួយ) ពេក គាត់និយាយខ្មែរប៉ៃឡាំបន្តិច។ ។

អ្នកទាំងបីដើរចេញទៅក្រៅ ដោយមានសារ៉ដៃ និងអ្នកជញ្ជូនអីវ៉ាន់ ដើរតាមមកដែរ ។ ឃើញឪពុកនាងខំរកពាក្យនិយាយភាសាខ្មែរដោយលំបាក នាង **ចន្ទមណី** ជំរាបគាត់ថា អោយនិយាយថៃទៅវិញព្រោះ **ឌីឃាទុឆ**ចេះ ភាសានេះស្ទាត់ណាស់ ។

ឮនាងអួតយ៉ាងនេះ **ឌីឃាទុឆ** មានទឹកមុខឡើងក្រហម ហើយតប ជាភាសាសៀម :

- យុនមិនគួរបំផ្លើសយ៉ាងនេះសោះ ខ្ញុំរៀននៅស្រុកខ្មែរធ្វើម្តេចនឹង និយាយត្រូវអក្សរល្អ ។

- និយាយបានប៉ុណ្ណឹងហើយ ដល់ណាទៀតទៅលោក **ទេព្យកោសល្ល** តប ។

លុះបានដល់រថយន្ត អតីតនាយទាហានក៏បបួលដោយស្មោះស្ម័គ្រ :

- លោកក្មួយមកជាមួយនឹងខ្ញុំមក ខ្ញុំនឹងជូនដល់ទីកន្លែង

- សូមកុំព្រួយថ្វី ខ្ញុំមានពួកម៉ាកច្រើនណាស់ ទៅចោលគេពុំកើតទេ ។

- យុនកុំភ្លេចទៅលេងនឹងខ្ញុំណា៎ ។ ជូនខ្ញុំដើរលេងផង ខ្ញុំជាអ្នកចំណូល ថ្មីមិនស្គាល់ស្រុកទេសសោះឡើយ ។

ពេលនោះឪពុកនាងបន្ថែមជូនលើសម្តីធីតា :

- អញ្ជើញកុំខាន ផ្ទះខ្ញុំលេខ ៩២ មហាវិថីមីស ។ អញ្ជើញកុំខាន ខ្ញុំគ្មាន ស្គាល់នរណាទេនៅភ្នំពេញ ។

**ឌីឃាទុឆ** ទទួលថាបាទដោយស្ងើយ។ ហើយក៏សំពះលាមិត្តទំនើប ដើរចេញទៅ។ ឪពុកនិងកូនក៏លូកដៃមកចាប់ដៃនាងកម្លោះតាមទម្លាប់អឺរ៉ុប ។ **ឌីឃាទុឆ** បានកាន់បាតដៃនាងមានសាច់ទន់ម៉ដ្ឋ មានម្រាមស្រួចស្រឡូន ហើយក្រចកលាបថ្នាំក្រហមពណិទទឹម ។

សិស្សកម្លោះដើរបន្តិចមក ហើយងាកទៅឃើញរកឡានព្រីម៉ាកកាត្រឺ ណូលមួយបរចេញ ហើយបត់ឆ្ពោះទៅទិសខាងជើង.......

## អរុណស្នេហា

នៅយប់ថ្ងៃនោះ ក្រោយពេលអនុរក្សបានទះដៃព្រួប១បង្គាប់ឱ្យទម្លាក់ មុងដេក **នីយាវុធ** ក៏ប្រតិបត្តិតាមទាំងទន់ដៃទន់ជើង ដៃគងលើថ្ងាស ព្រលឹងក៏បង្វិលនូវអនុស្សាវរីយ៍ថ្មីថ្មោង ដើម្បីក្រេបឱជារសឡើងវិញនៃការដ្ឋាន ដ៏ថ្លៃថ្លាដែលប្រសើរជាងយល់សប្តិទៅទៀត ។ អ្នកកំលោះនឹកដល់សេចក្តីរាក់ទាក់ និងស្និទ្ធស្នាលយ៉ាងស្មោះត្រង់របស់នាង ហើយឆ្ងល់ក្នុងចិត្តថា កិរិយាយ៉ាងនេះ ខ្មែរណាដែលប្រកាន់ដំបូន្មានសាស្ត្រាស្លឹករឹតនៅឡើយ គង់ចាត់ដោយពេប ជ្រាយថា នាងជាស្រីចើក ឃើញប្រុសភ្លាមក៏ដេញរកប្រតិបតែម្តង ! ចោទយ៉ាងនេះចំជាអយុត្តិធម៌ហើយ ព្រោះក្នុងកិច្ចការអ្វី១ក៏ដោយ យើងមិនត្រូវយកក្បួនខ្នាតតែមួយ ហើយក្អេងក្អាងដើរវាស់ ដើរវិនិច្ឆ័យទំនៀមទម្លាប់គ្រប់ជាតិ គ្រប់សាសន៍ដូច្នោះឡើយ ។ នារីខ្មែរដែលប្រកាន់មូរមុខអៀនកំប្រុន កញ្ញាអារ៉ាប់ ដែលយកស្បៃមកទទូរស្កុងបាំងមុខ ក្រមុំខ្មែរលើដែលលែងដើមទ្រូងនៅទទេ ហើយស្ត្រីអឺរ៉ុប ដែលស្និទ្ធស្នាលនឹងបុរសដោយស្មើមុខគ្នាយ៉ាងពេញលេញនោះ តើអ្នកណាខុស អ្នកណាត្រូវ អ្នកណាគ្រាន់បើជាងអ្នកណា ? បើយើង ចាត់ថាគេធ្វើផ្តេសផ្តាសគេក៏គង់ទាស់ចិត្ត នឹងស្ត្រីខ្មែរយើងដោយចោទថា ជាមនុស្សខ្វះសេចក្តីរាក់ទាក់ គ្មានសេចក្តីស្មោះសដែរ ។ បើយើងប្រកាន់ថា យើងប្រព្រឹត្តតាមសីលធម៌ តាមចរិយាសាស្ត្រតាមដំបូន្មានដូនតា ព្រឹទ្ធាចារ្យយើង គេក៏តបវិញថា ខាងគេក៏មិនឃ្លៀងឃ្លាតពីគុណសម្បត្តិទាំងនោះទេដែរ ។

មួយទៀតដើម្បីឱ្យងាយយល់នូវកិរិយា និងឫកពា នាង **ចន្ទមណី** និង **នីយាវុធ** អង្វរឱ្យអ្នកផងគិតថានៅប្រទេសថៃ ស្ត្រីមានការវិវឌ្ឍន៍តាមរបៀប អឺរ៉ុប ជឿនទៅមុខឆ្ងាយណាស់ ព្រោះស្រុកគេបានឯករាជ្យយូរអង្វែងមកហើយ ។ ឯយុវជនគេទាំងស្រីទាំងប្រុសក៏បានចេញទៅរៀននៅទ្វីបអឺរ៉ុប និង អាមេរិចយ៉ាងក្រាស់ក្រែលផង ។

ចំណែក **នីយាវុធ** វិញដោយធ្លាប់ក្រេបឱជារសរឿងប្រលោមលោកបរទេស ធ្លាប់ថ្លឹងយល់នូវគំនិតមារយាទស្ត្រីភាព ដែលពាក្យខ្មែរយើងបន្ទោស ហើយហៅក្លាយថា "ស៊ីវិឡៃ" វិញអ្នកកម្លោះនេះយល់ឃើញកិរិយានាង **ចន្ទ មណី** ប្រកបដោយសភាពធម្មជាតិប្រពៃណាស់ ។ គ្មានអ្វីមកបង្ខិតបង្ខំឬគ្មានអ្វីមកទប់ទល់ឱ្យស្ទាក់ស្ទើរសោះឡើយ នាងតែងសំដែងយ៉ាងស្មោះត្រង់ ដោយឥតលាក់លៀមទេ នូវគំនិតអ្វីទាំងស្រុងដែលមកចាប់បដិសន្ធិក្នុងចិន្តានាង ។ តាមដែលបានសង្កេតមកប្រាកដជានាងមានសមានចិត្តខ្លះ ដែរមកលើខ្លួន ។ ប៉ុន្តែបើគ្រាន់តែមានមនោសញ្ចេតនាប្រភេទនេះប៉ុណ្ណឹង ឃើញថានៅពុំទាន់គ្រប់បរិបូណ៌ទេ ។ រុក្ខជាតិដុះលើដីបែកក្រហែងក្នុងរដូវប្រាំងត្រូវការភ្លៀង យ៉ាងណាមិញ ដួងចិត្តអ្នកកំលោះ ដូចយើងធ្លាប់ស្គាល់មកហើយស្រាប់ក៏វារក សេចក្តីស្នេហាយ៉ាងនោះដែរ ។ មើលចុះ ដេកយល់សប្តិ ដើរយល់សប្តិ អង្គុយ យល់សប្តិ អាត្មនជ្រួលជ្រាបទៅដោយមនោសញ្ចេតនានេះតែមួយ ។ ចុះបើ ឥឡូវមកភពប្រសព្វលើសេចក្តីប្រាកដដែលឆើត លើសលុបជាងសេចក្តីល្ងើង ឃើញទៅទៀតនោះ តើនឹងញាប់ញ័រយ៉ាងណាទៅ ?

ឱ ! ធ្វើយ៉ាងម្តេចហ្ន៎ នឹងបានឱកាសទៅបណ្តុះបណ្តាលសមានចិត្ត និង មិត្តភាពឱ្យកាន់តែចំរើនរុងរឿងបាន បើធនធានគេក៏មានស្តុកស្តម្ភ ហើយគេជាជនបរទេសទៀតផង ? ដែលគេបបួលឱ្យទៅលេង ប្រហែលគ្រាន់តែជាការគួសមក៏មិនដឹងដែរ ព្រោះខ្លួនបានជួយយកអាសាគ្រប់យ៉ាងក្នុងពេលធ្វើដំណើរ ។ នឹងទៅរកជួបគេតាមសំដីបបួលហាក់ដូចជាឯងឥតក្តើ ឥតខ្មាស ដោយហេតុថា នៅមិនទាន់ដឹងច្បាស់នូវទឹកចិត្តគេយ៉ាងណាសោះ ដ្បិតស្គាល់គ្នានៅថ្មោងថ្មី ពេក ។ ហ្នឹង **នីយាវុធ** ស៊ូសង្កត់ចិត្តដាច់ស្រេចថា មិនទៅរកជួបទេ កុំឱ្យគេ ត្មេះតិះដៀលដល់ជាតិ ដល់អម្បូរដែលខ្លួនប្រកាន់ស្ទួយលើសជីវិតទៅទៀត ។ ប៉ុន្តែថ្វីបើបានប្តេជ្ញាចិត្តយ៉ាងនេះ សេចក្តីអួលផ្សា សេចក្តីនឹកអាល័យមិនរំងាប់ សាបសូន្យទៅបានឡើយ ព្រោះមនោគតិចេះតែគូររូបនាង **ចន្ទមណី** ឃើញញញឹមស្រស់នៅចំពោះមុខពុំដែលដាច់ ។

ថ្ងៃមួយ ចំនួនដល់ប្រាំថ្ងៃពីពេលចូលរៀនមក ជួនជាទិវាឈប់បុណ្យ ។ នៅពេលរសៀល **ធីឃាវុធ** ស្លៀកពាក់កុមប្លេ **"មុលមចី"** ខៀវប្រផេះ ហើយចងក្រវ៉ាត់យ៉ាងសង្ហាបានចេញពីលីសេទៅមើលកុននៅរោងអេដិន ។ លុះចេញពីមើលកុនស្រាប់តែទុចង់នឹងលួង **ទេព្យកោសល្ល** ហើយនិងធីតា ដែលចុះជណ្ដើរពីលើឡៅអគារសមសួនឥតផ្ទឹម ។ ក្រឡេកឃើញភ្លាម នាង ញញឹមពព្រាយមករកនាយកម្លោះ ដែលរកគេចខ្លួនពុំរួចក៏ដើរចូលទៅទាំងអេះអុញ ។

- សួស្ដីលោក ! សួស្ដីឃុន !

- យីក្មួយទេតើ ! អតីតនាយទាហានឆ្លើយដោយរាក់ទាក់ ។

- សួស្ដីបង ! នាងតបហើយបន្ថែម :

- ខ្ញុំសូមបន្ទោសបន្ដិចទៅចុះ កាលពីមុនសន្យាថានឹងនាំខ្ញុំដើរលេង ខ្ញុំខំ រងចាំមើលផ្លូវ ។ ឥឡូវធ្វើព្រងើយបំភ្លេចខ្ញុំចោលបាត់ ។

**ធីឃាវុធ** លុះបានសង្កេតដោយរំភើបថានាងលែងហៅខ្លួន " ឃុន១ " ដូចមុនទៀត ហើយក៏តបកល្យាណវិញថា :

- អត់ទោសខ្ញុំចុះ ខ្ញុំជាប់រវល់ច្រើនពេក រកឆ្លៀតពុំបានសោះតែម្ដង ។

- អញ្ចឹងមែនហើយ នាងសើកអោយ រវល់តែដើរមើលកុនម្នាក់ឯង ។ នេះដោយសារជៀសពុំរួចទើបចូលមកជួប ។

- កុំកាចពេកហ្ន៎ា **ចន្ទមណី** ឪពុកបន្ទោសដោយបន្ទន់សម្ដី ។ ធម្មតា អ្នករៀនសូត្រមិនសូវទំនេរដូចយើងទេ ។

ថាហើយបែរមុខទៅរកនាយកម្លោះ :

- បើក្មួយមិនជាប់ធុរៈទៅណាទៀតទេ មកទៅញ៉ាំទឹកក្រូច និយាយគ្នាលេងនៅផ្ទះខ្ញុំ ចាំខ្ញុំឱ្យគេជូនឡានមកសាលាវិញឱ្យទាន់ម៉ោង ។

ការមកលេងផ្ទះនាងលើកដំបូង ក៏សណ្ដោងទាញមកនូវការមកជួបគ្នា យ៉ាងនេះជាញឹកញយ ។ លុះស៊ាំ១ទៅក៏ឃើញថា ឪពុកក្ដី ធីតាក្ដី មិនកាន់ឫក ពាជាអ្នកមានសោះឡើយ ។ ដូច្នេះ **ធីឃាវុធ** ក៏ភ្លេចគិតពីឋានៈនៃគ្រួសារ របស់ខ្លួនដែរ ។ ស្ទើរមិនលស់ថ្ងៃ យប់ **ធីឃាវុធ** តែងមកជួបនឹងមិត្ត បរទេសទាំងពីរហើយនាំគ្នាជិះឡានលេង ជួនទៅគគីរ ជួនទៅទឹកខ្មៅ ( ឥឡូវ ហៅតាខ្មៅ ) ពោធិចិនតុង ឬភ្នំឧត្ដុង្គ ហើយជួនកាលពេលល្ងាចនាំគ្នាជិះកាណូត ឆ្លងទៅយកខ្យល់អាកាសនៅខាងជ្រោយចង្វា ។

ការជួបគ្នាញឹកញាប់បែបនេះ នាំឱ្យសមានចិត្ត ក្លាយជាមិត្តភាពយ៉ាងបរិសុទ្ធ ។ តមកឥទ្ធិពលវ័យក្មេងបណ្ដាលមិត្តភាពនេះឱ្យក្លាយទៅជាមនោ សញ្ចេតនាមួយដែលតែងធ្វើឱ្យបេះដូងយុវជនយោលគ្រឹកគ្រេង ។

នៅថ្ងៃឈប់ណាដែលខ្លួនខំទប់ចិត្តមិនចេញពីសាលា ដើម្បីបំពេញកិច្ច សិក្សាឱ្យបានជ្រះស្រលះ **ធីឃាវុធ** ក៏ស្លុតស្ញប់វីវរវាយ ។ ប៉ុន្តែដោយធម្មជាតិ ខ្លួនជាអ្នកមិនចេះបៀមទុក្ខសម្រេងឃ្សូរ មិនប៉ុន្មានម៉ោងក្រោយមកក៏តែងសើច ក្អាកក្អាយយ៉ាងព្រងើយ ជាមួយពួកម៉ាកដែលចេះក្រមាច់កំប្លែង ។ យុវបុរស យើងតែងតែញញើតខ្លាចបំផុតពេលដែលទម្លាក់មុងនិទ្រា ព្រោះសេចក្ដីនឹករលឹក តែងធ្វើឱ្យ

ស្រមៃឃើញរូបវរមិត្តដែលស្រស់ចំប្រប់ឱភាសឥតថ្មីម ។ ម្ល៉ោះហើយក៏ក្រហល់ក្រហាយតែម្នាក់ឯង ទំរាំនឹងតម្រង់ផ្គង់ចិត្តបានថា ខ្លួនត្រូវរៀនឱ្យបានសំរេចដូចប្រាថ្នាសិន ទើបអាចឈោងដៃទៅរកឆោមស្និទ្ធកើត ។

ចំណែកខាងនារីវិញ នាងពុំដែលញែកធ្វើវិភាគដួងចិត្តឱ្យដឹងថាតើចំណងរាប់អានរវាង **ឌីយ៉ាឌុឆ** និងខ្លួននាងជាវត្ថុធម្មតា ឬប្លែកពីធម្មតាសោះឡើយ ។ នាងគ្រាន់តែសង្កេតថាក្នុងគ្រាណាមានសំបុត្រអ្នកកំលោះមកប្រាប់ថា គេជាប់រវល់ពុំបានចេញមកលេងទេធ្វើមនាងធ្លាក់ក្តុកហើយនៅពេលនោះ ការកំសាន្តទាំងឡាយដែលនាងធ្លាប់ត្រេកត្រអាល ក៏ហាក់ដូចជាឥតរស់ជាតិទាំងអស់ ។

ថ្ងៃមួយឪពុកនាងមានធុរៈចូលទៅព្រៃនគរ នារីនាងនៅតែម្នាក់ឯងជា មួយស្រីភីលៀងទាំងពីរ ដែលកំពុងចាត់ការក្នុងផ្ទះ។ ដោយនាងពុំបានទទួលដំណឹងអ្វីជាមុនថា មិត្តនាងពុំបានមកទេនោះ នាងក៏រៀបចំខ្លួនហើយចុះមករង់ចាំនៅទីទទួលភ្ញៀវ ។ ពេលនោះនាងស្លៀកហ៊ូបពណ៌ពងក្រសា ហើយពាក់អាវពណ៌ផ្កាឈូកយ៉ាងសំណាម ។ ដោយនាយកំលោះយឺតពេលក្រមកដល់បន្តិច នាងក៏ចាប់សៀវភៅប្រលោមលោកអង់គ្លេសដែលមិត្តបានឱ្យនាងខ្ចី មកអានតទៅទៀតដើម្បីបន្ទប់ការរង់ចាំ ។ នាងអង្គុយក្នុងកៅអីវែង ដងខ្លួន ផ្អែកទៅភ្នាក់ដៃម្ខាង ហើយកំភួនជើងស្រឡូនរៀវក្លំសណ្តូកបណ្តោយទៅលើពូក ។ មិនយូរប៉ុន្មានពាក្យពេកចន៍ពិរោះ ហើយសាច់រឿងដែលនាំឱ្យស្រណោះដល់គូជីវិត ក៏នាំឱ្យសេចក្តីទន់ទីមរបស់នាងស្រងល់ភ្លេចភ្លាំងទៅ ។ ព្រលឹងកំពុងជក់ស្រាប់ តែឮសូរស្បែកជើងខ្សាក១ នាងងើបភក្រ្តឡើងហើយក៏ញញឹមពព្រាយ ។

- សួស្តីបង !

- សួស្តីអូន ! បងសូមអភ័យទោសចុះ ដោយយឺតជិតកន្លះម៉ោង ព្រោះ ស៊យជិះស៊ីក្លូមកបែកកង់ ហើយរកស៊ីក្លូទំនេរជិះពុំបានទើបដើរមក ។ **ឌីយ៉ា ឌុឆ** និយាយបណ្តើរក៏ដើរចូលជិតបណ្តើរ ។

- បង ! បងឯងមើលអីនេះ !

នាងដកក្រដាសពីរសន្លឹកបត់សៀតភ្លេចចោលក្នុងសៀវភៅដែលនាង កំពុងអាន យកមកបង្ហាញមិត្តនាង ។

កាលណានាងលាផ្ទត់ក្រដាសនេះឡើង អត្ថបទជាអក្សរខ្មែរក៏ប្រាកដ ឡើងចំពោះភ្នែក។

កាលបើឃើញក្រដាសនោះភ្លាម ទឹកមុខ **ឌីយ៉ាឌុឆ** ឡើងក្រហមទុំ អេះអុញ ដោយរកនឹកអ្វីមកដោះសាពុំបាន ។

នារីសៀមនិយាយតទៅទៀត :

- នេះប្រហែលជាកំណាព្យហើយ បានជាមានឃ្លា មានល្បះស្មើរប្រវែង គ្នា ។

- អូនស្មានត្រូវហើយ ជាពាក្យកាព្យពិតមែន ។

- តែអ្នកណាតែង ?

ដោយទាល់គំនិត ចៅបុរសក៏ឆ្លើយ :

- ខ្លួនបងនេះឯង តែងលេងហើយភ្លេចដៃដាក់ក្នុងសៀវភៅនេះមក ។

ឈ្លើយអូនកុំរវល់នឹងកាព្យឃ្លោង ឥតជាតិ ឥតដៅធ្វើអី ដែលយើងថា ទៅមើលកុននោះល្មមទៅហើយ តិចហួសពេល ។

- ហួសក៏ហួសទៅចុះ គ្មានអ្វីល្អប៉ុន្មានទេ ។ ខ្ញុំចង់ដឹងសាច់កាព្យនេះ ណាស់ ។ មុខជាពិរោះហើយ ។ បងឯងមិនទាន់ដឹងទេខ្ញុំចូលចិត្តកវីនិពន្ធណាស់ ។ ខ្ញុំធ្លាប់បានអានជាភាសាអង់គ្លេស និងភាសាថៃ ។ ហេតុនេះហើយបានជាចង់ ស្គាល់កាព្យភាសាខ្មែរទៀត ។ បងឯងមើលទៅ មើលជាភាសាខ្មែរសិន ។

រកវិធីដោះខ្លួនពុំរួចហើយ ទើប **ឌីយ៉ាឌុឆ** ទទួលយកសន្លឹកក្រដាស នោះមក

- អូនឯងគង់បានសង្កេតឃើញស្រាប់ហើយ កាព្យក្នុងសន្លឹកក្រដាសពីរ ផ្ទាំងនេះ មានពីរបែប ។ មួយបែបបងបានតែងតាមនិយម បារាំង ។ ក្នុងឆ័ន្ទ នីមួយៗមានដប់ពីរព្យាង្គ ហើយចុងជួនមាននៅតែត្រង់កន្ទុយឆ័ន្ទទេ ។

អីចឹងប្រហាក់ប្រហែលគ្នានឹងកាព្យអង់គ្លេសដែរ ។ **ធីឃារ៉ាវុធ** និយាយតទៅទៀត

- មួយបែបទៀត បងតែងតាមចំណូលចៃ និងខ្មែរជាពាក្យប្រាំពីរ ។

- សូមបងមើលកំណាព្យបែបបារាំងមុន។

នាងខិតអង្គុយមួយចំហៀង ហើយចង្អុលឱ្យនាយកំលោះអង្គុយម្ខាង ទន្ទឹមនាងក្នុងកៅអីវែងតែមួយ ។ **ធីឃារ៉ាវុធ** ចាប់អាន :

**លលក**

ថ្ងៃត្រង់ ។ វាលស្រែក្ដៅដូចជាភ្នក់ភ្លើងមួយយ៉ាងធំ ព្រះអាទិត្យចិត្ត ឃោរឃៅកំឡាចស្មៅ និងកញ្ច្រាំង ចំហាយខ្យល់បក់ភិបៗ លើទឹកល្អក់ក្នុងត្រពាំង ដែលមានកុកសំគមមួយចាប់កំពិសដោយសំងំ ។ សត្វនានាស្ងាត់មាត់ជ្រៀប ។ ចម្រិតដែលជាពិរម្យរបស់ស្រុក ស្រែនោះសោតក៏ជ្រកពួនដោយភ័ន្តភាំង អ្នកគង្វាលគោដេក ដៃគងថ្ងាសស្រមុកគ្រាំងៗ ក្រោមដើមអំពិលមួយក៏មានម្លប់ត្រជាក់ត្រជុំ ។ នៅវេលាដែលក្ដៅហប់ទូទៅទាំងវាលព្រៃព្រឹក្ស មានលលកមួយមកទំលើមែកមួយដែលឥតស្លឹក ហើយបក្សីនេះតាំងច្រៀង គ្រលួច ពិរោះឥតបី ។ ក្នុងផ្ទៃស្ងប់សំឡេងនោះដែលថ្លាដូចចរណៃ មកញាំងអ្នកដែល សន្ទឹងខ្នងផ្ទាល់ដីឱ្យស្រមៃឃើញវិមានឋានសួគ៌ា និងកញ្ញាល្អ ប្រិមប្រិយ ។

នាង **ចន្ទមណី** បានផ្ទៀងតាមចង្អុលដៃ **ធីឃារ៉ាវុធ** ដែលចុចបង្ហាញ នូវបន្ទាត់ កំពុងអានបណ្ដើរ ។ លុះចប់ការកាព្យបែបបារាំង ហើយ នាងនិយាយថា :

- បងប្រែទៅ ប្រែជាសៀមវិញ ប្រហែលជាស្រួលជាង ព្រោះខ្មែរ និង សៀម ភាសាស្រដៀងគ្នា ។ ហើយបើប្រែពីខ្មែរត្រូវ អង់គ្លេសប្រហែលជា ពិបាក ដូចជាប្រែពីថៃត្រូវអង់គ្លេសដែរ ។

- សៀមក៏ដោយ អង់គ្លេសក៏ដោយ ខ្ញុំមិនសូវប្រសប់ទេ ។ មុខតែរ រកាត់រកុបហើយ ។

- មិនអីទេបង លមើលទៅ !

**ធីឃារ៉ាវុធ** ហួសប្រកែកក៏ទទួលធ្វើតាមបង្គាប់ ។ ក្នុងពេលកម្លោះខ្មែរ ទាល់ពាក្យម្ដងៗនាងសៀមក៏ញញឹមជួយរកឱ្យលុះឃើញ ហើយក៏សម្លឹងមុខគ្នា សើចទាំងពីរនាក់ ។ លុះប្រែចប់ហើយ យុវតីនាងជូនសេចក្ដីដូចតទៅ :

- យីបងជំនាញតែងកំណាព្យបែបអឺរ៉ុបណាស់ ។ ពាក្យបញ្ចប់ចុង ក្រោយលើកទឹកចិត្តឱ្យខ្ពស់ ឱ្យអតៃណ្ដតែម្ដង ! មើលចុះអ្នក គង្វាលគោ ដែល ដេកផ្ទាល់ដី ដល់ឮទំនុកលលកក៏ស្រមៃនឹកដល់ទេបអប្សរ ធីតាល្អឯក !

ឮនារីសរសើរយ៉ាងនេះ មុខចៅបុរសក៏ឡើងក្រហមតែពុំចេញស្ដីថា អ្វី ឡើយ ។ មួយសន្ទុះក្រោយមក ទើបនាងនិយាយថែម :

- ឥឡូវ បងមើលកាព្យបែបខ្មែរទៅមើល ធ្វើបទធ្វើបែបផងទើប ពិរោះ ។

ដូចជាមនុស្សស្លន់បាត់ព្រលឹង **ធីឃារ៉ាវុធ** ប្រតិបត្តិតាមបង្គាប់យុវតី ដោយឥតប្រកែក ។

**ឥន្ទនីតាពរាត្រី**

**ធម្ម**ជាតិនិទ្រាស្ងាត់ជ្រងំ មាន់រងាវយំឮល្វឹងល្វើយ
ខ្យល់បក់ធាងដូងយោលទន់ជើយ រំភើយបក់ផាត់ក្លិនម្លិះលា ។

**ព្រះ**ចន្ទឈៀងគង់ភ្នំខ្មៅវែង    មេឃខ្ពស់ធំធេងវែងស្អាតថ្លា
សន្សើមប្រោះព្រំចុងព្រឹក្សា    ហៅសែនសុខាក្នុងរាត្រី ។
**តែ**ក្នុងចិត្តខ្ញុំមានកង្វល់    រូបរីតគិតដល់ត្រួយនារី
រូងនាងខ្ជូតតាមគ្រប់ទិសទី    នាំឱ្យរក់រីអស់អង្គកាយ ។
**ព្រាល**លឹងស្រមៃឃើញរវលក្ខណ៍    មានភ័ក្ត្រញញឹមស្រស់ពព្រាយ
ថែមពុសំដីនាងនិយាយ    ឡែបខាយពិរោះជាប់ពិសម័យ ។
**ដូច**ឃ្មុំស្រវឹងក្លិនបុប្ផា    ហើយហើរឆ្វៀវឆ្លាកណ្ដាលថ្ងៃ
ខ្លួនបងស្រវឹងនឹងមាសថ្លៃ    នឹករកមមៃគ្មានពេលលស់ ។
**ជន្លេន**ម្ដេចហ៊ានស្រឡាញ់ផ្កាយ    ខ្លួនតូចទាបឆ្ងាយម្ដេចឈោងខ្ពស់
ម្ដេចមិនមើលទ្រព្យមើលសក្តិយស    សញ្ជាតិទាំងអស់សុទ្ធខុសគ្នា ។
**គ្មាន**អ្វីគួរឱ្យសង្ឃឹមបាន    សំរេចកាលណាទើបហៅគាប់
**តែ**ទោះគិតឃើញត្រូវដូចម្ដេច    ស្នេហាពន្លិចសង្កត់ជាប់
ឱ ខ្លួនខ្ញុំអើយសែនអភ័ព្វ    ទុក្ខច្រើនស្រទាប់អ្វីម្ល៉េះទេ !
**ឆម្ម**ជាតិដេកលក់ដោយសុខុម    មាត់មាន់រងំដូចបំពេរ
ខ្យល់ច្រានធាងដូងឱ្យយោលទេរ    ជួយបក់បំបែរក្លិនចំប៉ា ។
**លោក**ខែលិចក្រោយភ្នំខ្មៅស្ដើង    ពពកមីរឡើងក្នុងមេឃា
សន្សើមស្រោចស្រស់ពសុធា  ហៅសែនវេទនាក្នុងចិន្ដា ។

នារីផ្ទៀងស្ដាប់សាច់កាព្យផ្អែមល្ហែម ហើយសម្លេងអ្នកអានដែលរណ្ដំរងំ ។ លុះចប់ហើយ នាងនៅស្ងៀមមួយស្របក់ធំដោយនាងស្រមៃហាក់ដូចសម្លេង និងសាច់ឃ្លោង ក្រគួចប្រគំពិរោះក្នុងត្រចៀកនៅឡើយ :

- បងប្រែទៀតទៅមើល៍ ។

**ឌីយាវុធ** ដែលឡឹនឡង់ដោយសិនិទ្ធភាពពុំដែលស្គាល់យ៉ាងនេះ ក៏មិនបានប្រុងស្មារតីគិតដល់សាច់កាព្យ ដែលបំបែកឱ្យដឹងស្នេហាកំបាំងរបស់ខ្លួនបានឡើយ ។ដូច្នោះហើយក៏ចាប់តាំងប្រែដោយស្មោះត្រង់ទាំងអស់ឥតមានលាក់លៀមតិចតួចឡើយ ។

នារីនាងត្រាប់ត្រងស្ដាប់ មុខនាងប្រែរំជួល ។ លុះសម្លេងកវីស្ងប់បាត់យ៉ាងយូរ ទើបនាងហាក់ដូចជាភ្ញាក់ខ្លួនឡើង ហើយជូនសេចក្ដីសង្ខេបថា :

- កាព្យទាំងពីរបែបនេះ ថ្វីបើប្រើវិធីខុលគ្នាយ៉ាងឆ្ងាយក៏គង់តែមាន ចំណងសម្ព័ន្ធមួយមករួបរួមគ្នាយ៉ាងជិត បង្ហាញឱ្យឃើញថាជាស្នាដៃជនតែម្នាក់ ដែលជាអ្នកកើតស្នេហាដោយឥតសង្ឃឹម ។ ក្នុងកាព្យ "លលក" ដូចខ្ញុំបានថាមកហើយអ្នកគង្វាលគោ គឺអ្នកដែលមានឋានៈទន់ទាប ឬក្រស្រមៃនឹកដល់ នាងទេពអប្សរ ពោលគឺនារីដែលមានពូជពង្សខ្ពង់ខ្ពស់ជាង ។ ក្នុងកាព្យបែប ខ្មែរ អ្នកតែងបានបញ្ជាក់អោយដឹងច្បាស់ថា ខ្លួនគាត់មានសេចក្ដីប្រតិព័ទ្ធនារី ម្នាក់ដែលជាធីតាកូន អ្នកមានទ្រព្យ អ្នកមានកិត្តិយស ហើយថែមទាំងមានជាតិខុសគ្នាទៀតផង ។ សរុបសេចក្ដីទៅឃើញថា បងឯងនេះលួចស្រឡាញ់ នារីដែលរៀនសូត្រជាមួយគ្នា មិនមែនខ្មែរទេ ។ បើមិនយួនក៏បារាំងជាប្រាកដ ។ប៉ុន្ដែខ្ញុំជឿថា ស្រីបារាំងច្រើនជាង ដ្បិតអីធម្មតាអ្នកមើលកុនជោកដូចបង ឯងនេះត្រូវចាប់ចិត្តនឹកលំអនារីអឺរ៉ុបណាស់ ។ ម្ល៉ោះហើយ.......... ម្ល៉ោះហើយ ក៏លួចស្រឡាញ់តែអ្នករៀនគ្នាឯងទៅ ។ ចំជាខូចមែន !

ក្នុងគ្រានោះស្ថានាការណ៍ **ទីយាទុធ** មិនខុសគ្នាប៉ុន្មានទេ ពីស្ថានការណ៍អ្នកប្រព្រឹត្តបទល្មើស ដែលសុភាចារបុរស កំពុងជជីកដេញដោបួសគល់ អំពើកំបាំងរបស់ខ្លួន ។ ជិតទាល់ច្រក អ្នកកំលោះនៅប្រកែកដោះសារ ដោយស្មើយ ៗ :

- មិនមែនទេអូន កាព្យនេះបងគ្រាន់តែលើកកែអផ្សុកទេ ។ នៅផ្ទាក់ រៀនបង គ្មាននារីយួន ឬ បារាំងរៀនជាមួយទេ ។

- កែអផ្សុកឯណាកើត ! បើមុខបងឯងឡើងស្លាំងយ៉ាងនេះ កុំកុហក ប្រសិនបើ យុន ឌ និងខ្ញុំជួយកើត ចាំយើងទាំងពីរជួយដោះស្រាយបញ្ហានេះ ជូន ។

និយាយខ្សិបៗ **ទីយាទុធ** ព្រមសារភាពទទួលទាំងស្ទាក់ស្ទើរថា ខ្លួនមានចាប់ចិត្តស្រឡាញ់កញ្ញាម្នាក់មែន ។ ដោយនាងចេះតែជជីកចង់ដឹងនាមនារី នោះពេក នាយកម្លោះក៏ភ្លាត់មាត់លន់តួថា :

- បើអូនកុំប្រកាន់ទោស ទើបខ្ញុំហ៊ាននិយាយប្រាប់ ។

- ប្រាប់មក មានទោសពៃរ៍អីយ៉ាងហ្នឹង ។

- ហឺ ! ពិបាកថាពេក

ព្រោះនាងកាន់តែឆ្ងេងឆ្ងល់ដឹងខ្លួនបន្តិចឡើងៗ ហើយនាងក៏រន្ទាន់សួរដោយ ញាប់ញ័រក្នុងឱរា ។

- ប្រាប់ឆាប់មកបង បើពុំនោះទេ ខ្ញុំខឹងហើយ ។

- នារីដែលបងលើកជាត្រួយជីវិតនោះ គឺ .....នោះគឺ.....នោះគឺ.....នោះ គឺ.....នោះគឺ... ដោយពាក្យទទួលសារភាព ហាក់ដូចជាពិបាកចេញពីបំពង់ក ពេក ចៅមាណព យើងក៏កើតជាយកដៃទៅលូកចាប់ហត្ថមាសស្នេហ៍មកក្តោបជាប់ ។ ហាក់បីដូចជាអស់កម្លាំងណាស់ ដោយបានប្រឹងប៉ុណ្ណឹង **ទីយាទុធ** ក៏ ផ្តួលខ្លួនក្រាបទៅលើកៅអីជិតជង្គង់ កំពូលនារី ហើយរៀបរាប់រអាក់រអួលថា :

- អូនអើយ មិនគួរបងក្បត់មិត្តភាពរបស់នាង ហើយនឹងឪពុកនាង យ៉ាងនេះសោះឡើយ ។ ខ្លួនបងជាអ្វី ? ជាកូនអ្នកស្រែចំការជនបទចុងកាត់មាត់ញក ជាសិស្សមិនទាន់បានសញ្ញាប័ត្រធំដុំនៅឡើយផង ។ មិនគួរហ៊ាន ងើបមុខសម្លឹងអ្វីខ្ពស់ដល់ម្លេះ ! ប៉ុន្តែថ្ងៃនេះជាត្រូវនិយាយប្រាប់នាងអំពីការណ៍ លាក់កំបាំងរបស់ដួងចិត្ត ខ្ញុំសូមបើកបង្ហាញប្រាប់ឱ្យអូនអស់ពីពោះ ទោះបីនាង បដិសេធច្រានបងចោលចេញបងក៏ឥតទោមនស្សអ្វីដែរ ។ សេចក្តីស្នេហាមិន ស្គាល់ខុស មិនស្គាល់ត្រូវសោះឡើយ ។ វិចារណញ្ញាណបង្គាប់បង កុំឱ្យសូវទៅមកផ្ទះអូនពេក ព្រោះមាការម្មណ៍កាន់តែលូតលាស់ដោយឥតសង្ឃឹម នាំអោយតែខ្លោចផ្សា ហើយធ្វើឱ្យសៅហ្មងដល់ការរៀនសូត្រឥតអំពើទេ ។ ត្រូវណាស់ហើយត្រូវគ្របដប់តែសេចក្តីស្នេហា នៅតែរុញច្រានបងឆ្ពោះទៅមកផ្ទះអូន ។ **ទីយាទុធ** ឈប់មួយស្របក់ដកដង្ហើមធំ ។ ក្នុងភូមិគ្រឹះដ៏ស្ងាត់ឈឹង ឮសូរ តែនាឡិការភ្លេងយោលតិកតក់ តិកតក់ ។ មួយសន្ទុះក្រោយមកទើប **ទីយា ទុធ** និយាយតទៅទៀត :

- អូនអើយ តាំងពីក្មេងតូចមក បងចេះតែគួចស្រឡាញ់អ្វីៗទាំងអស់ ដែលមកពីប្រទេសថៃ ។ បងប្រកាន់ស្រុកសៀមជាឧត្តមគតិខាងផ្នែក សោ ភ័ណភាព និងមនោរម្យ ។ ក្នុងពេលស្តាប់វិទ្យុ បើកាលណាបើសម្លេងនារី សៀមច្រៀងបងស្តាប់ ពិរោះទន់ដៃទន់ជើងអស់ហើយ ហើយតែងក្រងនូវសេចក្តីស្នេហាយ៉ាងត្រកាល យ៉ាង "រ៉ូម៉ង់ទិច" តែដល់ចប់ទៅតែងធ្វើឱ្យឈឺផ្សាក្នុងចិត្តក្រៃលែង ។ ទំនងការណ៍យ៉ាងនេះបង្ហាញឱ្យយល់ថា មុននឹងឃើញរូបអូន បងមានចិត្តចាំប្រុងស្រឡាញ់អូនទៅហើយ ។ លុះខ្លួននាងលេចមកប្រាកដនឹងភ្នែកមែន ហើយល្អប្រិមប្រិយ ព្រមទាំងមានសេចក្តីរាក់ទាក់ប្រសើរជាងយល់សប្តិទៅទៀត អូនអើយអូន បងសែនត្រេកអរផងព្រួយបារម្ភផង ។ បងត្រេកអរព្រោះបានឱកាសជាញឹកញាប់មកទទួលមិត្តភាពយ៉ាងស្មោះស្ម័គ្រ ហើយមកគយគន់រូបឆោមលោមពណ៌អូន និងកិរិយាចិត្តថ្លើមអូនដែលសមសួនឆើត ប្រពៃលើស ដែលសេចក្តីវីរវាយនាំអោយបងស្មានទុកនោះជាងឆ្ងាយណាស់ បងព្រួយបារម្ភ ព្រោះគិតឃើញថា នាងជាបុត្រី អ្នកមានបណ្តាសក្តិក្នុងប្រទេស មួយឯករាជ្យពេញទី ។ ប្រសិនបើនាងពុំមានសេចក្តីស្នេហាមកលើ

ខ្ញុំទេ នាង នឹងខឹងក្តាញ់នឹងខ្ញុំហើយខ្ញុំក៏ខូចខាតមិត្តភាពរបស់យើងជាអសារបង់ ។ បងគិត អើយរែងគិត ក្នុងចិត្តចំបែងឥតឧបមា ។ ឥឡូវបានជាទម្លាយបុសនៃការ សំងាត់ទៅហើយ សូមនាងថាមកចុះ សន្និដ្ឋានសេចក្តីមកចុះ ទោះនាងឆ្លើយ តាមនឹងសេចក្តីស្នេហាឥតសមហេតុសមផលនេះក្តី ឬ កាត់ទោស ដាក់កំហុស ដោយរុញច្រានចោលក្តី ខ្ញុំនឹងមិនតូចចិត្តសោះទេ ធ្វើម្តេចវាសនាខ្ញុំខើចខ្លីតែ ប៉ុណ្ណឹង ។

ដូចជាជនជាប់ចោទ នៅចំពោះមុខចៅក្រមកាត់ក្តី **ឌីយាឌុឆ** លុះ បាននិយាយការពារស្នេហាខ្លួនចប់ហើយក៏នៅឱនមុខនៅស្ងៀមចាំស្តាប់ដោយរន្ធត់នូវសេចក្តីវិនិច្ឆ័យ លុះចាំស្តាប់មិនឮអីសោះអស់ពេលមួយសន្ទុះធំទើបងើប មុខឡើងឃើញភក្ត្រស្ងួនភ្ងាក្រហមហើយនាងយកកន្សែងជូតទឹកនេត្រា ដែលជោរជន់ហូររហែង ។ នាយកម្លោះក៏នឹកក្នុងចិត្តថា ប្រាកដជាខ្លួនបានធ្វើឱ្យនាងថ្នាក់ថ្នល់យ៉ាងណាហើយ ទើបនាងខឹងហើយយោយំយ៉ាងនេះ ។ យល់ដូច្នោះ ហើយក៏រៀបរបខ្លួនក្រោកដើរចេញ :

- កុំយំថ្វីអូន បងសូមលាហើយ ។ ពីថ្ងៃនេះទៅមុខនាងនឹងលែងមាន អំពល់ ដោយសារបងទៀតហើយ ។

ថាភ្លាមក៏ស្ទុះក្រោកឈរភ្លាម ស្រាប់តែដៃនាងប្រវាចាប់ទាញដៃឱ្យអង្គុយទៅវិញ :

- បងអើយ កុំអាលយល់ខុស ។ ដែលបងសារភាពអម្បាញ់មិញ ធ្វើអោយខ្ញុំជួលចិត្តណាស់ ។ ហេតុនេះហើយ ទើបមានទឹកភ្នែកហូរខ្លះ ។ ខ្ញុំស៊ូកាត់សេចក្តីអៀនខ្មាសរបស់ស្ត្រីទៅចុះ ហើយសូមជំរាបបងដោយស្មោះត្រង់ដែរ ។ តាំងពីជួបគ្នា ដំបូងកាលណាមក សមានចិត្តចំពោះបងតែងដុះដាលក្នុងហឫទ័យអូន ហើយក្លាយទៅជាមិត្តភាព រួចទៅជាអ្វីមួយធំជាងនុ៎ងទៅទៀត ។ ទ្រូងអូនតែងញាប់ញ័រត្រេកអរក្នុងពេលជួបភក្ត្របង ។ លុះបងលាផុតទៅកាលណាផ្ទះនេះ ទីកន្លែងនេះក៏ក្លាយទៅជារហោឋានស្ងាត់ជ្រងំ ។ បងដឹងទេ ? ក្នុងពេលដំបូងដែលខ្ញុំឃើញសំណៅកំណាព្យបងក្នុងសៀវភៅនោះ អូនរន្ធត់ចិត្តហើយខំសំលឹងតួរអក្សរ ដែលមានទ្រង់ទ្រាយស្រដៀងគ្នានឹងអក្សរសៀមដែរ ។ អូនខំពិនិត្យមិនដាក់ភ្នែកទេ ព្រោះចង់ដឹងអាថិកំបាំងដែលកប់ក្នុងផៃន សេចក្តីនោះពន់ពេក ។

- អូន សំដីនាងទាំងប៉ុន្មានម៉ាត់នេះ ហាក់ដូចជាប្រស់បងឱ្យមានជីវិតថ្មីឡើង ។ ពីថ្ងៃនេះទៅបងនឹងខំរៀនឱ្យ បានសមនឹងសេចក្តីស្នេហារបស់អូន របស់យើងទាំងពីរ ។

ក្នុងពេលនោះ នាឡិកាធំ វាយម៉ោងប្រាំមួយល្ងាច ដោយបញ្ចេញសំឡេងធ្ងន់ៗ ដូចជាសូរគង់នៅវត្ត ។ យុវជនទាំងពីរភ្ញាក់ខ្លួនព្រើត ហើយកាន់ដៃគ្នាមកលេងក្នុងសួនមុខផ្ទះ ។ រុក្ខជាតិដោយត្រូវរស្មីអស្តង្គត ក៏បញ្ចេញលំអយ៉ាងចំពើបដើម្បីបូជាសេចក្តីស្នេហានៃគូសង្សារថ្មោងថ្មី ។

ផ្ទុយពីការសង្កេតធម្មតាទៅវិញ សេចក្តីស្នេហាដែល **ឌីយាឌុឆ** ក្តោបក្នុងដួងហឫទ័យមិនមែននាំឱ្យចៅបុរសរវើរវាយក្នុងការរៀនសូត្រទេ តែបែរក្លាយជាឱសថឬជាថាមពលថ្មីមួយលើកទឹកចិត្តឱ្យខំខ្នះខ្នែងជាងមុនទៅទៀត។ កាលពីដើមគ្រាន់តែមានគោលបំណងចូលធ្វើការយកប្រាក់ខែចិញ្ចឹមជីវិត ។ ឥឡូវត្រូវរកវិជ្ជាដើម្បីឱ្យសមនឹងគូស្នេហា ដែលបានផ្តេកចិត្តមកលើ ។ ក្នុងពេលដែលបានជួបគ្នាលើកក្រោយៗមក យុវជនទាំងពីរនាំគ្នាពិគ្រោះអំពីការកសាងអនាគត ដោយរួបរួមជោគវាសនាជាមួយគ្នា ហើយក៏បានដាច់ស្រេច ព្រមព្រៀងគ្នាថា លុះបានជាប់មធ្យមសិក្សាប័ត្រជាន់ទីពីរកាលណា **ឌីយា ឌុឆ** នឹងទៅបន្តវិជ្ជាឯប្រទេសបារាំងឱ្យបានថ្នាក់បរិញ្ញា ឬថ្នាក់បណ្ឌិតក្នុងផ្នែក អ្វីមួយទើបត្រឡប់មកវិញ ។

ក្នុងពេលដដែលនេះនាង **ចន្ទមណី** នឹងខំរៀនភាសាខ្មែរឱ្យចេះស្ទាត់ ព្រមទាំងចូលរៀនភាសាបារាំងនៅ ឯមហាវិទ្យាល័យនារីនៅដាឡាត់ទៀតផង នៅដើមឆ្នាំសិក្សាខាងមុខនេះ ពោលគឺត្រង់ពាក់កណ្តាលខែកញ្ញានៃឆ្នាំ ១៩៣៩ ។

លុះបានសំរេចព្រមគ្នាយ៉ាងនេះហើយ **ធីយ៉ាវុធ** ស៊ូកាត់ចិត្តក្នុង ឱកាសវិស្សមកាលនាខែមេសាខាងមុខ ខ្លួននឹងមិនដើរលេង មើលស្រុក មើលទេសជាមួយលោក **ទេពព្រហ្មកោសល្ល** និង **ធីតា** ទេ ដើម្បីយកពេលនៅប្រុង ប្រៀបរៀបខ្លួនចូលប្រលងឯខែ មិថុនា។ ថ្វីបើគូសង្សារមានចិត្តស្តាយក្រៃលែង មិនចង់បែកគ្នាដល់មួយខែយ៉ាងនេះក៏ដោយ តែនឹកគិតឃើញថា គប្បីពលិកម្មនេះសិនចុះ ដើម្បីកុំឱ្យ ស្ទាក់ស្ទើរដល់ដំណើរទៅអនាគត ។

អនាគត ? គូជីវិតទាំងទ្វីប្រាណនេះមើលឃើញតែថ្លា តែភ្លឺជានិច្ច ព្រោះ អំណាចកំលាំងអាយុនៅក្មេង ។ ឧបសគ្គកងកង្វល់អ្វី១ ច្រានថយចេញអស់មិន អាចទ្រាំបាននឹងរិទ្ធានុភាពនៃស្នេហាបានឡើយ ។

សេចក្តីត្រេកត្រអាលចំពោះជីវភាព និងសុភមង្គលកើតឡើងដោយកាមារម្មណ៍ រមែងធ្វើឱ្យយុវជនឋិតនៅក្នុងលោកមួយដោយ ឡែក ដែលប្រហែលជាឃ្លាតឆ្ងាយបន្តិចពីប្រាកដនិយាយ តែគង់ជិតទៅរកកវីនិពន្ធជាង ។ មើលចុះ សូម្បីតែផ្កាដែលកំពុងរីក ទឹកសន្សើម ដែលដេញពន្លឺអរុណនៅចុងស្មៅ ដូចគ្រាប់ពេជ្រ ហើយសម្លេងបក្សីដែលឆ្លងឆ្លើយគ្នាតាមមែករុក្ខា ក៏គូរសង្សារទាំងឡាយ តែងប្រតិស្ថ យល់ថា ជាវត្ថុសម្រាប់បូជាសេចក្តីស្នេហារបស់ខ្លួនទាំងអស់ ។

៤

### ន្លឹកគួលែនឋានបរមសុខ

ល្ងាចថ្ងៃអាទិត្យមួយ នៅក្នុងខែមីនា **ធីយ៉ាវុធ** បានមកលេងផ្ទះមិត្ត ខ្លួនទាំងពីរ ។

ក្នុងពេលនោះ ឪពុក និងកូនកំពុងអង្គុយយកលំហើយនៅរានហាលខាង ក្រៅដោយមានទឹកក្រូចមួយកែវម្នាក់នៅចំពីមុខ ។ លោក **ទេពព្រហ្មកោសល្ល** បានទទួលអ្នកកំលោះ ដោយរាក់ទាក់។ ឯនាង **ចន្ទមណី** ញញឹមពព្រាយទៅរក ហើយចៅរៅហៅមនុស្សបំរើលើក កៅអីមួយមកថែមទៀត ។ ចំណែក ខ្លួននាងក៏ចូលទៅរកទឹកក្រូចពោធិ៍សាត់ច្របាច់ ដាក់ទឹកកកមួយកែវមកជូនភ្ញៀវថ្មី ។ លុះបាន អង្គុយស្រួលបួលព្រមគ្នាហើយនាងក៏ស្នើសួរ :

- យីបង ! បងឈប់វិស្សមកាលនៅថ្ងៃណា ?

- ចាប់ពីថ្ងៃសុក្រទី មួយមេសានេះឯង ។ បងមកនេះដើម្បីមកលា លោក និង នាង ទៅផ្ទះនៅថ្ងៃនេះដែរ ។

**មាណវី** នាងតបបណ្តើរមើលមុខឪពុកនាងបណ្តើរ មានទំនងជានឹង សួរនូវការណ៍មួយ ដែលនាងរៀបនឹងថ្លែង :

- កុំប្រញាប់ទៅផ្ទះពេកបានឬ ទេ ?។ បើយើងឈប់លំហែកម្លាំង បានមួយអាទិត្យសិន សឹមគិតរៀរៀនវិញប្រហែលជាល្អជាង ដ្បិតអីខួរក្បាល កាលណាបានសម្រាកខ្លះតែងទទួលចាំ ទទួលយល់រហ័សណាស់ ។ គិតឱ្យមែន ទែន លំហែមិនមែនជាការឥតប្រយោជន៍ទេ ។ បងមើលខ្សែឃើប៊ីរីតពេកដាច់ ប៉ិត !

អីចឹងមែនលោក **ទេព្យកោសល្ល** សង្កេតឃើញកូននិយាយនេះត្រូវណាស់ ។ បើក្មួយ ទៅលេងសៀមរាប មើលអង្គរជាមួយយើងបាន យើងហៅសែនត្រេកអរ ។

ព្រោះមានការបបួលរន្ទាន់ពីមិត្តទាំងពីរដូច្នេះ ព្រោះមានបំណងចង់ជួប គួសង្សារឱ្យបានយ៉ាងយូរ ហើយព្រោះចង់ឃើញប្រាសាទដែលខ្លួនបានស្គាល់តែ ដោយសៀវភៅ **ធីយាវុធ** ក៏ផ្ចាលផ្ចាញ់សេចក្ដីស្នើរស្មាក់ ដើម្បីទទួលធ្វើ ដំណើរទៅជាមួយយៅវមាល្យ ។

ហេតុនេះហើយ បានជានៅពេលស្រាង១ថ្ងៃមួយ ក្រោយដែលបាន សញ្ជឹងហើយ ស្ទើចចំពោះបុរាណដ្ឋានទាំងឡាយតាមវង់តូចវង់ធំ ពិនិត្យលំអទេសភាពនៅបារាយណ៍ ហើយអួតសរសើរបាគង និងលលៃស្រេចមក អ្នកដំណើរបានជិះរថយន្តហ្វ័រដ៏ចាស់ពីរគ្រឿង បញ្ចាំងកាំរស្មីរគោមធំស្វានទំលុះ ផែនខ្មៅប្រផេះនៃវេលាទៀបភ្លឺ ហើយបរតាមថ្នល់ចេញពីស្រុកសៀមរាបឆ្ពោះទៅខាងជើង ។ ពពួកយុវជនបានរើទាញឡើងវិញដោយបីតិនូវព្រៃអង្គរ ដែលសាយក្លិនក្រអូបប្រហើរ ហើយស្មានយល់តាមទីចន្លោះ១ នូវកន្លែងដែលមាននាមល្បីខ្ចាយប្រកបដោយប្រវត្តិសាស្ត្រ ។

រថយន្តគ្រហឹមងុល ទទាក់អ្នកជិះដូចចង្អេរអុំអង្គរ ហើយបរតាម បណ្ដោយផ្លូវមាត់ស្រះស្រង់កាត់ភូមិត្រជាក់ ដែលក្មេងទើបភ្ញាក់ពីដេក ស្ទុះមកស្រែកហ៊ោទទួលតាមរបងផ្ទះពីមួយទៅមួយត១គ្នា រួចទើបចូលក្នុងផ្លូវលំ កញ្ឆ្លូសដីផូរហុយទ្រលោម កាត់តាមមុខប្រាសាទបន្ទាយសំរែ ដោយតម្រង់ជា ឱរាល់យកទិសខាងជើងជានិច្ច ។

ឡានខាងមុខ ដែលមានតួនាទីជាអ្នកនាំផ្លូវមានលោក **សុខវិន្ទ** ជា អ្នកកាន់ចង្កូត ហើយមានគ្រួសារគាត់ជិះជាមួយផង គឺនាងប្រភាជាភរិយា នាង **ឆដាវណ្ណ** ជាបុត្រីចៅ **វង្សរិទ្ធិ** ជាបុត្រា ព្រមទាំងចៅ **ទេវី** ដែលជាអ្នកជិតខាង ។ យុវជនទាំងបីនាក់សុទ្ធតែជាអ្នករៀននៅវិទ្យាល័យដូចគ្នាហើយ **វង្សរិទ្ធិ** និង **ទេវី** ដែលជាសិស្សអន្ដេវាសិក ដូច **ធីយាវុធ** ដែរបានចងមិត្តភាពជាមួយអ្នកកំលោះនេះយ៉ាងជិតស្និទ្ធ ។ ដូច្នោះនាកាល បានដំណឹងពីពួក ម៉ាកថា គេនឹងជូនមិត្តជាតិសៀមមកមើលប្រាសាទអង្គរ ហើយយុវជនទាំងពីរក៏ប្រទាញប្រទង់ដណ្ដើម **ធីយាវុធ** ឱ្យមកនៅផ្ទះរៀងខ្លួន ។ តែក្រោយមក ដាច់ស្រេចថាគួរ **ធីយាវុធ** មកសំណាក់នៅគេហដ្ឋានឪពុក **វង្សរិទ្ធិ** ចុះព្រោះ យល់ថា នាយ **សុខវិន្ទ** ជាថៅកែយ៉ាងធំនៅសៀមរាប ខាងការដឹកនាំអ្នក ដំណើរដោយរថយន្ត ។ អាស្រ័យហេតុនេះ អាចមានមធ្យោបាយទទួលពួកម៉ាក ដើរលេងបានដោយស្រួលយ៉ាងនេះហើយ ទើប **ធីយាវុធ** បានមកស្នាក់ ដំណេកក្នុងបន្ទប់ **វង្សរិទ្ធិ** ។ ឯលោក **ទេពកោសល្ល** នាង **ចន្ទមណី** និងស្រីភីលៀងទាំងពីរ លោក **សុខវិន្ទ** បានអញ្ជើញឱ្យមកនៅផ្ទះជាមួយដែរ តែអ្នកដំណើរសៀមបានប្រកែកតាមសេចក្ដីគួរសម ដោយយកលេសថា ខ្លួនបានវាយទូរលេខមកជួលបន្ទប់បីទុកមុននៅ មហាសណ្ឋាគារស្រេចទៅហើយ ។

រៀងរាល់ព្រឹក១ឡើង **វង្សរិទ្ធិ** តែងបរឡានហ្វរដ៏មួយបញ្ជិះប្អូនស្រី **ធីយាវុធ** និង **ទេវី** មកជួបជុំមិត្តថ្មីនៅមហាសណ្ឋាគារ រួចហើយក៏នាំគ្នា ដើរលេងទៅមើលប្រាសាទ ទៅហែលទឹកបារាយណ៍ ឬត្រូវវាស្រ័យបាយនៅឯស្រះស្រង់ ឬ ស្រះព្រះពិធូរ ។ ក្នុងឱកាសនោះលោក **ទេព្យកោសល្ល** និង គ្រួសារតែងប្រើរថយន្តរបស់លោក ដែលមានអ្នកបើកនៅប្រចាំការជានិច្ច ។

មានថ្ងៃមួយ **ទេវី** បានយកគូលែនមួយថង់ធំ មកចែកគ្នាខាំបករញ្ញី ក្នុងពេលទស្សនាប្រាសាទបាគង ។ ផ្លែឈើនេះ ដោយអ្នកទិញបានជ្រើសរើសយកតែផ្អែម១ នាំអោយនាង **ចន្ទមណី** សាកសួរពីកន្លែងដែលគេបេះយកមក ។ ពីពាក្យមួយទៅសំដីមួយពីអំនួតមួយទៅពិពណ៌នាមួយជាប់រៀងគ្នា រហូត ដល់ពួកទេសចរប្តេជ្ញាថានឹងទៅលេងភ្នំគូលែនដែរ ។

ក្នុងដំណើរឱកាសនោះលោក **ទេព្យកោសល្ល** ត្រូវបានបោះបង់ឡានរ៉ឺ ណូរបស់គាត់ មកនាំគ្នាជិះជាមួយ **ធីយារុធ** ក្នុងរថយន្តហ្វរដ៍ដែលបរតាម ពីក្រោយ ហើយដែល លោក **សុខ វិន្ទ** បានចាត់ចែងផ្គត់ផ្គង់ឱ្យ ។ ដើម្បីឱ្យទៅដល់ភ្នំបានពីព្រឹក អ្នកដំណើរត្រូវក្រោកពីស្រាង១ ព្រោះផ្លូវដែលមានចម្ងាយជាងសែសិបគីឡូម៉ែតពីសៀមរាបទៅភ្នំនោះ ច្រើនសំបូរដោយដីខ្សាច់ និងដោយស្ពានទ្រុឌទ្រោម ដែលជាហេតុនាំឱ្យដំណើរពប់ប្រទះនូវការលំបាកក្រៃលែង ។ មានតែរថយន្តហ្វរដ៍កញ្ចាស់ កង់ខ្ពស់ តួផុតស្រឡះពីដីទេ ទើបរត់ លឿនគគាចឥតមានទើសទាស់អ្វីឡើយ ។

លុះចេញផុតពីភ្នំបូក និងភ្នំតូច១ ដែលនៅរត់រាយតាមផ្លូវត្រង់នេះមួយ ត្រង់នោះមួយទៅមាគ៌ាក៏កាត់ទឹកកណ្តោចកណ្តែងស្ងាត់ជ្រៀប ។ បាតុកម្មជីវ ភាពក៏បាត់សូន្យ សូម្បីតែបក្សីតូចតាចក៏គ្មានហើរ ឬទំលើដុប គុម្ពោតដែលដុះ រាយ១ផងដែរ ។

រថយន្តទាំងពីរតូវបរដាច់ឆ្ងាយពីគ្នាចំនួនមួយរយម៉ែត ដើម្បីចៀសវាងកុំឱ្យ អ្នកខាងក្រោយរំខានច្រើនពេក នឹងធូលីដែលហុយដង្គោលពីឡានខាងមុខ ។ ដោយគ្មានខ្យល់ផាត់ជះចេញសោះ ម្សៅធម្មជាតិបានដក់ជាប់យ៉ាងយូរតាម គន្លងច្រកផ្លូវប្រលោះដុះឈើ ។ ផ្លូវលំដោយបោះបង់ ប្រាសចាក ការថែរក្សាជាយូរអង្វែងមកហើយ ក៏រឹតតែអន់ណាស់ទៅទៀតដោយរទេះគោ អ្នកដឹកគូលែនឆ្លូតពន្លិចកង់ ហើយតាំងកកាយត្រឡប់ដីទុកគន្លងដូចជាគេភ្ជួរ ។ ម្ល៉ោះ ហើយកាលណាប្រទះជង្ហុកម្តង១ រថយន្តហ្វរដ៍ដែល ម៉ាស៊ីនខ្លាំង ដូចដីរតែងបង្វិលកង់ទទេ ដោយឥតមានជម្រុលទៅមុខសោះឡើយ ។ មានជួនណាឡាន កំពុងតែបោលស្រួល១ ស្រាប់តែធ្លាប់ក្នុងកន្លែងដីធូរក្លីបនាំអោយចង្កូតលែងស៊ី ហើយយានរត់វេឆ្វេឆ្វាទៅរកដង្គត់ឈើនៅសងខាងថ្នល់ ។ បើដល់ស្ពានម្តង១ អ្នកដំណើរត្រូវតែចុះអស់ ព្រោះមានសុទ្ធតែមែកឈើពុក ហើយរាំអង្គើមិនឱ្យ មានសេចក្តីទុកចិត្តត្រង់ណាសោះតែម្តង ថ្វីបើមានរំខានយ៉ាងនេះច្រើនជំពូក យុវជនយើងចេះតែសប្បាយនិយាយខ្លាំង១ ដើម្បីសង្គ្រប់ជំនះ សម្លេងថ្ងូរ ឬ រោទិ៍នៃគ្រឿងយន្ត ។

ឥឡូវផុតព្រៃគុម្ពោតឈើតូចទាបអស់ហើយ អ្នកដំណើរបានចូលដល់ តំបន់រុក្ខជាតិខ្ពស់ត្រឆឹងត្រឆៃ ដែលបង្ហាញឱ្យដឹងថាចូលមកជិតដល់ទីដី ត្រជាក់នៅជិតភ្នំ ។ យ៉ាងនេះមែនហើយ បានជាអ្នកដំណើរយើងប្រទះកង់អ្នក ស្រុករែក ឬផ្ទុករទេះនូវផ្លែគូលែនទុំក្រហម ក្រមៅបរចេញមក ។ មិនយូរ ប៉ុន្មានអ្នកដំណើរយើងបានចូលដល់ជំរុំនៅជើងភ្នំ ដែលជាទីណាត់ជួបជុំនៃរទេះ គោបួន ដប់ចាំផ្ទុកផ្លែឈើ ដែលមានតែក្នុងទីនេះនៅប្រទេសខ្មែរទាំងមូល ។ តាមថ្នាក់ជណ្តើរចង្កេះភ្នំ អ្នកស្រុកប្រុស១រែក ស្រី១ទូលនាំគ្នាជញ្ជូនចុះហូរហែរនូវមុខរបរតែមួយប្រភេទនេះ ។

បន្ទាប់ពីបានចតរថយន្តដាក់ក្រោមម្លប់ឈើស្រួលបួលហើយលោក **សុខ វិន្ទ** នឹង នាង **ប្រភា** បាននាំគ្នាដើររកជួលអ្នកស្រុកពីរនាក់ឱ្យរែកម្ហូបអាហារ យកទៅខាងលើភ្នំ។ ឯយុវជនយើងនាំគ្នាជជុះរលាស់លំអងធូលីសើចអឹងកង ។

ពួកអ្នកដំណើរយើងពង្រាយគ្នារកូតឡើងចង្កេះភ្នំ ដែលចាស់បុរាណ យើងបានយកថ្មបាយក្រៀម មកតំរៀបជាកាំជណ្តើរបណ្តាក់រហូតដល់ខ្ពង់រាបខាងលើ ។ ជណ្តើរនេះក្នុងចំនួនរវាង ៥០-៦០ កាំមានចាត់ឱ្យមានថ្នាក់ធំទូលាយមួយល្មមអង្គុយបានស្រួលសំរាប់ជនរវាតក្បាលជង្គង់ឈប់ឱ្យបាត់មួយសន្ទុះសិន ។ ថ្វីបើសម្រាកបន្តិចយ៉ាងនេះ អ្នកដែលមិនធ្លាប់ឡើង ឬមិនសូវបាន ប្រព្រឹត្តិកីឡានៅតែដកដង្ហើមស្ទើរពុំដល់គ្នាហើយវិលមុខ ស្លុង។ លុះនៅផែពីរ-បីថ្នាក់នឹងដល់ទីរាបស្មើផ្លូវកាន់តែចោតខ្លាំងឡើង ។ ពួកក្មេង១ដើរលឿនទៅមុខ ស្រវឹងដោយព្រឹកព្រៃ ដោយទេសភាពបៃតងខ្ចីត្រជាក់ដល់ថ្លើម ។ លោក **សុខវិន្ទ** នាង **ប្រភា** និង លោក **ទេព្យកោសល្ល** ដែលធ្លាប់បានឡើងចុះភ្នំនេះ ឬដែលធ្លាប់ហ្វឹកហ្វឺនក្នុងការទាហាន ក៏មិនសូវជាអស់កំលាំងពេកទេ ។ អ្នកទាំងបីនេះដើរនិយាយឆ្លើយឆ្លងគ្នា

បណ្តើរតាមដែលស្តាប់គ្នាបាន ព្រោះអ្នកដំណើរសៀមចេះភាសាខ្មែរស្ទួចស្ទើងនៅឡើយ ។ ឃើញយ៉ាប់ខ្លាំងតែភីលៀងសៀមពីរនាក់ដែលមុខឡើងស្លាំងបបូរមាត់ធ្លាក់ស្លេសហើយដើរទ្រេតទ្រោត ថ្វី បើអ្នករែកម្ហូបពីរនាក់ជួយយកអាសាទប់ជំហរគាត់ផង ។

ឯយុវជនវិញ ដើរលឿនរ៉េញទៅមុន គិតតែពីនាំគ្នាថា ពីនាំគ្នាសើច ។ នាង ចន្ទមណី ដែលឥឡូវចេះខ្មែរបួន- ដប់ម៉ាត់ ក៏និយាយទៅរកសហជីវិនទាំង អស់ ខុសខ្លះ ត្រូវខ្លះ បណ្តាលឱ្យសេចក្តីសប្បាយងុំនៅជាប់រហូត ។

នាកាលបានឈប់ ដប់ប្រាំនាទីដើម្បីឱ្យបាត់ហត់បន្តិចមក អ្នកពនេចរក៏នាំគ្នាចាប់ដើរតាមផ្លូវជើងបណ្តោយខ្នងភ្នំ ដែលជាទួលរាបស្មើ ។ ផ្លូវកាត់ក្រោមម្លប់ឈើធំៗ ដែលបានជុំរុះស្លឹកទុំមកជាកំរាលយ៉ាងក្រាស់ ។ មួយម៉ោងកន្លះក្រោយមក ក៏បានទៅដល់ស្ពានឈើអន្ទើបៗមួយ ដែលផ្លោះកន្លួងស្ទឹងក៏មានទឹកថ្លា ហូរត្របាញ់ ។ មួយសន្ទុះមកទៀត អ្នកដំណើរក៏បានដើរចូលទៅក្នុងវត្ត ដែលមានទីលានទូលាយស្រឡះ បោសស្អាតផេងមានមេកុដិ ប្រក់ក្បឿងមួយ ហើយកូនកុដិពីរបីប្រក់ស្បូវជ្រកក្រោមម្លប់ខ្នុរ ព្រះវិហារតូចមួយ ដែលសង់ពុំទាន់រួច ហើយមានសាលាប្រក់ស្បូវមួយវែងសំរាប់ជាទីសំណាក់នៃអ្នកដំណើរ ។ អារាមនេះ ជាទីបរមសុខក្រៃលែង ។ ចិត្តអ្នកទីក្រុងដែលអ័ព្ទអួដោយសេចក្តីលោភលន់ ចង់បានហើយដែលភ័យព្រួយ ដោយសម្លេងគ្រហឹមដាក់គ្នា ខាងទ្វីបអឺរ៉ុបកាន់តែខ្លាំងឡើងៗ លុះមកដល់ទីនេះកាលណាក៏រលាយបាត់សូន្យ ។

ក្នុងពេលដែលចាស់ៗឈៀងចូលទៅថ្វាយបង្គំ ហើយយកអីវ៉ាន់ខ្លះប្រ គេនចំពោះលោកគ្រូចៅអធិការ ហើយពួកម៉ាកឯទៀតកំពុងប្រញាយរើសផ្លែ គូលែនផ្អែម ដែលលោកគ្រូបានបង្គាប់អោយអ្នកភូមិម្នាក់ឡើងកាច់មែកទម្លាក់មកឱ្យនាង **ចន្ទមណី** និង **ធីយាទុធ** បាននាំគ្នាទៅទួលម្ខាងព្រះវិហារដោយមានបំណងចង់ថតរូបអោយជាប់ទេសភាពផង ព្រោះនៅទីនោះមានដុំថ្មធំៗ សឹករេចរិលឡើងមូលត្រងោលដូចផ្សិតយក្សដុះកណ្តាលព្រៃ ។ មានដុំថ្មមួយខ្ពស់ ហើយធំជាងគេឯទៀតស្ពួយបន្ទើតនូវសំណង់មួយវែងប្រក់ស័ង្កសី ។ សេចក្តីចង់ដឹង បាននាំយុវជនទាំងពីរនាក់ត្រូវឡើងជណ្តើរឈើញ័រអន្ទើបៗចូលទៅក្នុងរោងនោះ ដែលជាជម្រកសម្រាប់ព្រះពុទ្ធរូបមួយព្រះអង្គឆ្លាក់ភ្ជាប់នឹងដុំ ថ្ម តួព្រះអង្គផ្ទុំសណ្តូកមានបណ្តោយរវាងដប់ប្រាំម៉ែត ។ ថ្វីបើមានគ្រឿង សក្ការៈបូជាស្ទេះស្ទូវ ហើយមានខ្លះជារបស់ចិនយួនដែលជាវត្ថុនាំឱ្យទាក់ចិត្ត ក្រៃលែង តែនារី និងចៅមាណពគួចញ្ចាប់ញ័រក្នុងហឫទ័យ ហើយកោតសរសើរ ចំពោះសទ្ធា និងសេចក្តីប៉ិនប្រសប់នៃបុព្វបុរស ។

ដោយនាងបានបបួល **ធីយាទុធ** ក៏ចុះមកបេះផ្កាចំប៉ី ដែលមានដើមដុះជិតទីនោះ ។ លុះបានដោះស្បែកជើងទុកនៅខាងក្រៅសាលាស្រេចហើយ យុវជនទាំងពីរក៏ចូលយកផ្កាទៅបូជាក្នុងថូមួយនៅប្រេបព្រះបល្ល័ង្ក ទើបនាំគ្នាលុតជង្គង់សូត្រមនស្ការថ្វាយយុវតី តាមសំនៀងថៃ ហើយនាយកំលោះតាមសម្លេងខ្មែរ ។ យុវជនទាំងពីរសូត្រថ្វាយបង្គំដោយជឿស្មោះ ហើយដោយមាន ទឹកមុខយ៉ាងជ្រះថ្លាផង ។ លុះចប់ធមិថ្វាយបង្គំហើយនាង **ចន្ទមណី** បែរ មុខញញឹមមករក **ធីយាទុធ** ហើយបន្ថែមសេចក្តីជាសម្រាយថា :

- សូមគុណព្រះបារមី ជួយជ្រោមជ្រែងយើងខ្ញុំព្រះករុណាទាំងពីរនាក់ ដែលមានចំណងស្នេហារឹតរួតយ៉ាងមាំមួន ។ សូមឱ្យបានផុតពីសេចក្តីលំបាក ហើយពានពារឧបសគ្គនានាទាំងពួង ។ សូមឈ្នះគ្រោះកាចនឹងសេចក្តីវង្វេងទាំងអស់ ដែលសព្វថ្ងៃកំពុងក្លាយទៅជាមោហ៏មាកបាំងមុខជនទាំងពិភពលោក បណ្តាលឱ្យកើតប្រទូសរ៉ាយឆ្ងាយចាកពីព្រះពុទ្ធោវាទ ។

**ធីយាទុធ** ដែលស្តាប់សំដីដ៏សែនពិរោះនេះ ដោយពេញចិត្តក្រៃលែង ក៏លើកហត្ថប្រណម្យហើយបន្តសេចក្តីថា :

- នាង **ចន្ទមណី** ជាគូព្រេងរបស់ខ្ញុំព្រះករុណាពិតប្រាកដ ។ ថ្វីបើ យើងបែកទៅកើតក្នុងអាណាខេត្តទីទៃខុសគ្នាបុណ្យទានដែលយើងបានកសាងរួមគ្នាពីជាតិមុន បាននាំអោយមកជួបវិញ ហើយគួចកើតនូវសេចក្តីប្រតិព័ទ្ធ ភ្លាមៗក្នុងគ្រាដែលយើងខ្ញុំព្រះករុណា

បានជួបគ្នាតាំងពីគ្រាដំបូង ហេតុនេះសូម ព្រះអង្គជួយទ្រទ្រង់ តម្រង់នូវចិត្តយើងខ្ញុំព្រះករុណាទាំងពីរនាក់កុំឱ្យមានថ្នាក់ថ្នល់ត្រង់ណាឡើយ ដើម្បីស្គាល់តែសុភមង្គលជារៀងរហូត ។

បន្ទាប់មក ចាស់ទុំ និងពួកម៉ាកទាំងឡាយ ក៏បានដើរចូលមកដល់កន្លែងនោះដែរ គូសង្សារទាំងពីក៏នាំគ្នាចុះមកជួបជុំ។ ក្រោមសេចក្ដីណែនាំនៃលោក **សុខទិន្ន** អ្នកដំណើរទាំងអស់បានទៅថ្វាយបង្គំស្នាមព្រះបាទដែលឆ្លាក់ក្នុងផ្ទៃ ថ្មហួសទៅមើលអាស្រមព្រះសង្ឃចង្រ្កមភាវនា អណ្ដូងប្រេង ទៅថ្វាយបង្គំព្រះពុទ្ធរូបនៅឆ័ត្រឥសី ទើបត្រលប់មកកាន់វត្តវិញ។

តាមផ្លូវជើងតូចលូនតាមចន្លោះដើមគូលែនដែលកំពុងពង្រុះផ្លែទុំជោរ លោក **សុខ ទិន្ន** បាននាំគ្នាចុះទៅរកកន្លែងទឹកធ្លាក់ ។ ដីទេរចុះសន្សឹម សូរ ទឹកហូរឮកាន់តែខ្លាំង ហើយក្លាយទៅជាគ្រហឹមរញ្ជួយទាំងពសុធា ។

កាលបើបានចេញពីផ្លូវបត់ចុងក្រោយបង្អស់ ទស្សនីយ៍ភាពក៏ត្រដាង ពេញទំហឹងនៅចំពោះភ្នែក បរិបូរណ៍ដោយកម្លាំង ដោយសម្រែកសន្ធាប់គួរឱ្យស្ញប់ស្ញែង ។ ហាក់បីដូចហ្វូងម្រឹកច្រឡោតដាលដោយខឹងពេញបន្ទុក ខ្សែទឹកវិលគួចត្របាញ់ លោតផ្លោះ ដុំថ្មស្ទុះដាំក្បាលចុះក្រោមរោទិ៍សន្ធាប់ ហើយទម្លាក់ខ្លួនយ៉ាងលឿនពីលើថ្នាក់កំពស់ប្រមាណពីរម៉ែត រត់ខ្ទាញ់ថ្លាឈ្វេងបែកពពុះ ស្គុលលើផ្ទាំងសិលារាបស្មើដូចផ្ទៃថ្នល់ ។ បានចំនួនម្ភៃម៉ែត ក៏កញ្ជ្រោលរោល រែកប្រមៀលបោះពួយធ្លាក់ទៅក្នុងជ្រោះមួយតូចចង្អៀត ជំរៅចោតត្រង់សន្លឹមសម្លឹងទៅក្រោមស្ទើបវិលមុខ ។

ទីក្រាលថ្មរាបស្មើនេះ ជាកន្លែងងូតយ៉ាងប្រណិត ។ ដោយគាប់ចិត្តពេក យុវជនទាំងក្រមុំទាំងកំលោះស្រែកគំនាប់ទី ហើយផ្លាស់ខោខ្លីអាវខ្លីសំរាប់ងូតទឹក រត់ចូលខ្សែវខ្វារ សប្បាយភ្លេចឃ្លាន ភ្លេចនឿយហត់អស់រលីង ។ អ្នកខ្លះឱនខ្នងរងដុំទឹកដែលធ្លាក់ពីលើ ហើយប្រកាសអួតថា វ៉ារីចេះគក់ចេះច្របាច់ស្រួលណាស់រើយ ! ខ្លះទៀតបណ្ដែតខ្លួនឱ្យរសាត់សស្រឹមក្នុងផែនត្រជាក់រំអិលតាមផ្ទាំងកំរាលថ្ម ។

ពួកចាស់ៗងូតអង្គុយស្ងប់ស្ងៀម គយគន់ល្បែងកំសាន្តនៃក្មេងៗដោយ ពេញចិត្ត ហើយដោយនឹកស្ដាយខ្លះផងក៏មិនដឹង ។

ក្នុងឱកាសវ៉ាកងនេះ **ធីយ៉ាវុធ** ខំព្យាយាមរើពិនិត្យ រើទន្ទេញឡើងវិញនូវមេរៀនទាំងឡាយ បំរុងនឹងចូលប្រលងក្នុងខែមិថុនាខាងមុខឱ្យបានជោគជ័យ ។ មួយអាទិត្យម្ដង អ្នកកម្លោះតែងសរសេរសំបុត្រដាក់ប្រៃសណីយ៍ផ្ញើរ ទៅឆោមស្និទ្ធដែលតបវិញថា នាងបានទៅលេងកែប និងបូកគោ ។ យើងពុំចាំ បាច់បញ្ជាក់ទេ សំបុត្រឆ្លើយឆ្លងទាំងនោះ ដែលច្រើនប្រើភាសាអង់គ្លេសជាកិច្ច ប្រសើរមួយដែរក្នុងការបម្រុងខ្លួនប្រឡង តែពោពេញទៅដោយសេចក្ដីប្រតិ ព័ទ្ធ ហើយផ្ដាំផ្ញើរកគ្នាជានិច្ច ។

លុះដល់ពេលត្រឡប់ចូលរៀនវិញ អ្នកកម្លោះក៏មិនសូវបានទៅមកផ្ទះ យុវមាល្យដែរ គិតតែសំលៀងប្រាជ្ញាសម្រួចចំណេះ ប្រុងនឹងយកឱ្យបាននូវមធ្យមសិក្សាប័ត្រទីមួយ ដែលជាដំណាក់កាលដំបូងក្នុងដំណើរឆ្ពោះទៅរកអនាគត ដែលនឹងរះឡើងដូចអរុណយ៉ាងភ្លឺថា ។

ខែឧសភាកន្លងផុតទៅ ដោយបានបើកឱកាសឱ្យគូជីវិតបានជួបភក្ត្រគ្នាតែពីរដង ហើយក្នុងពេលមួយយ៉ាងខ្លីទៀត ។ មិថុនា ហូរចូលមក នាំអោយការរៀបចំផ្ដាច់ព្រ័ត្រកាន់តែគ្រញ៊ិកឡើង ដើម្បីកុំឱ្យរាយមាយគំនិត **ធីយ៉ាវុធ** បានប្ដេជ្ញាថា ខ្លួននឹងមិនទៅលេងផ្ទះនាងទៀត តែលុះកាលណាបានប្រលងជាប់ រួចជ្រះស្រឡះ ។

ដូច្នេះហើយ បានជានៅល្ងាចថ្ងៃមួយ **ធីយ៉ាវុធ** ស្ទើរអង្គុយមិនជាប់ ក្នុងស៊ីក្លូរ ព្រោះនឹករំខាននឹងល្បឿនយឺតខ្ទៃៗនៃយាននេះ។ ចិត្តអរភិបៗ ព្រោះ ប្រឡងជាប់ថ្មីៗ ថ្មីបើវិញ្ញាសាយ៉ាងលំបាក ចៅមាណពរីកដើមទ្រូង រីកចិត្តប្រុង នឹងយកដំណឹងដ៏ប្រសើរនេះ ទាំងក្ដៅៗទៅប្រាប់ឆោមស្នេហា ។ ដល់ហើយ ស្ទុះលោតចុះភ្លែត រកតែស៊ីក្លូឈប់ស្រួលមិនទាន់ ហុចឱ្យថ្លៃឈ្នួលយ៉ាងដំណំទៅឱ្យអ្នកធាក់ ដើម្បីឱ្យគេជួយត្រេកអរខ្លួនផង ។ អ្នកកម្លោះ ទើបបានជោគជ័យ បោលចូលក្នុងបាហុនដ្ឋានដោយឥតផ្សូរផ្សង ស្រាប់តែទុចង៉ក់ស្រឡាំងកាំង ។

ក្នុងគេហដ្ឋានលោក **ទេពក្រោសល្ល** ហើយនិងកូនអង្គុយមើលមុខ គ្នាមានទឹកភ្នែកហូររហែង ។ ដោយឮសូរជើងដើរចូលមក អតីតទាហានថៃក៏ងាកមុខមករកញញឹមស្ងួតៈ

- ចូលមកក្មួយ ។ នៅពេលដែលបានទទួលខ្សែរលួសភ្លាម កូនគេគិតទៅប្រាប់ក្មួយដែរ តែខ្ញុំឃាត់ទាន់ ព្រោះយល់ថាក្មួយកំពុងជាប់ប្រលងក្រែង ដឹងទៅនាំឡប់ស្មារតី ។ ពេលនេះប្រហែលជាក្មួយមកប្រាប់យើងទាំងពីរថា បានប្រឡងជាប់ដូចយើង បានសង្ឃឹមជាមុនស្រេចយ៉ាងនោះហើយ ។

**នីយាវុធ** ដោយឃើញហេតុភេទទុក្ខព្រួយរបស់មិត្តទាំងពីរ ក៏ជំរាបដោយស្ងប់ស្ងួតនូវការណ៍ដែលខ្លួនបានបំរុងមកថ្លែងប្រាប់ដោយរីករាយ ។ លុះបានទទួលសេចក្ដីសរសើរនិងអបអរសាទរយ៉ាងរាក់ទាក់ តែថ្លែងដោយសំឡេងក្រៀមក្រំរួចហើយអ្នកកំលោះ ក៏សូមអភ័យទោស ហើយដណ្ដឹងសួរអំពីរ ដំណើរហេតុដែលនាំឱ្យមានរំជួលដូច្នេះ ។

ក្នុងបរិយាកាសស្ងាត់ជ្រងំនៃផ្ទះដ៏ធំល្វឹងល្វើយ សម្លេងស្អក១ នៃលោក **ថេបក្រោសល្ល** និយាយរៀបរាប់ប្រាប់មិត្តក្មេង ។ នាង **ចន្ទមណី** អង្គុយស្ងៀមទ្រមឹងភ្នែកសម្លឹង **នីយាវុធ** ពុំដាក់ហាក់ដូចជាចង់ស្រូបភ្ជាប់ នៅជាប់ដួងចិត្តកុំឱ្យរសាត់រសាយទៅបាននូវគោលដៅស្នេហាដែលនឹងឃ្លាតទៅឆ្ងាយ ក្នុងពេលឆាប់ៗនេះ លោក **ទេពក្រោសល្ល** និយាយថា :

- ក្មួយគង់ដឹងស្រាប់ហើយ កាលពីដើមខ្ញុំធ្វើស័ក្តិបីក្នុងកងទ័ពថៃ ។ ដោយមានការច្របូកច្របល់នាកាលរដ្ឋប្រហារមួយ ខ្ញុំក៏មានជាប់ឈ្មោះក្នុងបញ្ជីនៃពពួកជនដែលរដ្ឋាភិបាលប្រកាសថាជាអ្នកក្បត់ជាតិ ។ ដើម្បីជៀសវាងការផ្ដាញ់ផ្ដាលយ៉ាងឃោរឃៅក្នុងសម័យនោះ ខ្ញុំក៏បានភៀសខ្លួនរត់ចូល មកនៅក្នុងប្រទេសខ្មែរ ។ រឿងហេតុនេះមានមកយូរឆ្នាំហើយ ។ មិត្តភ័ក្តខ្ញុំ នៅក្រុងថេប ( បាងកក ) បានព្យាយាមតវ៉ា ហើយតុលាការទាហានបានចេញ សាលក្រមកាលពីប៉ុន្មានខែមុននេះថា ខ្ញុំស្លូតត្រង់បរិសុទ្ធឥតមានមន្ទិលអ្វីទេ ។ បានជាខ្ញុំមិនដាច់ចិត្តវិលត្រឡប់ទៅកាន់ប្រទេសដើមកំណើតវិញភ្លាម ក្នុងពេលនោះ ព្រោះកូនដែលទើបមកដល់មានសេចក្ដីស្រឡាញ់ ហើយចង់ស្គាល់ប្រទេស ខ្មែរជាមិត្តនេះខ្លាំងពេក ថែមទាំងចង់ទៅបន្តវិជ្ជានៅវិទ្យាល័យនារីឯដាឡាត់ ទៀតផង។ ខ្ញុំក៏បានដាច់ស្រេចថានឹងលែងធ្វើការរាជការតទៅទៀតដែរ ហើយរង់ចាំឱកាសល្អនឹងទៅនាំគ្រួសារទាំងអស់យកមកនៅជុំគ្នានាក្រុងភ្នំពេញនេះ ។

ងាកបែរទៅមើលយុវជនទាំងពីរ លោក **ទេពក្រោសល** ដែលមាន ទឹកមុខពោរពេញទៅដោយសេចក្ដីស្រណោះអាណិតក៏បន្ថែមសេចក្ដីថា :

- កាលពីម៉ោងបីរសៀលនេះ មានខ្សែលួសមកប្រាប់ថាម្ដាយ **ចន្ទមណី** គេឈឺធ្ងន់ ។ យើងនឹងចេញដំណើរទៅព្រឹកស្អែកនេះហើយ ។

## ៥

**ពពកខ្មៅបាំងមេឃា**

មហាវិស្សមកាល ! វ៉ាកងធំ ! ឈប់ពីរខែ ! ក្រោយពីបានប្រឡងជាប់ ដោយបានលេខជាប់ឋានៈយ៉ាងឆើតមក គួរណាស់ឱកាសសប្បាយបរិបូរណ៍ ដោយពន្លឺព្រះអាទិត្យ និងសេចក្ដីត្រេកត្រអាលយ៉ាងស្មោះស្ម័គ្រចំពោះជីវភាព ! តែមិនដូច្នេះឡើយ **នីយាវុធ** ឋិតក្នុងទិវារាត្រីអព្ចុអ្វ ព្រោះមានសេចក្ដីនឹក រលឹក និងភ័យព្រួយ ។

កាលពីដើម ខ្លួនបានគ្រោងទុក នឹងធ្វើដំណើរជាមួយគ្នាទៅទីនេះ ទីនោះ ដើម្បីឱ្យពាលពៅបានស្គាល់ស្រុកខ្មែរយ៉ាងជាក់លាក់ ។ ឥឡូវនៅឯកា ម្នាក់ឯង បន្ទោងចិត្តដោយរូបអនុស្សាវរីយ៍ ដែលបានថតជាមួយគ្នាក្នុងការធ្វើដំណើរទៅមើលបុរាណដ្ឋានឯខេត្តសៀមរាប ។ យូរៗលេចសំបុត្រមួយ ពីប្រទេសថៃ ហើយថ្ងៃនោះឯង អ្នកកម្លោះបានស្គាល់សុភមង្គលថ្លាស្អាតឥតមន្ទិល ។ បេះដូងយោងគ្រឹកគ្រេង ភ្នែកគយគន់ដោយស្នេហានៅតួអក្ខរា គ្រប់អង្គ ទំរាំន័យអត្ថបទជ្រួតជ្រាបក្នុងសតិប្រាជ្ញាបាន។ នាងជូនដំណឹងពី សុខភាពម្ដាយនាង ដែលបានធូរគ្រាន់បើ តែមិនទាន់ផុតភ័យនៅឡើយទេ ។ នាងរៀបរាប់ពីសេចក្ដីនឹករលឹក ហើយពិពណ៌នាអំពីសេចក្ដីស្នេហាដែលធ្វើឱ្យក្រៀមក្រំហឫទ័យ ព្រោះឃ្លាត បែកឆ្ងាយគ្នា ។

ឱសំបុត្រដែលវិចិត្រដោយអក្សររាងមូលក្រឡង់ ជាភាសាសៀម លាយអង់គ្លេស ហើយដែលបានស្រូបជាប់នូវពិដោរក្រអូបរបស់នារីយកមកផង តែងពោរពេញដោយពាក្យពេចន៍ និងមនោសញ្ចេតនា ផ្អែមល្ហែមទន់ត្រជាក់ដូច សំដីដែលនាងធ្លាប់ចរចា ។

កក្កដាបានលេចបាត់ទៅក្នុងមហាសមុទ្រ នៃសុគាសីហាដែលចូលមក ផ្លាស់ដោយនាំទាំងសេចក្ដីថប់ព្រួយកាន់តែច្បាស់ឡើង ។ ស្ថានការណ៍ពិភពលោក កាន់តែតានតឹង ស្រមោលសង្គ្រាមកាន់តែចូលខិតជិតមក ។ រវាងមួយអាទិត្យម្ដង **ទីឃាវុធ** បានមកលេងផ្សារស្វាយប៉ោ ទិញកាសែតអាន ហើយស្ដាប់ដំណឹងផ្សាយតាមវិទ្យុនៅផ្ទះមិត្តភ័ក្ដិ ។ សម្លេងអួតអាងអំពីកំលាំងរេហ៍ពលរៀងខ្លួន និងសូរត្រៀមអាវុធកាន់តែរន្ថាន់ឡើង ហើយនៅព្រំដែនអាល្លឺម៉ង់-ប៉ូឡូញឧប្បត្តិហេតុបង្ករឈាមកាន់តែញឹកញាប់ថែមទៀត ។ អាល្លឺម៉ង់ ស្រែកឡូឡាថា ប៉ូឡូញមើលងាយខ្លួន បារាំង និងអង់គ្លេសប្រកាសថាលែងស្ងៀមដូច កាអ៊ីត្លែរសេបអូទ្រីស ឬលែងញ៉ែមថយ ក្រោយបែបកាលនៅកុំមុយនីសទៀតហើយ ។ ខាងនេះក៏មិនថយ ខាងនោះ ក៏មិនថយទាល់តែផ្ទុះឆេះសន្ធោរសន្ធៅឡើង ។

**ទីឃាវុធ** ចំណែកក្នុងចិត្តខ្លាំងពេកក៏កើតឡើយណាយ លែងរាប់រកទេសភាពភូមិកំណើត ថ្វីបើនៅពេលធម្មតាខ្លួនតែងគួចប្រតិព័ទ្ធលើសលប់ ។ មានថ្ងៃមួយនៅចុងខែ សីហា អ្នកកំលោះបានសុំឪពុកម្ដាយមកស្នាក់នៅផ្ទះពូក ម៉ាកតាំងនៅត្រើយខាងកើតនៃស្ទឹងសង្កែ ។ គេហដ្ឋាននោះឯងមានគ្រឿងវិទ្យុមួយប្រដាប់ដោយខ្សែអាកាសចងយ៉ាងខ្ពស់ ភ្ជាប់ទៅថ្នោលឫស្សីដែលដោតនៅលើដំបូល ។ ល្ងាចៗឡើង អ្នកជិតខាងមកជួបជុំខ្ទោមី ស្ដាប់ដំណឹងពី ព្រៃនគរ ឬបាងកក ត្បិតពេលនោះភ្នំពេញយើងពុំទាន់មានគ្រឿងផ្សាយសម្លេងទំនើបបែបនេះនៅឡើយទេ ។ អ្នកណាដែលចេះភាសាបរទេស ។ មាននាទី បកប្រែដំណឹងប្រាប់គ្នា ។ យប់ៗឡើងជនបួន-ប្រាំនាក់ ដែលឃ្លានដំណឹងជាងគេទៀត តែងដេករវៀនចាំយាមជុំវិញតុវ៉ាឌីយោប្រុងនឹងក្រោកស្ដាប់តៗគ្នានូវ សម្លេងផ្សាយចេញពីប្រទេស រុស្ស៊ី ស៊ុយអ៊ែត អាល្លឺម៉ង់ បារាំង អ៊ីតាលី អង់ គ្លេស ទូគី សហរដ្ឋអាមេរិច អូស្ត្រាលី ។ កាលណាបានដំណឹងអ្វីប្លែក ក៏បន្តប្រាប់អ្នកជិតខាងភ្លាម ។

**ទីឃាវុធ** ដើមដំបូងហាក់ដូចជារវើរវាយមិនសូវស្រើបចង់ដឹងព្រឹត្តិការណ៍ទាំងនេះប៉ុន្មានទេ ព្រោះដួងចិត្តដោតត្រង់ទៅរកតែទិសមួយ ។ ប៉ុន្តែយូរៗទៅដោយអ្នកជិតខាងគេពឹង ព្រោះឃើញថាចេះភាសាបារាំង និងភាសា អង់គ្លេសក៏ព្រមស្ដាប់ ហើយបកប្រែទាល់តែយូរៗទៅកើតជក់ចិត្តនឹងល្បែងបែបថ្មីនេះដែរ ។

នៅពេលម៉ោងពីរយប់ នៅពេលនាទីរុស្ស៊ីកំពុងផ្សាយដោយសំដីទន់ ផ្អែមជាភាសាបារាំង អ្នកម្ចាស់ផ្ទះតែងលើកបបរសាប និងត្រីងៀតយកមកល្បៀង ។ **ទីឃាវុធ** ស្ដាប់បណ្ដើរបកប្រែសង្ខេបៗ បណ្ដើរ ប្រាប់អ្នកផងដែល ពុំចេះភាសាបារាំង ។ លុះចប់ការផ្សាយកាលណា ទើបនិយាយពិស្ដារទាំងស្រុងតែម្ដង ។ បន្ទាប់មកទើបនាំគ្នាធ្វើអត្ថាធិប្បាយប្ដូរយោបល់ទាល់តែស្មើយកម្លាំងក៏លក់នៅកៀនវ៉ាឌីយោនោះទៅ ។ លុះព្រឹកឡើងក៏នាំគ្នា ក្រោកស្ដាប់ ទាំងសើងមើងទាំងអុលនូវពត៌មានពីព្រៃនគរទៀត ។ ថ្វីបើដំណឹងទាំងនោះច្រើនតែស្រង់ហើយមិនប្លែកពីគ្នាប៉ុន្មាន អ្នកស្ដាប់ពុំមានជិនឆ្អន់សោះឡើយ ព្រោះយល់ឃើញថា ជោគជតាសកលលោកព្យួរជាប់ទៅលើសង្គ្រាមដែលកំពុង កំញើញបីដូចពពកខ្មៅ រសាត់មកបាំងមេឃា ។

នៅវិទ្យុបាងកក មានអ្នកនិយាយស្រីម្នាក់មានសម្លេង ហើយសម្រួល សម្តីស្រដៀងគ្នានឹង **ចន្ទមណី**។ វោហារនារីនោះ តែងនាំអ្នកកម្លោះឱ្យរំជួល ក្នុងចិត្តពន់ប្រមាណ ។

ដាច់ខែសីហាប្រិប កងទ័ពអាឡឺម៉ង់ក៏ជោរជន់លិចប្រទេសប៉ូឡូញភ្លាម ។ នៅថ្ងៃទី ២ កញ្ញា អង់គ្លេស និងបារាំងប្រកាសសង្គ្រាមតទល់នឹងអាឡឺម៉ង់ ។ ប្រវត្តិនៃសង្គ្រាមលោកលើកទីពីរ ក៏ចាប់ផ្តើមនៅពេលនោះ ដែលត្រូវលេប ថេរវេលាជិត ៦ ឆ្នាំទើបងវិ ។

ថ្ងៃទី ១០ កញ្ញាបានឃើញ **ឥឡាវុធ** ឡើងរថភ្លើងទៅភ្នំពេញដែលមានស្ថានភាពប្លែកឆ្ងាយពីសព្វដង ។ ពេលថ្ងៃទាហានដើរទៅមកតាមវិថីកាន់ តែមានកើនចំនួនឡើងជាលំដាប់ បារាំងស៊ីវិលដែល **ឥឡាវុធ** ធ្លាប់ស្គាល់រៀងមក ឥឡូវជាប់កំណែណ្ឌពាក់ឯកសណ្ឋានកាគី មានស័ក្តិមានយសលាន់ ។ យប់ៗឡើងវិធានការ "ងងឹតខាងក្រៅ" ពន្លត់ភ្លើងតាមថ្នល់ទុកត្រង់នេះមួយ ត្រង់នោះមួយ ដោយមានក្បាំងបំបែរពន្លឺឱ្យសំយុងធ្លាក់ជាកញ្ចុំត្រង់មកក្រោម ។ ឯអ្នកផ្ទះសោតក៏ទទួលបង្គាប់ឱ្យបិទបាំងសន្លឹកទ្វារបង្អួច កុំឱ្យមានរស្មីផ្ទាំងចេញក្រៅបានដែរ ។ ម្លោះហើយក្នុងពេលរាត្រីផែនខ្មៅមកគ្របដណ្តប់រាជធានី នាំឱ្យកើតអផ្សុកជាអនេក ។

ដោយព្ទដំណឹងថា នឹងមិនមានបើកថ្នាក់ទស្សនវិទូទៀតទេ ព្រោះខ្វះសាស្ត្រាចារ្យ **ឥឡាវុធ** ក៏ចូលទៅសួរដល់ការិយាល័យនៃលីសេ ហើយបានទទួលសេចក្តីបញ្ជាក់ថា រឿងនេះមិនទាន់មានអ្វីប្រាកដនៅឡើយទេ ប្រហែលជាបើកដែរតែនៅពេលក្រោយថ្នាក់ឯទៀតបន្តិច ។ នៅចុងខែកញ្ញាថ្នាក់ទស្សន វិជ្ជាក៏បើកបង្រៀនមែន ។ **ឥឡាវុធ** ដោយរួបរួមជាមួយមិត្តភ័ក្តិខ្មែរ ៧នាក់ ហើយ បារាំង ២នាក់ ក៏តាំងចាប់រៀនត្រដាបត្រដួស ព្រោះគ្រូវរល់ហាត់ហ្វឹកហ្វឺន ខាងក្បួនទាហានមិនសូវមានពេលមកពន្យល់បង្រៀនទេ ។ ម្លោះហើយសិស្ស ទាំងនោះ បើមិននាំគ្នាអានកាសែតទេក៏តាំងប្រលែងគ្នាក្តុងក្តាំងក្នុងថ្នាក់រៀន ។

ចាប់តាំងពីការតស៊ូនៃប្រទេសប៉ូឡូញរសាយសូន្យទៅ "សង្គ្រោម លេងៗ " ក៏តាំងងើបឡើងនៅព្រំដែនបារាំង អាឡឺម៉ង់ ។ ក្នុងពេលតែមួយ ជប៉ុនរវល់ជាប់ដៃជាមួយប្រទេសចិនយូរឆ្នាំមកហើយ តាំងកំរើកដើរនយោបាយប្រទូសរ៉ាយនឹងពួកស្បែកសកាន់តែខ្លាំងឡើងៗ ។ ប្រទេសថៃដែលស្រង់ក្លិនដឹងថា ខ្យល់នឹងបក់ពីទិសទីណាខ្លាំងជាងគេ ក៏ឈានជើងដើរតាមក្រោយបងជប៉ុនដរាប ។ ចំណែករាជការបារាំងនៅឥណ្ឌូចិន គេយល់ថាស្ថានការណ៍ " ធុំ " ក្លិនមិនសូវស្រួលសោះក៏ប្រែប្រមូលតំឡើងកិត្យានុភាពតាមការអាចបាន ។ ហេតុនេះហើយ បានជាសាស្ត្រាចារ្យជាតិបារាំងទាំងឡាយត្រូវស្លៀកពាក់ខោ អាវទាហានទាំងអស់ ។

ក្រោយបានដើរតតាក់តតុបបានជាពីរខែមក ថ្នាក់ទស្សនវិជ្ជានៅវិទ្យាល័យស៊ីសុវត្ថិ ដោយមានចំនួនសិស្សស្តួចស្តើងពេក ក៏ត្រូវបិទទ្វារជាស្ថាពរដើម្បី សំចៃបុគ្គលិកដែលត្រូវការខាងសឹកសង្គ្រាមជាង ។ សិស្សខ្មែរទាំងឡាយត្រូវ គេបញ្ជូនឱ្យទៅរៀននៅវិទ្យាល័យប៉េទ្រុសគីនាក្រុងព្រៃនគរ ។ ប៉ុន្តែដោយពេលនេះ សិស្សដេកក្នុងរបស់គេពេញចំណុះអស់ទៅហើយ រាជការលីសេនេះ បង្គាប់យុវជនយើងឱ្យដើររកជួលផ្ទះសំណាក់នៅក្រៅខ្លួនឯង ។ លុះជួលផ្ទះបានហើយ រៀបទីអាស្រ័យបានស្រួលបួលរួចកាលណាសិស្សកំសត់ យើងក៏នាំគ្នាទៅជួយចាងហ្វាងវិទ្យាល័យដែលជាជាតិបារាំងមួយធាត់ក្រអាញ ពោះកំប៉ោងប៉ុនពាងទឹក ហើយមានភ្នែកសល្អក់ដូចគ្រាប់ស្វាត ។ បារាំងនេះក៏សំដែងកំហឹង យ៉ាងសាហាវក្នុងពេលនោះ ព្រោះរាជការខាងស្រុកខ្មែរជជីកសុំឱ្យសិស្សរបស់ខ្លួនអាស្រ័យនៅក្នុងសាលា ។ គេស្រែកសន្ធាន់ឡូឡាដាក់យុវជនដែលឥតមានទោសពៃរ៍អីសោះ ថែមទាំងពោលពាក្យចាក់ដោតមកលើយ៉ាងធ្ងន់ៗទៀតផង ។ ទប់នឹងអំពើអយុត្តិធម៌ទាំងនេះពុំបាន **ឥឡាវុធ** ក៏តបឆ្លើយពីរបីមាត់ ហើយដើរចេញមកឡើងឡានឈ្នួលជាមួយ **ទេគី** ត្រឡប់មកភ្នំពេញវិញ

ក្នុងពេលនោះទឹកចិត្ត **ឥឡាវុធ** បរិបូណ៌ដោយសេចក្តីអស់សង្ឃឹម ព្រោះមិនដឹងពេលណាបានជួបនារីត្រួយជីវិតឡើយ ហើយព្រោះយល់ថា លែងបានឱកាសទៅរៀនប្រទេសបារាំង តាមបំណងជាយូរណាស់មកហើយដែរ ។ សង្គ្រាមក្នុងសមុទ្របណ្តាលឱ្យគមនាគមន៍រវាងឥណ្ឌូលចិន និងទ្វីបអឺរ៉ុបធ្វើបានដោយលំបាក ។ ឯ **មាលាដួងចិត្ត** ក៏ព្រាត់ប្រាស់ទៅឆ្ងាយ មិនដឹងជាបានជួបគ្នាទៀត

ឬដូចម្ដេចទេ ។ ទាំងអាឡេះអាល័យ អ្នកកម្លោះក៏បង្ខំចិត្តលាចាកកិច្ចសិក្សាដែលព្យុះអភ័ព្វមកបំបាក់ផ្ដាច់យ៉ាងនេះ ។ ដោយខំទប់នឹងភាពខ្សឹបខ្សួលនេះ **ឌីយ៉ាទុង** ក៏ឡើងពាក្យសុំធ្វើការខាងមន្ត្រីរដ្ឋបាល ។

ទុក្ខធ្ងន់មួយចំណែកទៀត ព្រោះសំបុត្រនាង **ចន្ទមណី** កាន់តែខ្លីៗ ហើយរយាលៗពេលទៅផង ។ កាលដើមអក្ខរានាងតែងមានសេចក្ដីឡៃបខាយ ពិរោះដ៏ជាឱសថទិព្វចំពោះសេចក្ដីស្នេហាដែលគ្រាំគ្រា ។ តែឥឡូវម្ដេចក៏យ៉ាងដូច្នេះ ? ចុកត្អូលអួលផ្សាអ្នកកំលោះ គិតយល់ដោយសមហេតុសមផលថា នយោបាយថៃ-តណ្ហូចិនក្នុងគ្រានេះ បានត្រេចទៅរកផ្លូវប្រទូស្តគ្នា ដែលជាហេតុនាំឱ្យមានការត្រួតពិនិត្យសំបុត្រស្នាមទាំងឡាយយ៉ាងតឹងរ៉ឹងនៅប្រៃសនីយ៍ ។ ចំណែកឯអ្នកសរសេរវិញ ហ៊ានប្រគល់ទៅក្រដាសតែដំណឹងខ្លីៗ ដែល មិនមែនជាការសំងាត់ឬដែលមិនមែនជាការផ្ទាល់ខ្លួនជ្រៅៗពេក ព្រោះអៀនផង មានការបារម្ភផង ចំពោះភ្នែកជនដទៃ ដែលចាំឆែកសំបុត្រទាំងនេះ ។

នៅដើមខែ កុម្ភៈ ឆ្នាំ ១៩៤០ ក្រសួងមហាផ្ទៃបានហៅ **ឌីយ៉ាទុង** ឱ្យចូលធ្វើការហើយចាត់ឱ្យទៅធ្វើជាបាល័ដ្ឋខេត្តនៅពោធិ៍សាត់ ។

~ ៦ ~

## សេចក្ដីលំបាកនៃអ្នករាជការតូច

មានអ្នកនិពន្ធម្នាក់ទឹកឆ្ងល់ ហើយដណ្ដឹងសួរខ្លួនឯងថា ហេតុដូចម្ដេចហ្ន៎ បានជាទីក្រុងភាគច្រើនក្នុងពិភពលោក ដែលតាំងនៅលើមាត់ស្ទឹង ឬទន្លេ តែងរីកចំរើននៅត្រើយខាងលិចជាងខាងកើត ការណ៍នេះគួរឆ្ងល់ពិត ! មិនបាច់ទៅរកឧទាហរណ៍ឯណាវែងឆ្ងាយទេ ។ មើលចុះភ្នំពេញ កំពង់ចាម បាត់ដំបង សៀមរាប ។ ល។ ទីក្រុងទាំងនេះសុទ្ធតែមានសង្កាត់ធំៗ តាំងនៅលើត្រើយ ខាងលិចទីដែលហូរកាត់ ។ ម្ដេចហ្ន៎បានជាគេចូលចិត្តផ្ដុំគ្នា នៅក្រោយខាងលិច ជាងខាងកើត ?

ឯក្រុងពោធិ៍សាត់ ក៏គេចមិនផុតពីក្បួនខ្នាតអាថិកំបាំងនេះដែរ ។ ផ្សារក្ដី ផ្ទះរាជការក្ដី សុទ្ធតែប្រជ្រៀតគ្នានៅខាងលិច ដងស្ទឹងមួយដែលមានពោះធំ ទូលាយដូចទន្លេ តែមានទឹកហូរហែរមិនឈប់ឈរតាមចន្លោះកូនកោះខ្សាច់ ដែលដុះលាតត្រដាងចាំស្ទះមុខសរសៃគ្នា។

បើអ្នកអញ្ជើញទៅពីភ្នំពេញ ហើយលុះយានអ្នកបានឆ្លងស្ពានបេតុង របស់ទីក្រុងផុតកាលណា អ្នកនឹងពើបផ្លូវបែកជាបី នៅចុងស្ពាននោះ ។ បើអ្នកហួសទៅត្រង់តែម្ដងនោះ បង្ហាញឱ្យឃើញថា អ្នកប្រញាប់ទៅបាត់ដំបងឱ្យបានឆាប់រហ័ស ។ ប៉ុន្តែបើអ្នកបត់ទៅខាងស្ដាំ នេះបកស្រាយឱ្យឃើញថា អ្នកចង់ចូលសំរាកនៅផ្សារស្រស់ស្រូបគុយទាវ កាហ្វេ ទឹកក្រូចនៅទីផ្សារពោធិ៍សាត់ មួយភ្លែតសិន ព្រោះជាទីដំណាក់របស់អ្នកដំណើរតាមឡានឈ្នួល ។

មានជួនកាលសេចក្ដីចង់ដឹង ចង់ស្គាល់ អាចប្រាទដៃអ្នកកាច់ចង្កូតយន្ត ឱ្យកាច់ទៅខាងឆ្វេងវិញ ។ បើអ្នកធ្វើយ៉ាងនេះអ្នកនឹងចូលតាមថ្នល់មួយដែល គ្រាន់តែក្រាលថ្មឥតចាក់ជ័រទេ ។

ទៅឆ្ងាយប្រហែលប្រាំរយម៉ែតពី " បង់កាឡូ " ដែលជាអគារថ្មទាប ក្រប៉ិក១រាងដូចឆ្នាក្រាបលបចាប់ព្រាបអ្នកនឹងបានដល់ផ្ទះចាស់មួយ ជញ្ជាំងក្តារ ប្រក់ក្បឿងដែលជរាភាព នាំឱ្យជនជាម្ចាស់ខំគាំទ្រប៉ះប៉ុននាយអាយ ដើម្បីជាទីជម្រករៀងរហូតមក ។ ជ្រកកណ្តាលគុម្ពចេក និងស្វា ផ្ទះកន្រ្តតនេះបើកទ្វារ ចំហរមកលើកូនភ្លឺមួយ ដែលជាគមនាគមន៍ភ្ជាប់មកថ្នល់រាជការ ហើយមាន ទម្រង់ដូចជាអណ្តាតយ៉ាងវែង ដែលលៀនធ្លេនមករកអ្នកដើរនៅទីឆ្ងា ។

ពូ **ហ៊ីង** និងមីង **ក្អាត់** ជាម្ចាស់នៃសំបុកចំឡែកនេះ ។ ប្រហែល ជាឃើញឈ្មោះអ្នកទាំងពីររួមនៅ ក្នុងវង្សសត្វស្រដៀងគ្នាយ៉ាងនេះហើយ ទើបចាស់ទុំឪពុកម្តាយទាំងសងខាងបានផ្សំផ្គុំឱ្យគាត់ ដោយកំប្លែងឱ្យគាត់បានគ្នាជាប្តីប្រពន្ធ ។ ទោះជាយ៉ាងណាក៏ដោយយើងគង់សង្កេតបានថា ការរួមវាសនានៃជនទាំងពីរបានប្រកបដោយសុខសម្រាន្តរហូតនាំឱ្យគូស្រករឯទៀត អៀនខ្មាស យ៉ាងច្រើននាក់ ។ គិតមើលចុះរៀបការសាមសិបប្លាយឆ្នាំមកហើយ តែពុំដែលមានផលរមាស់រង្កៀសចិត្តធំដុំទេ ។ គាត់មានកូនស្រីបីនាក់ តែឥឡូវបែកសំបុក បែកទ្រនំអស់ហើយ ។ នាងមួយបានទៅ " ម៉ៅ សៀវ " គ្រូបង្រៀន នាងមួយទៀត បានទៅថី ពេទ្យសត្វ ហើយនាងពៅបង្អស់ ទៅទិនិម្មាក់នៅក្រុមស៊ិរិយោជី ក្នុងងាដែលពាក្យបារាំងហៅថា " អារបង់ទែរ " ហើយដែល មានអ្នកខ្លះ ហៅដោយក្រមាច់ មិនគប្បីថា " អាពងទា " ទៅវិញ ។

កូនមានប្តីសីបែកផ្ទះសម្បែងអស់ហើយ ពូ **ហ៊ីង** និងមីង **ក្អាត់** ស្គាល់តែបរមសុខ ។ ថ្ងៃ១ឡើងពូហ៊ីង ដែលមានមាឌកន្តិលក្រអាញ ហើយសម្បុរខ្មៅដូចស្បែកសត្វដែលគាត់ខ្ចីឈ្មោះអីចឹង តែងថែសួនដំណាំដាំដុះមិន ឈប់ដៃទេ ។ ព្រឹក១ឡើងមីងក្អាត់រាងសង្ហិតកន្ទេចអាវេវ សមដូចសត្វយកឈ្មោះគាត់ទៀត ហើយគាត់តែងទូលចេក ល្ហុត ដំឡូង ស្វា តាមរដូវយកទៅ លក់ឯផ្សារ ។ លុះត្រឡប់មកវិញផល្លានុផលទាំងនោះក៏ក្លាយជាអង្ករត្រី សាច់ ព្រមទាំង ....ព្រមទាំងសេចក្តីសង្ឃឹមថា នឹងមានភ្លៀងនៅថ្ងៃរសៀល ឬពេល យប់ ឬ ពេលព្រឹកស្អែកទៀតផង ។

ដូចជាហ្វូងកណ្តូបដែលតែងតែរាតត្បាតស្រែចំការច្បារដំណាំនៅភូមិភាគខ្លះ នៅទ្វីបអាព្រិច អឺរ៉ុប ជំងឺល្បែងលក់ទេវតាបានព្រួសពិសរំលាយប្រាក់សន្សំរបស់ខ្មែរមិនថា អ្នកក្រុង ឬអ្នកស្រែទេ ។ ចំណែកឯចិនជាអ្នកផ្តើមគំនិត ហើយជាអ្នកមេលក់ភ្នាល់នោះចេះតែបានចំណេញបានកាក់កបជានិច្ច ។

នៅរដូវវស្សា ស្វាមីទាំងពីរ នាំគ្នាទិញភ្លៀងញ៉ូរកក្អិច ។ មីង **ក្អាត់** ទៅលក់ អីវ៉ាន់ ឯផ្សារតែឆ្លៀតឱកាសទៅរក **អាស៊ុក** មិនដែលខានទេ ។ គាត់ញៀនខ្លាំងណាស់ ដល់ជានៅថ្ងៃឧបោសថកំពុងស្តាប់ធម្មកថិកសំដែងទេស នា ឱ្យតែឮផ្គរត្អុលចុះ ភ្នែកគាត់វិលរំពៃសម្លឹងមើលមេឃភ្លេចសម្លឹងរកនិញ្វន អស់ ។

ចំណែកពូ **ហ៊ីង** វិញក៏មិនណយដែរ ឱ្យតែមានពេលទំនេរបន្តិចចុះ គាត់ទាញកង់កញ្ចាស់ជិះរ៉ោញទៅផ្សារ ។ លុះត្រឡប់មកវិញគាត់ឆ្ការដៃ ឆ្ការ ជើង ប្រកាសដំណឹងល្អប្រាប់អ្នកជិតខាង និយាយភាសាមួយចំលែកលាយចិន លាយខ្មែរប្រឡូកប៉ូប៉ាកញ្ចប់មាត់ដង្ហាញ " ឡុកជីឡុក ..... តាយឡុស៊ី ... ឡាត់.....តូយាង " ។

ម្លោះហើយ ផលនៃត្បិតត្បៀត សន្សំយ៉ាងណាក៏ដោយមិនព្រមនៅ បំប៉ោងថង់ពូ **ហ៊ីង** មីង **ក្អាត់** ទេ ចេះតែរសាត់ប៉ប្រុយទៅធ្វើជាពួកម៉ាកនឹង ចិនទេវតាមេឃភ្លៀងទៅវិញ។ ដោយអាស្រ័យហេតុនេះហើយ ទើបពូហ៊ីង បានទទួលការអនុម័តយល់ព្រមពីមីង **ក្អាត់** ឱ្យរៀបបំបែកល្វែងផ្ទះកន្រ្តត គាត់ឱ្យបានជាបន្ទប់មួយថ្មី ដោយយកខ្ទងទូកញ្ចាស់១ខ្លះ កន្ទេលក្រចូតពភ្លក់ខ្លះ មកបិទបាំងជាជញ្ជាំងទ្រូង។ កាលណាចាត់ការនេះរួចហើយគាត់ទៅផ្តាំផ្ញើនឹង **"ម៉ៅសៀវ"** ហើយនិង **"ថី"** កូនប្រសារគាត់ឱ្យជួយឃោសនាប្រាប់អ្នករាជការទាំងឡាយថា គាត់មានបន្ទប់មួយទុកជួល ។

ថ្ងៃមួយ **ទីឃាវុធ** ដែលទើបមកដល់ពោធិ៍សាត់ថ្មីថ្មោង កំពុងដើររកជួលផ្ទះក៏ឮដំណឹងនេះ ហើយក៏ចូលមកមើលទីកន្លែង ។ ឃើញស្រេចថា សម នឹងចិត្តភ្លាម ។ សមនឹងចិត្តយ៉ាងនេះ មិនមែនដោយឃើញថាមានផាសុខភាព ឬប្រណិតភាពអ្វីទេ គឺព្រោះយល់ថាជាកន្លែងស្ងាត់មិនសូវអ៊ូអរសមរម្យ នឹងទឹកចិត្តខ្លួនខ្លោចផ្សា ហើយដោយឃើញថាថ្លៃឈ្នួលដែលគេទារនោះក៏ថោក សមគួរល្មមនឹងប្រាក់ខែដែរ ។ ប្រាំបីរៀលដែលមន្ត្រីកំលោះយើងសង្ឃឹមបើកបាននៅរាល់ចុងខែ ។

មុនពេលនឹងឡើងឡានឈ្នួលមកកាន់ទីតាំងដំបូងនេះ ឪពុកម្ដាយ បានបង្គោះបង្អៀរបានប្រាក់១៥០រៀលមកឱ្យកូន ។ មូលធននេះបានបើក អំណោយឱ្យ**ទីឃាវុធ** ទិញបានប៊ីស៊ីក្លែតមួយ គ្រែឈើទាលមួយ តុវែងមួយ ហើយកៅអីផ្ដៅបី ។ ប្រដាប់ប្រដារទាំងនេះបានមករួមគ្នានឹងហិបឈើមួយ លាបពណ៌ជំពូ ពូករនាបមួយ ហើយនឹងវាំងននក្រហមមួយមានភ្ជិជាគំនូរសត្វ សេក ឬសារិកាពាំផ្កាហើរជិតវិមានស្រុកក្លិង្គ ។ តែប៉ុណ្ណោះអស់ហើយ ! ឪ សូមទោស នៅភ្លេចកូនមុងមួយទៀត ដែលគ្របគ្រែពុំបានពេញផង ។

**ទីឃាវុធ** ពុំមានឈ្នួលបំរើទេ ។ ការបោសច្រាសមីង **ក្អាត់** ដែលជាអ្នកចិត្តល្អគ្រាន់បើថ្វីត្បិតញៀនល្បែងភ្លៀង តែងមកធ្វើឱ្យក្នុងពេលដែល លោកបាល័ដ្ឋទៅសាលា ។ ការបោកអ៊ុតខោអាវត្រូវជួលយួន ដែលមួយអាទិត្យ ម្ដង មកទទួលយករបស់ប្រឡាក់ដល់ផ្ទះក្នុងពេលដែលនាំសម្លៀកបំពាក់ស្អាត ដែលបានបោកអ៊ុតរួចនោះមកប្រគល់ឱ្យវិញ ។ ដោយខ្លួនជាអ្នកថ្នាក់ថ្នមវត្ថុប្រើប្រាស់ **ទីឃាវុធ** តែងជូតខាត់ទោចក្រយានថ្មីរាល់ថ្ងៃរាល់ល្ងាចក្នុងពេលដែលត្រឡប់មកពីធ្វើការ ឬ ជិះយកលំហែវិញ ។

លំបាកធំជាងគេដែល **ទីឃាវុធ** ចំពប់ទៅលើ គឺការរិះរកប្រដាប់ប្រដារស្លៀកពាក់ ឱ្យបានគ្រប់សព្វតាមឋានៈ ជាមន្ត្រីក្រុមរដ្ឋបាលខ្មែរ។ ក្រោយកន្លងពេលយូរមក នាម៉ឺនកម្លោះយើងតែងនឹកឃើញដោយអៀនរឹងខ្លួនក្រៃលែង អំពីថ្ងៃដែលខ្លួនចូលទៅគំនាប់រេស៊ីដង្កប្រមុខខេត្ត ។ នៅថ្ងៃនោះលោក បាល័ដ្ឋថ្មី បានអង្វរលោកចៅហ្វាយខេត្ត ដែលជាអ្នកត្រូវនាំចូលទៅជួបលោក ធំបារាំងថាសុំស្លៀកពាក់តាមរបៀបអឺរ៉ុបបានហើយ ។ តែមន្ត្រីជាន់ខ្ពស់នេះជាអ្នកខ្លាចបារាំងផុតលេខ គាត់បង្ខំឱ្យអ្នកកម្លោះស្លៀកពាក់ស្រោមជើងខ្មៅ ស្បែកជើងខ្មៅទាល់តែបាន។ ប៉ុន្តែពេលរកកាត់អាវកុតកត្រង់មិនទាន់ ហើយដោយឡេវជ្រលក់ទឹកប្រាក់ត្រាម្កុដ ដែលខ្លួនបានដោយ គ្មាន់គ្នាញ់នូវអាវបើកក ដែលនៅថ្មីជាងគេ មកពាក់រំលេចដោយក្រវ៉ាត់អន្លូញបញ្ឆិត២ ពណ៌ខៀវ ក្រហម ។ សម្លៀកបំពាក់ប្រឡាយកាត់យ៉ាងនេះបើតាមប្រពៃណីខ្មែរ ក៏មិនត្រូវតាមអឺរ៉ុបក៏មិនប្រាកដ មីង **ក្អាត់** ដែលបានជួយចងក្បិនជាមួងឱ្យលាន់ មាត់ថា សមណាស់៧នឹងរូបរាងលោកបាល័ដ្ឋយើង។ សមក៏ដោយមិនសមក៏ដោយ តែ **ទីឃាវុធ** នឹកខ្មាសគេរឹងខ្លួនស្ពុកមុខឡើងក្រហម ស្ទើរប្រហែលពណ៌សំពត់ដែលខ្លួនស្លៀក ។ កម្មក្រាស់ពេកកូវ ព្រោះត្រូវជិះរ៉ឺម៉កកាត់មុខផ្សារ ឆ្ពោះទៅសាលាខេត្ត ដែលជាហេតុនាំឱ្យជនជាច្រើនឃើញបាល័ដ្ឋយើងក្នុងសម្លៀកបំពាក់ចម្លែកនេះ ។

ជាមួងនេះ ម្ដាយបានអោយតែពីរ ពោលគឺមិនគ្រប់ពណ៌ទេ ត្រូវសន្សំ ប្រាក់មួយខែបន្តិច ដើម្បីទុកទិញថែម ។ មួយទៀតត្រូវទិញស័ក្តិដាប់ធ្វើនៅសាលារចនាក្រុងភ្នំពេញសម្រាប់មកលំអស្មា និងកដៃអាវកុតស ។

ក្រណាស់មិនអាចឈោងយកឱន ឬសែសយអ្វីបានទេ ! អាវកត្រង់នេះ ត្រូវមានពីរបន្លាស់ ឯឡេវត្រាម្កុដទៀត ក៏ត្រូវរកទិញឱ្យបានរួសរាន់ដែរ ព្រោះឧឡារិកភាព និងបុណ្យងារ ដែលត្រូវប្រើប្រាស់មិនសូវដាច់ពេកទេ ។

ចំណាយទាំងនេះ ដែលលេបគ្មានសល់នូវប្រាក់ខែ ហើយនឹងជីវភាពថ្មី បរិបូណ៌ដោយការណ៍ចំឡែកមិនដែលស្គាល់ នោះបានបណ្ដាលឱ្យនាម៉ឺនតូចតាច ភ័ន្តភាំងស្មារតី ។ កាលនៅក្នុងសាលានៅឡើយ តែងយល់ថាធ្វើការរាជការ គង់មានបៀវត្សល្មមចិញ្ចឹមជីវិត ហើយគង់មានឱកាសដើរបំភ្លឺរាស្ត្រស្រែចំការឱ្យចេះរករបរឱ្យបានទាន់សម័យ ។ ឥឡូវខុសអស់រវល់តែខ្វល់នឹងផ្នែកសំភារៈ ដោះស្រាយបញ្ហាផ្ទាល់ខ្លួន ។ មួយទៀតនាយចៅហ្វាយខ្លួនតែងកាន់កិរិយា ឬ ជាប់ទម្លាប់ពុំគប្បីផង នាំឱ្យអ្នកមានឆន្ទៈល្អវង្វេងវង្វាន់ មិនដឹងចាប់ផ្ដើមត្រង់ណាមុនទេ ដើម្បីឱ្យបានជាប្រយោជន៍ពិតៗដល់ជាតិដល់ប្រទេស ។

**ឆីយារុធ** ទាស់ចិត្តក្នាញ់ជាងគេ នឹងចៅហ្វាយខេត្ត ។ មន្ត្រីជាន់ ខ្ពស់នេះ ជាមនុស្សអាយុសែសិបប្លាយហើយសក់កាត់ខ្លីពណ៌របាយអាចម៍ខ្លា ។ សំនួនសេចក្តីនេះ ពួកបារាំងដែលខ្ចីមមិនចង់ចេញឈ្មោះលាមកក៏ប្រែថាជា " អំបិលលាយម្រេច " ទៅវិញ ។ មាឌគាត់កន្ទុលហើយមាំ ។ កាលដែលគាត់នាំ **ឆីយារុធ** ទៅជួប "លោកធំ " បារាំងជាដំបូង ជាប្លង់តុងបានចេញមកប្រាប់ ថាឱ្យលោកចៅហ្វាយខេត្តអង្គុយចាំបន្តិចសិន ព្រោះលោកធំកំពុងជាប់ដៃសរសេរកំណត់ ។ ប្រមុខខ្មែរក្នុងខេត្តពោធិ៍សាត់ ក៏បង្គាប់ឱ្យសហការីអង្គុយលើ កៅអីមួយ ឯខ្លួនមានមុខស្លាំងធ្វើមាត់ជីបអូច១ ហាក់ដូចជាកំពុងរៀបរកពាក្យ បារាំង ទុកបំរុងនឹងនិយាយក៏មិនដឹង ឬមួយសេកមន្តអាគមឱ្យបារាំងទន់ចិត្ត បែរជាគួចរាប់អានខ្លួនវិញក៏មិនប្រាកដដែរ ។

នាកាលបានអនុញ្ញាតឱ្យចូល " គាល់ " ហើយលោកធំនៅតែធ្វើឫក ឱនសរសេរញាប់ស្មេក ដោយចង់បង្ហាញឱ្យឃើញថា ខ្លួនរវល់ពេញបន្ទុកពិតមែន ។ ឯចៅហ្វាយខេត្ត ឈរផ្ទាំងពីមុខតុ ធ្វើភ្នែកក្រឡេកក្រឡក់មានទឹកមុខ ដូចជា ឈឺបត់ជើងធំបន្តិច តូចបន្តិច ។ ក្រោយមកមួយស្របក់ធំទើបបារាំង ងើបមុខ ហើយបញ្ចេញកិរិយាដូចជាឆ្ងល់ខ្លាំង ច្រមុះកោងវែងជាបុច្ឆនសញ្ញា យ៉ាងសុទ្ធសាទ ។ លោកចៅហ្វាយខេត្តស្ទន់ខ្លាំងលើកដៃសំពះ បង្អោនក្បាលចុះ ហើយនិយាយបារាំងបីបឹស ប៉ប៉ិក ប៉ប៉ុកស្ទើរស្តាប់មិនបាន ។ លោករេស៊ីដង្គងក់ក្បាលទទួលដោយមុខមាំ វាយឫកក្រអឺត ហើយហុចដៃទន់ប្រផ្លាកកន្លងតុ មកចាប់ហត្ថមន្ត្រីខ្មែរទាំងពីរនាក់ ទើបចង្អុលកៅអីឱ្យអង្គុយ ។

ក្នុងពេលនោះ **ឆីយារុធ** នឹកក្នុងចិត្តថា ចៅហ្វាយខ្លួនដែលជាអ្នកខ្លាចបារាំងដល់ម្លេះ សមតែជាមនុស្សស្លូតបូត មានមេត្តាករុណាសណ្តោស អ្នកតូចអ្នកទាបមិនខានឡើយ ។ ប៉ុន្មានថ្ងៃក្រោយមកអ្នកកំលោះក៏ស្តាប់ឮនឹង សង្កេតដោយភ្នែកឯងនូវការណ៍ផ្សេង១ដែល បដិសេធក្តីស្មានទាំងនេះឱ្យឃើញថាខុសស្រឡះទាំងអស់ ។

លោកចៅហ្វាយខេត្តមិនមែនជាមនុស្សរម្យទម ហើយឧត្តមគតិជាមេបាសម្រាប់ជនខ្សត់ក្រដែលនៅល្ងង់ ហើយដែលរងាឥតអ្វីការពារនោះទេ គាត់ជាអ្នកលេងសើចសប្បាយ មិនចេះគិតនឹកនាដល់ប្រយោជន៏ប្រទេសជាតិតែម្តង ។ នៅផ្ទះគាត់មានប្រពន្ធចុងក្មេងបីនាក់ ព្រោះលោកស្រីធំឈ្លោះពុំឈ្នះក៏ អនុញ្ញាតឱ្យនៅជាមួយគ្រាន់ប្រើប្រាស់ជាអ្នកកំដរទៅ ។ មិនតែប៉ុណ្ណោះទេ ក្នុង ធុងខាងក្រោយឡាន " ក័ត្រសង់ដី " ពណ៌ឈាមជ្រូករបស់គាត់ គាត់លាក់ចប កាប់មួយទុកប្រចាំការជានិច្ច ។ គាត់បានបង្ហាញប៉ូលិសខេត្តជំនិតម្នាក់ឱ្យចេះបររថយន្ត ។ ប៉ូលិសនេះឯងមាននាទីជាមេធ្នាក់ដើរឃ្លាំមើលកូនក្រមុំអ្នកស្រុក ។ លុះខ្សិបខ្សុលបានការណ៍កាលណាប៉ូលិសនោះចូលទៅប្តឹងលោកចៅហ្វាយខេត្ត ទាំងយប់ នៅចំពោះមុខលោកស្រីថា មានចោរប្លន់នៅភូមិនេះ ឬភូមិនោះ ។ លោកចៅហ្វាយខេត្តយល់ល្បិចហើយក៏ប្រកាសថា ខ្លួនត្រូវចេញទៅចាត់ការ ដោយរួសរាន់ឱ្យទាន់ពេល ។ រួចហើយ ក៏នាំគ្នាបរអា " ក័ត្រដង់ដឺ " ចេញទៅ ។ ឯចបកាប់ដែលលាក់ទុកក្នុងធុងខាងក្រោយនោះ មានប្រយោជន៍ទុកកាប់ភ្លឺ ស្រែដែលជំទាស់មិនឱ្យឡានពារបានដោយស្រួល ក្នុងកិច្ចការដែលលោកចៅ ហ្វាយនិងប៉ូលិសជាគូកនត្រូវជើងគ្នាថាទៅរក " ក្តាមស្រែ " ពោលគឺនារីនៃនិគមជនបទ ។

កំហូចរបស់គាត់មិនមានព្រំដែនតែត្រឹមហ្នឹងទេ ។ គាត់ចូលចិត្តស៊ីផឹក ខ្លាំងណាស់ ។ ចៅហ្វាយស្រុកណាដែលចង់បានពិន្ទុល្អដើម្បីឡើងស័ក្តិរហ័សត្រូវ រៀបជប់លៀងអញ្ជើញគាត់មកសែនជាញឹកញាប់ ។ មិនសូវចេះធ្វើការក៏ហ៊ីចុះ ឱ្យចេះតែផ្គាប់បានហើយ ។

ល្ងាចថ្ងៃសៅរ៍មួយ ចៅហ្វាយស្រុកម្នាក់បានអញ្ជើញទាំងអ្នករាជការ សាលាខេត្ត និងសាលាដំបូងឱ្យទៅលេងសប្បាយនៅកន្លែងជិតទីប្រជុំស្រុក ដែលនៅចម្ងាយ ១០ គីឡូម៉ែតពីពោធិ៍សាត់ ។ លោកចៅហ្វាយស្រុកផ្គាប់បុណ្យ បានកេណ្ឌអ្នកស្រុកឱ្យសង់រោងប្រក់ស្លឹកពីរខ្នង ចំពីមុខបឹងធំដែលនៅ កណ្តាលវាលស្រែបន្លែ ដោយភ្លេងភ្លាត់ និងចំរៀងទ្រហឹងអឹងកង ។ ស្រាឡូលី តាម៉ារលី និងក្លូសដរដែលបានមកពីបិណ្ឌបាតតាមផ្ទះចិនហួរគគុកគគាក់ចូល ក្នុងកែវទៅលាយនឹងទឹកដូង និងទឹកកក ។ ក្នុងពេលនោះដោយគមនាគមន៏តាមសមុទ្ររវាងឥណ្ឌូចិន និងប្រទេសបារាំងប្រទះសេចក្តីលំបាកដោយកប៉ាល់ មុជទឹក អាល្លឺម៉ង់តាមរាតត្បាតពេក បារាំងនៅស្រុកអាយទើប

នាំគ្នាបិតស្រាចុះសញ្ញាថ្មីលក់លាន់ ។ សូម្បីតែទឹកសូដារក៏មិនសូវសំបូរដែរ គេច្រើនយកទឹកដូង មកប្រើជំនួសវិញ ។ ថ្វីបើសុរាអោយទាំងនោះ មិនមានគុណភាព និងឱជារស ដូចទឹកស្រវឹងមកពីអឺរ៉ុប ក៏គង់ធ្វើឱ្យមន្ត្រីខ្មែរសម័យនោះសប្បាយភ្លេចកង្វល់ទាំងពួងផងដែរ ។ លោកចៅហ្វាយស្រុកឱ្យចាត់យកត្រីរស់ធាត់៧ធំ ដែលទើប ចាប់បានពីបឹង ទៅបិតដីឥដ្ឋឃ្លុំជិតហើយដុតក្លែមស្រាឆ្ងាញ់កប់អាកាស ។

**ឌីយ៉ាខុង** និងសភាចារបុរសម្នាក់ឈ្មោះ **ប្រាមោឡូ** ដែលជាអ្នកពុំ ចេះស្រា ពុំសប្បាយនឹងស៊ីផឹក ហើយស្អប់ខ្ពើមសម្ដីអ្នកប្រមឹក ក៏បបួលគ្នារំកិលថយក្រោយបន្តិចម្ដង១ ហើយនាំគ្នាលួចដើរចេញទៅក្រៅ នៅពេលដែលលោក ចៅហ្វាយខេត្ត និងចៅហ្វាយកំពុងបេះត្រីបញ្ចុកឬបង្អកស្រាពួកស្រីល្ខោន និងអាយៃដែលធ្វើឫកមាយាគ្រប់បែប ដើម្បីបង្វិល ខួរនៃអ្នកកក្រេកត្រអាលនឹងកាមគុណ។

ចេញផុតពីរោងទទួលភ្ញៀវមកកាលណា វាយោត្រជាក់បក់ជាជំនោរ មកលើភក្ត្រអ្នកទាំងពីរ ហើយនាំមកនូវក្លិនប្រហើរនៃផ្កាព្រំមេឃពណ៌ ស្វាយរំលេចចំរុះដោយផ្កាយគ្របដណ្ដប់គុម្ពោតព្រៃ ដែលស្បែយប់ខ្មៅជួយប្រែ រាងជាសត្វឃោរឃៅ មានតែនៅក្នុងរឿងប្រតិស្ន ។

នៅដាច់៧ឆ្ងាយពីគ្នាភ្នក់ភ្លើងបញ្ចេញអណ្ដាតក្រហមភ្លឺបភ្លែត ផ្ដល់កំដៅស្រមោល គោដែលដេករកេតរកូត ហើយកំពុងទំពារអៀងលំអិតយល់សប្តិ ដែលរកទីបញ្ចប់គ្មាន ។ នៅក្រោមរស្មីពព្រូលនៃរាត្រីខ្មមអ្នកចាំលានស្រែ ត្រដាងដំបូលស្បូវសប្រផះ ។

មន្ត្រីកំលោះទាំងពីរបាននាំគ្នាដើរចេញឆ្ងាយ ហើយពោលទឹកស្ដាយ ពេលដែលមកខាតបង់ដោយអំពើប៉ោឡែយ៉ាងនេះ ។

យើងមិនមកតាមគេមិនបានទេ **ប្រាមោឡូ** និយាយ បើពុំនេះទេ គេចាត់យើងថា ជាមនុស្សឆ្វេង ជាមនុស្សចូលធ្លុងគេពុំចេះ ។ មួយទៀតអាចធ្វើ រាយការណ៍សំងាត់ប្ដឹងបង្កាច់យើង ហើយដាក់ពិន្ទុអាក្រក់យើង ។ រាជការខាងក្នុងពុំដឹងអ្វីសោះ ក៏ផ្លាស់យើងទីណាត់ទីនែង ឬផ្អាកយើងមិនឱ្យឡើងថ្នាក់អស់ពេលយ៉ាងយូរ ។

អីអាក្រក់ដល់ម្លឹងហ្ន៎ ! **ឌីយ៉ាខុង** ភ្លាត់មាត់ហើយនិយាយថែម :

- បានអីចឹងហើយ តើម៉េចក៏ខ្លាចបារាំងម្ល៉េះ ? មើលចុះតាប៊ុខ្ញុំគាត់ សំពះគាត់ប៉ាយពួកច្រមុះកោងស្ទើរតែគ្រប់គ្នា ។

- បើគ្រាន់តែប៉ាយប៉ុណ្ណេះ វាមិនសូវជាប៉ុន្មានទេ **ប្រមោឡូ** ពេប មាត់ដោយមើលងាយ ។ ប្អូនឯងទើបមកថ្មីណាស់បានជាមិនទាន់ដឹងកិច្ចការ ។ លោកតាខេត្តហើយនឹងលោកតាខ្ញុំត្រូវគ្នាប៉ុនគេជើត ។ គាត់ផ្កាប់ គាត់ក្ដេបគ្នីបលើកជំនូនជាញឹកញាប់យកចិត្តយកថ្លើមថា " លោកធំ " ។

- អារសាច់ជូនខ្លាទើបនៅស្រុកសុខ ។

- ត្រូវហើយប្អូន ! ប្អូនឯងគិតមើល តាមបញ្ញត្តិរាជការជាន់ខ្ពស់រេស៊ី ដង់ប្រមុខខេត្តជាទីប្រឹក្សា ហើយជាអ្នកជួយមើលការខុសត្រូវក្នុងតុលាកាខ្មែរ ។ បងធ្លាប់បានឃើញមកហើយដែរថា មានចងហ្វាងខ្លះយកការអ្វីដែលចំរូង ចំរះពេកទៅស្នើយោបល់លោកធំ ។ នេះជាការធម្មតាទេ គ្មានអ្វីគួរឱ្យបន្ទោសបានទេ ។ តែលោកតាខ្ញុំបែរជាបង្គាប់ឱ្យសុភាចារបុរសថា កាលណាស៊ើបសួរ រឿងនីមួយៗចប់ត្រូវធ្វើរាយការណ៍ជាភាសាបារាំងខ្ទាស់ជាប់ពីរលើសំណុំរឿង។ នៅរសៀលថ្ងៃច័ន្ទ លោកចាងហ្វាងប្រមូលសំណុំរឿងទាំងអស់ទៅស្នើលោកធំ ។ ក្រោយដែលបានសម្លឹងរាយការណ៍សង្ខេបទាំងនោះមួយពព្រិចភ្នែករួចហើយ លោកធំក៏ចារដាក់ថា " បីខែមួយឆ្នាំឱ្យរួចខ្លួន " ។ល។ ....លុះមកដល់ ថ្ងៃពុធ ដែលជាថ្ងៃកាត់ក្ដី លោកចាងហ្វាងក៏ផ្ដើមចែករង្វាន់ឱ្យអ្នកជាប់ចោទ ទាំងឡាយតាមចំណារលោកធំ មិនឱ្យល្មៀងទេ ។ ការចុះចូលឱនលំទោនហើយ គោរពប្រតិបត្តិយ៉ាងនេះ ជូនលទ្ធផងខ្ទប់ភ្នែកបារាំងអោយលែងមើលឃើញអ្វីទាំងអស់ ។ រឿងណាដែលគាត់ត្រូវមានលាភគាត់ធ្វើរាយការណ៍ខ្លួនគាត់បំបែរ សន្និដ្ឋានលោកធំឱ្យស្របទៅតាមលាភរបស់គាត់ ។ គាត់ត្របាក់គ្រិបគ្រិប ! ឥតញញើតមាត់ទេ ឥតកោតក្រែងការិះគន់ពីជនណាទេ ព្រោះអីលោកធំបាន សម្រេចយ៉ាងនេះរួចមកហើយ ! អីដល់ម្លឹងហ្ន៎..." ។

រឿងស្ទាត់កំបាំង ដែលមិត្តថ្មីយកមកបង្ហាញឱ្យឃើញនេះនាំឱ្យ **ឌីយារុន** ក្រហល់ក្រហាយនៅពុំសុខសោះ ។ កាលពីដើម គិតមកធ្វើការបំរើជាតិនិងជនរួមជាតិ ។ ឥឡូវមានទម្ងន់ធ្ងន់មកសង្កត់ដៃជើងសង្កិនប្រាជ្ញាមិនឱ្យ កម្រើករួចសោះឡើយ ។ ដោយបានខ្ចីពិសោធន៍ពីតែក្នុងសៀវភៅមកធ្វើជាគោលជីវិតពិតប្រាកដ ដែលបរិបូណ៌ដោយភាពគ្រាតគ្រើមនោះ មានសល់សែន ស្ទើរតែគ្រប់ជំហាន ។ កំលាំងក្មេងយុវថាមពលដែលនៅតែឯកឯង មិនងាយនឹងកន្ត្រោងបំរះរួចទេពីសំណាញ់អំពល់ដែលរំស្រោបរួបរឹតខ្លួនបានពេញទី ។

បណ្តាលព្រឹត្តិការណ៍ទាំងឡាយ ដែលបានឆ្លាក់ជាប់ជ្រៅទៅលើផ្ទាំង នៃពេលផ្តើមបំរើរាជការនេះ **ឌីយារុន** បានចាំឥតភ្លេចនូវរឿងមួយជាងគេ ព្រោះជាហេតុនាំឱ្យខ្លួនទាក់ទងក្នុងការស៊ីសំណូក ដល់ក្នុងពេលនោះជាដំបៅ មួយរីកធំៗឡើង ហើយធ្វើឱ្យប្រយោជន៍ជាតិមានគ្រោះថ្នាក់គួរអោយព្រឺខ្លួន ។

ធម្មតាអ្នករាជការនៅខេត្តក្រៅតែងស្វែងចង់សប្បាយហ៊ឺហារណាស់ធ្វើឱ្យរាស្ត្រប្រជាគ្នាកោតញញើតដូចខ្លាចទេវបុត្រទេវតាយ៉ាង នេះដែរ ។ ថ្វីក៏ ពុំដូច្នោះព្រោះតែងមានអ្នកជប់លៀងនាម៉ឺននាសែន ដើម្បីបំបាត់ បំបិទត្រចៀក ឬខ្ទប់ភ្នែកមិនឱ្យដឹងឮច្បាស់នូវកិច្ចការអ្វីដែលទាក់ទងនឹងផលប្រយោជន៍ពួក ក្រពើទាំងនោះ ។ ក្នុងពពួកជនបែបនេះ **ឌីយារុន** បានសង្កេតឃើញសហ គ្រិនម្នាក់ឈ្មោះ **ហុងឈី** ជាកូនចៅចិនដែលតែងតែឡើងចុះសាលាខេត្ត ហើយដែលបានអញ្ជើញបុគ្គលិកធំតូចនៃក្រុមរាជការទៅជប់លៀង កំសាន្តនៅ ទីនានាយ៉ាងញឹកញយ ។

បាល័ដ្ឋខេត្តយើងមានមុខតំណែងខាងត្រួតត្រា ហើយកាន់បញ្ជី សំភារៈ ។ រវាងពីរខែមុននេះ ចៅកែ **ហុងឈី** បានចូលដេញថ្លៃ ដើម្បីរ៉ាប់រង ទទួលដេរឯកសណ្ឋានប៉ូលិស ខេត្តចំនួន ៥០០ សម្រាប់ ។ ក្នុងពេលនោះ **ហុងឈី** ហ៊ានថ្លៃយ៉ាងថោកជាងគេបំផុត ។ អ្នកចូលដេញថ្លៃឯទៀតពោល ថា យកថ្លៃយ៉ាងនេះមុខជាខាតពុំខាន ប៉ុន្តែហុងឈី គាត់ឆ្លាតណាស់....

ថ្ងៃមួយនៅពេលជិតដល់ម៉ោងចេញពីធ្វើការ គាត់ចូលជួបនឹង **ឌីយារុន** ក្នុងបន្ទប់ការិយាល័យ ។ គាត់លុតជង្គង់ហើយលើកដៃសំពះ ប្រណម្យដាក់ខ្លួនយ៉ាងទាប លោកបាល័ដ្ឋដែលជាអ្នកពុំចូលចិត្តនឹងការលុតក្រាបយ៉ាងនេះក៏ស្ទុះមកទាញដៃចៅកែឱ្យអង្គុយលើកៅអីនៅចំពីមុខតុ ។

ខ្ញុំប្របាទម្ចាស់ **ហុងឈី** ( ចាប់និយាយ ) អរព្រួចតែម្តងដោយបាន ដំណឹងថា ព្រះតេជព្រះគុណម្ចាស់អញ្ជើញមកកាន់តំណែងនេះ ។ ខ្ញុំប្របាទមាន មុខរបរបន្តិចបន្តួច សូមជ្រកម្លប់បារមីព្រះតេជព្រះគុណផង ។

- កុំមានប្រសាសន៍យ៉ាងនេះមិនត្រូវទេ ខ្ញុំជាអ្នករាជការនៅក្មេងថ្នាក់ តូចទាប ហើយទើបមកកាន់ការថ្មីៗ ពុំអាចមានអំណាចអ្វីជួយលោកបានទេ ។

- ប្រាកដជាជួយបាន ព្រះតេជព្រះគុណ ។ ព្រះតេជព្រះគុណគង់ ជ្រាបស្រាប់ហើយថា ខ្ញុំបាទបានដេញថ្លៃ ទទួលដេរខោអាវឱ្យពួកប៉ូលិសខេត្ត ។ ឥឡូវនេះរកសាច់សំពត់អោយបានដូចប៉ាន់រាជការនៅទីនេះពុំបានទេ ។ បើចង់បានត្រូវចុះទៅភ្នំពេញ ។ ហើយសំពត់កំពុងឡើងថ្លៃយ៉ាងនេះ មុខតែជាខាតលិចលង់ស្លាប់ហើយ ។

- បើអញ្ចឹង តើឱ្យខ្ញុំជួយយ៉ាងម្តេចទៅ ?

- ទានប្រោសមានសំពត់មួយធីទៀត ពណ៌ខុសពីប៉ាន់បន្តិច តែសាច់ ស្រដៀងគ្នាដែរ ។ សូមព្រះតេជព្រះគុណពិនិត្យមើលចុះ ។

ថាហើយ **ហុងឈី** ក៏ទាញយកជំនៀវក្រណាត់សំពត់ពីរបែបមក ដាក់ជិតគ្នាឱ្យលោកបាល័ដ្ឋមើល ។

-ព្រះតេជព្រះគុណមើលចុះមិនខុសគ្នាទេ ។ ឯសាច់កំណាត់សំពត់ បែបរបស់ខ្ញុំបាទចង់ក្រាស់ផង ជាប់ជាងផង ។

បាល័ដ្ឋក្មេងស្ទាបពិនិត្យសាច់សំពត់ទាំងពីរធី ដោយប្រុងប្រៀប ស្រាប់តែចៅកែបែរសម្លឹងទៅទ្វារបន្ទប់ ឃើញបិទជិតល្អហើយទើបទាញ ស្រោមសំបុត្រមួយខ្សាកពីក្នុងហោប៉ៅលើកជូនដោយដៃទាំងពីរទៅមន្ត្រី ហើយនិយាយថា :

- សូមព្រះតេជជួយសង្គ្រោះចុះ ខ្ញុំប្របាទមិនភ្លេចព្រះគុណទេ ។

- **ឌីយ៉ាខុង** ដោយមិនដឹងឧបាយកលពួកសូកប៉ាន់ ក៏សួរដោយ ស្មោះត្រង់ថា :

- ស្រោមសំបុត្រអីនេះ ?

**ហុងឈី** ដែលក្រោកឈរបំរុងនឹងចេញទៅហើយនោះ ក៏ឆ្លើយ ដោយអៀនប្រៀនថា ជាសេចក្តីសាស័ព្ទបំភ្លឺស្ថានការណ៍ របស់ខ្លួនក្នុងការដេញថ្លៃ ។ អ្នកម៉ៅការបានបន្ថែមថា :

- សូមព្រះតេជព្រះគុណយកសំបុត្រទៅពិចារណា នៅឯផ្ទះផងចុះ ព្រោះឥឡូវនេះហួសម៉ោងធ្វើការរបស់ព្រះតេជហើយ ។ ខ្ញុំប្របាទសូមប្រតិ ប័តន៍ហើយ ។

ដោយល្ងាចនេះខ្លួនបានជួបណាត់នឹង **ប្រាមោទ្យ** ថានឹងជិះទោចក្រ យានយកលំហែតាមដងស្ទឹង **ឌីយ៉ាខុង** ក៏ប្រមូលស្រោមសំបុត្រនិងប៉ាន់សំពត់ ទាំងពីរបែបដោយបន្ទីបន្ទាន់ដាក់ក្នុងកាតាបយួរ តែដោយទឹកឆ្ងល់ក្នុងចិត្តថា សេចក្តីអធិប្បាយអីក៏វែងម្ល៉េះស្រោមឡើងកំប៉ោងតែម្តង ។

❧❀❧

នាម៉ឺនកំលោះទាំងពីរនាក់ជិះកង់ទន្ទឹមគ្នា ជើងធាក់ឈ្នាន់យ៉ាងបន្ធូរ ៗ ភ្នែកគន់មើលទេសភាពតាមមាត់ស្ទឹង ក្នុងពេលដែលព្រះអាទិត្យជិតអស្តង្គត ។ រាងកាយនារីខ្លះ ដែលកំពុងអង្គុយត្រាំទឹកហូរក្នុងទីនោះ នាំឱ្យ **ឌីយ៉ាខុង** រំជួលចិត្តដូចទឹកដល់គូប្រចាំចិត្តដែលឃ្លាតទៅឆ្ងាយ ។

ជួនបានទៅដល់កូនរានទំនេរមួយ ដែលជ្រកក្រោមដើមអំពិលមួយ ដើមធំស្កឹមស្កៃ មិត្តទាំងពីរក៏ចុះពីទោចក្រយានត្រូវអង្គុយសន្ទនាពីនេះបន្តិច ពីនោះបន្តិច។ ជំរុលនៃការសាសងគ្នាឥតដើមចុងយ៉ាងនេះ បាននាំឱ្យលោកសុភានិយាយពីលោកដង្ហៅ **ហុងឈី** ប្អូន! ប្អូនដឹងទេ ផ្ទះប្រក់ក្បឿងនៅ ត្រើយម្ខាងនោះជាផ្ទះរបស់ដង្ហៅ ហុងឈី តាប៉ិនេះ ស៊ីកប់ស៊ីអាំងសំបើមណាស់ ។ គាត់ទទួលជប់លៀងអ្នករាជការដោយឥតរុញរានឹងចាយវាយទេ តែកាលណាគាត់ចាយមួយកាក់ មុខតែគាត់បានចំណេញមួយរៀល ឬ ពីរៀល ហើយគាត់ញ៉ក់ញីអ្នកក្រ តើអ្នកណាហ៊ានក្អក បើនាម៉ឺនមិនថាតូចមិនថាធំទេ សុទ្ធតែ ត្រូវជើងនឹងគាត់អស់ហើយ ។

- យល់ដឹងប៉ុណ្ណឹងហ្ន៎ ! លោកបាល័ដ្ឋឆ្ងល់ ។

លោកសុភា បន្ថែមសេចក្តីថា :

- ខ្ញុំឮថាគាត់ទទួលដេញថ្លៃដេរខោអាវឱ្យប៉ូលិស ។ ប្អូនចាំមើលចុះ មុខតែគាត់យកសំពត់ផ្តេសផ្តាសមិនបានដូចគំរូទេ ។ គេនិយាយលាន់ថា តាប៉ិ **ហុងឈី** កំពុងដើររកទិញសំពត់បាតផ្សារកញ្ចាស់ៗ ផុយគគ្រក់យកទៅដេរ ដាក់ឱ្យរាជការហើយ ។ ហេតុនេះហើយបានជាគាត់ហ៊ានថ្លៃថោកជាងគេ ។

**ឌីយ៉ាខុង** រៀបនឹងហាមាត់ប្រាប់មិត្តអំពីរឿងដែលខ្លួនបានជួបនឹង អ្នកជំនួញទុច្ចរិតអម្បាញ់មិញនេះទៅហើយ ស្រាប់តែមាននារីពីរនាក់រូបស្អាតបាត ហើយតែងខ្លួនស្រស់បំប្រៃដើរចេញពីវត្តជិតទីនោះ នាំមិត្តទាំងទ្វេប្រាណ ឡប់ស្មារតីរវល់តែគយគន់ទៅវិញ។ លុះនាងក្រមុំបែរក្រោយផុតពីមុខទៅ នាម៉ឺនកំលោះភ្លេចរឿងដើមក៏នាំគ្នាពិចារណា ធៀបផ្ទឹមតែពីសោភ័ណភាពនៃ កញ្ញាដែលទើបតែបត់ចូលទៅក្នុងផ្ទះ ។

**នីយាវុធ** ដេកនទៀលរលាក់បើកភ្នែកភ្លឹស១ ព្រោះទ័លចំណេះ ក្នុងការស្វែងរកសេចក្ដីលង់លក់ពុំបាន ។ ប្រាក់៥០០រៀល ច្រកក្នុងស្រោម សំបុត្រដែល **ហុងឈី** បានប្រគល់ឱ្យមក ដោយកុហកថាជាសេចក្ដីអធិប្បាយពន្យល់នោះ ជះចំហាយក្ដៅដូចរងើក ភ្លើង។ ថ្វីបើសេចក្ដីសុចរិត សេចក្ដីស្លូត ត្រង់របស់បាល័ដ្ឋខេត្តថ្មី ពុំមានអ្វីនាំឱ្យសៅហ្មងដល់តួចមួយសោះឡើយ តែក្ដីទីទ័លក្រនាំបង្វិលខួរ អោយវវាតចិត្តពីផ្លូវត្រង់មួយភ្លែតដែរ។ " បើអញទទួលយកទៅ (អ្នកកំលោះជញ្ជឹងគិតតែក្នុងចិន្តា) ម៉្លេះសមអញនឹងសងជំពាក់ប្រាក់ ដែលបានខ្ចីពួកម៉ាកយកមកទិញប្រដាប់ប្រដាផ្សេង១បានរួចជ្រះស្រឡះ ។ រំពឹងលើប្រាក់ខែឯណាកើត ? បានត្រឹមតែ ៤៦រៀល កាត់ថ្លៃ បាយឈ្នួលផ្ទះ ថ្លៃ គុយទាវឈ្នួលបោកអ៊ុតខោអាវអស់ចេញមួយខែ១ នៅសល់មិនបាន៥រៀលផង " ។

ប៉ុន្តែ មានគំនិតមួយទៀតលេចធ្លោឡើង "បើអញទទួលយកសំណូកនេះទៅប៉ូលិស ដែលតែងទទួលបញ្ញត្តិឱ្យស្លៀកពាក់ខោអាវ នេះបានមួយឆ្នាំមុខ ជាវេទនាធំហើយ ។ ស្លៀកពាក់អោយជាប់យូរឯណាកើត បើផុយតាំងពីថ្មី ហើយ ។ ពីរខែមិនទាន់ទេ មុខជារហែក ខ្ទេច។ ត្រូវកុំភ្លេចថាគ្នាត្រូវដើរហាត់នឿយណាស់ ។ ឯកសណ្ឋាននេះ លុះត្រូវញើសត្រូវថ្ងៃត្រូវភ្លៀង ក៏កាន់តែអន្តរាយរហ័សទៅទៀត ។ ប៉ូលិសនោះម្នាក់១បានប្រាក់ខែតែ១២ រៀលទេ ។ បើមិនចង់ដើរផ្លូវទុច្ចរិតទេ មុខតែបង្អត់បង្អះប្រពន្ធកូនហើយទើបសន្សំប្រាក់មកកាត់ដេរ បន្លាស់ថ្មីបាន ។ គិតសព្វ១ទៅមិនត្រូវសប្បាយតែម្នាក់ឯង ហើយឱ្យមនុស្ស៥០០នាក់ទៀត រងវេទនាដោយសារខ្លួនឯងយ៉ាងនេះសោះ ឡើយ។ មួយទៀត ខ្លួនបានតាំងចិត្ត តាំងពីនៅក្នុងសាលាមកថាស្អប់ខ្ពើមអំពើពុក រលួយណាស់មិនគប្បីលះបង់ឧត្តមគតិខ្លួន តាំងពីដើម ទីយ៉ាងនេះទេ " ។

លុះបានសម្រេចចិត្តយ៉ាងនេះហើយ មន្ត្រីកំលោះក៏ធូរទ្រូងភ្លាម "ព្រឹកនេះអញនឹងហៅ **ហុងឈី** ឱ្យយកប្រាក់ចង្រៃ នេះទៅ វិញចុះ អញមិនត្រូវការទេ ! " ។ ដោយកំលាំងនៃសេចក្ដីពេញចិត្តនឹងខ្លួនឯងយ៉ាងនេះ **នីយាវុធ** ក៏កើតងងុយរកដំណេកភ្លាម ។ ដូច្នេះ ហើយក៏ទាញចង្កៀងប្រេងកាត"ផ្កាញ់ ព្យុះ"មកសង្កត់គន្លឹះបង្ហើបបំពង់កែវផ្លុំពន្លត់ទៅ ។ ប្រាសចាកពីកង្វល់បានកាលណា ចិន្តា អ្នកកំលោះ ក៏ផ្ដេកផ្ដោះទៅរកនាងវរមិត្តដែលព្រាត់ទៅទីឆ្ងាយ យូរខែហើយ ។ ព្រលឹងមាសបងអើយម្ដេចឡើយក៏បាត់ដំណឹងជ្រៀបយ៉ាងនេះ ?

## ៧

## ស្ថានការណ៍កាន់តែអ័ព្ទអួឡើង

តាំងពី **នីយាវុធ** បានប្រគល់ប្រាក់ ៥០០ រៀល ឱ្យ **ហុងឈី** វិញ ពីរខែបានកន្លងផុតទៅហើយ ។ ក្នុងពេលដែលចូលមក ជួបនឹងលោកបាល័ដ្ឋ លើកក្រោយនេះ ឈ្មួញទុច្ចរិតបានធ្វើមុខក្រមូវ ហាក់ដូចជាចង់និយាយថា " យី អានេះចំជាភ្លើមែន ! គេយកនំឱ្យស៊ី ហើយនៅមិនចេះស៊ីទៀត ។ មិនអីទេអា នាង ! ចាំមើលចុះគង់តែអញបានសម្រេចដូចប្រាថ្នាទេ " ។ តែ **នីយាវុធ** ដោយពេលនោះ ជាប់រវល់ការងារទៀតច្រើន ក៏ពុំបានចាប់អារម្មណ៍នឹងកិរិយា ព្រហើនកោងកាចនេះឡើយ ក្នុងចិត្តគិតថា មុខតែក្រុមប៉ូលិស និងបានសម្លៀក បំពាក់ធ្វើដោយសំពត់ស្វិត ហើយជាប់បានយូរដូចរាជការបានកំណត់ ហើយផ្ដល់គំរូមកជាមិនខាន ។

ថ្ងៃមួយក្នុងខែឧសភា គឺក្នុងពេលដែលអ្នកម៉ៅការជិតត្រូវយកឯក សណ្ឋានសេនា្យនុភាពប៉ូលិសមកជូនរាជការ ស្រាប់តែពូលង់តុង ចូលមកជំរាប លោកបាល័ដ្ឋថា ទានចៅហ្វាយខេត្តត្រូវការចង់ជួប ។ ដើម្បីតបនឹងសេចក្តីគោរពនៃសហការី "ប្របាទម្ចាស់" គ្រាន់តែងក់ក្បាល ហើយធ្វើមុខមាំដាក់ឱ្យ :

- **ទុំឆ ! ទុំឆ** ឯងជាប្រធានគណៈកម្មាការទទួលខោអាវប៉ូលិស ។ អាទិត្យក្រោយនេះគេនឹងនាំរបស់ទាំងនោះយកមកឱ្យពិនិត្យហើយ ។

ចៅហ្វាយខេត្តឈប់មួយសន្ទុះ ដូចជាគិតរកពាក្យសិន ។ ក្នុងការប្រាស្រ័យជាមួយអ្នករាជការក្រោមបង្គាប់ មន្ត្រីធំនេះមិនមែននិយាយថា " ខ្ញុំៗទេ ព្រោះយល់ថាហាក់ដូចជាបន្ទាបបន្ថោកខ្លួនពេក ។ ឥឡូវនឹងប្រើពាក្យ " អញៗ ក៏ដូចជាជួរគ្រោតគ្រើមពេកដែរ ។ ម្លោះហើយក៏ដាច់ស្រេចថា ត្រូវតែជៀសកុំនិយាយពាក្យទាំងពីនេះតែម្តង ។ ហាក់ដូចជាមានកិច្ចព្រមព្រៀងមួយដោយ ឥតចេញស្តីអ្នករាជការសាលាខេត្តតែងស្តាប់បានថា បើកាលណាក្នុងប្រសាសន៍ លោកចៅហ្វាយខេត្តគ្មានប្រធានក្នុងប្រយោគណាមួយទេនោះ ត្រូវបកស្រាយថា លោកចង់ថា ខ្លួនលោកប្រាកដហើយ " ។

មួយស្របក់ក្រោយមក " ប្របាទម្ចាស់ " និយាយថែម :

- .....បានពិនិត្យសាច់កំណាត់សំពត់រួចហើយ....ឃើញថាមិនខុលពីគំរូ រាជការប៉ុន្មានទេ....យល់ថា ស៊ីញ៉េទទួលយកបាន ។

- ទានប្រោស សំពត់ **ហុងឈី** មិនល្អទេ ផុយណាស់ក្រែងតែចៅ កែទិញសំពត់ផ្សេងៗ ហើយមានសាច់ស្វិតជាជាងដែលយកមកខ្ញុំប្របាទម្ចាស់ ពិនិត្យនោះពុំដឹង ។

- គ្មានកំណាត់ឯណាថ្មីទៀតទេ .....ឃើញថាគួរសមល្មមហើយ ។

- ទានប្រោស បើសំពត់កំផុយដដែលទេ ខ្ញុំប្របាទម្ចាស់មិនហ៊ានចុះ ហត្ថលេខាទទួលយកទេ ។

ព្រោកំហឹងចូលមកជ្រួតជ្រាប លោកចៅហ្វាយខេត្តព្រមានដោយមុខ ក្រញ៉ូវ :

- វុំធ ឯងខ្ចីសេចក្តីណាស់ ម្តេចក៏ក្អេងក្អាងដល់ម្លឹង !

- ទានប្រាសទេខ្ញុំប្របាទម្ចាស់យល់ឃើញថា បើព្រមទទួលរបស់ផុយ ពព្រិចយ៉ាងនេះទៅ មុខជានាំឱ្យខូចប្រយោជន៍រាជការផង ហើយខូចប្រយោជន៍ ប៉ូលិសផង ព្រោះមិនស្ថិតស្ថេរបានប៉ុន្មានថ្ងៃទេ ។

- ចៅហ្វាយខេត្តច្រឡោតតួង :

- យីក្មេងនេះ មាត់ពុំទាន់បាត់ធំក្លិនទឹកដោះផង ហ៊ានមកប្រដៅឯង ។ ទៅចុះមិនបាច់ជួបមុខយូរទៅទៀតទេ ។

ពីរម៉ោងក្រោយមក **ឌីយ៉ាទុំឆ** ក៏បានទទួលលិខិតបង្គាប់ឱ្យចេញ ត្រួតពន្ធដែលទារបានតាមឃុំនានា ក្នុងស្រុកបាកាន និងក្រគរ ។ បេសកកម្ម នេះទំរាំនឹងបំពេញរួចត្រូវលេបពេលអស់ពីរសប្តាហ៍យ៉ាងតិច ពោលគឺល្មមតែផុតថ្ងៃណាត់ដែល ត្រូវទទួលឯកសណ្ឋានប៉ូលិស ។ យ៉ាងនេះមែនហើយទើបមានដីការខេត្តមួយ តាំងលោកភូឈួយខេត្តជាអ្នកទទួលភណ្ឌទាំងអស់វិញ ជំនួស **ឌីយ៉ាទុំឆ** ដែលជាអ្នកមានសមត្ថភាពដោយយកលេសថាបាល័ដ្ឋនេះជាប់រវល់ទៅបំពេញមុខនាទីមួយយ៉ាងសំខាន់ ។ មានដំណឹងល្ហេចល្ហៀងថា ក្នុងរឿងខោ អាវប៉ូលិសនេះ " ប្របាទម្ចាស់ " បានជំនូន " មួយខ្នាស់ធំ " ពីសេចក្តី ដឹងគុណនៃ **ហុងឈី** ។ បើនឹកដល់រឿងនេះកាលណា បាល័ដ្ឋក៏ក្តៅក្រហាយតែ មិនធ្វើដូចម្តេចកើត ។

ក្នុងពេលដែល **ឌីយ៉ាទុំឆ** រងទណ្ឌកម្មដើរត្រួតនៅគ្រប់ឃុំ ក្នុងស្រុក បាកាន និង ក្រគរទាំងនេះ ព្រោះខ្លួនមិនព្រមទទួលសំណូក ៥០០រៀល ហើយ រឹងទទឹងមិនបណ្តោលឱ្យ នាយចៅហ្វាយបានលាភដោយធូរ ។

ស្ថានការណ៍ក្នុងសកលលោកកាន់តែធ្លាក់ដុនដាបទៅ ។ នៅទ្វីបអឺរ៉ុប កងទ័ពអាកាសនិងកងទ័ពរថក្រោះអាល្លឺម៉ង់ ទំលាយបាន ស្រួល១នូវការតស៊ូនៃកងទ័ពហូឡង់ បិលស៊ិក និងបារាំង ។ នៅឥណ្ឌូចិន ជប៉ុនឡើងចាងកាន់តែ ព្រហើន ហើយដាក់កម្រិតឱ្យគេឯងកាន់ តែធ្ងន់១ឡើង ។

ឯប្រទេសសៀម ដែលឈ្លៀវឈ្លាតរក្សាខ្លួនបានគង់វង្ស ឯករាជ្យ រហូតមកក៏ដើរការប៉ិនប្រសប់ក្នុងពេលនេះទៀត ។ គិតមើល ចុះតាំងពីរលាស់ខ្លួនចេញរួចពីចំណុះអាណាចក្រខ្មែរកាលណាមកសៀមចេះតែបានចំរើនរុងរឿងជានិច្ច ។ នៅទ្វីបអាស៊ីប៉ែកអាគ្នេយ៍ និង ខាងកើតមានតែសៀម និងជប៉ុនទេ ដែលចេះកាច់ចង្កូតគេចរួចផុតពីចំណើនៃមាត់ចក្រពត្តិនិយមរបស់បស្ចឹមប្រទេស ។ ដូច្នេះយើងមិន ត្រូវងឿងឆ្ងល់ទេ បើឃើញប្រទេសទាំងពីរនេះរួម គំនិតចែកហ៊ុនគ្នាដណ្តើមយកនូវឥណ្ឌូចិនទៀត ។ ដើម្បីសម្រេចគោលបំណងនេះសៀម បានត្រៀមរៀបចំជើងចែវតាំងពីចម្ងាយ ។

ដូច្នេះហើយ បានជានៅចុងខែមិថុនា គ.ស ១៩៣៩ នាយករដ្ឋមន្ត្រី សៀមបានប្រកាសថា ចាប់ពីថ្ងៃទី ២៤ ខែដដែលនេះតទៅ ប្រទេសសៀម ដែលជាប្រទេសហៅថា " ស្យាម ឬ សៃអេម " ត្រូវប្រែថា " ថៃឡង់ដ៏ " វិញ ។ ចំពោះខ្លួនឯងវិញ សៀមក៏បន្លឺហៅថា " ប្រថេតថៃ " ត្រង់នឹងពាក្យខ្មែរថា " ប្រទេសថៃ " ។

គោលបំណងក្នុងការកែប្រែឈ្មោះយ៉ាងនេះ គឺមានគំនិតកំបាំងចង់លេបប្រទេសលាវ និងភូមិខ្លះក្នុងដែនតុងកឹង ដែលជាទីលំនៅ របស់ប្រជាជនពូជអម្បូរថៃដែរព្រមទាំងប្រទេសកម្ពុជាទៀតផង ។ ថ្វីបើខ្មែរយើងពុំជាប់ពូជ ពង្សអ្វីនិងថៃ ឬឡាវទាល់តែសោះតែសៀម យកសំអាងថា កាន់សាសនាដូចគ្នា និយាយភាសាស្រដៀងគ្នា ដូច្នេះសៀមក៏សម្លឹងម៉ក់១ ឃ្លាំឱកាសនឹងស្ទុះមកប្របាក់ពាំយកកម្ពុជាទាំង មូលតែម្តង ។

នៅថ្ងៃទី ១២ ខែមិថុនា គ.ស ១៩៤០ រដ្ឋសភាសៀមបានធ្វើសច្ចាប័ន ចំពោះកត្តិកាសញ្ញាមិនឈ្លានពានគ្នារវាងបារាំងថៃ ។ អត្ថបទនេះបានផ្តល់អត្ថ ប្រយោជន៍ដល់ប្រទេសសៀមសំខាន់គ្រាន់បើដែរ ដូចជាសម្រេចថាបង្ខិត ព្រំដែន សៀម-លាវ រហូតមកដល់ខ្សែ ភាគជ្រៅនៃទន្លេមេគង្គជាដើម ។ ប៉ុន្តែដោយឃើញថា ក្នុងពេលនោះបារាំងបរាជ័យចាញ់អាល្លឺម៉ង់ ហើយលែងមានពីសពុលអ្វីទៀតនៅ ភូមិភាគចុងបូពាប្រទេសសៀម ក៏រើទាមទារថ្មីទៀតដូចជា យកទន្លេមេគង្គជាបន្ទាត់ព្រំដែនរហូតក្នុងអាណាខេត្តលាវ ។ បើបារាំងព្រមឱ្យ សេចក្តីទាមទានោះមែន សៀមត្រូវលែងដែនដីលាវដែលនៅចំពីមុខក្រុងហ្លួង ព្រះបាង និងប៉ាក់សេ ។

មិនត្រឹមតែប៉ុណ្ណេះឡើយ នៅក្នុងខែសីហា យន្តហោះសៀមបាន លួចរំលោភមកបាចខិតប័ណ្ណលើដែន កម្ពុជាទាមទារយក ខេត្តបាត់ដំបង និងសៀមរាបថែមទៀត ។ វិទ្យុនិង កាសែតបាងកកព្រុសឡូង១នូវពាក្យត្មេះតេះ ដៀលដល់បារាំងដែលអាល្លឺម៉ង់ វាយ បាក់លោងទៅហើយ ។ ដូចបានពណ៌នាមកហើយ **ឪយាឌុឩ** ជាអ្នកឧស្សាហ៍អានកាសែត ហើយស្តាប់វិទ្យុយកពត៌មានណាស់ ។ អំពើ កំណាចរបស់សៀមតែងនាំឱ្យនាម៉ឺនកំលោះ ក្តាន់ក្តាញ់ពន់ប្រមាណ ។ ហេតុតែនៅក្មេងហើយមានឧត្តមគតិបរិបូណ៌ដោយសេចក្តីសុចរិត ស្លូតត្រង់ តាមដំបូន្មានសីលធម៌បានសិក្សានោះ ទើបចៅមាណពយើងនៅពុំទាន់យល់ថា ចរិយាសាស្ត្រដែលគ្រូអាចារ្យប្រៀន ប្រដៅមាន ប្រយោជន៍តែមួយមុខ គឺគ្រាន់តែធ្វើឱ្យយុវជនមានអំពល់ប៉ុណ្ណោះ ។ ឯអ្នកកាច់ចង្កូតប្រទេសដែលមានឫទ្ធិ មានអំណាចវិញប្រកបដោយ កិរិយាដូចចោរហនេយ្យំសុទ្ធវិស័យ ។ ឱ្យតែបានឱកាសចុះក៏ស្ទុះទៅសស្រ្តប់ក្រញីអ្នកតូចជាងខ្សោយជាងហើយប្លន់ដណ្តើមយកទឹកដី គេ តែម្តង ។

ក្នុងពេលដើរទស្សនាការតាមឃុំនានាដូចបានទទួលបង្គាប់មក **ឪ យាឌុឩ** តែងទំពាអៀងនូវសេចក្តីក្តៅក្រហាយពីរយ៉ាងខឹង មួយនឹងចៅហ្វាយ នាយស្តីបន្ទោសទាំងទទឹងទិស ហើយខឹងមួយទៀតនឹងប្រទេសសៀមដែលខ្លួន រាប់អានជាមិត្តយ៉ាងស្មោះអស់ពីពោះ បែរជាចង់ទាមទារចំណែកផ្តាច់ខេត្តជាទីស្នេហា និងជាទីគោរពពីមាតុភូមិខ្លួនថែមទៀតកំលាំងកំហឹងនេះបាននាំឱ្យ លោក បាល័ដ្ឋ គិតសុំលា

ពីមុខតំណែងបច្ចុប្បន្ន ។ នេះនៅពុំបានទទួលផងនូវ ដំណឹងមួយទៀតសំខាន់លើសលុបដែលរង់ចាំខ្លួនឯងផ្ទះឯណោះ ។ ក្រោយដែលបានដេកដើរ ឯស្រុកស្រែអស់ ១៧ ថ្ងៃមក ល្ងាចមួយនាម៉ឺនកម្លោះក៏បានត្រឡប់មកផ្ទះពូ **ហ៊ឹង** មីង **ភ្នាត់** វិញ ។ លុះបានមុជទឹកជំរះកាយស្រួលបួលហើយ ទីឃាវុធក៏ចាប់រើបាច់សំបុត្រ និងកាសែតដែលប្លុងតុសាលាខេត្ត បានយកមកផ្ញើទុកឱ្យនឹងមីង **ភ្នាត់** ។ **ទីឃាវុធ** បានសង្កេតអក្សរនៅលើ ស្រោមសំបុត្រមួយដែលស្គាល់ជាក់ជាអក្សរ **ទេគី** ជាមិត្តស្និទ្ធរបស់ខ្លួន ។ **ទេគី** បានបោះបង់កិច្ចសិក្សាដំណាលគ្នានឹង **ទីឃាវុធ** ដែរ ហើយបានមកសុំ ធ្វើការនៅក្រុមសម្ងាត់ ។ គ្រាន់តែចាប់សំបុត្រនោះភ្លាម ក៏ហាក់ដូចជាមានបុព្វវិញ្ញាណក្ខ័ន្ធមួយមកអង្រួនឱ្យនាម៉ឺនកំលោះរន្ធត់ញាប់ញ័រដោយបារម្ភ។ អារម្មណ៏ថប់ព្រួយក៏ក្លាយជាការពិត ត្បិតសេចក្ដីសំបុត្រនោះនាំឱ្យ **ទីឃាវុធ** រោលរាលអន្ទះអន្ទែងក្នុងខ្លួនក្រៃលែង ។

ដោយមិនទាន់អស់ចិត្ត **ទីឃាវុធ** លើកសារកំណាចមកអានថ្មីម្ដង ទៀត ដោយផ្ចិតផ្ចង់ ។ **ទេគី** បានសរសេរថា : សំឡាញ់ដូចឯងបានស្ដាប់ឮតាមវិទ្យុ ឬអានដឹងក្នុងកាសែតស្រាប់ហើយ ប្រទេសសៀមកំពុងឆ្លៀតឱកាសក្នុងពេលបារាំងអន្ទកាល ដើម្បីវាតអំណាចរំលោភមកលើដែនដីខ្មែរ និង ឡាវ ។ មិនគួរធ្វើយ៉ាងនេះសោះ ! ប្រទេសដែល យើងទុកជារៀមច្បង បែរជាចង់ត្របាក់ប្អូនតូចៗមើលតែត្រីឆ្កៅតែម្ដង ។ ប៉ុន្តែគិតសព្វៗទៅគ្មានអ្វីគួរឱ្យឆ្ងល់បានទេ ដូចជាមានប្រវត្តិសាស្ត្រជាសក្ខីភាពស្រាប់ហើយ ។ **សុរិន្ទ គោរាភខណ្ឌ បុរីរម្យ ច័ន្ទ បុរី** សុទ្ធតែជាភស្តុ តាង ឥតលុបទៅណាបានទេ ចំពោះការស្រេកឃ្លានរបស់ប្រទេសនេះ ។

សំឡាញ់អើយ ប្រទេសជិតខាងមានគំនិតទុច្ចរិតយ៉ាងនេះយូរយារ ណាស់មកហើយ ។ គេដើររកកលឧបាយ គេល្បិតជិតល្អណាស់បានជាខ្ញុំថាដូច្នោះ ព្រោះមានការមួយ ដែលក្រុមសំងាត់បានស៊ើបអង្កេត ហើយទទួលពតិមានយ៉ាងជាក់ច្បាស់ ។ ការនេះទាក់ទងមកលើខ្លួនឯង ហើយថ្លើមប្រមាត់ឯងមិនល្បៀងទេ ។

លោក **ទេព្យកោសល្ល** ពិតជានាយទាហានសៀមមែនតែគាត់មិន បានភៀសខ្លួន ដោយជាប់ចោទថា បានរួមគំនិតជាមួយពួកបះបោរធ្វើរដ្ឋប្រហារទេ ។ គាត់ជាចារបុរស ដែលបន្លំធ្វើជាអ្នកភៀសខ្លួនក្នុងពេលមានកលិយុគ ដើម្បីមកលួចស៊ើបដំណឹងនៅប្រទេសយើង ។

ក្នុងពេលចុងក្រោយនេះ គាត់បានយកញញឹមកូនស្រីគាត់ដែលភ្លឺ ចិញ្ចាចដូចអរុណរះ ដើម្បីឧបករណ៏រំលាយដួងចិត្តយុវជនយើងប្រយោជន៏ ស៊ើបការឱ្យបានលទ្ធផលកាន់តែប្រសើរឡើង កាលពីរ៉ាកងខែមុននេះយើងបាន ជូនគាត់ដើរលេងក្នុងខេត្តសៀមរាប គាត់ឆ្លៀតឱកាសនោះដើរថតវាលកប៉ាល់ហោះ និងបន្ទាយទាហាន ។ ខ្ញុំមិនបន្ទោសឯងទេ ប៉ុន្តែត្រូវយើងប្រយ័ត្នប្រយែងខ្លួនទៅថ្ងៃមុខទៀត ។ តាមសង្កេតមើលទៅនារីសៀមអាចប្រៀប បានទៅនឹងផ្កាប្រភេទខ្លះ ដែលមានទ្រង់ទ្រាយយ៉ាងល្អ មានក្លិនយ៉ាងក្រអូប សំរាប់ជានុយឱ្យឃ្មុំឬសត្វល្អិតមកចោមរោមហើយក្ដោបត្របកត្រសោបចាប់ សត្វទាំងនោះ ហើយរំលាយជាអាហារទៅ ។

ស្រីចង្រៃ.....ស្រីកាឡកិណ្ណី....ស្រីថ្លើមខ្មៅ.....យ៉ាងនេះមែនឬអី ? ចិត្តឆ្លើយភ្លាមថា មិនមែនទេ ! ពុំមែនទេ ត្បិតអីកិរិយានាងទន់ភ្លន់យ៉ាងនេះ សេចក្ដីស្នេហ៍ត្រង់យ៉ាងនេះ មិនសមនឹងមានគំនិតអាក្រក់លាក់លៀមបានឡើយ ។ ឯឪពុកសោតក៏គួរសំគាល់បានថាជាអ្នកមានចិត្តធមិ ចិត្តភក្តី ឥតវេរបានទេ ។ **ទីឃាវុធ** អន្ទះអន្ទែងវិលវល់ក្នុងសេចក្ដីសង្ស័យ ហើយបំរះឯកោក្នុងគ្រែមួយ ដែលមានសភាពដូចជាក្រាលនូវបន្លាដែលចាក់សាច់មុតពេញខ្លួនរកផ្អៀង ទៅខាងណាក៏ពុំផុតរំខានបានឡើយ ។ ដោយធ្លាប់អានសៀវភៅ និងមើលកុន ហើយដោយនឹកដល់រឿងម៉ាតាហារី ក្នុងសង្គ្រាមលោកលើកទី១ បាល័ដ្ឋកំលោះ ក៏មានអារម្មណ៏មួយភ្លែត ។ គេថា ពួកចារបុរសឬចារនារីប្រសប់លាក់គំនិតណាស់ ក្លែងធ្វើឫកពាឱ្យឯងភ្លេចខ្លួន ។ អីចឹងមែនហើយហ្ន៎ ! នាងចារនារី **ចន្ទមណី** ជាបុត្រីចារបុរស **ទេព្យកោសល្ល** វិចិត្រករ ។

ក្រុមសម្ងាត់ធ្វើការម៉ត់ចត់ល្អណាស់ មិនងាយចោទព្រាវៗកើតទេ ។ មួយទៀត **ទេគី** គឺជាមិត្តស្និទ្ធស្នាលរបស់ខ្លួនមានការណ៍ស្ងាត់កំបាំងយ៉ាងណា ពុំលាក់លៀមនឹងគ្នាឡើយ។ ឯ **ឪឃាទុធ** ធ្លាប់បាននិយាយប្រាប់សំឡាញ់ថា ខ្លួនចាប់គួចស្នេហានាង **ចន្ទមណី**។ ទាល់តែច្បាស់ការណ៍ប្រាកដណាស់ ហើយ ទើបមកហ៊ានមករំលាយបេតីដ៏ធំទូលាយរបស់ខ្លួន ។ ពិតជាក្រុមចោរ កម្មទាំងឪពុកទាំងកូនមែនហើយ ទើបឥឡូវលែងឱ្យដំណឹងមកសោះ ។ ខ្លួន អើយខំស្រឡាញ់គេបង់ចិត្ត ! ឥឡូវគប្បីរកវិធីកែខ្លួន សងសឹកសេចក្តីស្នេហាថ្លាបរិសុទ្ធ ដែលមានមនុស្សពាលយកមកឈ្លីលេងជាល្បែង ។

មួយទៀតខ្លួននឹងទ្រាំធ្វើការនៅពោធិ៍សាត់ទៅទៀតក៏ពុំកើតដែរ ។ ចៅហ្វាយនាយស្អប់ខ្លួនហើយ មុខជាគេនឹងគុំរករឿងផ្លាស់ចេញពុំខាន ដើម្បីចាំទទួលលាភក្រៅរាជការដោយឥតមាននរណាថាចាំជំទាស់ ។

តាំងពីដើមខែកញ្ញាមក **ឪឃាទុធ** បានស្ម័គ្រចិត្តចូលធ្វើទាហាន ។ ដូចសាមីខ្លួន បានគ្រោងទុកជាមុន លោកចៅហ្វាយខេត្តអរណាស់ ដោយប្រទះ ឃើញយ៉ាងងាយៗនូវមធ្យោបាយគាស់បំបាត់មនុស្សទាស់មុខទាស់មាត់យ៉ាងនេះ ។

រាជការទាហានបានបញ្ជូនអ្នកកម្លោះយើង ឱ្យមកហាត់ហ្វឹកហ្វឺននៅបន្ទាយមាសក្នុងខេត្តកំពង់ឆ្នាំង ។ ភូមិរមាសជាទីប្រជុំជនសំខាន់មួយតាំងនៅ លើផ្លូវរថភ្លើងទៅបាត់ដំបង។

ដោយសារសេចក្តីធ្ងិតធ្ងង់ ព្រោះជាកិច្ចបន្ទប់ទុក្ខផង ហើយជាវិធានការអាចឱ្យខ្លួនបានអាសាបំរើជាតិមាតុភូមិ ដោយកំលាំងផង **ឪឃាទុធ** បានហាត់ក្នុងអំឡុង ៣ ខែក៏ចេះ យ៉ាងជំនាញក្នុងក្បួនទាហាន ។ ក្នុងថេរវេលា ដដែលនេះស្ថានការណ៍កាន់តែធ្លាក់ដុនដាបទៅរកបុថុជ្ជន និងគ្រោះថ្នាក់ ។

នៅចុងខែកញ្ញា សៀមបានបង្កឆាកបង្កើតឧប្បត្តិហេតុ កាន់តែញឹក ញាប់ឡើងតាមដងទន្លេមេគង្គក្នុងដែនប្រទេសឡាវ ។ ការលបវាយឆ្មក់គ្នាក៏ ក្លាយជាការបៀតបៀនពេញទំហឹង។ ក្រុមសេនាធិការបារាំង បានបញ្ជូនទ័ពពីតុងកឹងមកផ្តុំគ្នានៅភូមិភាគ សេរីសោភ័ណព្រមទាំងបញ្ជូនទាហានខ្លះទៀតមានទាំងបារាំង ទាំងកងអាសាបរទេស ហើយពួកយួនធ្មេញខ្មៅផង មកពង្រាយជាក្បួនការពារសន្តិសុខតាមព្រំដែនខ្មែរ-សៀម និងនៅត្រើយខាងឆ្វេង ទន្លេមេគង្គនៅប្រទេសឡាវ ក្នុងពេលតែមួយនោះ កងទ័ពសៀមដែលសម្បូរ ទៅដោយយុទ្ធភណ្ឌ បានលើកចូលមករុករាន អាណាខេត្តលាវនៅត្រើយខាងស្តាំទន្លេ ។ ប៉ុន្តែទោះបីជាខំខ្នះខ្នែងដូចម្តេច ក៏មិនទាន់ឡើងមកត្រើយខាងកើតបានឡើយ ។

លុះចូលមកដល់ក្នុងខែវិច្ឆិកា ស្ថានការណ៍កាន់តែល្អក់ខ្វល់ បណ្តាលបារម្ភណ៍គ្របសង្កត់ទ្រូងប្រជាជនគ្រប់គ្នា ។ ខែធ្នូ ១៩៤០ បានឃើញឧប្បត្តិហេតុ ដែលមានកាន់តែញឹកញាប់ឡើង ក្លាយទៅជាសង្គ្រាមមួយពេញលក្ខណៈ ។ បើខាងសៀមធ្វើមកយ៉ាងណាខាងបារាំងក៏សងយ៉ាងនេះទៅវិញភ្លាម ។ គឺនៅពេលនេះហើយ ដែលកងឯកភាពរបស់ **ឪឃាទុធ** បានទទួលបង្គាប់មកផ្តុំ ក្នុងបរិវេណសេរីសោភ័ណដែរ ។

ដោយកាលមុនបានបង្ហោះបង្ហៀរយកសំភារៈជាច្រើនទៅច្បាំង ឯអឺរ៉ុបកងទ័ពបារាំងនៅឥណ្ឌូចិនទាំងមូល មានតែរថក្រោះ ១៥ យន្តហោះប្រដេញ សញ្ញា ម៉ូរ៉ាន ១៤ យន្តហោះប្រេតេ ៤ សំរាប់ទំលក់គ្រាប់បែក ព្រមទាំងយន្ត ហោះបូតេសបួន ដប់ទៀត ។ ឯរថក្រោះ ១៤ គ្រឿងនោះចាស់រេចរឹលណាស់ ទាល់ឱ្យបរដោយកម្លាំងយន្តខ្លួនឯងពុំកើតទៅហើយ ។ ម៉្លោះហើយត្រូវលើក យកទៅដាក់បន្តំជិះលើឡានកាម៉្យុង។ នេះគឺជារឿងអាខ្មាក់អាខ្មិនទំនើបថ្មី ព្រោះពេលរំលងផុតយូរមកហើយក៏គួរអស់សំណើចដែរ តែក្នុងសម័យនោះខ្មែរ គ្រប់រូបក្នុងភូមិភាគបាត់ដំបង សៀមរាប ភ័យខ្នែកស្លន់ស្លោនៅលើថ្ងាស ។

តាំងពីថ្ងៃ ២៧ វិច្ឆិកា មក កងទ័ពអាកាសថៃ ចាប់ទំលាក់គ្រាប់បែក លើទីក្រុងនានាក្នុងដែនឥណ្ឌូចិន មានថាខេត្ត និងសុវណ្ណខេត្ត (ស្ទឹងខេត្ត ) ជា ដើម ។ ពីរថ្ងៃក្រោយមក សៀមរាបបានផ្តាច់គមនាគមន៍ដោយវិទ្យុ និងទូរស័ព្ទ ហើយនៅថ្ងៃទី ២ធ្នូ

អគ្គរាជទូតសៀម ប្រចាំប្រទេសបារាំងបានដើរចេញពីក្រុង វីស្ស៊ី ជារាជធានីបណ្តោះអាសន្នរបស់បារាំង ដោយយកលេសថាត្រូវធ្វើដំណើរ ។

ក្រុមសេនាធិការបារាំង ក៏ខំប្រមែប្រមូលទាហាន និងយោធា មធ្យោបាយដែលសេសសល់មកផ្តុំនៅកន្លែងណា ដែលអាចរងគ្រោះថ្នាក់មុនគេ។ នៅថ្ងៃទី ២៨ ធ្នូ សៀមបានចិត្តកាន់តែហ៊ានខ្លាំងឡើងបានលើកចូលមកវាយប៉ុស្តិ៍ភេលេង (ឥឡូវហៅក្លាយជាប៉ៃលិន) ដោយចេញមុខ ។

ឆ្នាំ គ.ស ១៩៤១ បានផ្តើមឡើង ដោយឃើញទ័ពសៀមចូលបៀត បៀនពេញទំហឹង ។ នៅថ្ងៃទី ៨ មករា បច្ចាមិត្តចូលមកដុតបំផ្លាញបន្ទាយទាហានក្រុមរក្សាស្រុកនៅប៉ោយប៉ែត ហើយកងទ័ពអាកាសគេព្រហើនហោះមក ទំលាក់គ្រាប់បែក **នៅក្រុង សេរីសោភ័ណ មង្គលបុរី បាត់ដំបង ស្ទឹងត្រែង** បណ្តាពលរដ្ឋខ្មែរចាស់ ក្មេង តូចធំ ដែលឥតមានទាក់ទងក្នុងរឿង នេះសោះស្លាប់បាត់បង់ជីវិតអស់ច្រើននាក់ ព្រោះតែសេចក្តីឈ្នានិះ និងលោភោ ។ ថ្ងៃទី ៩ និង ទី ១០ ខែដដែល ក្រុងសៀមរាបក៏ទទួលសេចក្តីវិនាសពីលើអាកាសយ៉ាងដំណំណាស់ដែរ ។ ក្នុងថ្ងៃលើកក្រោយកងយន្តហោះប្រដេញ បារាំងបំផ្លាញយន្តហោះទំលាក់គ្រាប់បែកសៀម បានមួយគ្រឿង។ ចំណែកកងអាកាសយានបារាំងវិញ ដោយមានមធ្យោបាយស្តួចស្តើងពេក ហ៊ានទៅលួចព្យាបាទដែនបច្ចាមិត្តតែក្នុងពេលយប់ងងឹត ។

បារាំងបានផ្តុំទ័ពនៅពីមុខក្រុងសេរីសោភ័ណក្រាស់ក្រែលគ្រាន់បើដែរ ព្រោះមានបំណងចង់វាយចូលដែនខ្មាំងតាមប៉ោយប៉ែត **អរញ្ញ** ។ ដើម្បីឱ្យផែនការនេះបានប្រកបដោយជោគជ័យ កងនាវាក៏ទទួលបង្គាប់ដើរឧបាយកល បញ្ឆោតធ្វើកិរិយាហាក់ដូចជានឹងនាំទ័ពទៅឡើងគោកត្រង់តំបន់ **ចន្ទបុរី**។ ហេតុនេះហើយ បានជាមានការប្រយុទ្ធគ្នានៅកោះចាងក្នុងឈូងសមុទ្រសៀម នៅថ្ងៃទី ១៧ មករា ។ ក្នុងឱកាសនោះ កងនាវាបារាំងដែលមាននាវាពិឃាដ **ឡាម៉ុតពីកេ** ជាមេកន្លោង បានបំផ្លាញ និងពន្លិចនាវាពិឃាដសៀមអស់បីគ្រឿង ហើយនាវាយាមឆ្នេរសមុទ្រមួយទៀតត្រូវរបួស។ សរុបសេចក្តីទៅ ៤0 ភាគរយនៃមធ្យោបាយជើងទឹករបស់សៀម ត្រូវខ្ទាតចេញពីការប្រយុទ្ធ ។ ចំណែកខាងនាវាបារាំងវិញ ថ្វីបើយន្តហោះសៀមដេញតាមទំលាក់គ្រាប់បែក តែបានគេចខ្លួនរួច ឥតមានរខិតអ្វីដល់តិចតួចមួយឡើយ ។

ជ័យជំនះមានឡើងតែក្នុងទឹកទេ ប៉ុន្តែនៅលើគោកវិញ វាសនានៃអា វុធពួកឥណ្ឌូចិន ពុំបានភ្លឺថ្លាដូចយ៉ាងនោះឡើយ ។ នៅថ្ងៃទី ១០ មករា កងទ័ព សៀម បានឆ្លងព្រំដែនមកវាយប៉ុស្តិ៍សំរោង (សៀមរាប) ហើយនៅយាងដង្កំ និងក្បាលក្របី (ប៉ោយប៉ែត) ។ នៅថ្ងៃទី ១៦ ដែលជាថ្ងៃកំណត់របស់ក្រុម សេនាធិការបារាំងថា នឹងលើកទៅវាយកំចាត់កងទ័ពសៀមមិនដឹងខ្លួននោះបែរ ជាថ្ងៃបរាជ័យទៅវិញ ។ ក្រុមសេនាធិការសៀម ដោយមានពួកចារបុរសស៊ើបបានដឹងច្បាស់ជាមុន បានប្រុងប្រៀបខ្លួនជាស្រេច ។ នៅថ្ងៃនោះ ចាប់ពីម៉ោង ៣ ទៀបភ្លឺ កងទ័ពបារាំងបានចេញពីទីតាំងធម្មតាទៅពួនបង្កត់ខ្លួនតាមជួរដងព្រៃ ។ គ្រានោះ ព្រិន្ទបាល **ឌីយ៉ាទុជ** បានទទួលបង្គាប់ផ្នែករបស់ខ្លួនទៅចាំ ស្ទាក់ត្រង់ច្រក កូនអូរមួយ។

ក្នុងរាត្រីស្ងាត់ ដែលមានពន្លឺផ្កាយបង្ហាញរាងនូវវត្ថុទាំងឡាយយ៉ាងស្រពិចស្រពិល កងទាហានបានលបចូលទៅកាន់លេណដ្ឋានថ្មីដែលបានជីកទុក ប្រចាំការពីថ្ងៃមុន ដោយប្រុងប្រយ័ត្នប្រយែងមិនឮសូរប្រិបព្រួបសោះឡើយ។ ទីទុយ និងចង្រិតដែកយំម្តងៗនាំឱ្យសីតុណ្ហភាពដែលនៅចន្លោះមានភាពណែនក្តន់ណាស់ទៅទៀត។ ពួកទាហានមុជក្រាបហើយនៅនឹងខ្លួនថ្កល់អាវុធគងលើត្រង់ស្នេប្រចាំការភ្នែកដៅសំលឹងទៅទីតាំងថៃ ដែលនៅត្រង់មាត់ព្រៃម្ខាង វាលចំងាយប្រហែល ២00 ម៉ែត្រ ។ ទឹកចិត្តរីកថ្លាកង ទាហានខ្មែរសង្ឃឹមថាម្តងនេះមុខជាជោគជ័យបើកឡើងហើយ ដើម្បីសងសឹកជូនជនរួមជាតិ ដែល បានបាត់បង់ជីវិតដោយស្នាដៃខ្មាំង ។

មនោសញ្ចេតនាបែបនេះបានធ្វើឱ្យឱរា **ធិយាទុធ** ក្តៅជាងពួកម៉ាក ដទៃទៀត ព្រោះខ្លួនត្រូវសងសឹកពីរជាន់ គឺមួយចំពោះជាតិដែលមានសត្រូវមកភាតត្បាត ហើយមួយទៀតចំពោះឧត្តមគតិសេចក្តីស្នេហា ដែលមានជនអបលក្ខណ៍មកញាក់ញីឈ្លានជើង ។ លុះនឹកដល់សេចក្តីសំបុត្ររបស់ **ទាគី** ដែល បានបើកបង្ហាញឱ្យឃើញនូវគំនិតអាក្រក់ របស់ជនដែលខ្លួនលើកជាមិត្ត ឬជាឆ្នើមត្រួយចិត្តកាលណាឡើង អ្នកកំលោះយើងក៏ក្តាប់កាំភ្លើងដោយកំហឹង ហើយប្រុងតម្លោះកៃបាញ់ទៅលើបច្ចាមិត្តដែលគ្មានរូប ។ ឱនាយ **ទេពគោសល្ល** និងនាង **ចន្ទមណី** ! បើអ្នកឯងទាំងពីរនាក់ហ៊ានបង្ហាញខ្លួនក្នុង គ្រានេះ មុខជាអ្នកឯងគ្រោះជួជក់ធំហើយ ។

ម៉ោង ៥ ទៀបភ្លឺកាំងភ្លើង ៧៥ ម.ម ចំនួន ១០ ដើមដែលជាសំណល់ បាតឃ្លាំង បានចាប់បាញ់ក្អួងៗ បំផ្លោងទៅខាងមុខប្រយោជន៍ជារនាំងឱ្យទា ហានថ្មើជើងរុលទៅរកខ្មាំង ។ ឯ " អាខ្វាក់អាខ្វិន " ដែលបានយកមកប្រើនៅ ទីនោះចំនួនប្រាំគ្រឿងនឹងគេក៏ងក់កាត់ ជញ្ជាំងស្រែចូលបាញ់នឹងគេដែរ ។

មធ្យោបាយខ្សត់ខ្សោយយ៉ាងនេះនឹងយកជោគជ័យបាន តែកាលណា ខ្មាំងគ្មានប្រដាប់យ៉ាងនោះ ឬមួយពុំបានដឹងខ្លួនត្រៀមការទុកជាមុនផង ។ តែស្ថានការណ៍ពុំមែនយ៉ាងនោះសោះឡើយ ព្រោះជប៉ុនបានផ្តល់ឱ្យទ័ពសៀមនូវយោធបរិក្ខាយ៉ាងឆើតៗ ហើយក្រុមសេនាធិការ សៀមសោតក៏បានទទួលរាយការណ៍ពីចារបុរសយ៉ាងច្បាស់ៗ អំពីផែនការកំបាំងរបស់បារាំង ។ ដូច្នេះសៀម ចាត់ការសម្រាប់តបតនឹងការវាយលុកបានជាស្រេច ។ ដោយសំងាត់ សៀមបានប្រមូលរថក្រោះ នឹងកាណុងយ៉ាងក្រាស់ក្រែលមកលាក់ទុកក្បែរកន្លែងដែលស៊ើបការណ៍ដឹងថា បារាំងប្រុងនឹងវាយទម្លុះ ។ សៀមពុំក្អក ពុំគ្រហែមទេ ទុកឱ្យកាណុងព្រុសតាមចិត្តដើម្បីឱ្យឱកាសសំគាល់ ទីតាំងកាំភ្លើងធំទាំងនេះ ។ កាណុងបារាំងបាញ់ពុំមានប្រសិទ្ធភាពអ្វីសោះ ព្រោះសៀមបានដឹងខ្លួនដកទាហានទៅទីតាំងមួយថ្មី ឃ្លាតពីដើមបន្តិច ។ សៀមពុំមាត់ពុំកអ្វីសោះ ទុកឱ្យទាហានខាងបារាំងរុលចូលសងកាំភ្លើងរបស់ខ្លួន ។ លុះបានទីហើយកាណុងសៀមក៏បាញ់ផ្ទឹងស្រោចមកលើកាណុងបារាំង ឯកាំភ្លើងយន្តសៀមក៏បាញ់រះជះគ្រាប់ដូចព្រិល ។

គ្រាប់កាំភ្លើងធំសៀមហោះជ្រែកអាកាសរយទាំងពាន់ បញ្ចេញសំលេងរំវែងគ្រលួច បន្ទាបខ្លួនចុះបំបែកមែកឈើ ហើយស្ទុះមកបុកដីជះបំណែកពិឃាតទៅគ្រប់ទិស ។ ក្នុងៗរថបន្ទុកបារាំង "អាខ្វាក់អាខ្វិន" បារាំងដោយ គ្រាប់ធ្លាប់ចំពីលើ ក៏ផ្ទុះកំចាយបំណែកបណ្តាលឱ្យប្រេងសាំងឆេះហុយទ្រលោម ។ ឯកាណុងបារាំងសោតទៀតក៏ចូលក្នុងវិនាសកម្មក្នុងយ៉ាងឆុតឆាប់ ព្រោះបច្ចាមិត្តគេមានចំនួនលើសលប់មកចោមព្រួតបំផ្លាញ ប៉ុន្តែថ្វីបើធ្លាក់ក្នុងស្ថានការណ៍ចាញ់ប្រៀបខ្មាំងយ៉ាងនោះក៏ដោយ កងទាហានខ្មែរស៊ូក្រាញ់នៅនឹងកន្លែងមិនព្រមដកខ្លួនថយទេ ។

លុះឃើញថា កាណុងបារាំងស្ងាត់មាត់លែងបាញ់ហើយ សៀមក៏ឈប់ដែរ ។ ក្នុងពេលនោះលេចឮសូរយន្តខ្ទ័រកក្រើកដី ។ កងរថក្រោះរគើមចេញពីមាត់ព្រៃម្ខាង មកព្រុសភ្លើងបែបនាគរាជក្នុងរឿងសស្ត្រាស្លឹករឹត ។ ម៉ុងៗកាំភ្លើងរថក្រោះបាញ់ស្រោចមកលើទាហានខ្មែរ ដែលក្រាបនៅស្មៀមចាំល្មមដល់ប្រយោលនឹងយកកាំភ្លើងយន្តបាញ់ត ។ ក្នុងពេលនោះបារាំងពុំមានកាណុង សំរាប់បាញ់រថក្រោះទេ ដូចនេះទាហានតាំងបំបែរបំពុងកាំភ្លើង សំរាប់បាញ់ យន្តហោះ តំរង់មកលើអណ្តើកដែកទាំងនោះវិញ ។ ចាត់ការដូចនេះជាមធ្យោបាយយុទ្ធជនសោះ ព្រោះគ្រាប់កាំភ្លើងបាញ់យន្តហោះមិនអាចទំលុះផ្ទាំងដែកក្រាស់បានឡើយ ។ ឱកម្មក្រាស់ពេក ក្នុងពេលដែលទាហានថ្មើរជើង កំពុងជាប់ដៃខាងក្រោម ស្រាប់តែយន្តហោះលាបសញ្ញាទង់សៀមហោះចេញ ពីជុំពពកមានបាញ់រះមកចោលគ្រាប់ បែរកក្រើករំពើកទាំងពសុធា ។

ទាហានខ្មែរខំតស៊ូដោយមធ្យោបាយស្ទួចស្តើង មានទំនងដូចកូនកាន់ ចង្កឹះទៅតាមដេញវាយយក្សា ។ ថ្ងៃរះពេញពន្លឺចោលរស្មីទៅលើវិការដ្ឋានមួយ ដែលបរិបូរណ៍ដោយឈាមហូរដេរដាស និងសេចក្តីវិនាសយ៉ាងឆុតឆាប់ ។

ដោយទាហានបាញ់កាំភ្លើងយន្ត នៅក្បែរខ្លួនត្រូវគ្រាប់ ហើយមាន លោហិតហូរពពុសស្គុលចេញពីមាត់ **ធីយ៉ាឌុង** ក៏ស្ទុះទៅបាញ់ជំនួស។ គ្រាប់កាំភ្លើងព្រួសចេញពីមាត់ ត្រែក្រហមដោយក្តៅហើយធ្លាក់បីដូចគេបាចទៅលើស្បែកគ្រាស់នៃរថក្រោះ ឧបមាដូចជាតំណក់ទឹកភ្លៀងធ្លាក់លើខ្នងទា ដែលកំពុងដើរ ។ អណ្តើកយន្តចេះតែបោលសំរុកជិតមក១ **ធីយ៉ាឌុង** ចេះតែ សង្កត់កៃបាញ់គ្មាននឹកនាដកខ្លួនមកឡើយ ស្រាប់តែឮសូរភ្លឹប ញ័រខ្លួនខ្វាក ហើយងងឹតមុខជ្រប់ដួលទ្រេតទៅលើមាត់លេណដ្ឋាន ......។

## ៨

## ស្រលាញ់ជាតិបង្វាបស្នេហា

ក្រុងអរញ្ញប្រះថេត ( អរញ្ញប្រទេស ) ឬដែលហៅដោយខ្លីថា **អរញ្ញ** ជាទីប្រជុំជនតូចមួយតាំងនៅក្នុងដែនថៃជិតព្រំដែនខ្មែរ ។ មានផ្លូវដែក និង ផ្លូវ ថ្នល់ភ្ជាប់ទីក្រុងនេះទៅបាងកក ។ ដូចទីក្រុងឯទៀត ដែលនៅក្បែរព្រំដែនក្នុងពេលដែលសាន្តត្រាណសកម្មភាព នៅអរញ្ញបានរីកចំរើន តែដោយរបររត់គយមួយមុខ ។ តាំងពីសង្គ្រាមរវាងថៃ-បារាំងនៅ ឥណ្ឌូចិនបានផ្ទុះឡើងកាលណា **អរញ្ញ** ក៏ក្លាយជាទីសំណាក់ដ៏ភាគច្រើននៃជនពាក់ឯកសណ្ឋាន ។

ដោយឃើញថាអរញ្ញ នៅជិតរណសិរ្សក្រុមសេនាធិការសៀមបាន លើកអគ្គការសំខាន់ផ្សេង១មកតាំងនៅទីនេះ ។ នៅវត្តមួយឆ្ងាយពីផ្សារបន្តិច រាជការបានកេណ្ឌយកសាលាធំ សម្រាប់និមន្តព្រះសង្ឃឆាន់ មករៀបតុបតែង មន្ទីរពេទ្យរះកាត់បណ្តោះអាសន្ន ។

នៅថ្ងៃទី ១៦ មករា បុគ្គលិកមន្ទីរពេទ្យមានសេចក្តីភ្ញាក់ផ្អើលខុសពីធម្មតា ។ តាំងពីទ្បេបភ្លឺមកកាណុងឆ្លងឆ្លើយគ្នាពុំដាច់សូរសោះ ។ បន្ទាប់មកយន្តហោះប្រដេញ និងយន្តហោះចូលលុករវាង ៥០ គ្រឿង ហើរកាត់ឆ្ពោះ ទៅសមរភូមិ ។ មន្ទីរពេទ្យនេះមានដុកទ័រសក្តិប្រាំជាមេ ហើយដុកទ័រស័ក្តិបីពីរ នាក់ទៀតជាអ្នកជំនួស ។ គិលានុបដ្ឋាយិកា ១៥ នាក់ ដែលសុទ្ធតែជានារីស្ម័គ្រចិត្តចាំបំរើការក្រោមបង្គាប់ស្រីម្នាក់ជាមេធំ ។ ក្នុងពពួក **មាណវី** ស្លៀកពាក់សទាំងនោះ យើងបានជួបឡើងវិញនូវយុវតីម្នាក់ដែលធ្លាប់ស្គាល់មកហើយ ។

នាង **ចន្ទមណី** កាលណានាងឃើញថាម្តាយនាងបានធូរស្រាលហើយ នាងក៏បានសុំអនុញ្ញាតពីអ្នកដ៏មានគុណទាំងពីរដើម្បីស្ម័គ្រចិត្តចូលហ្វឹកហ្វឺនជាគិលានុបដ្ឋាយិកា ព្រោះនាងយល់ថា ការថែអ្នករបួសក្នុងពេលមានសង្គ្រាមជាអំពើកុសលផង ហើយជាឱកាសបំពេញករណីកិច្ចចំពោះជាតិផង ។ មួយទៀតកាលណាយើងមានការធ្វើ យើងតែងបំភ្លេចបាននូវកង្វល់ និងទុក្ខព្រួយបើមិនបានទាំងអស់ក៏គង់បានភាគខ្លះដែរ ។ នាងពុំមានចូលចិត្តឱ្យកើតសង្គ្រាមទេ ។ តើធ្វើដូចម្តេចបើអ្នកគ្រប់គ្រងប្រទេសនេះបាននាំមាតុភូមិឱ្យរមៀលចូលក្នុងភ្នក់ភ្លើងយ៉ាងនេះទៅហើយ ។ នាងយល់ថាគប្បីពលរដ្ឋទាំងឡាយបំពេញករណីកិច្ចតែរៀង១ខ្លួន ។

ក្នុងពេលនាងចូលបំរើជាតិតាមស្ត្រីភេទ ចិន្តានាងប្រមើលដោយវិតក្កដោយភ័យព្រួយ ចំពោះទំហំមុខរង្វះនៃជ្រោះកំណាច ដែលធ្វើឱ្យនាងឃ្លាតឆ្ងាយពីគូសង្សារ ។ ដើមដំបូង នាងបានសរសេរសំបុត្រជូនពតិមានក្បោះក្បាយ ដល់មិត្តនៅស្រុកខ្មែរ ។ ប៉ុន្តែតាំងពីរាជការទាំងសងខាងចាត់ឱ្យមានក្រុមត្រួតពិនិត្យកាលណាមក នាងខំទប់ចិត្តសរសេរតែយ៉ាងខ្លី១ ហើយតមកទៀតក៏ឈប់សរសេរសោះតែម្តង ។ មិនមែនថា នាងដាច់អាល័យទេ ។ នាងស្ងួតស្ងប់គិតមកគូសង្សារកំលោះគ្មានលោះពេលសោះឡើយ ។

ក្រោយពេលនាងបានហាត់រៀន ខាងព្យាបាលអ្នករបួស និងថែរជំងឺ បាន ៣ ខែមក គឺនៅពេលដែលស្ថានការណ៍បានចោទចំហាយកាន់តែក្តៅឡើង រាជការក៏ចាត់ឱ្យនាងមកធ្វើការប្រចាំមន្ទីរពេទ្យអរញ្ញ ។ មិនបានប៉ុន្មានថ្ងៃចំបាំងក៏ឆេះសន្ធោសន្ធៅបណ្តាលឱ្យមានរបួសមានស្លាប់មានអ្នករងទុកគ្រប់យ៉ាង ។

ដោយឃើញប្រទេសទាំងពីរ ដែលត្រូវរួបរួមដោយចំណងភាតរភាព ព្រោះមានសាសនាដូចគ្នា មានប្រពៃណីដូចគ្នាមានសិល្បះនិងវប្បធមិដូចគ្នា បែរប្រខាំគ្នាញក់ញីគ្នាដល់ម្លេះ សេចក្តីស្អប់ខ្ពើមសង្គ្រាមដែលតែងមានស្រាប់ មកហើយក្នុងចិន្តានាង ក៏កាន់តែរីកធំឡើងទៀត ។ ស្នេហាថ្លៃថ្លាដែលហប្ញទ័យ នាងបានអោបក្រសោបទុក បានបិទផ្លូវមិនឱ្យនាងយល់សោះថា ហេតុដូចម្តេចបានជាមនុស្សលោកចំបាច់ត្រូវការស៊ីសាច់គ្នាដូចសត្វតិរច្ឆាន ។ ប៉ុន្តែវិសាល ភាពនៃធមិនេះហួសកំលាំង ហួសនិស្ស័យគំនិតរបស់នាង ដូច្នេះនាងស៊ូទ្រាំបំពេញមុខងារជាករណីកិច្ចដោយស្ងប់ស្ងៀម ។

នៅរសៀលថ្ងៃទី ១៦ មករា កងរថយន្តពេទ្យបានផ្ទុកអ្នករបួសមក ឱ្យមន្ទីរពេទ្យវះកាត់ក្នុងវត្ត ។ កងកាកបាទក្រហមថៃប្រមូលរើសយកពុំថា ទាហានរបួសជាតិសៀម ឬទាហានសហព័ន្ធឥណ្ឌូចិនទេ ។ ព្រោះទាហានខាងគេ ចេះតែមានថ្មីដៃជឿនទៅមុខដរាបគេចាប់បានពួកត្រូវរបួសខាងបារាំងបាន យ៉ាងក្រាស់ក្រែល ។ រវាងបីម៉ោងមកហើយ រថយន្តកាកបាទក្រហមបានជញ្ជូន អ្នករបួលមកប្រគល់ឱ្យមន្ទីរពេទ្យក្នុងវត្ត ។ ទាំងពេទ្យធំ ទាំងសហការីកានី បានវះកាត់ដាក់ថ្នាំឬរុំរបួសឥតបានឈប់ដៃបានឡើយ ។ តាមធម្មតាមន្ទីរពេទ្យ នេះគ្រាន់តែចាត់ការសើ១បណ្តោះអាសន្នតែប៉ុណ្ណោះ ព្រោះពុំមានឋបនភ័ណ្ឌអ្វីមាំមួនទេ ។ ដោយហេតុដូច្នេះហើយបានជារាជការសឹក បានចាត់ឱ្យមានខ្សែរថ ភ្លើង ពិសេសមួយសម្រាប់ដឹកអ្នកដំណើររាល់ថ្ងៃទៅថៃរទាំនៅមន្ទីរពេទ្យធំ១នា ក្រុងបាងកកទៀត ។

តាំងពីថ្ងៃត្រង់មក ពេទ្យធ្វើការពុំបានឈប់សំរាកទេ ។ ឥឡូវម៉ោង ៥ រសៀលហើយ ពួកអ្នករបួសក៏ស្បើយចំនួនទៅដែរ ។ បុគ្គលិកចាប់ផ្តើម សង្ឃឹមថា បន្តិចទៀតបានឈប់សំរាកហើយ ។

ក្នុងគ្រានោះនាង **ចន្ទមណី** បានរុំរបួសឱ្យទាហានម្នាក់រួចក៏ចេញមក យកអាកាសត្រង់មាត់ទ្វារសាលា។ មួយសន្ទុះក្រោយមករថយន្តខ្វែងជើងក្អែក ក្រហមមួយមកឈប់ត្រង់មាត់ជណ្តើរ ។ គិលានុបដ្ឋាយិកាពីរនាក់ស្ទុះទៅបើក សន្ទះខាងក្រោយ ហើយនាំគ្នាសែងចុះនូវបុរសម្នាក់ ដែលដេកស្តូកស្តឹងពុំដឹងខ្លួន ។ ថ្វីបើអ្នកសន្លប់នោះ មានក្បាលរុំស៊ោងពោងមានមុខ និងឯកសណ្ឋានប្រឡាក់ឈាមជោកនាងគ្រាន់តែចោលភ្នែកមួយភ្លែតក៏ញ័របេះដូងព្រួយរន្ធត់ ។ យីម្តេចអីចឹង ? ច្រឡំភ្នែកទេដឹង !

ទាំងថប់ព្រួយអួលផ្សា នាងដើរតាមពួកអ្នកសែងអ្នករបួសចូលក្នុងបន្ទប់វះកាត់ ។ នាងដឹងថា កាលនោះរាជការខាងឥណ្ឌូចិនបានបញ្ជាញឱ្យទាហានទាំងឡាយពាក់ខ្សែដៃស្ពាន់សគ្រប់១គ្នាប្រដាប់ដោយកូនបន្ទះមួយដែល មានចារដាក់ឈ្មោះ ដើម្បីងាយស្គាល់នាមក្នុងឱកាសមានគ្រោះថ្នាក់ជាយថាហេតុ ។ ដើម្បីឱ្យអស់ពិភាល់ នាងទាញដៃស្តាំអ្នករបួសសន្លប់មកមើលឈ្មោះ ។ គ្មានសង្ស័យទៀតទេ ! នៅលើបន្ទះស្ពាន់សមានឆ្លាក់អក្សរបារាំងថា " ព្រិន្ទ បាលទោ **ទីឃាវុធ** លេខប្រចាំខ្លួន ១៣.៣៣៩ " ។

ញ័រខ្លួនចំប្រប់ នាងខំទប់មិនឱ្យទឹកភ្នែកជោរជល់ ហើយហូរចេញមកបានដោយថ្នាក់ថ្នមដៃ គ្រូពេទ្យសក្តិប្រាំបានចាប់លាប៉ង់សឺម៉ង់ក្បាល ដែលគិលានុបដ្ឋាយិកាបានរុំជាបណ្តោះអាសន្ននៅទីប្រឡូកគ្នា ។ លុះបានពិនិត្យហើយ លោកដុកទ័របានថ្លែងថារបួសនេះសើរ១

ទេ ព្រោះត្រូវនឹងអំបែងគ្រាប់កាំភ្លើង ដែលជះមកពីចំងាយ ។ បន្ទាប់មកគ្រូពេទ្យចាប់ដោះអាវហើយគយគន់មុខ របួសធំមួយត្រង់ឆ្អឹងជំនីទៀតដុកទ័រយកក្រមាមសង្កត់ទើបលាន់មាត់ថា :

- យីបាក់ឆ្អឹងជំនីអស់ពីរ តែមិនដឹងជាប៉ះពាល់ដល់គ្រឿងក្នុង ឬដូចម្ដេចខ្លះ ។ មុននឹងយកទៅឆ្លុះវិទ្យុឆាយាកម្មត្រូវចាក់ឈាមបញ្ចូលសិន។

ថាហើយក៏បង្គាប់ទៅស្ត្រីមេគិលានុបដ្ឋាយិកា ឱ្យយកបំពង់កែវមកបឺតឈាមអ្នករបួស ដើម្បីធ្វើវិភាគមើល ដែលជាហេតុឱ្យដឹងថា លោហិតគេ ជាប់ក្នុងប្រភេទអក្សរណា ។ ១៥នាទីក្រោយមក នាងព្យាបាលចូលមកជំរាបលទ្ធផលវិញ ។

- ឈាមពួកអក្សរ " យ " ទាន ។ ខ្ញុំបានរកសព្វគ្រប់អស់ហើយ ឈាមស្រស់ប្រភេទអក្សរនេះ អស់រលីងគ្មានសល់បន្តិចសោះ ។

គ្រូពេទ្យនៅស្ងៀមមួយស្របក់ទើបសួរថា :

- ពួកគ្នាយើងដែលបានចុះឈ្មោះស្ម័គ្រចិត្តបំរុងឱ្យឈាមនោះ តើមាន នរណាជាពួកអក្សរ " យ " ដែរឬទេ ?

នាង **ចន្ទមណី** ដែលឈរផ្ទាំងដូចភ្លេចព្រលឹង ព្រោះសេចក្ដីព្រួយបារម្ភមកសង្កត់ណែន ក៏ភ្ញាក់ខ្លួនព្រើតដោយឮសំនួរនេះ ។ នាងឆ្លើយថា :

- ខ្ញុំលោក ឈាមខ្ញុំអក្សរ " យ " ដែរ ។ លោកត្រូវការប៉ុណ្ណាក៏ អញ្ជើញយកចុះ ឱ្យតែបុរសនោះបានផុតពីគ្រោះថ្នាក់ ។

ការបើបានទទួលឈាមពីនាងដល់ក៏រិត អតិបរមាដែលនាងអាចបាន ធ្វើអំណោយបានរួចហើយ អ្នករបួសដែលពីមុនស្លឹតស្លាំងដូចទេសឯកនោះ ឥឡូវប្រែសំបុរហាក់ដូចជាមានជីវភាពឡើងវិញ ។ គ្រោះធំដែលនាំឱ្យនាងតក់ស្លុតក៏ចំហុតនេះ បានធ្វើនាងត្រេកអរមួយយ៉ាងដែរ ព្រោះនាងបានឱកាសដ៏ប្រសើរយកឈាមនាងទៅជួយទ្រទ្រង់ដោយផ្ទាល់នូវជីវិតបុរសមួយដែល នាងលើកជាកំពូលនៃចិត្តនាង ។ នាងឆ្វេងយល់ដោយព្រឺព្រួចជាបេះដូងទាហានខ្មែរ បានយោគយោលបូមឈាមក្នុងសេរីរាង្គកាយដែលមានឈាមរបស់នាង លាយជាមួយដែរ ។ ការឆ្លុះវិទ្យុក៏បានបង្ហាញឱ្យឃើញថា គ្មានធ្លុះធ្លាយ ឬ ប៉ះពាល់ដល់គ្រឿងសំខាន់អ្វីទេ ។ ប៉ុន្តែដោយមុខរបួសនោះធំពេកហើយដោយខាតបង់ឈាមក្រាស់ក្រែលផង អ្នករងគ្រោះថ្វីបើបានទទួលថែទាំយ៉ាងមុតមាំនៅតែមិនទាន់ដឹងខ្លួននៅឡើយ ។

នៅពេលនោះខ្សែរថភ្លើង ដែលត្រូវដឹកអ្នករបួសយកទៅថែរក្សានៅមន្ទីរពេទ្យធំនាក្រុងបាងកក បានទទួលចំណុះពេញក៏ចេញដំណើរផុតទៅហើយ ។ ដូច្នេះពេទ្យក៏រៀបចំ ដំណេកដ៏សមគួរ ដល់អ្នករបួសណាដែលទើបមកដល់ ក្រោយគេសំណាក់សិន ។ កាលៈទេសៈនេះពេញចិត្តនាង **ចន្ទមណី** ណាស់ ព្រោះនាងនឹកថា ជាឱកាសនាំឱ្យនាងបានថែទាំមិត្តបានយូរពេលទៅទៀត ។

លុះនាងបានងើបពីអស់កំលាំង ដោយគេបានបឺតឈាមនាងបញ្ចូល ទៅឱ្យគូកំសត់របស់នាងហើយ នាងក៏ផ្ចិតផ្ចង់សួររកដំណឹងភ្លាមពីអ្នករបួស ។ មិត្តនារីម្នាក់ឈ្មោះ **សុមជិត្ត** ( សមចិត្ត ) បានឆ្លើយថា :

- កុំព្រួយថ្វីបង **ចន្ទមណី** ។ ទាហាននោះបានឡើងសំបុរស្រស់ឡើងវិញហើយ ឥឡូវនេះក៏ចាប់ដឹងខ្លួនបន្តិច១ផង ។ លោកគ្រូពេទ្យសក្ដិប្រាំ មានប្រសាសន៍ថា ក្រែងតែមានប្រែប្រួលចំឡែកយ៉ាងណាក៏មិនដឹង ។ បើពុំ នោះទេអាចនឹងក្រោកដើរបានក្នុងអំឡុង ៣ អាទិត្យទៅមុខទៀត ។

នាង **ចន្ទមណី** ទទួលដំណឹងនេះដោយត្រេកអរណាស់ ។ នាង ញញឹមអរគុណ **សុមជិត** ដែលសួរនាងបន្ថែម :

- បងប្រហែលធ្លាប់ស្គាល់អ្នករបួសនេះហើយ បានហាក់ដូចជាឈឺ ឆ្អាលដោយមានចិត្តខុសសព្វដង ។

- នាង **ចន្ទមណី** តបនឹងសំនួរនេះដោយស្មោះត្រង់ :

- ប្អូនអើយ កាលដែលខ្ញុំទៅលេងស្រុកខ្មែរ ខ្ញុំបានជួបបុរសចិត្តជានេះ ឯង នាំមើលស្រុកទេសជាមួយឪពុកខ្ញុំ ។

- បន្ទាប់មកនាង **ចន្ទមណី** ក៏អធិប្បាយរៀបរាប់អំពីអនុស្សាវរីយ៍ពី ប្រទេសកម្ពុជា ឱ្យសហជីវិនីនាងស្ដាប់ ។

សូរគោះទ្វារទីប១ ហើយសម្លេងស្ត្រីហៅរន្ថើនតែទាំងព្រួយ :

- លោកគ្រូពេទ្យទាន លោកគ្រូពេទ្យ ។

បន្តិចក្រោយមក ទើបឮសម្លេងបុរសឆ្លើយមកដោយជាប់ទាំងសេចក្តីងងុយមក ផង !

- អ្នកណា ! មានការអ្វី ?

- ខ្ញុំ **សុមជិត្ត** នារីឆ្លើយ ។ អ្នករបួសខ្មែរឈ្មោះ **ឆិយាខុឆ** នោះ សន្លប់បាត់ស្មារតីទៀតហើយ ហើយកំដៅខ្លួនឡើងដល់៤០អង្សារ ។

ចេញពីបន្ទប់ដំណេកទាំងសឹងម៉ឹង ពេទ្យសក្តិប្រាំក៏ដើរខ្លួនទោរទន់ ដោយអត់ងងុយ ឆ្ពោះទៅកាន់សាលាអ្នករបួស ។ ខាងក្រៅអាកាសត្រជាក់នៃអាធ្រាត្រជះស្រោចមកលើរាងកាយធ្វើឱ្យស្វាងងងុយបន្តិច ។ គ្រូពេទ្យយកដៃញីភ្នែក ហើយដកបង្ហើមស្រូបយកកម្លាំងពីត្តិកាល ។

ក្រោមពន្លឺសន្ទោសន្ទៅនៃគោមឆ្លុះបញ្ចាំង ដុកទ័រតាំងឱ្យនាងព្យាបាលចាប់បង្វិលខ្លួនអ្នករបួស ។

- យី មុខដំបៅឆ្អឹងជំនីរហើមច្រើនជាងមុនហើយគុំខ្ទុះផងតើ ។ ត្រូវ តែដឹកយកទៅក្រុងថេបភ្លាម១ទើបបាន ។ ធ្វើម្តេចទៅហ្ន៎ ! បើរថភ្លើងពេទ្យចេញផុតទៅហើយ ។ បើចាំជិះរថភ្លើងធម្មតាដែលចេញម៉ោង៩ ព្រឹកនោះដូចជាយូរពេក ។

ឈប់មួយសន្ទុះ គ្រូពេទ្យក៏អធិប្បាយជូនសហការីស្តាប់ថែមទៀត ។ ប្រដាប់វិទ្យុឆ្លុះយើងតូចពេក ចាស់ពេកទើបឆ្លុះមិនបានល្អិតល្អន់ បណ្តាលមាន ហេតុយ៉ាងនេះ ។ ដូចនេះត្រូវគិតដូចម្តេចបានដល់ទៅក្រុងថេបដោយរួសរាន់ ។

ក្នុងពេលនោះ **ចន្ទមណី** ដែល **សុមជិត្ត** បានទៅដាស់ហៅមកដែរ បានចូលមកដល់ហើយឮសូរសំដីខាង ក្រោយនេះទើបនាងស្នើរសុំថា :

- កាលពីម្សិលមិញ ឃុន **ឆ** ខ្ញុំបានបើករថយន្តមកលេងនឹងខ្ញុំ ។ បើខ្ញុំសុំអនុញ្ញាតលោកដឹកអ្នករបួសនេះ ទៅក្រុងថេប ដោយឡានផ្ទាល់ខ្លួនបានទេ ?

មន្ទីរពេទ្យសេនារក្ស នៅវិថីរាជទេវី ជារោងព្យាបាលមួយប្រកបដោយអគារមានក្បាច់ក្បូរបែបជាន់ចាស់នៅអឺរ៉ុប ។ សំណង់នានាតាំងនៅដាច់១ពីគ្នាដោយថ្នល់ ដោយលានស្មៅដោយស្រះ ឬ ដោយកសិន បាននាំមកសេចក្តីស្ងប់ដល់អ្នករបួសទាំងឡាយ ដែលទទួលថែទាំនៅទីនោះ ។

ក្នុងអគារមួយត្រង់ជាន់ខាងក្រោម ដែលមានគ្រែស១ ចំនួនសាមសិប តម្រៀបជាពីរជួរ **ឆិយាខុឆ** ដេកសន្ធឹងសន្ធៃសម្លឹងមើលពិដានធ្វើភ្នែកធ្លឹះ១ ។ លើកូនតុមួយដាក់ជិតក្បាលដំណេក បាច់ផ្កាកុលាបដាស្រស់ចំប្រប់ បង្ហាញឱ្យឃើញថា ក្នុងទីក្រុងខ្មាំងដែលខ្លួនរសាត់មកដល់នេះ នៅមានជនសប្បុរសដែរ ដែលទាក់ចិត្តដល់ជីវិតខ្លួន ។

ក្រោយពេលពេទ្យបានវះទម្លាយមុខដំបៅ បង្ហូរខ្ទុះចេញ ហើយចាក់ថ្នាំគ្រប់យ៉ាង ជីវិតទាហានខ្មែរកម្លោះនេះ ដែលត្រូវជាប់តែប៉ុនសរសៃសក់ទៅហើយ ក៏ស្រវាចាប់បានបន្តិចម្តង១ នៃឫសកែវនៃសង្សារវត្ត ។

នាង **ចន្ទមណី** លោក **ទេព្យកោសល្ល** ព្រមទាំងភរិយា និង ប្អូនឯទៀតបានយកចិត្តទុកដាក់មកសួរសុខភាពអ្នករបួស ព្រឹកល្ងាចពុំលស់ថ្ងៃទេ។ ថ្នាំណាដែលពេទ្យគ្មាន តែដែលមានលក់នៅផ្សារងងឹតតំលៃយ៉ាងខ្ពស់នោះ លោក **ទេព្យកោសល្ល** ចាត់ឱ្យទិញឥតរុញរាទេ ធ្វើដូចម្តេចឱ្យតែមិត្តកំលោះ នេះបានរំដោះផុតពីភ័យ ។

ក្រោយពេលដែល **ទីឃាវុធ** ចាប់ដឹងខ្លួនឡើងវិញហើយ នាង **ចន្ទមណី** បានសង្កេតឃើញថា កាលណានាងមកសួរម្តងៗ មុខអ្នកជំងឺនេះ ឡើងក្រហមទុំខាំមាត់ក្រឹតៗ ដោយក្រោធខឹងខ្លាំង ហើយបែរភ្នែកចេញពុំមើលចំនាងទេ ។ ដោយឃើញហេតុយ៉ាងនេះច្រើនដង នាងក៏ហាក់យល់ថា គួប្រចាំចិត្តខឹងនឹងនាង ព្រោះប្រកាន់សេចក្តីស្នេហាជាតិ ។ នាងគិតឃើញថា មនោសញ្ចេតនាបែបនេះ ជាវត្ថុធម្មតាទេ ដូច្នេះហើយទើបនាងមិនប្រកាន់ខឹងតបតវិញឡើយ ។ ធ្វើម្តេចប្រទេសទាំងពីរ បែរជាខ្មាំងនឹងគ្នាហើយខ្លួនកំលោះនោះ សោតក៏ត្រូវរបួសយ៉ាងដំណំដោយស្នាដៃទាហានថៃជាតិរបស់នាងទៀតផង។ តាំងពីនោះមកនាងពុំសូវមកញឹកញាប់ពេកទេ ព្រោះយល់ថា គប្បីបុរសនេះ ជាសះស្បើយមែនទែនសិនសឹមពន្យល់ឱ្យដឹងច្បាស់ ។ ក្នុងពេលនេះចង់និយាយឱ្យអស់សេចក្តីទៅពុំទាន់បានក្រែងលោកញ្រោលខឹងខ្លាំង បែរជាធ្លាក់ឈឺធ្ងន់ ទៀត ។

កន្លះខែក្រោយមក **ទីឃាវុធ** បានគ្រាន់បើមែនទែន ក៏ដើរតិចៗ ចេញមកខាងក្រៅអង្គុយលើជើងម៉ាមួយ យករំរហើយមើលរស្មីព្រះអាទិត្យ ដែលលាតសន្ធឹងលើផែនស្មៅ កាត់ស្មើ ហើយដែលស្រមោលម្លប់ល្ងាចកំពុងរុញ ច្រានកាន់តែរួញខ្លីទៅៗ ។ ឮសូរជើងខ្សាកៗ មកពីចំហៀងម្ខាង **ទីឃាវុធ** ក៏ងាកទៅឃើញនាង **ចន្ទមណី** ស្លៀកពាក់កៈប្រូង (រ៉ូប )ពណ៌ផ្ទៃមេឃលំអរដោយជ័រពណ៌សនៅត្រង់ក និងដៃ ។ នាងដើរចូលមកដោយញញឹមពព្រាយ ។ ដៃនាងកាន់បាច់ផ្កាក្លួយម៉ាយ (អរគីដេ) ពណ៌កុឡាបព្រមទាំងក្មេងស្រីម្នាក់ កាន់កញ្ចប់វេចដោយសំពត់មួយដើរមកតាមផង ។ បង្វិចនោះជាសណម មានចំណី ឬផ្លែឈើដែលជាវត្ថុបំរុងសម្រាប់អ្នកជំងឺ ។

**ទីឃាវុធ** ក្រោកឈរភ្លាមមុខក្រញូវតបនឹងនារី ដែលអោនខ្លួនលើកដៃសំពះយ៉ាងទន់ភ្លន់ ។ នាងរៀបនឹងផ្តើមមាត់ចរចារ ស្រាប់ឱ្យតែបន្ទោស បោកបោះទាំងគ្រើមៗ ហើរចេញពីមាត់បុរសខ្មែរ :

- ល្អហើយនាងចារនារី ខ្ញុំធ្លាក់មកកណ្តាប់ដៃនាងហើយ ។ យកទៅសំលាប់តែម្តងទៅល្អជាង កុំបាច់មកញញឹមលលួង ធ្វើអ្វីទៀត ខ្ញុំគ្មានការសម្ងាត់ អីនឹងប្រាប់ទេ ។ មួយជីវិតខ្ញុំចាញ់បោកនាងឯងតែម្តងបានហើយ ។

ថាហើយដើរចេញក្រេស ពុំចោលភ្នែកមើលធិតាល្អស្រស់ ដែលទឹក នេត្រាហូរស្រប់ភក្រ្តា ។

## ៩

## សន្តិភាពតូក្យូ

តាំងពីបរាជ័យថ្ងៃទី១៦ មករា គឺបរាជ័យដោយខ្វះមធ្យោបាយ និង ដោយកេត្យានុភាពស្តួចស្តើងពេក តែដោយពុំមែនយុទ្ធជនយើងខ្វះវិរកម្មទេ តាំងពីថ្ងៃនោះមកព្រឹត្តិការណ៍កាន់តែដើរលឿនរន្ថើនឡើង ។

ទ័ពសៀមច្រានទ័ពឥណ្ឌូចិន ហើយវាយកាត់ព្រំដែនចូលលុកមកបាននៅច្រើនតំបន់ទៀត ។ ព្រោះឃើញកូនសំពាយគាត់បានប្រៀបដូច្នេះ នៅថ្ងៃទី ២០ មករា គ.ស ១៩៤១ ម៉ាសៀកន្ឡើក៏តាំងស្នើរតាំងខ្លួនជាអាជ្ញាកណ្តាល ។ ដើមដំបូងបារាំងមិនព្រមទេ ហើយទទូចចង់និយាយផ្ទាល់នឹងសៀមតែម្តង ព្រោះគិតឃើញថា គ្មានអ្វីគួរទុកចិត្តព្រឺក្រកន្ឡើបានសោះឡើយ ។ ប៉ុន្តែដោយ ឃើញស្ថានការណ៍របស់ខ្លួនកាន់តែទន់ខ្សោយជាលំដាប់រាល់ថ្ងៃ ពួកភ្នែកសក៏សង្កត់ចិត្តលេបសេចក្តីខ្មាសហើយព្រមថានឹងទំលាក់អាវុធឈប់តស៊ូ ចាប់តាំងពីថ្ងៃទី ២៨ មករា តទៅ ។

" ក្របីស៊ីស្រូវបងមិនសូវហានដេញ ក្របីដើរចេញបងដេញស្រីមើល " ។

ក្រុមសេនាធិការសៀមដែលយកទំនុកច្រៀងនេះ ជាឧត្តមគតិ ឬជាក្បួនយុទ្ធសាស្ត្រ តាំងពីចាប់ផ្តើមវាយខ្មែរ និងលាវ ក៏បញ្ជាយន្តហោះទំលាក់ គ្រាប់បែកគគ្រឹកគគ្រេងនៅសៀមរាប និងសេរីសោភ័ណក្នុងថ្ងៃទី ២៥ និង ២៧ មករា ព្រោះនៅម៉ោង ១០ ព្រឹកថ្ងៃស្អែក ប្រតិបត្តិការសឹកទាំងឡាយក៏ ត្រូវផ្អាកឈប់ទាំងអស់ ។

នៅថ្ងៃទី ២៩ អ្នកតំណាងខាងបារាំង និងសៀមចាប់ជួបចរចាគ្នានៅ លើនាវាកោះជប៉ុនឈ្មោះ " ណាតុរិ " ដែលបោះយុទ្ធថ្កាចតនៅកំពង់ព្រៃនគរ ។

៣ ថ្ងៃក្រោយមក ការផ្អាកបាញ់ក៏បានចុះហត្ថលេខា ដោយមាន កំណត់ពេល ១៥ ថ្ងៃគិតពីថ្ងៃ ២៨ មករា តទៅ។ ដូច្នេះការផ្អាកបាញ់នេះ ត្រូវផុតអាយុនៅថ្ងៃទី ១១ កុម្ភៈ។ គូខ្មាំងទាំងសងខាងមានកាតព្វកិច្ចរក្សាជួរ ក្បាលទ័ពត្រឹមបន្ទាត់ប្រទល់យោធា នៅថ្ងៃទី ២៨ មករា ។

លុះបានសម្រេចគ្នាយ៉ាងនេះហើយ បារាំង និង សៀម ក៏នាំគ្នាទៅចរចាសន្តិភាពនៅក្រុងតូក្យូរាជធានីជប៉ុន ។ ក្នុងគ្រានេះជប៉ុនតាំងខ្លួនអាប៊ីត្រ ជាមជ្ឈត្តករ បើកឱកាសឱ្យកូនសំពាយរបស់ខ្លួន បំផ្លើសការទាមទារពីបារាំង ។ ខ្លាបាក់លោងនេះ គ្រហឹមញេញមាត់ដែលអត់ចង្កូមសោះ ។ តែបងចចកពុំមានញញើតខ្លាចដល់តូចមួយឡើយ គិតពីលោតមកប្របាក់ដុំភ្លៅទាំងពីរ គឺខ្មែរ និង ឡាវ ។ កិច្ចចរចារនេះទាក់ទងដល់ជីវិតកម្ពុជរដ្ឋមែនពិត តែខ្មែរយើងពុំមានសិទ្ធចូលជជែកនឹងគេទេ ព្រោះយើងមិនទាន់បានឯករាជ្យនៅឡើយ គេចាត់ទុកយើងជា " បរិមាណឥតទំងន់ " សៀមកំញើញទារបារាំងរោទិ៍ទល់តែយ៉ាងនេះ លុះដល់ថ្ងៃទី ១១ កុម្ភៈដែលជាថ្ងៃផុតកំណត់ផ្អាកបាញ់ ។ ដោយមិនបានផលអ្វីសោះ គូភាគីក៏យល់ព្រមពន្យាថេរៈវេលាថែម ១៥ ថ្ងៃទៀត ។ បន្ថែមពេល យ៉ាងនេះហើយក៏នៅមិនដាច់ស្រេចដែរ ក៏លើកថ្ងៃកំណត់ទៅថ្ងៃ ៧ មីនា ។ ដើមដំបូងជប៉ុនធ្វើជា " អ្នកកណ្តាល " ដោយខន្តី ។ ប៉ុន្តែដោយក្រោយមកទប់ នឹងក្នាញ់ពុំបានដោយខឹងថាខូចពេលវេលាយូពេក ក៏តាំងលាត់ដៃអាវ មូរជើងខោ ចូលប្រឡូកជ្រៀតផង ។ បារាំងភ័យញ័រខ្លួនដូចមាន់ឃើញទឹកក្តៅ ក៏តាំងទំលាក់ស្លឹកត្រចៀកព្រមស៊ីញេលិខិតសំរបមួយ នៅថ្ងៃទី១១ មីនា ។ រហូត ដល់ថ្ងៃទី ៩ ឧសភា គ.ស ១៩៤១ ទើបគូភាគីបានចុះហត្ថលេខាលើសិទ្ធិសញ្ញាជាសម្រេច ។ ឯកសារនេះបង្ខំឱ្យកម្ពុជា និង ឡាវ លះបង់អាណាខេត្តអស់ ៧0000 គីឡូម៉ែតទ្វេគុណ ។ បារាំងបានយល់ព្រមតែធ្វើបបនីយ៍យ៉ាងជាក់លាក់ ព្រោះថាសិទ្ធសញ្ញានេះកើតឡើងដោយមានការបង្ខិតបង្ខំពីមហាអំណាចក្រៅសៃវៀន។

អ្នកអានទាំងឡាយ គង់ឆ្ងៃយល់នូវទំហំទុក្ខលាយកំហឹងដែលពុះ ពោរក្នុងទ្រូង **ឥឃាវុធ** ក៏ជាអ្នកស្នេហាជាតិយ៉ាងមោះមុតក្នុងពេលដែល សំណាងអាក្រក់មកកាត់ពន្លះ មែកធាងនៃមាតុភូមិបណ្តាលឱ្យកាន់តែរួមតូចទៅ ។ ទុក្ខនេះត្រូវគុណមួយជាដប់ទៀត ព្រោះ អកុសលផ្ទាលមកជាប់ជាឈ្លើយនៃប្រទេសខ្មាំង ។ ពិតមែនតែពេទ្យសៀមត្រូវថែរក្សារបួសឱ្យខ្លួនបាន ជាសះស្បើយដោយស្រួលបួល ។ ពិតមែនតែកាថែទាំនេះបានធ្វើដោយថ្នាក់ថ្នមតែទាហានកម្លោះយើងចាត់ការជាធម្មតាវិញ ។ បើមានទាហានសៀមត្រូវរបួស

ដូចខ្លួនក៏គង់មានពេទ្យខ្មែរ គិលានុដ្ឋាយិកាខ្មែរ បីបាច់យកចិត្តទុកដាក់ដូចគ្នាដែរ ។ មួយទៀតដោយនឹកឃើញដល់ពិសេធន៍ថ្នាំងថ្មីរបស់ខ្លួន **ឌី យាឌុធ** ខំប្រយុទ្ធមាំមួនក្នុងចិត្ត ប្រឆាំងនឹងអាការមួយដែលខ្លួនចាត់ទុកជាស្នេហ៍របស់សៀម ។ ស្នេហ៍នេះជាជំងឺរាតត្បាតធំណាស់ ។ មើលចុះនៅតាមនិគមជនបទ ឱ្យឮតែមានល្ខោនសៀមមកលេងកាលណាវាឆ្កួតទាំងស្រី ទាំងប្រុស ទាំងចាស់ទាំងក្មេងតែម្តង។ សំដីសៀមក៏ពិរោះ ញញឹមសៀមក៏ស្រស់ បង្អែមសៀមក៏ឆ្ងាញ់ពិសាកិរិយាសៀមក៏ទន់ភ្លន់ អ្វីទាំងអស់របស់សៀមគួរប្រតិព័ទ្ធ ។ គិតសព្វៗទៅទាំងនោះសុទ្ធតែជាថ្នាំពិស ឬជានុយ ។ ខ្មែរស្លាប់តែនឹងស្នោះត្រង់ ហើយលង់ក្នុងកណ្តាប់ដៃគេច្រើនលើកច្រើនគ្រាណាស់មកហើយ ។ ល្មមដល់ពេលភ្ញាក់ខ្លួនហើយដឹង!!!!

ចិន្តាមួម៉ៅនៃ **ឌីយាឌុធ** រោលឆាបឆេះខ្លាំងឡើងទៀត ។ យី ! នាងចារនារី នឹកដល់មាណវីនេះភ្លាម កំហឹងមកអង្រួនអស់អង្គប្រាណ។ អ្នកកំលោះដេកទន្ទឹងចាំដល់ថ្ងៃត្រឡប់ទៅស្រុកវិញ ។ ព្រោះគួចស្អប់សៀមមិនថារូបណាទេ ។ នៅយូរៗទៅសំអប់កាន់តែក្រាស់ណែនឡើង ។ មិនខ្ជីនិយាយរក អ្នកណាទេ ឬគួរសមនឹងជនណាទាំងអស់ សូម្បីតែចំពោះសមាជិកកាកបាទក្រហមក៏ដោយ ។ បាយទឹកលេបបានពីរ បីម៉ាត់ រួចតាំងសញ្ជប់សញ្ជឹងតែម្នាក់ឯងរងទន្ទឹងតែថ្ងៃដែលបរកបក្ខទាំងពីរខាងត្រូវប្តូរឈ្លើយគ្នាទៅវិញទៅមក ។

សន្ធិសញ្ញាសន្តិភាពតូក្យូ ឬហៅដោយខ្លីថា " សន្តិភាពតូក្យូ " ជាគំរូ អយុត្តិធម៌យ៉ាងក្រាស់ៗឆៅៗ ។ ចិត្តខ្មែរទ្រូងខ្មែរនឹកដល់កាលណាក៏ក្តាន់ក្តាញ់ឥតចេះចប់ ។ គិតមើលចុះ ខេត្តបាត់ដំបងត្រូវដាច់ទៅទាំងមូល ហើយយកដោយទាំងភាគធំនៃខេត្ត **កំពង់ធំ សៀមរាប ស្ទឹងត្រែង** " ថ្វីបើមិនសូវសំខាន់ " ព្រមទាំងចំនៀរខេត្តពោធិ៍សាត់មួយបន្ទះទៅទៀតផង ។ បងប្អូនកាន់សាសនាដូចគ្នា មានប្រពៃណីដូចគ្នា ស្រូបយកអារ្យធម៌ដូចគ្នា ពិតមែនតែបើបានឱកាសកាលណា បងតែងលោតមកត្របាក់ប្អូនលេបដោយឥតញញើតមាត់ទេ ។ ទាំងនេះនៅតែថាមិនមែនដោយអំណាចឃោរឃៅទេ គឺដោយស្រណោះអាណិតទៀត ។ គេយកលេសថា ព្រោះតែមានមនោសញ្ចេតនាជាបងប្អូនយ៉ាងនេះហើយ ទើបគេស្ទុះមកជួយស្រោចស្រង់ យើងឱ្យរួចពីភារៈកញ្ជះបាតជើងបារាំង ។ អីចឹង មែន ! ព្រោះតែចង់ឱ្យខ្មែរបានល្អហើយ ទើបដេញខ្មែរយើងឱ្យលែងរៀនខ្មែរ លែងឱ្យស្ត្រីខ្មែរស៊ីស្លា លែងឱ្យស្លៀកសំពត់ចងក្បិន ហើយបង្ខំពាក់ក្រឡេមក្រឡើមពេញទាំងក្រុងបាត់ដំបង ថាក្មេងៗទៅចុះគ្រាន់មើលសមភ្នែកខ្លះ ឯចាស់ៗកណ្តាលមនុស្សវិញ ម្តាយកូនអើយមើលតែស្វាប៉ាហ៊ីតែម្តង !

គេស្រឡាញ់យើងណាស់ សូម្បីតែនាមស្រុកទេស ភូមិតូចតាចអ្វីក៏គេ ដូរគ្មានសល់ឡើយ ។ បាត់ដំបងក្លាយជាប្រះតះបងក្រឡាញ់ ជាភិប៊ុលសុងក្រាម " ពបុលសង្គ្រាម " ម៉ោងជាអៈធិតថេវដេត " អទិត្យទេវតេជ " សសរ ស្តម្ភជា " ផៃរិរៈយ៉ដេត " អ្វីទេពៃរិយេ តេជគឺ " សត្រូវខ្លាចតេជៈ " ។ ប្រែ អស់គ្មានសល់អ្វីទេ ភូមិវត្តស្វាយ ឡើងទៅជាអាំជៈវ៉ុន " អម្ពវ័ន" អូរតាគី ជា ក្លួងប្រះអាក់យី " អូរព្រះអគ្គិ " ។

ដូចអ្នកអានទាំងឡាយគង់បានដឹងស្រាប់ហើយ អូរតាគីជាភូមិកំណើតរបស់ទីយាវុធ។ ក្រោយពីបានត្រឡប់អំពីជាប់ជាឈ្លើយសង្គ្រាមនៅក្រុងបាងកកមក ទាហានកំលោះក៏បានទទួលតំណែងថ្មីជាចៅហ្វាយស្រុកពួក ។ ទីប្រជុំជនពួក តាំងនៅខាងលិចរវាង ១៥ គ.ម ពីទីក្រុងសៀមរាប ពីពួកទៅស្ទឹងព្រះស្រុក ជាព្រំដែនថ្មីក្នុងភូមិនេះមានចំងាយតែ ៧ គ.ម ប៉ុណ្ណោះទេ ។

ដោយហេតុថា ព្រំដែនអង្កិតជិតមកទីប្រជុំជន ដូច្នេះបញ្ហាថ្មី ចំណោទថ្មីក៏កើតឡើង ស្ទើរមិនលស់ថ្ងៃ នាំឱ្យអ្នកមានមុខតំណែងត្រួតត្រាបានកង្វល់អំពុលមិនចេះតិចទេ ។ បន្តិចថាមានចោរលួចបន្តិចថាមានចោរប្លន់ ថាមានរត់គយ ។ ពួកទុច្ចរិតទាំងអស់រត់ផ្លូចចុះផ្លូចឡើងកាត់ព្រំដែនដូចគេកាត់របាំងកំពុក ។ អ្នកនៅខាងដែនថ្មីរបស់សៀមក៏ដូចអ្នកនៅខាងដែនខ្មែរដែរ តែងលួចឆ្លងព្រំដែនទៅមកសួររកបងប្អូន ។ បន្តិចឮមានឧប្បត្តិហេតុយ៉ាងនេះ យ៉ាងនោះមិនសូវស្ងាត់ទេ នាំឱ្យចៅហ្វាយស្រុកពួករវល់ចាត់ការមិនស្គាល់ថ្ងៃយប់ឡើយ ។ ដោយមានបណ្តាញបញ្ហាចាក់ស្រេះគ្នាយ៉ាងនេះ រាជការសៀមដែល បានមកតាំងសាលា **អាំ ភើ** មួយនៅសសរស្តម្ភហើយសាលាចង្វាត់

នៅក្រឡាញ់ តែងមករួមទាក់ទងនឹងរាជការខ្មែរ បារាំងជាញឹកញាប់ ។ គ្រាប់តែជួយគ្នា ដើម្បីសំរួលការដោះស្រាយបញ្ហាផ្សេងៗ ប៉ុណ្ណោះទេ តែមិត្តភាពនិងចិត្តថ្លើម គ្មានអ្វីទាក់ទងផងសោះឡើយ ។

ចៅហ្វាយស្រុកកំលោះ **ឌីឃាវុធ** ខំយកចិត្តទុកដាក់ប្រតិបត្តិការ ជាបំផុតប្រយោជន៏ជួយសម្រាលទុក្ខកង្វល់ប្រជារាស្ត្រស្លូតត្រង់ជាជនរួមជាតិ ។ អ្នកខ្លះមានស្រែភ្លឺនៅខាងខ្មែរ តែមានផ្ទះនៅខាងសៀម ហើយអ្នកខ្លះក៏ផ្ទុយទៅវិញ ដោយឃើញថាប្រជារាស្ត្ររហេមរហាមនឹងព្រំដែនអយុត្តិធម៌នេះខ្លាំងពេក រាជការទាំងសងខាងក៏បានព្រមព្រៀងគ្នាចេញប័ត្រជនណា ដែលពើបលើបញ្ហានេះ ដើម្បីអនុញ្ញាតឱ្យឆ្លងកាត់ទៅវិញទៅមកបានត្រឹមជំរៅ ២៥ គ.ម ពី ព្រំដែន ។ រាស្ត្របានធូរទ្រូងគ្រាន់បើ អ្នករាជការសៀមក៏កកិលមករកទាក់ទងចងសមានចិត្តជាមួយអ្នករាជកាខ្មែរដែរ ព្រោះនៅក្រឡាញ់មានអីកំសាន្ត នៅព្រៃជ្រូកមានអីលំហែចិត្ត ហើយនៅសសរស្តម្ភមានអីកែអផ្សុកនឹងសេចក្តីធុញទ្រាន់ ? សុទ្ធតែ " ម៉ៃ មី " ទាំងអស់ ។ ម្លោះហើយសៀមតែងសុំមកលេងដល់សៀមរាប ដែលសំបូរត្រីសាច់សំបូរបុរាណដ្ឋាន ជាទីមនោរម្យរំដោះសេចក្តីនឿយណាយ ។

**ឌីឃាវុធ** ជួបប្រាស្រ័យនឹងពួករាជការសៀមបង្គ្រប់តែកិច្ចប៉ុណ្ណោះ គឺប្រាសចាកនូវសេចក្តីរាក់ទាក់ជានិច្ច ថ្វីបើនាយ **អរាំភើ** សសរស្តម្ភ ចេះតែគួរ សមមករក ព្រមទាំងយកជំនូនខ្លះដូចជាទឹកដោះគោកំប៉ុងជាដើម ដែលខាងខ្មែរយើងមិនសូវសំបូរមកផ្គាប់ចិត្តទៀតផង ។ ដោយមិនចង់ជំពាក់គុណគេយូរ ចំពោះសេចក្តីគួរសមយ៉ាងនេះ **ឌីឃាវុធ** តែងតបស្នងវិញភ្លាមដោយស្រា ឡូលីតា ម៉ារិល ក្លូសដរ ឬពិកអូរង្សដែលបានរាំងបិតនៅព្រៃនគរ ឬដោយត្រី ងៀត ត្រីឆ្អើរ ត្រីប្រមាទន្លេសាប ។

ដោយនាយ **អរាំភើ** ចេះតែជជីកអញ្ជើញពេក ហើយដោយមាន បំណងទៅមើលប្រជារាស្ត្រដោយឆ្លងទៅធ្វើស្រែភ្លឺ នៅក្នុងដែនដីដែលទើបបាន ទៅសៀមផង **ឌីឃាវុធ** ក៏ចូលទៅស្នើការនេះចំពោះលោកចៅហ្វាយខេត្ត ។ មន្ត្រីធំនេះបានតបយោបល់ថាការទៅមើលអ្នកស្រុកខាងយើងទៅប្រកបរបរ ចិញ្ចឹមជីវិតក្នុងដែនសៀមនោះ ជានិច្ចប្រសើរម្យ៉ាងដែរ ដើម្បីឱ្យពលរដ្ឋនៅទី នោះយល់ថារាជការខ្មែរពុំមែនបោះបង់ចោលឡើយ ។

ព្រឹកព្រហាមថ្ងៃមួយដោយមាន " ដោយប៉ូលិសសាលាស្រុកម្នាក់ ឈ្មោះ **ថន** ជូនទៅផង **ឌីឃាវុធ** ក៏ចាប់ចក្រយាន (ឌីឡិកតា) កង់ធំ លាបពណ៌ឈាមជ្រូក ហើយជិះទៅខាងលិចឆ្ពោះទៅរកព្រំដែនស្ទឹងព្រះស្រុក " ។

ថ្ងៃរះលឿងទុំ បានសេចក្តីរីករាយទៅលើវិការដ្ឋានមួយដែលមន្ត្រី កំលោះធ្លាប់ចូលចិត្តយូរមកហើយ ។ ឧសភាបាននាំមកនូវភ្លៀងដំបូងដើមឆ្នាំ ហើយវាលស្រែក៏មានជីវិត ដោយសកម្មភាពភ្ជួររាស់ ។ ហ៊ុយៗ ! គោទាញនឹម ន័ង្គលតឹងក ឯហ្វូងរីក និងគ្រលីងគ្រលោងដើររោមជាបរិវារចាំដណ្តើមជន្លេន និងដង្កូវដែលផាលបានគាស់កកាយចេញមក ។

ស្ទឹងព្រះស្រុក ស្ពានដែកចង្អៀតមួយឆ្លោះកន្លងទឹកល្អក់ខាប់នេះ ហើយព្រំដែនថ្មី ។ នាយកតម្រួតប្រចាំការ ដោយស្គាល់លោកចៅហ្វាយស្រុកច្បាស់ ក៏ស្ទុះមកលើកដើមឫស្សី លាបពណ៌ក្រហម ដែលដាក់ឃាំងទទឹកផ្លូវ ហើយលើកដៃគំនាប់ដោយគោរព ។

នយោ **សុវុឌ្ឍន៍សិរីឆ័យ**" សិរិជ័យ " នាយ **អរាំភើ** សសរស្តម្ភដែល បានទទួលដំណឹងពីសាលាស្រុកពួកជាមុខ ក៏បានចាំទទួលមន្ត្រីខ្មែរនៅទីនោះ ដោយរីករាយរាក់ទាក់ ។ អ្នករាជការដែលមានសញ្ជាតិខុសគ្នានេះប្រាស្រ័យកាន់គ្នា ទៅវិញទៅមកលាយខ្មែរលាយសៀម និងអង់គ្លេស ដូចជាស្និទស្នាល គ្នាណាស់ ។

នៅខាងនេះព្រំដែន ក៏ដូចជាខាងនោះដែរ វាលស្រែបរិបូរទៅដោយការប្រកបរបរចិញ្ចឹមជីវិតតែមួយយ៉ាង គឺរបរធ្វើស្រែចំការ ។ នាយ **អៅរំភើ** បានជូនសហសេវិកខ្មែរដើរមើលគ្រប់ទិសទីដែលមានអ្នកស្រុកខាងពួកសៀមរាប មកភ្ជួររាស់ ។

លុះដល់ថ្ងៃត្រង់នាយ **អៅរំភើ** ជជីកអញ្ជើញមន្ត្រីខ្មែរទៅពិសាបាយឯផ្ទះខ្លួន ។ កាលនោះ **ឌីឃាវុធ** បានប្រកែកយ៉ាងយូរ ដោយយកលេសថា មានការប្រញាប់ ឬអីផ្សេងៗទៀតតែមិនឈ្នះសេចក្ដីគួរសមរបស់សៀមឡើយ ។ ដោយពេលនោះបានដើរមកជិតផ្ទះល្អជាងនៅភូមិសសរស្ដម្ភនាយ **អៅរំភើ** សៀមទាញដៃហើយបំបត់ចង្កូតកង់ **ឌីឃាវុធ**ចូលទៅក្នុងរបងមុខគេហដ្ឋាន ។ កាលនោះឯង **ជុឡាណន្ទ** (ចុលានន្ទ) ជាភរិយា **អៅរំភើ** តែងខ្លួនស្រស់ បស់ស្មុះចុះពីលើផ្ទះមកបង្អោនកាយលើកដៃសំពះភ្ញៀវទាំងបង្ខំនេះ ។ ក្នុងពេលនោះ **ឌីឃាវុធ** ក៏លំអោនខ្លួនតបសេចក្ដីគួរសមទៅវិញ ហើយក៏របូតមាត់និយាយសៀមពីរបីមាត់ទៅរក ។ នាងសៀមភ្ញាក់ខ្លួន ហើយហាមាត់លំអ ដោយធ្មេញថ្លា ទើបថ្លែងសរសើរ :

- យី យុនចុះភាសាសៀមច្បាស់លាស់ណាស់តើ !

ហួសពេលប្រកែក **ឌីឃាវុធ** ក៏ព្រមដើរចូលក្នុងគេហដ្ឋានមាន រៀបតុកៅអី រួចស្រេច ។

ការលៀងអាហារពេលនោះ មាននំបញ្ចុកទឹកសម្លមាន់ មានត្រី អណ្ដែងចៀនគ្រឿង មានទឹកគ្រឿកាពិ ផ្សំដោយអន្លក់ស្ពៃ គ្រប់ត្រសក់ដែល ផ្គួបគ្នានឹងប្លូធូចៀន ហើយលើកឱជារសដោយស្រាម៉ារិល លាយសូដានិងទឹកកក ។ ការនិយាយគ្នារំលឹកដោយសោភ័ណភាព និងញញឹមស្រស់នាង **ចុលា នន្ទ** ក៏បង្កើតនូវបរិយាកាសមួយដែលចូលមករំលាយ ដោយឥតដឹងខ្លួនសោះ នូវភាគខ្លះនៃក្រមួនកំហឹង និងសំអប់ ដែលបានរុំស្រោបដួងហឫទ័យ **ឌីឃា វុធ** ពីមុនរៀងមក ។ កិរិយានិយាយទន់ភ្លន់ សំលេងសើចពិរោះ កាយវិការសមសួនមុខមាត់រូបរាងកំពរ និងរបៀបតុបតែងខ្លួនដោយមានរស់ជាតិនៃភរិយាក្មេងរបស់នាយ **អៅរំភើ** បានធ្វើឱ្យចៅហ្វាយស្រុកកម្លោះរំលឹកដល់ .....អនុស្សាវរីយ៍ចាស់ ។

ដូចជារបោមតាមដេញរោមខាំគោ គំនិតនេះតាមរំខានចៅហ្វាយស្រុករៀងរហូតតាមផ្លូវ ក្នុងពេលដែលធាក់កង់ត្រឡប់មកពួកវិញ ។ ប៉ុន្តែសេចក្ដីភ័ន្តភាំងស្មារតីយ៉ាងនេះមិនបានឋិតយូរប៉ុន្មានទេ ។ លុះបានចេញផុត ឆ្ងាយពីសសរស្ដម្ភទីដែលមានឥទ្ធិពលថ្មីបង្ខំឱ្យរំលឹកដល់មនោសញ្ចេតនាចាស់ កំហឹងក៏ចូលមកអង្រួនខ្លាំងទៀត ។ នឹកស្ដាយថា មិនគួរសោះខ្លួនមកចាញ់ ល្បិចទន់ភ្លន់របស់សៀមធូរៗងាយៗដល់ម្ល៉េះ ! ស្មារតីភ្លឺស្វាងយ៉ាងនេះ ឋិតនៅបានតែមួយស្របក់ក៏សេចក្ដីពិភាល់គួចដុះឡើងក្នុងចិន្ដា ។ សូម្បីតែតុលាការ មានប៉ូលិស មេឃុំចៅហ្វាយស្រុកអង្កេតជាមុន.... ដែលមានសភាចារបុរស ស៊ើបសួរយ៉ាងខ្ចេចខ្ចីក៏មានការភ័ន្តច្រឡំដែរក្នុងការកាត់ក្ដី ។ រឿងចារកម្មនោះគ្រាន់តែមានពិរុទ្ធ ដោយផ្អែកជំនឿទៅលើរាយការណ៍ភ្នាក់ងារសម្ងាត់ម្នាក់ប៉ុណ្ណោះ តែគ្មានភស្ដុតាងឯទៀតមកបញ្ជាក់ថែមសោះ ។ គេគ្មានបានចាប់ឯក សារអ្វីៗដែលបង្ហាញឃើញថា ឪពុកនិងកូនបានប្រព្រឹត្តអំពើទ្រុស្ដមិត្តដល់ត្រង់ណាឡើយ ។ ពិតមែនតែរាជការសៀមខិលខូចឆ្លៀតយកឱកាសនៅពេលដែលបារាំងបាក់ដៃបាក់ជើង ដើម្បីចូលលុកដណ្ដើមយកដីខ្មែរ ប៉ុន្តែមនុស្សសៀមមិនមែនជាជនចិត្តអាក្រក់គ្រប់គ្នាទេ ។ នាង **ចន្ទមណី** ក្ដីលោក **ទេព្យកោសល្ល** ក្ដី ប្រសិនបើជាមនុស្សមានពុតអាក្រក់មែន ម្ដេចក៏មិនបោះបង់ខ្លួនចោលនៅក្នុងពេលដែលខ្លួនធ្លាក់ក្នុងកណ្ដាប់ដៃគេ ។ នេះបែរជាមកយកចិត្តទុកដាក់ថែ ទាំខ្លួនរៀងរហូតដល់ជា ។ មានទាហានខ្មែរឯទៀតដែលត្រូវរបួស ហើយបានមកដេកមន្ទីរពេទ្យសេនារក្សដូចគ្នាបានប្រាប់ថា បើកុំតែមានសៀមពីរនាក់ ឪពុក និង ធីតាដឹកខ្លួនយកមកអារញ្ញទាំងយប់ដើម្បីយកមកថែរក្សានៅបាងកកបានទាន់ពេលវេលាទេ ម្ល៉េះសមពិបាកនឹងជាហើយមើលទៅ ។ មានម្នាក់ទៀតបានបញ្ជាក់ថាកាលនៅអារញ្ញនាងសៀមបានទាំងព្រមឱ្យពេទ្យយកម្ជុល បឺតឈាមនាងមកចាក់បញ្ចូលឱ្យ **ឌីឃាវុធ** ទៀតផង ។ ឱប្រសិនបើខ្លួនទំលាក់កំហុស ហើយចោទគេទាំងភ័ន្តច្រឡំមែន ! ឱទ្រូងអើយសែនស្ដាយ ហើយអួលផ្សា!

នាក្រុងបាងកកត្រង់ចំពីក្រោយសួនសត្វឈ្មោះ " ឌុសិត " ( តុសិត ) មានច្រកមួយបែកចេញពីថ្នល់ធំ ។ លុះបានចូលរំលងផ្ទះពីរបីខ្នងមក អ្នកដើរ ក្នុងច្រកនោះសឹងបានដល់ទៅមុខគេហដ្ឋានមួយធំស្រឡះ ជញ្ជាំងក្តារលាបពណ៌បៃតងចាស់ ដំបូលប្រក់ក្បឿងក្រមៅ ។ មើលពីថ្នល់ទៅផ្ទះនេះ ឃើញពុំសូវច្បាស់ទេ ព្រោះកំបាំងដោយដើមសាវយុត ចំប៉ា និង ដើមផ្កាឯទៀត ដែលចោលពិដោលល្ងឹងល្ងើយ ។ កូនស្ពានក្រាលក្តារមួយបង្កោងខ្នងកន្លងសិន ទឹកថ្លា ខ្មៅដែលលំអដោយព្រលឹតក្រហម ។ ស្ពាននេះជាមធ្យោបាយភ្ជាប់គមនាគមន៍ច្រកសាធារណៈ ។

នៅលើរបងបន្ទះឈើលាបពណ៌ស ដែលដោតតំរៀបហែរតាមមាត់កសិន ដើមចេក ទុំបំបែកមែកបញ្ចេញសន្លឹកញឹកក្រាស់លើរានខ្ពស់តូចទ្រវែង ដែលជាទ្រើងសម្រាប់លតានេះដាច់មុខ ។ នៅចំហៀងខាងក្រៅទ្វាររបងធំទូ លាយល្មមរថយន្តចេញចូលបានយ៉ាងស្រួល ស្វាយអុករ៉ង ( ទ្រូងព្រេក ) មួយដើមស្លឹកស៊ុបទ្រុប ចោលម្លប់ត្រឈៃទៅលើមាត់ទឹកពាក់កណ្តាល ហើយនៅក្នុងសួនពាក់កណ្តាល ។ រោងមួយប្រដាប់ដោយបន្ទះឈើលាបពណ៌លឿង ក្រហមខៀវឆ្លាស់គ្នា ហើយព្យួរទៅលើជើងដែកលាបខៀវ បានយកមកបញ្ឈរទុកក្រោមដើមស្វាយនេះ សម្រាប់អង្គុយលំហែរនៅពេលថ្ងៃក្តៅ ។ ទីភូមិនេះ ពន្យល់ឱ្យឃើញថា ម្ចាស់ពុំមែនជាអ្នកមានថ្មីទេ ដែលចូលចិត្តសង់ភូមិគ្រឹះ សំដែងឫក ឬបញ្ចេញធនធានដែលខ្លួនទើបរកបាន ។ ផ្ទុយទៅវិញអ្វីៗនៅក្នុងទីឋាននេះសុទ្ធតែធ្វើឃើញភាពស្រគត់ស្រគំមានទ្រព្យាតជីដូនជីតាមកយូរហើយ ។ ផ្ទះក៏មានរូបរាងបែបចាស់ សួនក៏សុទ្ធតែដាំដោយរុក្ខជាតិដែលបានផ្តល់ផ្កាផ្តល់ម្លប់ច្រើនតំណមក ហើយ ។ សន្តិភាពស្ងួតស្ងប់ សោយរាជ្យជានិរន្តរ៍ ក្នុងទីកន្លែងនេះ ។

នៅក្នុងសង្កាត់នេះ ពុំសូវមានមនុស្សអ៊ូអរទេ ។ យូរៗ " សាមឡ " ( កង់បី ) មួយរត់ រ៉ៅញូរលាស់សន្ទុះព្ទសូរភ្លឺបៗ ដូចសកុណាទទះស្លាប់ ។ មួយសន្ទុះក្រោយមកតុណ្ហីភាពក៏បន្ត សេចក្តីស្ងប់ស្ងាត់ជាថ្មីឡើងវិញ ។ នារីម្នាក់កាន់សៀវភៅក្រាស់ធំមួយក្បាលមកអង្គុយយោលតែកតោក្នុងត្រូវតែនាង ពុំបានបើកសៀវភៅនេះអានទេ ព្រោះភ្នែកសំលឹងទៅឆ្ងាយឥតទីដៅ ហាក់ដូចជាដេញតាមអារម្មណ៍ផ្សេងៗដែលកំពុងបដិសន្ធិក្នុងវិញ្ញាណនាង ។ កូនត្រីល្អិត ៗ ក្រហមៗ ហែលបណ្តើរគ្នាញូង់តាមចន្លោះគុម្ពព្រលឹត ។

សព្វដង សព្វគ្រា វិការដ្ឋានបរិបូណ៌ដោយសន្តិភាពប្រសើរយ៉ាងនេះ តែងតែទាក់ចិត្តនាងក្រៃលែង ។ តែនៅថ្ងៃនេះនាងពុំអើពើផងឡើយ ។ នាងយល់ និងស្គាល់ច្បាស់ហើយនូវកំលាំង និងទំហំកំហឹង ដែលបោកបក់ជាព្យុះក្នុងទ្រូងបុរសកំលោះជាគូប្រចាំចិត្ត ។ មែនទេ ឬអ្នកផងតែងសរសើរណាស់ ដល់ជនដែលចេះលើកស្ទួយករណីកិច្ចចំពោះមាតុប្រទេស ឱ្យបានខ្ពស់ផុតលើស មនោសញ្ចេតនាទាំងពួង ។ តែច្រឡោតអីដល់ជ្រុលហួសទៅជាព្រហើន ហើយប្រមាថមើលងាយសេចក្តីស្នេហា យកជើងញូក់ញីបុកបែនដូច្នេះ ។ ម្តេចក៏យកអយុត្តិធម៌មកកាច់មូលចោទនាងថា ជាចារនារី គួរតែដោះអាថ៌កំបាំងនេះឱ្យផុតសង្ស័យបាន ។

នាង **ចន្ទមណី** ជាអ្នកអានយល់ដោយស្មានស្រេចមកហើយ កំពុងតែត្រិះរិះបញ្ហានេះ ស្រាប់តែឮសូរស្បែកជើងអូសខ្សាកៗមកពីក្រោយ ។ លោក **ធេព្យគោសល្ល** ដោយឃើញមុខកូនចេះតែក្រៀមក្រំ តែងជួញចិត្តរកវិធីបន្លប់ទុក្ខ :

- យីកូន យើងគិតដើរលេងមើលស្រុកមើលទេសបន្តិច ឬអី ?

- ដើរលេងឯណាកើតឃុន **ឪ** បើសង្គ្រាមលោកកំពុងតែរាលដាលឆេះ ។ ឯចំបាំងថៃ និងឥណ្ឌូចិនសោត ក៏ទើបតែស្ងប់រលត់ទៅផង ។

- **ឪ** ទើបបានទទួលសំបុត្រមួយច្បាប់ពីក្មួយ **សុវណ្ណរ័ន** និង នាង **អារណុន** ដែលទើបបានទៅកាន់កន្លែងថ្មីជា **អរាំភើ** នៅ " ពៃរីរយតេជ " ។

នាងសួរដោយឆ្ងល់ :

- ស្រុកអីអញ្ចេះមិនដែលឮឈ្មោះទេ យុន **ឪ**?

- ជាតំបន់មួយដែលខ្មែរហៅថា សសរស្តម្ភ ដែលឥឡូវរាជការថៃ តាំងជា **អរាំភើ** " ពៃរីរយតេជ" វិញ ដើម្បីពិរោះរណ្តំជាង ។

- ខ្ញុំមិនយល់ផងសោះនូវផលប្រយោជន៍ ដែលទៅលោតដណ្តើម ដែនដីរបស់គេមកធ្វើជារបស់ឯង ហើយកែប្រែឈ្មោះ ដាក់ផ្តេសផ្តាសដូច្នេះ ។ មើលចុះ ក្រឡាញ់ត្រូវក្លាយជា " ពិបុលសង្គ្រាម " ។ កុំយើងឆោតស្មានថា ខ្មែរ ៗដែលជាអ្នកស្រុក អ្នកភូមិនៅទីនោះ គេល្ងង់ទៅហៅតាមយើងឡើយ។ មួយទៀត ដូចយុន **ឪ** ជ្រាបស្រាប់ហើយ ឯប្រវត្តិសាស្ត្រក៏បង្ហាញតួយ៉ាងច្រើនណាស់មកហើយ ដែរថា ការរំលោភដណ្តើមយកដីរបស់គេយ៉ាងនេះ មិនដែល នាំមានសេចក្តីសុខទេ ។ មើលបារាំងសេស និង អាល្លឺម៉ង់ជាឧទាហរណ៍ស្រាប់ មើលចុះសង្គ្រាមសព្វថ្ងៃនេះធ្វើឱ្យមនុស្សរាប់លាននាក់ស្លាប់បាត់បង់ជីវិត ។ ខ្ញុំបានស្ម័គ្រចិត្តធ្វើនាងព្យាបាលរបួសនៅពេលចំបាំងមែនពិតតែគ្រាន់តែនៅរក្សារបួសប៉ុណ្ណោះទេ ។ មិនមែនខ្ញុំពេញចិត្តនឹងការប្រយុទ្ធគ្នាសោះឡើយ ។ លោក **ទេព្យកោសល្ល** សំលឹងមើលមុខកូនដោយពេញចិត្តហើយអាណិតទើបតបថា :

- នរណាដឹង ? សង្គ្រាមជាសេចក្តីត្រូវការរបស់ធម្មជាតិក៏មិនដឹងដែរ ? អាចនឹងមានកំលាំងអ្វីធំ មានឥទ្ធិពលអ្វីពីនិស្ស័យយើងយល់មកបង្កើតឱ្យមានដូច្នោះក៏មិនដឹង ? គួរគិតមើលអង្រ្កងលើកគ្នាទាំងហ្វូងទៅប្រខាំគ្នាស្លាប់ប៉ុនគេហាល ។ ខ្វះណាស់ដើមឈើដែលអាចស្លឹកមកផ្គុំហើយភ្ជាប់ជាសំបុកបាន ។ មួយទៀតម្តេចក៏ធម្មជាតិបង្កើតមានសត្វខ្លះស៊ីសាច់ ហើយសត្វខ្លះទៀតស៊ីស្មៅ ។ បើស៊ីស្មៅទាំងអស់គ្នាវាចប់ទៅហើយ ។ លែងឃើញខ្លាលោតត្របាក់កាច់ករមាំងក្តាន់ទៅហើយ ។ ហ្អើយរឿងយ៉ាងនេះនិយាយមិនចប់ទេ ។ **ឪ** យល់ថា ក្នុងជីវភាពគប្បីរើសតែភាពខាងល្អដើម្បីយកមកត្រេកត្រអាលទៅប្រសើរជាង ។ ដូច្នេះយើងគួរទៅលេងតាមសេចក្តីអញ្ជើញនាយ **អរាំភើ** សសរស្តម្ភ តើកូនឯងនឹកថាដូម្តេច ? យើងអាចបង្ហួសទៅមើលអង្គរបានទៀតផង ។ មួយទៀតគេបានបបួល **ឪ** ទៅទិញដីស្រែមួយកន្លែងក្នុងចង្វាត់ " ខេត្ត " បាត់ដំបង ។ បើឃើញថាសមល្មមក៏គួរតែទិញដែរដីនេះ ។ យើងនឹងទៅតាំង ភូមិនៅទីនោះ ។ នៅក្នុងក្រុងយូរត្រូវីព្វអួណាស់ ។

តាមទំលាប់របស់ខ្លួន **ទីយាវុធ** តែងក្រោកពីព្រហាម ហើយដើរ ត្រួតមើលគុម្ពផ្កា នឹងផ្កាស្មៅលំអនៅមុខសាសាស្រុក ។ ដើរបណ្តើរគិតបណ្តើរ ។ គិតអំពីពេលដែលលោក ចៅហ្វាយខេត្ត បានចាត់ខ្លួនទៅភ្នំពេញថ្មីៗនេះ ដើម្បីបំពេញបេសកម្មរាជការ និងអំពីខ្លួនបានជួបនឹង **វេគី** ជាមិត្តខ្លួនធ្វើការ នៅក្រុមសម្ងាត់ ។ កាលនោះភឿនទាំងពីរបាននាំគ្នាត្រូវអាស្រ័យអាហារនៅ ភោជនីដ្ឋាន កុងសាំង ។ នៅចំពោះមុខកែវស្រាមារលីលាយសូដា និង ប៊ីតហ្វត កផុយល្អក កម្លោះទាំងពីរក៏ចាប់និយាយពីកិច្ចបំរើការផ្សេងៗតមក **ទីយាវុធ** ក៏បាបរៀបរាប់ប្រាប់មិត្តអំពីខ្លួនត្រូវរបួសធ្ងន់ហើយខ្មាំងរើសយកទៅថែរក្សានៅអារញ្ញហើយនៅបាកកកទៀត ។ អធិប្បាយអំពីគ្រួសារ លោក **ទេព្យកោសល្ល** ព្រមទាំងកូនគាត់យកចិត្តទុកដាក់ផ្តល់ថ្នាំសង្កូវ ហើយម្ហូបអាហារគ្រប់សព្វ ។ ពន្យល់អំពីថា

ខ្លួនលែងបណ្ដោយចាញ់បោកអ្នកណាទៀតហើយ ។ ខ្ញុំបានទាំងដាក់សម្ដីនាង **ចន្ទមណី** ជាពាក្យធ្ងន់ៗឈឺចាប់ទៀតផង **នីយាវុធ** បញ្ចប់សេចក្ដីថ្លែងប្រាប់មិត្តរបស់ខ្លួន ” ។

**ទេតី** ស្ដាប់ហើយបើកភ្នែកធំៗហើយតប :

-យី **នីយាវុធ** ខ្ញុំភ្លេចឈឹងតែម្ដងហើយ ។ មានការភ័ន្តច្រឡំធំ ណាស់ ។

-ច្រឡំអីហ្នឹងហាស ? ចៅហ្វាយស្រុកសួរដោយប្រញាប់ ។

-ដែលថា គេធ្វើចារបុរសមកស៊ើបការណ៍សម្ងាត់នោះមិនមែនទេ មិនមែន **ទេព្យកោសល្ល** ទេ ។ គឺសៀមម្នាក់ទៀត ដែលបានមកបើកហាងលក់អីវ៉ាន់មួយនៅផ្សារចាស់ទេតើ ។ ខ្ញុំបានចាត់ឱ្យគេអង្កេតខ្ទិចខ្ទីអស់ហើយ តាប៉ិះ **កោសល្ល** គាត់បានភៀសខ្លួនមកស្រុកយើងដោយស្លូតត្រង់ទេតែទោះ ជាយ៉ាងណាក៏ដោយ គាត់ជាសៀមគាត់ជាពលរដ្ឋប្រទេសមួយដែលបានលូកដណ្ដើមដែនដីមាតុភូមិយើងអស់មិនតិចដែរ ។

**នីយាវុធ** សញ្ជប់មួយសន្ទុះទើបតប :

-ឯងនិយាយនេះត្រូវហើយ ។ ខ្ញុំបានទៅស្បថអង្គរស្រេចថា បើមិនបានបាត់ដំបងមកវិញទេ ខ្ញុំក៏មិនខ្វីទាក់ចិត្តរាប់រកសៀមណាជាក្លើម្រាក់ ជាមិត្តភក្ដិ ឬជាអ្វីទាំងអស់ ។ ប៉ុន្តែមកទាស់ស្ដាយបន្តិច ព្រោះការភ័ន្តច្រឡំរបស់ឯង បានបណ្ដាលខ្ញុំប្រព្រឹត្តអាកប្បកិរិយាមិនគប្បីតបនឹងសេចក្ដីគួរសម និងការយកចិត្តទុកដាក់របស់គេ ។ មិនគួរសោះ !

មិនគួរសោះ ! នេះជាពាក្យបន្ទោសខ្លួនឯង ក្នុងពេលកំពុងដើរត្រួតគុម្ពផ្កា ។ មិនគួរសោះ ! ស្ដាយណាស់មិនគប្បីសោះជាតិដទៃមើលងាយខ្លួន បានថា ជាមនុស្សពាលមនុស្សជ្រួរមើលគុណគេ ។

១០

## ជួបគ្រាហើយតែមានឧបសគ្គធំរារាំង

ថ្ងៃពូនគ្នាជាខែ ខែជាឆ្នាំ ។ សង្គ្រាមលោកប្រែភក្ត្រ ប្រែទិសនៃជោគ វាសនា ។ នៅអឺរ៉ុប អាមេរិចកាំង អង់គ្លេស និងរុស្ស៊ី រុញច្រាន អាល្លឺម៉ង់ ទ័លច្រក ។ នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិច ជប៉ុនដកចង្កាមាន់រត់ផ្លោះចេញពីកោះមួយ ដោយអាមេរិចកាំងដេញតាមកែងប្រកិត ។ បាងកក ព្រៃនគរ ភ្នំពេញ ត្រូវគ្រាប់បែករងគ្រោះខូចខាតយ៉ាងដំណំ ។

នៅថ្ងៃទី ៩ មីនា គ.ស ១៩៤៥ ជប៉ុនចាប់បានបារាំងនៅកម្ពុជាដាក់ ទ្រុងដាក់តារាង ហើយប្រកាសឱ្យខ្មែរឯករាជ្យ ។

ចំជាខិលមែនម៉ាសៀកកញ្ជ្រិច ! សៀមដណ្ដើមយកដីខ្មែរបាន ក៏ព្រោះតែគាត់ ។ ឥឡូវគាត់ជិតដួលបះជើង គាត់ស្រែកថា ខ្មែរឯករាជ្យ ។

នៅសៀមរាប ជប៉ុនចាប់បញ្ជូនពួករាជការស៊ីវិលបារាំងនៅភ្នំពេញ អស់ ។ ឯនាយទាហានបារាំងនាំគ្នារត់ចូលព្រៃ ដើម្បីប្រុងប្រយុទ្ធប្រឆាំងវិញ ។ ជប៉ុនលើកគ្នាបណ្ដាក់នៅគ្រប់ខេត្ត ហើយតាំងខ្មែរៗធ្វើការជំនួសបារាំងអស់ ឯ ខ្លួនឯងកាន់តំណែងជាទីប្រឹក្សា ។

កាលនោះប្រទេសខ្មែរ និងប្រទេសសៀមមានឋានៈស្មើរប្រហែលគ្នា ព្រោះ " ឯករាជ្យ " ដូចគ្នា ហើយជប៉ុនយកជើងមកជាន់ពីលើសង្កត់កប់កែងដូចគ្នា ។ ក្នុងកាលៈទេសៈនេះ ព្រំដែនស្ទឹងព្រះស្រុក ស្ទើរតែរលុបស្នាមបាត់ ព្រោះមនុស្សទៅមកហាក់ដូចជាបានតាមអំពើចិត្ត។ ពួកសៀមហូរមកលេងសៀមរាប ហើយមើលអង្គរឯខ្មែរៗជ្រួលលាន់ទៅសួរបងប្អូនខាងក្រឡាញ់ទឹកជោរបាត់ដំបង ។

ថ្ងៃមួយជាថ្ងៃអាទិត្យ។ ដោយឆ្លៀតឱកាសពុំមានកិច្ចការនៅការិយាល័យ **នីយាទុធ** ក្រោកពីដំណេកឡើងក៏ត្រួតមើលទីលំនៅប៉ូលិសសាលាក្រុងដែលសង់នៅរោងវែង ប្រក់ស្បូវ ហើយមានជញ្ជាំងស្លឹកដូងឃាំងចែកជាបន្ទប់ៗ ។ លោកចៅហ្វាយស្រុក កំពុងតែកិនប៉ោចៗថា ប្រពន្ធប៉ូលិសម្នាក់នោះទុកឱ្យមានអាចម៍មាន់គរក្រោមផ្ទះ ហើយថានាងម្នាក់ទៀត បណ្ដោយឱ្យមានជ្រាំស្អុយគគ្រុកស្រាប់តែ **ចន** មកគំនាប់ហើយនិយាយថា :

-ព្រះតេជគុណ **អេរ៉ំតើ** សសរស្ដម្ភមកទៀតហើយ ។ ម្ដងនេះមកឡានទាន ។

នុំះ ឈប់នៅថ្នល់ ។

**នីយាទុធ** ដើរតំរង់មកភ្ញៀវដោយទឹកមុខស្មើៗ គឺមិនធុញទ្រាន់មិនត្រេកអរ ។ នាយ **សុវណ្ណន៍** និងនាង **ចុលានន្ទ** ចុះពីឡានផ្លិតចាស់ម៉ាក ហ្វរដ៏មួយដែលលើកដំបូលជិត ហើយមកឈរចាំត្រង់ជណ្ដើរសាលាស្រុក ។ លុះ **នីយាទុធ** មកដល់ជិត បុរស-ស្ត្រីសៀមទាំងពីរលើកដៃសំពះសួរដោយ រាក់ទាក់ ។

-ជំរាបសួរលោក សុខសប្បាយជាទេ ?

និយាយគ្នាបណ្ដើរ អ្នកទាំងពីរនាំ **នីយាទុធ** ឆ្ពោះទៅរកឡាន បណ្ដើរ ។ នាយ **សុវណ្ណន៍** សួរ :

-ខ្ញុំនាំបងប្អូនពីរនាក់មកលេងផង តើមើលអង្គរបាន ឬទេ ? **នីយា ទុធ** ដោយឥតទាន់ឃើញមុខអ្នកដំណើរ ដែលកំបាំងនឹងដំបូលឡានក៏ឆ្លើយដោយរួសរាន់

ព្រោះយល់ថា ជាឱកាសតបស្នងសងគុណគេ ដែលបានទទួលហើយ លៀងអាហារខ្លួននៅសសរស្ដម្ភ :

-មានអីលោក មានអីយុន ខ្ញុំថ្ងៃនេះទំនេរ ខ្ញុំជូនលោកទៅផងក៏បាន ប្រសិនបើមិនសូវចង្អៀតពេកទេ ។

-មិនចង្អៀតទេ តែកុំលោកពិបាកអី ។ គ្រាន់បើកអនុញ្ញាតក៏អរ ណាស់ទៅហើយ ។

ដោយចិត្តជាអ្នកមិនចង់ចាញ់សៀមក្នុងសេចក្ដីគួរសម **នីយាទុធ**_ឆ្លើយវិញភ្លាម :

-មិនពិបាកអ្វីសោះឡើយ ខ្ញុំអរណាស់ដោយបានជួបលោក និងយុន ទាំងពីរនាក់។ មួយទៀត ខ្ញុំអញ្ជើញលោក និងយុនព្រមទាំងភ្ញៀវរបស់លោកផងទៅពិសាបាយថ្ងៃត្រង់ឯមាត់បារាយណ៍ ។

ថាហើយក៏បែរទៅរកដោយ **ចន** ដែលឈរជិតទីនោះឱ្យបជួលរឺម៉ក ដឹកកន្ទេល ខ្នើយ ទិញមាន់ត្រូវាំងហើយត្រីរសទៅដុតព្រមទាំងស្រាទឹកកក ផ្លែ ឈើ ហើយប្រដាប់ប្រដារគ្រប់យ៉ាងទៅរៀបចំបារាយណ៍នៅវេលាថ្ងៃត្រង់ ។ ចៅហ្វាយស្រុកបញ្ជាក់ឱ្យរកមីងស្រីៗ ជាអ្នកជិតខាងពីរបីនាក់ទៅជួយស្ងួដណ្ដាំផង ។ បន្ទាប់មកដកកាបូបយកពីររយរៀលប្រគល់ទៅ **ចន** ។ ចាត់ការនេះស្រេចហើយ **នីយាទុធ** ក៏បែរមករកភ្ញៀវដែលនាំខ្លួនដើរទៅរកឡាន ។

-យីយុន ខ្ញុំមកនេះមិនបាច់យុនពិបាកលៀងបាយទឹកអីទេ នាង **ចុលានន្ទ** ឧទានដោយសំឡេងស្រួយស្រេះ ។

-ពិបាកអីចឹង រាប់អានស្រឡាញ់គ្នាហើយ អ្នករាជការខ្មែរតប ។

លុះជិតទៅដល់ឡាន **នីយាទុធ** សំលឹងទៅខាងក្នុងហើយទុចង៉ក់ ស្រឡាំងកាំង ទាំងយានិក ហើយទាំងចៅហ្វាយស្រុកក៏ធ្វើមុខមឹងមាំងដូចគ្នា ។

ក្នុងពេលនោះនាយ **សុវណ្ណន៍** ដែលមិនដឹងរឿងរ៉ាវអ្វីសោះក៏ចាប់ផ្ដើម ណែនាំឱ្យស្គាល់គ្នា :

-នេះយុន **ទេព្យកោសល្ល** វិចិត្រករជាឪពុកមាដីជូនមួយខ្ញុំ ។ នេះ នាង **ចន្ទមណី** ជាកូនគាត់ ។ នេះលោក **នីយាវុធ** ជាចៅហ្វាយស្រុកពួក ហើយជាមិត្តរបស់អាណុន និងខ្ញុំ ។ លោកមានចិត្តល្អណាស់ ហើយរាប់អានគ្នា ទៅវិញទៅមកដោយជិតស្និទ្ធ ។

អ្នកនៅក្នុងឡានហើយនៅក្រៅឡាន លើកដៃសំពះសួររកគ្នាទៅវិញទៅមកតែស្មារតីភ័ន្តភាំងវង្វេងខ្លួន ស្ងួតទឹកមាត់អស់រកពាក្យមួយម៉ាត់និយាយ ពុំបានផង ។

ព្រោះប្រកាន់ខ្លួនជាមគ្គុទ្ទេសក៏ **នីយាវុធ** ប្រកែកពុំព្រមអង្គុយខាង ក្រោយជាមួយ លោក **ទេពកោសល្ល** និងនាង **ចន្ទមណី** ទេ។ ជូរនាង **ចុលានន្ទ** ដែលមុនអង្គុយទន្ទឹម នឹងប្ដីដែលជាអ្នកកាន់ចង្កូតក៏ត្រូវឡើងជិះ ខាងក្រោយវិញទុកកន្លែងមុខចៅហ្វាយស្រុក ។

កិរិយាយុវជនទាំងពីរដែលថៃដន្យបានដឹកដៃមកឱ្យជួបគ្នាជានិច្ចក្នុង ពេលនេះកាន់កិរិយាឆឹតៗហាក់ដូចជាមិនដែលស្គាល់គ្នាសោះ ។ ម្ខាងគិតឃើញថា មិនដឹងជាគេនៅខឹងសំបារនឹងខ្លួនឯងយ៉ាងណានៅឡើយ ព្រោះស្រុករបស់ខ្លួនបានដណ្ដើមយកទឹកដីរបស់គេ ចំណែកឯម្ខាងទៀតនៅជាប់អៀនប្រៀន ព្រោះខ្លួនបានចោទគេដោយខុស ហើយបញ្ចេញកាយវិការព្រហើនដាក់គេថែមទៀត **នីយាវុធ** យល់ច្បាស់ដែរថាខ្លួនត្រូវរៀបចំមានយុត្តិធម៌ឡើងវិញដោយទទួលសុំទោសទាំងឪពុកទាំងកូន តែហាក់ដូចជាមិនទាន់សមកាលៈទេសៈ។ កុំបាននាង **ចុលានន្ទ** និយាយចចេចចចាចរហូតតាមផ្លូវ កុំអីមិនដឹងជាបរិយាកាសចង្អៀតចង្អល់យ៉ាងណាទេ ចំណែកលោក **ទេព្យកោសល្ល** គាត់ក៏មានគំនិតស្របដូចគ្នាដែរ គាត់ខំនិយាយពីនេះពីនោះបន្ទប់ តែដោយឥតចេញសំដីអ្វី ឬធ្វើកិរិយាយ៉ាងណាដែរ អាចឱ្យសហជីវិនទាំងឡាយចាប់ភ្លឹកថា កាលពីដើម អ្នកធ្លាប់ស្គាល់អ្នកកម្លោះខ្មែរដែរ ។

**នីយាវុធ** អង្គុយសំកុកក្រងុកស្មារតីទ្បឺនឡង់ ឯភក្ត្រនាង **ចន្ទ មណី** កាន់តែក្រៀមក្រំទៅ ដោយមនោសញ្ចេតនាច្រើនប្រភេទមក កញ្ជ្រោលបោកបាចក្នុងហឫទ័យនាង។

ព្រោះ **នីយាវុធ** បានស្នើសួរយោបល់ **សុវណ្ណរ័ន** ឡានក៏បើកហួសភូមិមុខនាង មិនបានឈប់មើលអង្គរវត្តទេ ព្រោះទាំងអស់គ្នាស្រុះមាត់គ្នាថា ធ្លាប់បានមកមើលច្រើនលើកច្រើនគ្រាណាស់ទៅហើយ ។ បន្តិចក្រោយមក រថយន្តក៏សញ្ជៀវវែងជាការព្រមានមុននឹងឆ្លងកាត់ទ្វារជ័យចូលទៅក្នុងបរិវេណអង្គរធំ ។ ពួកអ្នកដំណើរក៏នាំទៅឈប់ចំមុខប្រាសាទបាពួន ហើយដើរចូលមើល វិមានបែកបាក់នោះ ។ លោក **ទេព្យកោសល្ល** និង **ចុលានន្ទ** និងនាង **ចន្ទមណី** ដើរជួរខាងមុខ ឯ **នីយាវុធ** និង **សុវណ្ណរ័ន** បោះជំហានរង្វើលៗពីក្រោយ ។

**នីយាវុធ** គយគន់រូបឆោមនាង **ចន្ទមណី** ដោយញាប់ញ័រព្រោះ សង្កេតឃើញថា នាងស្គមខុសចំណាំដើមបន្តិច ។ ចំពោះចក្ខុមន្ត្រីកំលោះ ភាពស្រកសាច់នេះ បានញុំាងសំបុរនាងស្លេកស្លាំងបន្តិចដែរ តែកណ្ដាលមានដូចជារស្មីអ្វីមួយដែលញុំាងអាណិត ហើយគោរពផង ។ ទុក្ខព្រួយបានបន្ទុំសម្ផស្ស និង សោភ័ណភាពនាងកាន់តែមានតុល្យភាពស្រស់ស្រគំឡើង ។ យីកុំតែខ្មាសសហជីវិនទៀត កុំអី **នីយាវុធ** នឹងស្ទុះទៅសុំទោសនាង អំពើព្រហើនគ្រោតគ្រើម របស់ខ្លួន ។ ក្នុងពេលនោះចៅហ្វាយស្រុកកំលោះយល់ថា ការសុំទោសជាការ ចាំបាច់បំផុតខានពុំបានទេ ថ្វីបើសម្បថបានហាមប្រាមខ្លួនថា លែងចង់ស្នេហាជា ថ្មីឡើងវិញបាន ។ ទោះបីខំទប់ចិត្តយ៉ាងណាក៏អនុស្សាវរីយ៍ចាស់នៅតែរីក កញ្ជ្រោលប្រាកដរូបឡើងក្នុងវិញ្ញាណយុវមន្ត្រីខ្មែរ ។ ឱ ! ពីដើមជិតដិតដល់ ហៅគ្នាទៅវិញទៅមកជា

ពាក្យ "បង... អូន" យ៉ាងទន់ផ្អែម ។ ឥឡូវសេចក្តីសង្ឃឹមនេះបែកខ្ចាត់ខ្ចាយអស់ ទុកសល់ឱ្យបំណែកដែលចោលពន្លឺភ្លែត១ដូចកំទេចចរណៃ។

បាពួន ពិមានអាកាស ព្រះលានជ័យ ព្រះលានស្តេចគំលង់ ថៃវស្ត្រីគ្រប់លក្ខណ៍ ...កាលដើមមើលបុរាណវត្ថុល្អរកអ្វីប្រៀបពុំបានក្នុងសាកលបាននាំយុវមិត្ត ដែលញញើតចិត្តគ្នារៀងខ្លួនដោយការយល់ច្រឡំកាន់តែសាំមាត់កនិយាយរកគ្នា ។ ប្រាស្រ័យគ្នានេះតែងប្រើពាក្យកណ្តាល១ទេ មិនឱ្យអ្នកសង្កេតការណ៍ ណាចាប់ថ្នាក់ថាធ្លាប់ស្គាល់គ្នាឡើយ ។

ដោយអស់កំលាំងផង ដោយបានអាស្រ័យម្ហូបអាហារនៅចំពោះទេស ភាពយ៉ាងស្រស់ប្រិមប្រិយ៍ផង ហើយដោយត្រូវខ្យល់បក់រហៀក១ថែមទៀត អ្នកដំណើរក៏បែររកកន្ទេលខ្មៅយដែល **ឌីឃាវុធ** បានចាត់ចែងស្រេចនៅលើសាលាសំណាក់ ។ ស្ត្រី១នៅល្វែងម្ខាង បុរស១នៅល្វែងម្ខាង ។ មិនយូរប៉ុន្មាន ការនិយាយឆ្លើយឆ្លងក៏រំងាប់អន់ចុះ ដោយមានការដកដង្ហើមធូរស្នើ១មកជំនួសវិញ ។

លុះឃើញភ្ញៀវដេកលក់ស្រួលដូច្នេះ **ឌីឃាវុធ** ក៏លបចុះទៅខាងក្រោម ។ ព្រោះវិញ្ញាណកំពុងខ្វល់គ្រប់យ៉ាងពេកដំណេកក៏រឹងរកបិទភ្នែកមិនជិត ។ រសាប់រសល់អស់អង្គកាយ ចៅហ្វាយស្រុកក៏ចុះពីសាលាសំណាក់ ដើម្បីទៅរកត្រាំទឹកបារាយណ៍ដែលថ្លាឆ្វង់។ នៅកន្លែងចុះត្រង់ជំរៅត្រឹមដើមទ្រូងខ្លះ លិចក្បាលខ្លះ ឬមួយន្ទងរាជការខេត្ត បានបោះបង្គោលប្រចាំសម្រាប់ត្រូវហែលទឹកលេង ។

កំលោះព្រួយចិត្តកំពុងតែត្រូវបង្គោលមួយ ហើបក្បាលមើលទៅខាងកណ្តាលបារាយណ៍ ស្រាប់តែឮសូរជើងមនុស្សដើរផ្លូក១មកធ្វើឱ្យល្អក់ចិត្ត ដែលកំពុងតែស៊ើងមមើងទៅវែងឆ្ងាយ ។ គិតស្មានថាពួកដោយ **ថន** ចុះមកដងទឹកយកទៅលាងចានឆ្នាំងចៅហ្វាយស្រុកក៏បែរមុខមកទាំងមួម៉ៅ ហើយក៏ភ្ញាក់ព្រើត ។ នាង **ចន្ទមណី** ស្លៀកពាក់ឈុតងូតទឹកពណ៌ត្រួយអំពិលញញឹម ចិញ្ចាចលុយទឹក ហើយហក់ហែរគោះជើងតម្រង់មក រកបង្គោលមួយដែលនៅចម្ងាយ ១ ម៉ែតពី **ឌីឃាវុធ** ។

-អត់ទោសខ្ញុំផងបានទេ (នាងនិយាយមករក) ដោយខ្ញុំបានមកទម្លុះ ទម្លាយភាពឯកោរបស់លោកក្នុងពេលនេះ ។

**ឌីឃាវុធ** សង្កេតក្នុងចិត្តដោយអួលផ្សាថា នាងមិនបានហៅខ្លួនថា "បង១" ដូចសម័យមុនទេ តែហៅ " លោក " ឬ "ឃុន" ទៅវិញ ។ បន្ទោស នាងម្តេចបានព្រោះកំហុសមកពីខ្លួនឯងទាំងស្រុង ។

នាង **ចន្ទមណី** ឱនក្បាលមាត់ក្រហមស្រស់ ក្រេបទឹកថ្លាជាល្បែងទៅក្នុងអាកាស ដើម្បីបង្កើតជាកូនឥន្ទធនូមើលបានតែមួយភ្លែត។ នាងថែមវាចា :

-ខ្ញុំគេងមិនលក់ទេ ព្រោះរសាប់រសល់ក្នុងចិត្តពេក ។ ដោយឃើញ លោកចុះមកងូតទឹក ខ្ញុំក៏លបចុះតាមដែរ ដ្បិតអីមកដល់បារាយណ៍ហើយមិន បានងូតទឹកនោះចំជាស័យធំហើយ ។ មួយទៀតខ្ញុំចង់ជួបលោកបន្តិច ដើម្បីបញ្ជាក់ពីរ បីម៉ាត់ប៉ុណ្ណោះ ។ បារាយណ៍ អង្គរ និងបុរាណដ្ឋានទាំងឡាយដែលខ្ញុំ បានឃើញជាថ្មីក្នុងពេលនេះ នាំឱ្យខ្ញុំនឹកព្រួយដល់ពេលដែលធ្លាប់រីករាយជាមួយ គ្នាកាលពីសម័យមុន ។ តែបើតាមមើលទៅជួបគ្នាពេលនេះជាវេលាក្រោយបង្អស់ហើយ យើងនឹងលែងមានភពប្រសព្វបានឃើញមុខគ្នាទៀតហើយ។ អាកប្បកិរិយាលោកកាលនៅពេទ្យសេនារក្សបាងកកនោះ បានបង្ហាញឱ្យឃើញច្បាស់ថា លោកស្អប់ខ្ញុំណាស់ ស្អប់គ្រួសារខ្ញុំណាស់ ព្រោះជាខ្មាំងសត្រូវ ។ ខ្ញុំមិននឹកខឹងប្រកាន់នឹងលោកទេ សូម្បីតែតូចមួយក៏គ្មានដែរ ។ ខ្ញុំសង្ឃឹមថាដែល ខ្ញុំកាត់មករកនិយាយ នឹងលោកក្នុងពេលនេះ ជាភស្តុតាងឃើញថា ខ្ញុំនិយាយពិតត្រង់មែន ។ ខ្ញុំមិនខឹងនឹងលោកទេ បែរជាសរសើរលោកវិញ ព្រោះលោកលើកសេចក្តីស្រឡាញ់ជាតិខ្ពស់ផុតមនោសញ្ចេតនាឯទៀតទាំងអស់ សូម្បីតែសេចក្តីស្នេហាក៏យ៉ាងនោះដែរ ។

និយាយមកដល់ត្រង់នេះ នាងទប់ទឹកភ្នែកពុំឈ្នះ ក៏ដំណក់ប៉ុនគ្រាប់ ពោតហូរលង់មកលើថ្ពាល់ទាំងសងខាង ។ **ឌីឃាវុធ** នឹកអាណិតញ៉័រដើម ទ្រូងប៉ផ្លុកស្ទើរស្ទុះទៅត្រកង

សព្ទាប់មួយស្របក់ធំទើបតប :

មានការភ័ន្តច្រឡំធំណាស់ នាងចាំខ្ញុំនិយាយប្រាប់នាងអស់ដើមទង  តែកុំនិយាយនៅទីនោះ យើងជិះទូកវិញ ។

ថាហើយក៏ស្រែកហៅដោយ **ខន** នាំគ្នាសែងទូកបារាំងដែលទុកចោលនៅក្រោមសាលា ។ ទូកនេះស្រួចក្បាលស្រួចកន្សៃទាប នៅលើទឹកហើយ ស្ទុះលឿនទៅមុខដោយចែវពីរភ្ជាប់ទៅនឹងគែមទាំងសងខាង ដែលទុកសំរាប់គាស់ទឹកក្នុងកិច្ចកីឡាផ្ទាល់ខ្លួន ។

នៅចន្លោះមេឃថ្លាខៀវទាំងពីរ គឺមួយនៅគ្របពីលើ ហើយមួយ ទៀតឆ្លុះទៅក្នុងទឹក ទូករុលទៅមុខត្រង់ទៅកណ្តាលបារាយណ៍ ដោយចង្វាក់ យ៉ាងមាំមួននៃចែវទាំងពីរដែល **ឆីយាវុធ** កាន់គាស់គង្គាដោយប៉ិនប្រសប់ ។ នាង **ចន្ទមណី** អង្គុយប្រឈមមុខនឹងចៅវាយស្រុកសំលឹងមើលសាច់ដុំនៅកួយដៃអ្នកចែវដែលជូនសន្ទឹង ជូនរុកតាមចង្វាក់ ហើយបរិបូរដោយថាមពល ។ ដើមស្គន់ហុចផ្កាសក្បុះមកលើទឹក ឯគុម្ពស្មៅយោលយោគបណ្តុះពណ៌ មាសទុំដោយបន្ទោរដើមតាមវាយោដូចដងខ្លួននាដកាក្រោមសំឡេងប្រគុំភ្លេងពិណពាទ្យ ។ ហ្វូងប្រវឹកស្ទុះផ្អើលទទះស្លាបហើរ ហើយស្រែកតវ៉ាថា ជីប១ ។

យុវជនទាំងពីរនាំគ្នាបេះផ្កាស្មៅដាក់ទូកបណ្តើរ ហើយសាសងសេចក្តី បណ្តើរ :

មានការភ័ន្តច្រឡំធំណាស់នាង ហើយខ្ញុំមិនដឹងថានឹងសុំទោសនាងដូច ម្តេចបានចំពោះកិច្ចអំពើកំហុសរបស់ខ្ញុំ ។ មួយទៀតខ្ញុំមិនដឹងជាតបគុណយ៉ាងណាទេ ចំពោះកិច្ចដែលនាងហើយលោក **ទេព្យកោសល្ល** បានជួយជីវិតខ្ញុំគង់ទ្រង់មកដល់សព្វថ្ងៃ ។

សុំទោសអីបង  នាងរបូតមាត់ហៅថា " បង " ដូចពីដើម ដែលជាហេតុនាំញញឹមស្ងួតមួយមកលើភ័ក្ត្រ **ឆីយាវុធ** ។

-ខ្ញុំពុំដែលនឹកប្រកាន់ទេ  ពុំដែលនឹកថា បងប្រព្រឹត្តឆ្គាំឆ្គងត្រង់ណាទេ ។ កំហឹងរបស់បងតបតចំពោះអំពើទ្រុស្តមិត្តរបស់ប្រទេសខ្ញុំនេះចំជាត្រូវហើយ ។ ខ្ញុំពុំដែលសរសើររដ្ឋាភិបាលគ្រប់គ្រងដោយពួកកាន់អំណាចផ្តាច់ការ ដែលលួចឆ្មក់យកដែនដីគេមកពង្រីកអាណាខេត្តរបស់ខ្លួនឯងយ៉ាងនេះទេ ។ អំពើបែបនេះបើជាជនសាមញ្ញធម្មតាប្រព្រឹត្ត លោកចាត់ហៅថា លួចប្លន់ តែរដ្ឋាភិបាលណាមួយជាអ្នកផ្តើមគំនិតទៅវិញ អ្នកផងគេហៅថា ជាកិច្ចនយោបាយ ។ ខ្ញុំមិនស្ញើចសរសើរទេ ចំពោះនយោបាយបែបនេះ ។ គ្រួសារខ្ញុំទាំងអស់គ្នាក៏យល់យ៉ាងនេះដែរ ។ ដើម្បីបំបាត់ទៅតាមការអាចបាននូវអយុត្តិធមិ  និងកំណាចព្រៃផ្សៃ ដែលសាយចេញពីនយោបាយបែបនេះ ខ្ញុំបានស្ម័គ្រចិត្តធ្វើ នាងព្យាបាលដោយមានបំណងជួយថែរក្សាអ្នករងគ្រោះ ព្រោះសង្គ្រាមមិនថា ជាតិណា១ឡើយ ។

អូន ! **ឆីយាវុធ** ហៅនាងយ៉ាងនេះដោយរំភើបចិត្ត ។ បងសូមគោ រពដោយស្មោះ ចំពោះការយល់ត្រូវរបស់អូន ។ តែទោះបីស្រឡាញ់ជាតិយ៉ាងណា ក៏មិនត្រូវកាន់អាកប្បកិរិយាព្រហើន គ្រាតគ្រើមតបស្នងនឹងធមិសប្បុរស និងមនុស្សធមិទេ។ បងខឹងច្រឡោតហួសពេក ព្រោះមានការមួយ ....

តមក **ឆីយាវុធ** ក៏តាំងរៀបរាប់អំពីសំបុត្រ **ទេគី** ដែលចោទនាង ថាជាចារស្ត្រី អំពីខ្លួនក្តៅក្រហាយរត់ចូលធ្វើទាហាន ហើយអំពីការជួបគ្នានៅ លើកក្រោយជាមួយ **ទេគី** ដែលប្រាប់ខ្លួនថាភ័ន្តច្រឡំវិញទេ ។

នាងត្រង់ត្រាប់សំដីខ្សាវ១ដែលលន់តួថាខ្លួនខុស ។ នាងនៅស្ងៀមភ្លេចបេះផ្កាយោនយានដែលរាំចាក់ក្បាច់ល្អឆើតក្រោម សន្ទុះនៃវាយោ ។

-កំហុសបងធំណាស់ មិនដឹងកែខ្លួនយ៉ាងណារួចទេ ។ អូនអើយ ! វាសនាយើងមុខតែមិនបានជួបរួមរ័ក្សគ្នាដូចគោលបំណងដើមទេ។ យើងជួបមុខគ្នាពេលនេះប្រហែលជាលើកក្រោយបំផុតហើយ ព្រោះបងបានទៅសច្ចាប្រណិធានចំពោះព្រះភ័ក្រព្រះពុទ្ធរូបនៅអង្គរថា ដរាបណាខេត្តខ្មែរ ដីខ្មែរ ដែល បានទៅសៀមក្នុងពេលថ្មី១នេះមិនត្រឡប់មកខ្មែរវិញទេ ដរាបនោះបងប្តូរផ្តាច់ មិនព្រមយកសៀមជាមិត្ត ជាក្លើ ជាម្រាក់អ្វីឡើយ។

សម្បថនេះធ្ងន់ណាស់ ធំណាស់ មិនអាចបំពានបានដោយលេង១ទេ ហើយចំណែកខ្លួនបងក៏គ្មានឆន្ទៈ នឹងលាភលាសម្បថនេះផង ដែរ ព្រោះអូនអើយ បងស្តាយភូមកំណើតបងខ្លាំងណាស់។ បងមិនភ្លេចទេគុណនាង មិនភ្លេចទេអនុស្សាវរីយ៍ក្រអូប ដែលអូនបាន បោះពុម្ពជាប់ក្នុងទ្រូងក្នុងប្រម៉ាត់របស់បង។

**នីយាវុធ** ឈប់មួយសន្ទុះទើបនិយាយថែម:

-តើអូនលើកទោសឱ្យបងបានដែរឬទេ? បងបានធ្លោយខ្លួនប្រព្រឹត្ត ខុសពីរយ៉ាងធំចំពោះនាង។ ទីមួយ គឺបងធ្វើឱ្យអូនបង់គំនិត ចងចិត្តមកលើបងទីពីរ គឺបងកាន់កិរិយាឆ្គងមិនគប្បីចំពោះសុទ្ធចិត្តរបស់អូន។

ទឹកភ្នែកហូរស្រក់ភ័ក្ត្រនាង **ចន្ទមណី** តែនាងមិនមានទឹកនាជូត ចេញសោះឡើយ។ កម្លាំងយោបំស្ទុះចុកណែនបំពង់ក បណ្តាលឱ្យនាងចេញវាចាអ្វីពុំរួចសោះក្នុងគ្រានោះ។

## ១១

## កន្លាត្រដោករោនីលើចុងអំពិល

ស្ពានស្វាយដូនកែវ ជាគោលជាសញ្ញាមួយកំណត់ព្រំដែនខេត្តពោធិ៍សាត់ និងបាត់ដំបង ។ ក្នុងសម័យដែលសៀមចូលមកញាក់ញី ប្រទេសយើង ស្ពាននេះក៏ក្លាយទៅជាស្ពានអន្តរជាតិ ប្រឈមមុខកម្ពុជរដ្ឋដែករួញហើយខើចឡើងតូច ចំពោះប្រទេសថៃដែលប្រាថ្នាចង់ ធ្វើអាល្លឺម៉ង់ ឬជប៉ុនក្នុងអាស៊ីអាគ្នេយ៍ ។

ឥឡូវមេក្លោងទាំងឡាយបាក់លោងផ្ដោះចង្កេះអស់ហើយ កូនសំពាយក៏ត្រូវខ្ទាត់ អាណាខេត្តដែលខ្លួនបានលេប ហើយស្លាប់នៅ ពាក់កណ្តាលបំពង់កនោះមកម្ចាស់ដើមវិញ ។ ធម្មតាសត្វស្វែងរកអំពាមិនដែលរលាស់ចំណី ដែលកំពុងត្របាក់លេបដោយងាយ១ស្រួល១ ទេ ។ ដូច្នេះត្រូវតែមហាអំណាច ដែលមានជ័យជំនះក្នុងសង្គ្រាមលោកលើកទី ២ កំញើញបង្ខំទើបរបេះពីមាត់ ពីក្រញ៉ាំ ។

ថ្ងៃទី ៨ ធ្នូ គ.ស ១៩៤៦ សម្លេងម៉ាស៊ីនធ្ងន់១ នៃរថយន្តដឹកទាហាន ខ្មែរបានកំរើករំជួលអព្ភព្រឹកព្រហាម ដែលស្រោបក្រុង ពោធិ៍សាត់ ក្នុងស្រោមធាតុអាកាសត្រជាក់ នាំទទួលដេកស្រណុកមិនចង់កម្រើកខ្លួន ។ គោមរថយន្តនៃចំងាយពពកធូលី ដែលហុយគួច ឡើងបានបង្ហាញទីតាំងខ្លួនដោយភ្លើងភ្នក់គោម ដែលឆេះប៉ផ្ទុយ ឬដោយគំនរស្លឹកឈើស្ងួតដែលគេបានបោសប្រមូលទុក ហើយដែល បញ្ចេញអណ្តាតសន្ធោសន្ធៅផ្សាយកំដៅ និង សុខុមាលភាពនៃជនចាស់១ ដែលចាញ់រងា ។

នៅលើរថយន្តឥតដំបូល ទាហានកាំភ្លើងបញ្ឈរចន្លោះក្បាលជង្គង់ ហើយឱបដៃកំប្រោនក្នុងចរន្តខ្យល់ត្រជាក់ ។ ក្រោមកិច្ច ត្រួតត្រា និងបញ្ជានៃ លោក **ជួន្ស៊ុង** ក្នុងឋានៈជាទេសរដ្ឋមន្ត្រីហើយ ឧ.ស **ជីហ្សុងតែ្សរ** ជាតំ ណាងបារាំង យោធាយើងបានចេញ ដំណើរឆ្ពោះទៅកាន់បាត់ដំបង ដើម្បីលុបលាងអាម៉ាសមុខដែលនាំក្តៅក្រហាយចិត្តជាង ៥ ឆ្នាំមកហើយ ។

ម៉ោង៧ គត់ កងក្បួនរថយន្តចូលដល់គោលព្រំដែន នាយទាហានខ្មែរ ម្នាក់និង នាយតំរួតសៀមម្នាក់ បានចុះហត្ថលេខាលើ សេចក្តីកត់ហេតុបញ្ជាក់ អំពីលក្ខណៈ ការឆ្លងព្រំដែន ។ ការចុះស៊ីញ៉េនេះបានធ្វើនៅត្រង់ពាក់កណ្តាល ស្ពានៃស្ពានស្វាយដូនកែវ ។

បន្ទាប់មកកងតម្រួតថៃក៏ឡើងឆ្ពោះទៅបាត់ដំបង ។ មួយសន្ទុះក្រោយមកទៀត រថយន្ត " ស្កោការ " មួយដោយមានរថយន្តផ្ទុកទាហានជាង ជូនទៅផង ក៏ចេញដំណើរតម្រង់ទៅទិសតែមួយនោះដែរ ។

នៅម៉ោង ៨ និង ១៥ នាទី ក្បួនរថទីពីរទាំងអស់មាន ១៥ គ្រឿង ក៏បើកចេញទៅតាមទៀត ។ ពុំបានប៉ុន្មានក៏ទៅគឿងនឹងស្ពានឈើ ដែលពួកសៀមបានពន្យុះពួកឧទ្ទាមដុតបំផ្លាញ ដើម្បីរំខានដំណើងនេះ ។ ពួកទាហាន ជាងបាននាំគ្នាធ្វើការប៉ះប៉ុនអស់ពេលជាងមួយម៉ោងទើបស្រេច ។ ដោយហេតុថា ពួកខ្មែរឥស្សរៈបានលបផ្តាច់ផ្លូវតមនាគមន៍នៅច្រើនកន្លែងទៀត លុះដល់ល្ងាចទើបក្បួនរថយន្តបានចូលទៅដល់ទីប្រជុំជនមោងឫស្សី ។ នៅយប់នោះ ពួកឧទ្ទាមបានមកលបបាញ់បង្អើល មួយសន្ទុះត្រង់ស្ថានីយន៍អយស្ម័យយាន ។ កងរថយន្តល្បាតបានចេញត្រួតមើលការណ៍ ហើយសង្កេតឃើញថា ស្ពានឈើ នានាតាមថ្នល់ទៅក្រុងបាត់ដំបងចាប់ឆេះហ៊ុយទ្រលោម

ព្រឹកថ្ងៃទី ៩ ម៉ោង ៨ កងទាហានក៏ចេញដំណើរពីក្រុងមោងឫស្សី ហើយពីរម៉ោងក្រោយមក ក៏ចូលទៅដល់ស្ពានថ្ម ។ កាលនោះបាត់ដំបងមានសភាពហាក់ដូចជាទីក្រុងមួយស្លាប់បាត់បង់វិញ្ញាណ ។ អ្នកស្រុកបិទទ្វារស្ងាត់ ជ្រាបហើយពុំមានចរាចរអ្វីឡើយក្នុងវិថីនានា ។ ម៉ោង ១០ កន្លះ ឧ.ស **ដឺហ្សុងគ្យែរ** ចូលទៅកាន់សណ្ឋាគារខេត្ត ដោយមាននាយ **តារិន្ទ** វរាំងភ័យ ជាមេចង្វាត់ ព្រមទាំងនាយទាហានឯទៀតនៅចាំទទួល ។ កាលនោះពួកសៀម ទាំងអស់គ្នាសុទ្ធតែស្លៀកពាក់ឯកណ្ឋានពេញយស តែមុខស្លាំងព្រោះនឹកស្តាយចំណីដែលរបូតពីមាត់ ។

នៅដងកើ ទង់ខ្មែរ-បារាំងក៏ចាប់រលាស់ផ្តត់តាមចរន្តខ្យល់ឡើងវិញ ។ បន្តិចក្រោយមកទើបមានពិធីប្រគល់ខេត្តជូនលោក **ជុំឡុង** ជាតំណាងរាជរដ្ឋា ភិបាលខ្មែរដើម្បីកាន់កាប់ជាថ្មី ក្រោយដែលទឹកដីនោះបានព្រាត់ប្រាស់ទៅជាង ៥ ឆ្នាំ ។

ក្រោមសេចក្តីដឹកនាំយ៉ាងសកម្មនៃមន្ត្រីខ្មែរ ជីវភាពទាំងខាងរាជការ ទាំងខាងមហាជន ក៏ចាប់រៀបចំមានដំណើរឡើងដោយរួសរាន់ ។ មិនមែនចាត់ ការទៅបានដោយស្រួល១ប៉ុន្មានទេ ។ ព្រោះអ្នកដែលដកខ្លួនថយទៅបានបង្កប់រោយអំបែងដប បង្កប់បន្លា ពោលគឺញុះញង់ពួកខ្មែរឥស្សរៈចំនួន ៥៦០០ នាក់ ធ្វើរំខានគ្រប់បែបយ៉ាង ។ ទំរាំបង្ក្រាបចលានេះ ឱ្យសាបរលាបអស់បានត្រូវខាតពេលច្រើនឆ្នាំទៅមុខទៀត ព្រោះយល់ថា ខេត្តទាំងមូលត្រូវការពារសេចក្តីលំបាកច្រើនពន់ប្រមាណ រដ្ឋាភិបាលខ្មែរក៏រើសមន្ត្រីឆើត១ច្រើននាក់មកកាន់កាប់គ្រប់នាទី ។ កាលនោះ **ឱឃាវុធ** ក៏បានទទួលបង្គាប់ផ្លាស់ពីខេត្តសៀមរាប ដើម្បីមកកាន់តំណែងជាភូឈួយខេត្តទីពីរនៅបាត់ដំបងដែរ ។

លោកភូឈួយខេត្តទីពីរ ពិនិត្យដោយប្រុងប្រយ៉ែននូវសេចក្តីរាយការណ៍ប៉ូលិស និងសាលាស្រុកដែលជូនដំណឹងអំពីចារកម្ម និងភេរវកម្ម ដែលជនរួមជាតិក្នុងដែនខេត្តកំពុងរងគ្រោះនៅឡើយក្រែក ! សូរគន្លិះទ្វាររបើក ។ ដោយធ្វើភ្នែកក្រឡើតក្រឡាប់ប្លុងតុងពាក់ឯកសណ្ឋានកាគីដើរត្រុន១ កាន់នាមប័ត្រមួយយកមកជូន ។ ក្រឡេកឃើញឈ្មោះភ្ញៀវកាលណា មុខរាជការនេះសំដែងការងឿងឆ្ងល់មួយសន្ទុះ លាយដោយសេចក្តីត្រេកអរផង ហើយប្រាប់ទៅលេខាហារីនោះថា :

- អញ្ជើញគាត់ចូលមក ។ ចំណែកខ្លួន **ឱឃាវុធ** វិញក៏ប្រញាប់ ដែតម្រង់ក្រវ៉ាត់ សំរួលកអាវក្រៅ ហើយដើរចេញពីក្រោយតុមកចាំទទួល ។

កាលនោះអ្នកដែលដើរចូលមកក៏ភ្ញាក់មិនតិចដែរ ដោយឃើញអ្នកកាន់អំណាចលើកដៃសំពះតបវិញ ភ្ញៀវនោះក៏ភ្លាត់មាត់ថា :

- យីលោកក្មួយទេតើ ខ្ញុំអរណាស់ ខ្ញុំគិតថា នឹងនាំគ្នាទៅលេងនឹងលោកក្មួយឯសៀមរាបឯណោះតើ ព្រោះរលឹកណាស់ ។ តាំងពីបានទទួលទាន អាហារយ៉ាងឆ្ងាញ់ជាមួយគ្នានៅបារាយណ៍មក ក៏បាត់ដំណឹងឈឹងសូន្យ ។

**ឱឃាវុធ** ញញឹមហើយអញ្ជើញភ្ញៀវ គឺមិនមែននរណាក្រៅពីលោក **ឧកញ៉ាកោសល្ល** ទេ អង្គុយនៅកៅអីមុខតុ ឯខ្លួនអង្គុយនៅកៅអី ទន្ទឹមនៅម្ខាងដែរ រួចហើយទើបនិយាយ :

- ខ្ញុំត្រេកអរណាស់ ដែលបានជួបលោកនៅពេលនេះ ។ ខ្ញុំគិតស្មាន ថា លោកអញ្ជើញទៅប្រទេសថៃផុតទៅហើយ ។

- ទៅឯណា ! ខ្ញុំមកតាំងទីលំនៅ នៅស្រុកខ្មែរជាស្ថាពរហើយ ។ គ្រួសារខ្ញុំក៏មកនៅរួមគ្នាអស់ដែរ ។

សង្ឃឹមដែលកាលពីមុនកប់បាត់ទៅក្នុងគំនរទុក្ខ និងកង្វល់គ្រប់យ៉ាង ដែលមកគ្របសង្កត់ទ្រូងភូឈួយខេត្តកំលោះឥឡូវក៏រុលងើបចេញបានមក អង្រួនបេះដូងដោយត្រេកអរឥតឧបមា ។ ដែនដីទាំងឡាយដែលខ្ចាត់បាក់បែកទៅនោះ ឥឡូវបានចូលមកក្នុងរង្វង់ប្រជាជាតិអស់វិញហើយ ពោលគឺ លក្ខណ្ឌទាំងប៉ុន្មានដែលខ្លួនបានសច្ចាចំពោះព្រះភក្ត្រព្រះពុទ្ធរូបនៅអង្គរវត្ត ក៏បានសម្រេចដូចបំណងទាំងអស់ ។ ដូច្នេះហើយទើបសេចក្ដីសង្ឃឹមយ៉ាងទន់ត្រជាក់បានមករុំក្រសោបហឫទ័យមន្ត្រីកំលោះ ។ ដោយខំទប់សង្កត់មនោសញ្ចេតនាគ្រប់បែបយ៉ាងដែលពុះពារ លោកភូឈួយក៏សួរថា :

- លោកអញ្ជើញមកនេះមានធុរៈអ្វីដែរ !

- លោកក្មួយ កាលដែលថៃមកកាន់ការទីនេះខ្ញុំបានទិញដីស្រែពីអ្នក នេះបន្តិច អ្នកនោះបន្តិចនៅក្នុងភូមិជ្រោយម្ទេសប្រមូលទៅបាន ១៥០ ហិកតា ។ ឥឡូវខ្ញុំយកលិខិតលក់ដូរ ដែលធ្វើក្នុងពេលនោះមកជូនរាជការថ្មីបញ្ជាក់ សំគាល់ជាកម្មសិទ្ធិរបស់ខ្ញុំតទៅ ។

- បាទលោកបាន សូមលោកទុកឯកសារនៅទីនេះសិនចុះ ចាំខ្ញុំចាត់ ការជូន ។

ទុចមួយសន្ទុះដូចជាចង់រកពាក្យនិយាយតទៅទៀត ទើបនាម៉ឺន កំលោះសួរថែមទៀតថា :

ចុះសព្វថ្ងៃនេះលោកនៅឯណា ?

- នៅឯជ្រោយម្ទេសឯណោះ ! អញ្ជើញលោកក្មួយទៅលេងផ្ទះបានម្ដង ។ មានអីទានចូលទៅបានស្រួលទេតើ។ ខ្ញុំបានលើកផ្លូវមកជាប់ថ្នល់រាជ ការស្រាប់ហើយ ។

ដោយឮសូរឡានបរមកតាមផ្លូវតូច ដែលលើកកាត់ស្រែកំពុងមានស្រូវទុំនៅសងខាង ហើយចូលតម្រង់មករកផ្ទះបុរសម្នាក់ស្លៀកពាក់ខ្មៅបែបអ្នកច្រូតកាត់ដើរផង រត់ផង ចេញតាមទ្វារតូច ដែលចោះក្នុងរបងឈើគ្រាក់មាំ ៗ ហើយបោះតំរៀបប្រកិតគ្នាដូចស្និតចេក។ បុរសនោះចេញមកខាងក្រៅក៏ប្រទះរថហ្សីបមួយបរដោយមាណពម្នាក់ស្លៀកខោជើងវែង ហើយអាវសឺមីដៃខ្លីកាគីបញ្ឈប់ម៉ាស៊ីនឡាន ហើយបង្ខិលជើងលោតឆ្លុបមកដី ។ ប៉ូលិសខេត្ត ៤ នាក់ប្រដាប់កាំភ្លើងមីត្រៃយ៉ែតជាប់នៅដៃ ក៏ចុះស្រពីលើយានតាមមកដែរ ។ អ្នកបើកឡានសួរទៅបុរសស្លៀកពាក់ខ្មៅថា :

បង លោក **ឆេឌ្យកោសល្ល** នៅឬទេ ? ខ្ញុំជាភូឈួយខេត្ត ខ្ញុំមាន ការជួបលោកបន្តិច ។

បន្ទាប់ពីបង្អោនខ្លួនហើយសំពះ បុរសស្រុកស្រែនោះឆ្លើយ :

- ទានប្រោស លោកប្រុស លោកស្រីបានចេញពីងងឹត១ម្លេះទៅភូមិ ភ្នំធំ ដើម្បីទៅរកជួលមនុស្សមកច្រូត....បើ ព្រះតេជគុណមានការអ្វី១ជួបនឹង នាងក៏បាន ។

នាងចាត់ការ ជួសលោកឪពុកទាំងអស់ ។

ថាហើយក៏ស្ទុះទៅបើកទ្វារធំ ដែលប្រដាប់ដោយបន្ទះនិង ចំរឹងដែកយ៉ាងមាំ១ ។ លុះរថយន្តហ្សីបវារចូលផុតទៅទ្វាររបងក៏បិទឃិបមកវិញ ។ ដោយឮសូរសម្លេងឡាននាង **ចន្ទមណី** ស្លៀកពាក់ពណ៌ផ្ទៃមេឃតាមលំអានស្រុកស្រែ តែមានលំអរត្រង់ដើមទ្រូងដោយបន្ទះរំយោលជ័រស្អាតបានដើរ ចេញមកមើលដោយនឹកពិភាល់ក្នុងចិត្តថា ឪពុកនាងម្ដេចក៏រហ័សត្រឡប់មកវិញម្ល៉េះហ្ន៎ ...លុះឃើញរថយន្តហ្សីប ហើយឃើញប្រុស១ស្លៀកពាក់បែបទា ហាន នាងក៏តក់ស្លុតមួយសន្ទុះ ។

**នីយាវុធ** ដែលទើបបររថយន្តចូលមកក៏លោតចុះ ដោះមួកសំពត់ ហាមធំទន់ប្រផ្នាគំនាប់នាង ទើបនាងស្គាល់ហើយលើកដៃសំពះ ថែមទាំងញញឹមផង :

- យីលោកទេតើ ខ្ញុំខំតែភ័យ ។ លោកមានធុរៈអី ? អញ្ជើញលោកមកក្នុងផ្ទះ ។

ភូឈួយខេត្ត ក៏បែរមកបង្គាប់ ប៉ូលិសម្នាក់ដាក់ឡានចតក្រោយស្វាយមួយដើម ដុះក្នុងលានមុខផ្ទះ ទើបឡើងជណ្ដើរពីរបីកាំចូលទៅក្នុងភូមិគ្រឹះដែល ទើបសង់រួចរវាង ៤-៥ ខែប៉ុណ្ណោះ ។ នារីអញ្ជើញភ្ញៀវអង្គុយនៅសាឡុងធ្វើពី ខ្លឹមនាងទួនលំអរដោយកែបមានផ្កាស្រស់ ហើយដែលទើបបានទទួលថ្មីដែរពីបាងកក ។ នាងចាត់ឱ្យស្ត្រីម្នាក់ទៅលើកទឹកក្រូច ដាក់ទឹកកកពីរកែវយកមកជូន ។ ភក្ត្រនាងញញឹមស្រស់ នាងចាប់និយាយ :

- ឃុន **៥** បានប្រាប់ខ្ញុំអស់ហើយថា លោកបានជួយចាត់ការបញ្ជាក់កម្មសិទ្ធិ លើដីធ្លីនេះបានរួសរាន់ណាស់ ។ ចំណែកខ្លួនខ្ញុំ (នាងថែមទាំងសំឡេងអៀនបន្តិច) ខ្ញុំក៏បានសង្ឃឹមទុកថា ថ្ងៃណាមួយលោកនឹងមកលេងខ្ញុំពុំខានដែរ ។

- នាងអើយ ក្នុងពេលនេះខ្ញុំរវល់ដកខ្លួនពុំរួចសោះតែម្ដងអស់ពីរឿងមួយធ្លាក់ទៅរឿងមួយទៀត ។ សូមនាងកុំប្រកាន់ទោសថាខ្ញុំជូរ ថាខ្ញុំបំភ្លេច ចោលគុណនាង និងលោកឪពុករបស់នាង ។ សូម្បីតែថ្ងៃនេះជាថ្ងៃអាទិត្យផង ក៏ខ្ញុំមិនទំនេរដែរ លោកទេសរដ្ឋមន្ត្រីបានប្រើខ្ញុំមកត្រួតប៉ូលិសដែលតាំងពង្រាយតាមផ្លូវថ្នល់ ។ ខ្ញុំឆ្លៀតឱកាសនេះឆ្វៀងចូលមកសួរសុខទុក្ខលោក និងនាងមួយភ្លែតប៉ុណ្ណោះ ។

- លោកធំចាត់ការយ៉ាងនេះត្រូវណាស់ ព្រោះថ្វីបើ " ម៉ុំ " ត្រង់នេះ មិនមានផលរមាស់អ្វីក៏ដោយ តែខ្ញុំនៅមិនទាន់កក់ក្ដៅប៉ុន្មានទេ ។ បន្តិចមានគេមកប្រាប់ថា បានឃើញពួកព្រៃដើរកាត់ត្រង់នោះត្រង់នេះមិនសូវឈប់ទេ ។ ដោយលោកបានសង្កេតឃើញស្រាប់ហើយ ឪពុកខ្ញុំបានលើកកំពែងដាក់ដែក សំរួចពាំងនៅពីមុខផ្ទះហើយពឹងផ្អែកទៅលើគុម្ពឫស្សី និងរបងលួសបន្លាពីក្រោយនិងពីចំហៀង តែហាក់ដូចជាមិនទាន់គត់ម៉ត់ប៉ុន្មានឡើយ ។ ទាំងនេះ ថ្វីបើរាជការបានតាំងប៉ុស្តិ៍ប៉ូលិសនៅជិតថែមទៀត ។

យុវជនទាំងពីរនាក់ហៅគ្នាទៅវិញទៅមកថា " លោក" ឬ " នាង " យ៉ាងនេះដោយឃ្លាតគ្នាដ៏យូរ ហើយដោយមិនទាន់ដឹងចិត្តម្នាក់ៗ ក្រែងមានប្រែប្រួលខ្លះឬយ៉ាងណា ព្រោះសម័យនោះឋិតក្នុងកាលៈទេសៈប្លែកខុសពីធម្មតានៅឡើយ ប៉ុន្តែប្រសិនបើមានអ្នកភ្នែកទិព្វ ឬអ្នកឈ្លាសវៃខាងមើលចិត្តធ្លុះ គេនឹងយល់ភ្លាមថា ពុំមានប្រែប្រួលអ្វីទេ ក្នុងមនោសញ្ចេតនាក៏ផ្អែមល្ហែម ដែលរួតក្រសោបចិត្ត និងអាត្មនទាំងពីរ ។

**នីយាវុធ** រៀបក្រោកឈរលានាងត្រឡប់ទៅបាត់ដំបងវិញហើយ តែនាង **ចន្ទមណី** ទទូចអង្វររង់ចាំអាស្រ័យបាយថ្ងៃត្រង់សិន ហើយចាំជួប នឹងឪពុកម្ដាយដែលអាចត្រឡប់មកវិញក្នុងរវាងពីរម៉ោងទៀត ។ នាងថែម សេចក្ដីថា :

បើលោកមិនជិនណាយ និង ទេសភាពស្រុកស្រែពេកទេ ខ្ញុំនឹងបបួល លោកទៅមើលគេច្រូតស្រូវបានមួយម៉ោង ។ នាងនាំលោកភូឈួយដើរកាត់ភូមិខាងក្រោយផ្ទះ ដែលមានស្រះមួយធំហើយជ្រៅនៅចំកណ្ដាល ។ នៅក្នុងទឹកថ្លាឆ្លុះដល់បាតត្រកួន និងកញ្ឆែត ហែលបោះដៃទន្ទាំងរកគ្នាទៅវិញទៅមក ។ នៅតាមមាត់ស្រះដើមត្របែក និងដូងតុកកែចោលម្លប់ត្រជាក់ស្ងប់ ។ ផុតពីស្រះទៅក៏បានទៅដល់ជង្រុកធំៗ ពីរោងគោរោងរទេះ ដែលមានគុម្ពឫស្សីញឹកក្រាស់ដុះព័ទ្ធជាប់ណែនជារបង ។

នាងចន្ទមណី ពន្យល់អតីតសង្សារដែលដើរទន្ទឹមស្មាគ្នា :

- គុម្ពឫស្សីនេះមានពីមុនមកស្រាប់ ឯនៅគៀនខាងវិញក៏ទើបចាប់ ដាំបាន ៣-៤ ឆ្នាំប៉ុណ្ណោះទេ ដូច្នេះមិនទាន់បានក្រាស់ល្អ នៅឡើយ ។ ដើម្បីគ្រឿងការពារបានមាំមួនល្អ ឃុន **៥** គាត់បានធ្វើរបងលួសបន្លាព័ទ្ធពីក្រៅថែមមួយជាន់ទៀត ។ ដូចលោកបានជ្រាបតាមឯកសារកម្មសិទ្ធិស្រាប់ហើយ ឃុន **៥** បានទិញដីភូមិនេះចំនួន ៤ ឆ្នាំមកហើយដោយមានឃុន **សុវណ្ណ៍** ជា អ្នកណែនាំ ។

តែកាលនោះគាត់ គ្រាន់តែទៅមករៀបភូមិឋានធ្វើរបងផ្ទះដែល លោកឃើញអម្បាញ់មិញ ទើបនឹងសង់រួចប៉ុន្មានខែនេះទេ ។ ៦ ខែមុនពេល ភ័ន្តប្រែគាត់បានលក់ភូមិករផ្ទះសំបែងឯបាងកកអស់រលីង ព្រោះគាត់ចង់មក ឆ្ងាយពីក្រុងធំ និង នយោបាយដែលធ្វើឱ្យវិលមុខ ។

កាលណោះយុវជនទាំងពីរបានដើរទៅទ្វាររបងលួសបន្លា ហើយដែល មានកូនរោងមួយសំរាប់អ្នកយាមនៅអែបជិតផង ។

ចេញផុតពីរបង និង គុម្ពប្ញស្សី វាលស្រែខែបុស្ស-មាឃ ក៏ត្រដាង ឡើងនូវទេសភាពបរិបូណ៌ដោយផែនមាសនៃស្រូវទុំ ដោយក្លិនកញ្រ្ជាំងដែលទើបច្រូតហើយថ្មីៗ ហើយដោយវាយោដែលពត់ជារលកនូវដើមស្រូវដែលទើបចាប់ទុំ តែមិនទាន់ត្រូវដើមប្ញស្សីមកសង្កត់ ផ្ដេក ដើម្បីបំរុងចាំកណ្ដៀវច្រូតនៅឡើយទេ ។ សំឡេងអ្នកច្រូតច្រៀងតគ្នានឹងមាត់លលកដែលយំឆ្លើយឆ្លងពីចុងដង្កោរមួយទៅមួយនាំវិញ្ញាណឡើនឡង់ដោយសុខុមដុមនិង សំរាន្តចិត្ត ។

អើតផុតពីចុងអំពិល កង្ហារត្រដោកមានកន្ទុយដូចមាត់ចែរោទិ៍ស្រែក ឮងូងប្រណាំងគ្នាតាមលានបញ្ជាន់ស្រូវ ដើម្បីប្រាប់អ្នករោយថាមានខ្យល់បក់មកល្មមធ្វើការបានហើយកុំនៅស្ញៀមធ្វើអ្វីទៀត ។

នាង **ចន្ទមណី** នាំ **ឥឡិយាទុធ** ដើរតាមភ្លឺពីស្រែមួយទៅស្រែមួយទៀតក្រោមពន្លឺនៃព្រះអាទិត្យ ។ ជួបនឹងពួកច្រូត នាងតែងឈប់សួរពីជំនឿន ការដែលកំពុងធ្វើ ។ ឯ **ឥឡិយាទុធ** ភ្លេចខ្លួនជាភូឈ្លួយខេត្ត ក៏ហៅថាមា ហៅ មីងហើយសើចលេងនឹងគេលាន់ ។

- នុំះ បង វត្តជ្រោយម្ទេស ។

ភូឈ្លួយកំលោះបែរមុខមើលនារីឆ្នើមជីវិត ដែលសេចក្ដីស្និទ្ធស្នាល បង្កប់ហៅថា "បងៗ "ឡើងវិញនោះ ទើបដក់ភ្នែកដេញតាមដៃនាងចង្អុល ។

ដូចជាកោះមួយអណ្ដែតលើសាគរពណ៌មាសទុំ រុក្ខជាតិស្លឹកបៃតង ចាស់ប្រាកដរូបឡើង នៅចំចក្ខុវិញ្ញាណអ្នកដើរកាត់វាលស្រែ ។ ដំបូលព្រះ វិហារ និងជហ្វារាងស្ទើតស្ទួយបន្លេចខ្លួនឱនផុតពីចុងឈើ ផ្សាយសន្តិភាព បរមសុខដល់ទីជិតខាង ។ កណ្ដឹងសិរិទ្ធិយោងរណឹងរណុងនៅដំបូលបួស្ដសម្លេង ព្រាបថ្ងូរ មាត់សិស្សមើលសាស្ត្រាស្លឹករឹតបានដឹកដួងចិត្តទៅកាន់សាកលមួយខុសពីទីជុំវិញ ។

យុវជនទាំងពីរនាក់ ចូលក្នុងខឿនវត្តហើយតំរង់ទៅរកបូជនីយដ្ឋាន ដែលឈរទំងំស្ដឹមស្ដែជាច់ពីកុដិនានា ។ ដោយពេលឃើញទ្វារបង្ហើបចោលឥតមានជនណានៅអ្នកទាំងពីរក៏នាំគ្នាដោះស្បែកជើង ហើយថ្វាយបង្គំព្រះជីវ ដើម្បីចូលសក្ការៈបូជា ។ អនុស្សាវរីយ៍កាលខ្លួននាំគ្នាថ្វាយបង្គំព្រះអង្គចូលនិព្វាន នាភ្នំគូលេនក៏ប្រាកដរូបស្ដែងឡើងក្នុងសេចក្ដីនឹករលឹកនៃយុវជន ។ លុះសូត្រមន្តស្ដាចប់កាលណា **ឥឡិយាទុធ** លុតជង្គង់លើកដៃប្រណម្យម្ដងទៀត ។ ហើយប្រកាសថា :

- កាលពីមុនខ្ញុំព្រះករុណាបានទាំងសច្ចាប្រណិតធានថា លុះត្រាតែ ទឹកដីខ្មែរ ដែលបាត់បង់ទាំងប៉ុន្មានក្នុងឱកាសសង្គ្រាមរវាងថៃ-ឥណ្ឌូចិន បានត្រឡប់មករួមក្នុងមាតុភូមិវិញ ទើបខ្ញុំព្រះករុណាអាចចងមិត្តភាពឬសម្ព័ន្ធភាពអ្វីៗជាមួយជនជាតិសៀមបាន ។ ឥឡូវពាក្យសច្ចាទាំងប៉ុន្មានក៏បានសំរេចទាំងអស់ហើយ ។

រួចហើយ ទើបបែរមុខមករកនាងដែលអង្គុយបត់ជើងក្រញឹមនៅជិត ម៉េចអូន ពាក្យសន្យាជាន់ដើមផ្ទាល់ខ្លួនយើងទាំងពីរនៅមានជីវិតមែន ឬទេ ?

ពោះទ្រូងនាងទើបញ័រចំប្រប់ ដោយសេចក្ដីត្រេកអរ ទឹកភ្នែកនៃសុភមង្គលក៏ពោរ ហើយហូរជោរជាន់ធ្លាក់មក ។ កាលនោះនាងពុំតបថាអ្វីទេ គ្រាន់តែលូកដៃស្ដាំទៅស្រវាចាប់ដៃស្ដាំរបស់មិត្តនាង រួចហើយនាំគ្នាក្រាបគោរព ហាក់ដូចសន្យាជាថ្មីម្ដងទៀត ក្នុងជីវិតនេះលែងមានព្រាត់ប្រាស់គ្នាទៀតហើយ ។

នៅខាងក្រៅត្រង់ដំបូលតូចមួយ ដែលមានដើមចារមួយកំពុងចោល មួប់យ៉ាងខាត់ខែប ព្រោះថារដូវត្រូវរោយស្លឹក ហើយបញ្ចេញផ្កាពណ៌រងើកភ្លើងកំលោះគង្វាលគោម្នាក់វាយទំនុកក្លែងៗតែឯកា ។ សម្លេងស្រួយប្រាវដែលភាពស្ងាងថ្លារបស់អាកាសជួយសំអាត

កាន់តែរង់ថែមទៀត បានវាយសេចក្តីដូចតទៅហាក់ដូចជាកិច្ចគោរពសព្ទសារធុការចំពោះសេចក្តីស្នេហា ហ្មត់ហ្មងបរិសុទ្ធដែលទើប បានពានពាររួចមកនូវឧបសគ្គច្រើនជាន់ :

ថ្ងៃបាចរស្មីលើវាលស្រែ ឱទេសភាពប្រែពណ៌ដូចមាស
ហើយផ្សាយនូវបរិយាកាស រីករាយត្រចះក្រោមមេឃខៀវ ។
ជ្រនៀវងទន់មែកតាមវាយោ ហ្វូងគោនាំគ្នាស៊ីញៀវ
អ្នកច្រូតដៃញាប់ក្តាប់កណ្តៀវ តែមាត់ច្រៀងជ្រៀវចំអន់គ្នា
កង្ហាររោទិ៍ងួងចុងអំពិល លលកឥតខ្ចិលហៅគូវា
អកហើរខ្ពស់ឆ្វាយលើវេហាស៍ ឃ្លាំងមើលមច្ឆាក្នុងបឹងកក់ ។
កញ្ច្រាំងកាត់ថ្មីក្លិនឈ្ងួលក្តៅ ដើមស្មៅផ្កាស្រស់ផ្តល់អន្ទក់ ។
ក្របីចាញ់ថ្ងៃចូលត្រាំភក់ ធ្មេចលក់តែមាត់ទំពារលេង ។
សន្តិសោយរាជ្យក្នុងធម្មជាតិ មនោរម្យវាតទីតាំងវែង
នាំសុភមង្គលយ៉ាងស្អាតធេង បូជាគូព្រេងដែលស្នេហា ។

ចប់